ឆាំមុខនៅអាស៊ី

Maybank

រោយការណ៍ប្រចាំឆ្នាំ២០២០

ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី

ស្ថិតនៅជាមួយលោកអ្នក

ធនាគារអន្តរជាតិល្អបំផុត
នៅកម្ពុជាឆ្នាំ២០២០

ពីកម្មវិធីពានរង្វាន់Asiamoney
Best Bank Awards 2020

ច្រើនជាង
៣០%នៃកំណើន
ចំនួនអ្នកចុះឈ្មោះ និងធ្វើប្រតិបត្តិការ
លើM2U និងM2E

ជំនួយផ្នែកហិរញ្ញប្បទាន
ជាង ៦០លានដុល្លារ
ដែលកំពុងប្រើប្រាស់ដើម្បីជួយសម្រួលដល់
អតិថិជនកម្ចីទាំងបុគ្គល និងសាជីវកម្ម

Humanising
Financial Services
SINCE 1960



ស្ថិតនៅជាមួយលោកអ្នក

មិនមានអ្នកណាម្នាក់ ប្រាថ្នាចង់បានពេលវេលាដ៏លំបាកនោះទេ។ ប៉ុន្តែរាល់ពេល ដែលជួបស្ថានភាពលំបាក នោះនឹងមានក្តីសង្ឃឹមមួយ ដែលកើតមកជាមួយ។ លោកអ្នកនឹងយល់កាន់តែច្បាស់ ថាតើនរណាជាមិត្តពិតប្រាកដរបស់លោកអ្នក ដែលលោកអ្នកស្គាល់ និងអាចពឹងពាក់បាន។ ឆ្នាំ២០២០ គឺជាឆ្នាំដ៏លំបាកមួយ។ ដោយសារតែការរីករាលដាលនៃជំងឺកូវីដ១៩ សេដ្ឋកិច្ចមានការធ្លាក់ចុះយ៉ាងខ្លាំង។ អាជីវកម្មជាច្រើន ត្រូវបានបិទ។ វិបត្តិសេដ្ឋកិច្ច និងផ្លូវចិត្តបានកើតឡើង។

ទោះបីជា ស្ថិតក្រោមការរីករាលដាលនៃជំងឺកូវីដ១៩មួយនេះ យ៉ាងណាក៏ដោយ ធនាគារ មេយប៊ែង នឹងស្ថិតនៅជាមួយលោកអ្នកជានិច្ច។ ពួកយើង បានបង្កើតអាជីវកម្មនេះ ឡើងមកដើម្បីស្វែងយល់អំពីអ្វី ដែលលោកអ្នកកំពុងជួបប្រទះ និងដើម្បីជួយសម្រួលលោកអ្នកតាមវិធីនានា ដែលពួកយើងអាចធ្វើទៅបាន។ ចាប់តាំងពីការរីករាលដាលនៃជំងឺកូវីដ១៩ ធនាគារ មេយប៊ែង បានចាប់ផ្តើមផ្តល់សេវាប្រឹក្សាផ្នែកហិរញ្ញវត្ថុ សម្រាប់អតិថិជនរបស់ខ្លួន ដែលរងផលប៉ះពាល់ដោយរោគរាតត្បាត បន្ថែមពីលើកញ្ចប់ជំនួយហិរញ្ញវត្ថុ តាមរយៈការរៀបចំឥណទានឡើងវិញ និងការកំណត់ពេលវេលាឡើងវិញ សម្រាប់ការសងឥណទាន ក៏ដូចជាការផ្អាកការសងប្រាក់កម្ចីជាដើម។

នៅតាមសហគមន៍ ពួកយើង បានផ្តល់ការគាំទ្រដល់ស្ត្រីតម្បាញកម្ពុជា តាមរយៈការផ្តួចផ្តើមប្រកបដោយការកោតសរសើរ ដែលបានបន្តផ្តល់នូវឱកាសរកប្រាក់ចំណូល និងស្របទៅតាមបេសកកម្មរួមរបស់រាជរដ្ឋាភិបាលក្នុងការបង្កើនសេដ្ឋកិច្ច និងជួយសហគមន៍នៅក្នុងពេលដ៏លំបាកមួយនេះ ដែលបណ្តាលមកពីជំងឺកូវីដ១៩។ ស្ត្រីតម្បាញរបស់យើង ប្រមាណជា ២៥០នាក់ ដែលបានទទួលការបណ្តុះបណ្តាលក្រោមកម្មវិធីស្ត្រី និងតម្បាញរបស់ធនាគារ មេយប៊ែង តាមរយៈការសហការជាមួយដៃគូអនុវត្តកម្មវិធីរបស់ពួកយើង អង្គការសូត្រពណ៌ តាមរយៈការផលិតម៉ាស ត្បាញដោយដៃផ្ទាល់ប្រមាណជាង ១១០,០០០ម៉ាស ដែលធ្វើពីកប្បាស និងសូត្រសុទ្ធ ដើម្បីជួយសម្រួលដល់ការលំបាកនៃការរីករាលដាលនៃជំងឺកូវីដ១៩ នៅក្នុងតំបន់។

ពួកយើង ក៏បានរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងកម្រិតថ្នាក់ជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងវីរុសនេះផងដែរ។ នេះ គឺកើតចេញពីការយកចិត្តទុកដាក់ ហើយនេះក៏ជាអ្វីដែល បេសកកម្មនៃការផ្តល់ជូនសេវាហិរញ្ញវត្ថុប្រកបដោយអរិយ្យភាព របស់ពួកយើងផងដែរ។ បើទោះបីជានៅក្នុងឆ្នាំថ្មីនេះ ភាពមិនប្រកដប្រជានៅតែមានច្រើនក៏ដោយ ប៉ុន្តែរឿងមួយ ដែលពិតប្រាកដច្បាស់លាស់នោះ គឺធនាគារ មេយប៊ែង នឹងបន្តធ្វើជាមិត្តរបស់លោកអ្នករាល់ពេលដែលអ្នកត្រូវការជំនួយ។ស្ថិតនៅជាមួយលោកអ្នក ពួកយើង នឹងធ្វើការដើម្បីឆ្លងកាត់ការរីករាលដាលនៃនៃជំងឺកូវីដ១៩ មួយនេះ ហើយនិងចាប់ផ្តើមកសាងអនាគតឲ្យកាន់តែល្អប្រសើរឡើងវិញ។

១៩៩៣

សម្ពោធ សាខាធនាគារ មេយប៊ែង ដំបូងបំផុតនៅក្នុងរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

២០១២

សាខាធនាគារ មេយប៊ែង បានចុះបញ្ជីក្នុងស្រុក ក្លាយជា ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី

២០១២

សម្ពោធសេវាធនាគារ តាមប្រព័ន្ធអ៊ីនធឺណែត Maybank2u ដែលឆ្លាប់បានទទួលពានរង្វាន់ដាក់ឲ្យប្រើប្រាស់នៅកម្ពុជា

២០១៦

សម្ពោធជាផ្លូវការ អគារមេយប៊ែង ថៅវើរ ដែលជាអគារខ្ពស់ថ្មីមួយនៅកណ្តាលរាជធានីភ្នំពេញ ដែលនេះបានបង្ហាញពីការប្តេជ្ញាចិត្តរបស់ធនាគារ មេយប៊ែង ក្នុងការធ្វើជាដៃគូជាមួយប្រទេសកម្ពុជា ក្នុងដំណើរនៃការរីកចម្រើនរបស់ខ្លួន

២០១៦

សម្ពោធដាក់ឲ្យប្រើប្រាស់ ប័ណ្ណឥណពន្ធវីសារូបភាពដំបូងគេបំផុត នៅក្នុងទីផ្សារ

២០១៦

នាំយកកម្មវិធី ទំនួលខុសត្រូវសង្គមចម្បង របស់មូលនិធិធនាគារ មេយប៊ែងដែលមានឈ្មោះថា កម្មវិធីស្ត្រី និងតម្បាញ និងកម្មវិធីបណ្តុះបណ្តាលចំណេះដឹងផ្នែកហិរញ្ញវត្ថុ Maybank CashVille Kidz





២០១៤

សម្ពោធ Maybank Premier Wealth ដែលជាការផ្តល់ជូនថ្មីមួយ ត្រូវបានរចនាឡើង ដើម្បីបំពេញតម្រូវការអតិថិជនជាន់ខ្ពស់ តាមរយៈដំណោះស្រាយហិរញ្ញវត្ថុ ដែលមានលក្ខណៈផ្ទាល់ខ្លួន និងទូលំទូលាយ

២០១៥

សម្ពោធ ដាក់ឲ្យប្រើប្រាស់ ប័ណ្ណឥណពន្ធវីសាដែលជាប័ណ្ណដំបូងគេបំផុត មានមុខងារពីរដែលអនុញ្ញាតឲ្យម្ចាស់ប័ណ្ណអាចប្រើប្រាស់បានទាំងនៅក្នុងប្រទេស និងក្រៅប្រទេស

២០១៥

បានចុះអាជ្ញាប័ណ្ណភាព ជាដៃគូជាមួយ American Express ដែលធ្វើឲ្យធនាគារ មេយប៊ែងក្លាយជាធនាគារតែមួយគត់ ដែលអាចទទួលយកការទូទាត់តាមរយៈប័ណ្ណ American Express

២០១៨

សម្ពោធ កម្មវិធីអភិវឌ្ឍន៍ ជំនាញផ្នែកឌីជីថល FutureReady ក្នុងគោលបំណងពង្រឹងចំណេះដឹងរបស់និយោជិតផ្នែកជំនាញឌីជីថល

២០១៩

បន្ថែមសមត្ថភាព Host-to-Host Capabilities នៅលើប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ M2E របស់យើងឲ្យ មានដំណើរការដោយផ្ទាល់តាមរយៈSTP ដែលភ្ជាប់ផ្ទាល់ទៅនឹងប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ក្នុងស្រុករបស់អតិថិជនរបស់យើង

២០២០

ការដាក់ឲ្យប្រើប្រាស់កម្មវិធីធនាគារចល័ត Maybank2u KH ជាមួយនឹងបទពិសោធន៍សេវាកម្ម និងការរចនាបែបថ្មី UI/UX ដែលការរចនានេះ មានលក្ខណៈស្តង់ដារ ដូចទៅនឹងកម្មវិធីនៃបណ្តាប្រទេសនានា ដែលធនាគារ មេយប៊ែង កំពុងធ្វើប្រតិបត្តិការ

អំពី
របាយការណ៍ប្រចាំឆ្នាំ

របាយការណ៍ប្រចាំឆ្នាំរបស់ ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី គឺជារបាយការណ៍ចម្បងរបស់ធនាគារ ដែលបង្ហាញនូវរបាយការណ៍កិច្ចការក្រុមហ៊ុន និងរបាយការណ៍ហិរញ្ញវត្ថុ ដែលផ្តល់ជូននូវការប៉ាន់ប្រមាណអំពីសមិទ្ធិផលរបស់ធនាគារ នៅក្នុងឆ្នាំ២០២០ និងទស្សនៈវិស័យរបស់យើងនៅក្នុងឆ្នាំ២០២១។

និមិត្តសញ្ញា ដែលមាននៅក្នុងរបាយការណ៍នេះ៖

ធនធានទាំង៥ ដែលបានប្រើប្រាស់សម្រាប់បង្កើនគុណតម្លៃរបស់យើងមានដូចជា៖

- ធនធានហិរញ្ញវត្ថុ
- ធនធានមនុស្ស
- ធនធានបញ្ញា
- ធនធានសង្គម និងទំនាក់ទំនង
- ធនធានផលិតភាព

ភាគីពាក់ព័ន្ធរបស់យើងត្រូវបានបង្ហាញតាមរយៈ៖

- អតិថិជន
- សហគមន៍
- វិនិយោគិន
- និយោជិត
- និយ័តករ

បញ្ហាចម្បងដែលយើងបានកំណត់មានដូចជា៖

- អភិបាលកិច្ចល្អ
- សង្គម
- បរិស្ថាន
- ផលិតផល និងសេវាកម្ម
- និយោជិត

ឯកសារយោងបន្ថែម៖

បង្ហាញពីទីតាំង ដែលលោកអ្នកអាចស្វែងរកព័ត៌មានផ្សេងៗក្នុងរបាយការណ៍នេះ។

បង្ហាញពីទីតាំង ដែលលោកអ្នកអាចស្វែងរកព័ត៌មានផ្សេងៗនៅលើអនឡាញតាមរយៈគេហទំព័រ www.maybank2u.com.kh។

មាតិកា
របាយការណ៍ប្រចាំឆ្នាំ

០១

ទិដ្ឋភាពទូទៅ

- ០៤ ប្រវត្តិ និងប្រតិបត្តិការរបស់ពួកយើង
- ០៦ បណ្តាញសាខានៅក្នុងប្រទេស
- ០៨ មុខងារអាជីវកម្មជាយុទ្ធសាស្ត្រ នៃសម្ព័ន្ធធនាគារ
- ០៩ រចនាសម្ព័ន្ធរបស់សម្ព័ន្ធធនាគារ
- ១០ រចនាសម្ព័ន្ធរបស់ធនាគារ
- ១១ សារសំខាន់ពីប្រធានក្រុមប្រឹក្សាភិបាល
- ១៤ សារសំខាន់ពីនាយកប្រតិបត្តិ
- ១៨ ដំណោះស្រាយក្នុងស្ថានភាព នៃការរាតត្បាតជំងឺកូវីដ១៩

០២

យុទ្ធសាស្ត្រដើម្បីបង្កើតគុណតម្លៃ

- ២០ យុទ្ធសាស្ត្ររបស់ពួកយើង
- ២២ បរិបទនៃប្រតិបត្តិការរបស់យើង

០៣

ធនធានហិរញ្ញវត្ថុ

- ២៤ ទស្សនៈឆ្លុះបញ្ចាំងរបស់នាយក នាយកដ្ឋានហិរញ្ញវត្ថុ
- ២៦ នាយកដ្ឋានសេវាហិរញ្ញវត្ថុសហគមន៍
- ២៨ នាយកដ្ឋានធនាគារកិច្ចសាជីវកម្ម

០៤

ធនធានបញ្ញា

- ៣០ ការផ្តល់ជូនគុណភាពសេវាកម្ម
- ៣១ នាយកដ្ឋានគ្រប់គ្រងហានិភ័យ

០៥

ធនធានមនុស្ស

- ៣២ នាយកដ្ឋាន ធនធានមនុស្ស
- ៣៦ ក្រុមប្រឹក្សាភិបាល
- ៣៨ គណៈកម្មាធិការប្រតិបត្តិ

០៦

អភិបាលកិច្ចប្រកបដោយទំនួលខុសត្រូវ

- ៤០ របាយការណ៍ស្តីពីអភិបាលកិច្ចក្រុមហ៊ុន
- ៤៤ របាយការណ៍លើការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង
- ៤៩ របាយការណ៍គណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល

០៧

ធនធានសង្គម និងទំនាក់ទំនង

- ៥៣ របាយការណ៍ស្តីអំពីចីរភាព

០៨

របាយការណ៍ហិរញ្ញវត្ថុ

- ៦០ របាយការណ៍ក្រុមប្រឹក្សាភិបាល
- ៦៣ របាយការណ៍របស់សវនករឯករាជ្យ
- ៦៥ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
- ៦៦ របាយការណ៍លទ្ធផលពេញលេញ
- ៦៧ របាយការណ៍បម្រែបម្រួលមូលធន
- ៦៨ របាយការណ៍លំហូរសាច់ប្រាក់
- ៦៩ កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

០៩

ព័ត៌មានផ្សេងៗ

- ១១៤ ព័ត៌មានសាជីវកម្ម

ប្រវត្តិ និង ប្រតិបត្តិការរបស់ពួកយើង

បង្កើតក្នុងឆ្នាំ១៩៦០ ធនាគារ មេយប៊ែង គឺជាសម្ព័ន្ធសេវាហិរញ្ញវត្ថុធំជាងគេបំផុតនៅប្រទេសម៉ាឡេស៊ី ជាមួយនឹងការពង្រីកវត្តមានរបស់ខ្លួននៅក្នុងតំបន់អាស៊ាន។ ធនាគារ មេយប៊ែង បានបង្កើតឡើងនៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៣ និងបានចាប់ផ្តើមរីកចម្រើនតាំងពីមានសាខាតែមួយ រហូតដល់ក្លាយជាធនាគារ ដែលបានចុះបញ្ជីក្នុងស្រុកនៅក្នុងឆ្នាំ២០១២។

គុណតម្លៃរបស់យើង

- **T** ការធ្វើការជាក្រុម
- **I** ភាពសុចរិត
- **G** ការរីកចម្រើន
- **E** ឧត្តមភាព និងប្រសិទ្ធភាព
- **R** ការកសាងទំនាក់ទំនង

គុណតម្លៃ **T.I.G.E.R** គឺជាគោលការណ៍ណែនាំនិយោជិតធនាគារមេយប៊ែងទាំងអស់ក្នុងការបំពេញបេសកកម្មសេវាហិរញ្ញវត្ថុប្រកបដោយអរិយ្យភាព។

បំពេញ

បេសកកម្មរបស់យើង

សេវាកម្មហិរញ្ញវត្ថុប្រកបដោយអរិយ្យភាព

ពួកយើង ព្យាយាមបំពេញនូវតម្រូវការអតិថិជនរបស់ពួកយើង ដោយកសាងទំនាក់ទំនងដ៏គួរឲ្យទុកចិត្តដែលបន្តពីមួយជំនាន់ទៅមួយជំនាន់តាមរយៈ គ្រប់វិធីសាស្ត្រដែលអាចធ្វើបាន។ ពួកយើង ជឿជាក់លើ ការផ្តល់ជូនដល់ដៃគូពាក់ព័ន្ធទាំងអស់នូវដំណោះស្រាយហិរញ្ញវត្ថុដែលស្មើភាព និងងាយស្រួល។

ណែនាំ

ចក្ខុវិស័យរបស់យើង

សម្រេចគោលបំណងរបស់អាស៊ីជាមួយលោកអ្នក

ដោយសារតែភាពរីកចម្រើន ជាមួយនឹងអតិថិជនរបស់ពួកយើង ពាណិជ្ជសញ្ញារបស់ធនាគារ មេយប៊ែង បានបង្ហាញវត្តមាននៅប្រទេសអាស៊ានទាំង១០ ប្រទេសចិន និងបណ្តាទីផ្សារសកល សំខាន់ៗផ្សេងទៀត។ ចក្ខុវិស័យរបស់យើង គឺក្លាយខ្លួនទៅជាធនាគារធំជាងគេក្នុងអាស៊ាន តាមរយៈការបំពេញមហិច្ឆតារបស់អតិថិជន នៅក្នុងតំបន់ និងតភ្ជាប់ពួកគេទៅកាន់បណ្តាប្រទេសក្នុងតំបន់អាស៊ី និងពិភពលោក។

ជាមួយនឹងភាពលេចធ្លោរបស់យើង

ពួកយើង ផ្តល់សេវាកម្មជូនសហគមន៍ ប្រកបដោយ ភាពសាមញ្ញ ស្មើភាព និងការគិតគូរពីមនុស្សជាតិ

ដែលបានណែនាំដោយបេសកកម្មរបស់យើង។

និយោជិត ធនាគារ មេយប៊ែង

ជាង **៤២.000**នាក់ដែលកំពុង បំពេញបេសកកម្ម របស់ខ្លួនជូនសហគមន៍តែងតែ គោរពនូវគុណតម្លៃ **T.I.G.E.R**។

កេរ្តិ៍ឈ្មោះ សេវាកម្មហិរញ្ញវត្ថុសហគមន៍ ផ្លែកបុគ្គលដ៏ខ្លាំងរបស់យើង

បានផ្សព្វផ្សាយទូទាំងតំបន់អាស៊ាន។

និងរចនាសម្ព័ន្ធរបស់យើង

ដើម្បីសម្រេចបាននូវបេសកកម្មរបស់យើង ពួកយើងបានផ្តល់ជូនសេវាកម្មហិរញ្ញវត្ថុ របស់យើងតាមរយៈសរសរស្តម្ភអាជីវកម្មចំនួន៣សំខាន់ៗ និង ទទួលបានការគាំទ្រដោយមុខងារកិច្ចការក្រុមហ៊ុននានា នៅ១៨ប្រទេស ជុំវិញពិភពលោក។

នៅប្រទេសកម្ពុជា សរសរស្តម្ភអាជីវកម្ម និងមុខងារកិច្ចការក្រុមហ៊ុនរបស់យើង មានរចនាសម្ព័ន្ធដូចខាងក្រោម៖

សរសរស្តម្ភអាជីវកម្ម

នាយកដ្ឋានសេវាហិរញ្ញវត្ថុសហគមន៍

សម្រាប់៖

បុគ្គល អាជីវកម្មខ្នាតតូច និងមធ្យម សាជីវកម្មខ្នាតមធ្យម

សេវាកម្មផ្តល់ជូន៖

តំណាងអាជីវកម្មខ្នាតតូច និងមធ្យម តំណាងបុគ្គល សេវាធនាគាររូបវន្ត បុគ្គលជាន់ខ្ពស់ Premier Wealth មូលនិធិប្រាក់បញ្ញើ ធានារ៉ាប់រង Bancassurance ធនាគារកិច្ចបែបនិម្មិត្ត និងទូទាត់ និងអាជីវកម្មបំណុល។

នាយកដ្ឋានធនាគារកិច្ច និងសាជីវកម្ម

សម្រាប់៖

ក្រុមហ៊ុនសាជីវកម្ម និងគ្រឹះស្ថាន

សេវាកម្មផ្តល់ជូន៖

តំណាងអាជីវកម្មខ្នាតតូច និងមធ្យម ធនាគារកិច្ចពាណិជ្ជកម្ម តំណាងរយៈពេលខ្លី និងតំណាងរយៈពេលវែង តំណាងវិចារូបន៍ ហិរញ្ញប្បទានពាណិជ្ជកម្ម សេវាកម្មពាណិជ្ជកម្ម ដំណោះស្រាយទូទាត់ និងការគ្រប់គ្រងសាច់ប្រាក់។

នាយកដ្ឋានទីផ្សារសកល

សម្រាប់៖

បុគ្គល និងសាជីវកម្ម

សេវាកម្មផ្តល់ជូន៖

ទីផ្សាររូបិយប័ណ្ណ ប្រឹក្សាយោបល់លើប្រតិបត្តិការសាច់ប្រាក់ និងការផ្លាស់ប្តូររូបិយប័ណ្ណ។

មុខងារកិច្ចការក្រុមហ៊ុន

នាយកដ្ឋានប្រតិបត្តិការអាជីវកម្ម។ នាយកដ្ឋាន កិច្ចការក្រុមហ៊ុន និងទំនាក់ទំនងសាជីវកម្ម
នាយកដ្ឋានហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រ ។ នាយកដ្ឋានធនធានមនុស្ស
នាយកដ្ឋានប្រតិបត្តិតាម ។ នាយកដ្ឋានគ្រប់គ្រងហានិភ័យ ។ នាយកដ្ឋានសវកម្មផ្ទៃក្នុង

ប្រវត្តិ និងប្រតិបត្តិការរបស់ពួកយើង

ពួកយើង ផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដ៏ពេញលេញ ដែលរួមមាន សេវាហិរញ្ញវត្ថុទូទៅ និងសេវាហិរញ្ញវត្ថុដែលអនុលោមតាមច្បាប់ Shariah ក្នុងវិស័យធនាគារ កិច្ចពាណិជ្ជ ធនាគារវិនិយោគ និងក្រុមហ៊ុនធានារ៉ាប់រង នៅទូទាំងសម្ព័ន្ធធនាគារ ដែលមានអតិថិជនបុគ្គល សាជីវកម្ម និងក្រុមហ៊ុនរហូតដល់ជិត ១៥លាននាក់។

ការផ្តល់ជូនគុណតម្លៃ ទូទាំងតំបន់អាស៊ាន

ដោយប្រកាន់ខ្ជាប់ទៅនឹង គោលបំណងរបស់ពួកយើងក្នុងការផ្តល់ជូនសេវាហិរញ្ញវត្ថុប្រកបដោយអរិយ្យភាព ពួកយើងបានដើរតួនាទីជាអ្នកដឹកនាំ ក្នុងការចូលរួមគាំទ្រដល់ភាគីពាក់ព័ន្ធរបស់យើង ដើម្បីឆ្លងកាត់ពេលវេលាដ៏លំបាកមួយនេះ នៅក្នុងឆ្នាំនេះ ដែលបណ្តាលមកពីការរាតត្បាត។ នៅក្នុងការប្តេជ្ញាចិត្តរបស់យើង ដែលតែងតែស្ថិតនៅជាមួយអតិថិជន និងសហគមន៍របស់ពួកយើងទាំងពេលវេលាល្អ និងពេលវេលាលំបាក ដោយពួកយើង បានបង្កើតនូវការផ្តួចផ្តើមនានា ដើម្បីជួយឲ្យការរស់នៅរបស់ពួកគេមានការរីកចម្រើន និងអាចក្រោកឡើងវិញពីការប្រឈមនានា។

១,៨៩ ប៊ីលានដុល្លារ

(៧, ៦ប៊ីលានរីងហ្គីត)

តណទានទិញគេហដ្ឋាន ដែលមានតម្លៃសមរម្យ ដែលបានអនុម័ត នៅក្នុងប្រទេសម៉ាឡេស៊ីក្នុងឆ្នាំ២០២០។

៥,៧៣ ប៊ីលានដុល្លារ

(២៣ប៊ីលានរីងហ្គីត)

ប្រាក់កម្ចីបុគ្គលទាំងអស់នៃសម្ព័ន្ធធនាគារ ដែលស្ថិតក្រោមវិធានការជំនួយហិរញ្ញវត្ថុ ត្រឹមចុងឆ្នាំ ដោយកម្មវិធីផ្អាកសងប្រាក់កម្ចីសរុបដំបូង ១៦៥ប៊ីលាន់រីងហ្គីត បន្តរហូតពេញមួយឆ្នាំ២០២០។

ជាង ៤.៤០០ នាក់

អាជីវកម្មខ្នាតតូច និងមធ្យម ដែលទទួលបានការគាំទ្រពីកម្មវិធីឌីជីថលតាមរយៈ Sama-Sama Lokal ហើយបានរកប្រាក់ចំណូលបានលើស ០,៥០ប៊ីលានដុល្លារ (២លានរីងហ្គីត) ដោយមិនគិតថ្លៃ។

ជាង ៤,៩៨ លានដុល្លារ

(២០លានរីងហ្គីត)

ចូលរួមបរិច្ចាគក្នុងការផ្តួចផ្តើមប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ របស់ MERCY ប្រទេសម៉ាឡេស៊ី និងក្រសួងសុខាភិបាល។

ជាង ០,៧៥ លានដុល្លារ

(៣លានរីងហ្គីត)

រៃអង្គាសមូលនិធិ ដើម្បីជួយដល់សហគមន៍ដែលងាយរងគ្រោះ និងជួយដល់ការគាំទ្រប្រឆាំងប្រយុទ្ធនឹងជំងឺកូវីដ១៩។

និងទូទាំងពិភពលោក

ពួកយើងមានវត្តមាននៅក្នុងប្រទេសចំនួន១៨* ប្រទេស ដែលរួមមានប្រទេសអាស៊ានទាំង១០ ហើយប្រទេសម៉ាឡេស៊ី សិង្ហបុរី និង ឥណ្ឌូនេស៊ី ជាទីផ្សារក្នុងស្រុក។ ពួកយើង ក៏មានវត្តមានផងដែរ នៅក្នុងមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិដូចជា ទីក្រុងឡុងដ៍ ទីក្រុងញ៉ូវយក ទីក្រុងហុងកុង និងទីក្រុងខូបៃ។

២.៦២៦
បណ្តាញសាខាបុគ្គលទូទាំងពិភពលោក

៥១
បណ្តាញសាខាធនាគារវិនិយោគទូទាំងពិភពលោក



* ប្រទេសមិនមែនអាស៊ានរួមមាន ប្រទេសចិន ប្រទេសអារ៉ាប់ ឥណ្ឌា ប៉ាគីស្ថាន ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក ប្រទេសអ៊ីបេហ្គីស្ថាន និងអារ៉ាប់រួម។

សម្រាប់ព័ត៌មានលំអិតអំពី បណ្តាញសកលរបស់ពួកយើង សូមចូលទៅកាន់ មុខងារអាជីវកម្មជាយុទ្ធសាស្ត្រនៃសម្ព័ន្ធធនាគារ នៅទំព័រទី៨ និងនៅលើគេហទំព័រ www.maybank.com/en/worldwide/all-countries.page?

បណ្តាញសាខា
ក្នុងប្រទេស

ធនាគារ មេយវ៉ៃង ជាធនាគារមួយក្នុងចំណោមធនាគារកំពូលទាំង១០នៅក្នុងព្រះរាជាណាចក្រកម្ពុជា យោងលើទ្រព្យសកម្ម។ ធនាគារនេះបានបង្កើតឡើងនៅរាជធានីភ្នំពេញ ក្នុងឆ្នាំ១៩៩៣និងបានចាប់ផ្តើមរីកចម្រើន តាំងពីមានសាខាតែមួយ រហូតដល់ក្លាយជាធនាគារ ដែលបានចុះបញ្ជីក្នុងស្រុកនៅឆ្នាំ២០១២។ ធនាគារ មេយវ៉ៃង បានផ្តល់នូវសេវាកម្មហិរញ្ញវត្ថុគ្រប់លំដាប់ ចាប់ពីសាជីវកម្មពាណិជ្ជកម្ម និងសេវាកម្មធនាគារកិច្ច ក៏ដូចជាធនាគារតាមអ៊ីនធឺណែត និងទូរស័ព្ទដៃចល័តផងដែរ។ ធនាគារ មេយវ៉ៃង មានប្រតិបត្តិការក្នុងរាជធានីភ្នំពេញនិងតាមបណ្តាខេត្តសំខាន់ៗមួយចំនួនក្នុងប្រទេសកម្ពុជាជាមួយនឹងបណ្តាញសាខាចំនួន២១។



បណ្តាញសាខាក្នុងប្រទេស

សាខានៅរាជធានីភ្នំពេញ

ការិយាល័យកណ្តាល
ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៣

សាខាម៉ៅសេទុង
ថ្ងៃទី២១ ខែមករា ឆ្នាំ២០០៩

សាខាទួលគោក
ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៩

សាខាទឹកថ្លា
ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៨

សាខាអូឡាំពិក
ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩

សាខាកម្ពុជាក្រោម
ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣

សាខាអូរបែកក្អម
ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣

សាខាបឹងកេងកងទី១
ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤

សាខាជ្រោយចង្វា
ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣

សាខាតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ
ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១២

សាខាច្បារអំពៅ
ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩

សាខាអូរឬស្សី
ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤

សាខាស្ទឹងមានជ័យ
ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១

សាខានៅបណ្តាខេត្ត

សាខាក្រុងសួង
ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤

សាខាកំពង់ចាម
ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១

សាខាសិរីសោភ័ណ
ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣

សាខាសៀមរាប
ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩

សាខាបាត់ដំបង
ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០

សាខាព្រះសីហនុ
ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០

សាខាតាកែវ
ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤

សាខាតាខ្មៅ
ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤

សូមចូលទៅកាន់គេហទំព័រ www.maybank2u.com.kh សម្រាប់ព័ត៌មានបន្ថែម

មុខងារអាជីវកម្មជាយុទ្ធសាស្ត្រ
នៃសម្ព័ន្ធធនាគារ

Malayan Banking Berhad គឺជាក្រុមហ៊ុនមូលធនមេ និងត្រូវបានចុះបញ្ជី ជាសម្ព័ន្ធធនាគារ មេយប៊ែង។ ក្រុមហ៊ុនបុត្រសម្ព័ន្ធ និងប្រតិបត្តិការអន្តរជាតិសំខាន់ៗរបស់យើងមានដូចតទៅ៖

ធនាគារបែបឥស្លាម

សម្ព័ន្ធធនាគារ មេយប៊ែង បែបឥស្លាម គឺជាសម្ព័ន្ធធំមួយនៃធនាគារបែបឥស្លាមដែលមានទ្រព្យសកម្មច្រើនជាងគេនៅក្នុងតំបន់អាស៊ាន។ គោលជំហរនេះ ត្រូវបានគាំទ្រដោយគោលការណ៍ច្បាប់ឥស្លាមទីមួយ ដើម្បីផ្តល់ជូនអតិថិជននូវសេវាកម្ម និងផលិតផលហិរញ្ញវត្ថុ ដែលអនុលោមទៅតាមច្បាប់Shariah។ ពួកយើងបង្កើនអានុភាពរបស់យើង ដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបច្ចេកទេស និងបណ្តាញចែកចាយរបស់សម្ព័ន្ធធនាគារ មេយប៊ែង តាមរយៈបណ្តាញធនាគារទាំង៣៥៤នៅទូទាំងប្រទេសម៉ាឡេស៊ី ហើយនឹងមានវត្តមាននៅក្នុងប្រទេសដទៃទៀតដូចជា ប្រទេសឥណ្ឌូនេស៊ី ប្រទេសសិង្ហបុរី ទីក្រុងហុងកុង ប្រទេសអង់គ្លេស និងប្រទេសអារ៉ាប់ អេមីរ៉ាត។

ធនាគារវិនិយោគ

សម្ព័ន្ធ Maybank Kim Eng (MKE) គឺជាការរួមបញ្ចូលគ្នានៃក្រុមហ៊ុនពីរគឺ Maybank Investiment Bank Berhad និង Maybank Kim Eng Holdings Limited ដែលមានដំណើរការប្រតិបត្តិការវិនិយោគនៅក្នុងប្រទេសម៉ាឡេស៊ី ប្រទេសសិង្ហបុរី ប្រទេសថៃ ប្រទេសហ្វីលីពីន ប្រទេសឥណ្ឌូនេស៊ី ប្រទេសវៀតណាម ទីក្រុងហុងកុង ប្រទេសឥណ្ឌា ប្រទេសអង់គ្លេស និងប្រទេសសហរដ្ឋអាមេរិក តាមរយៈសាខាធនាគារវិនិយោគចំនួន ៥១សាខា និងការិយាល័យផ្សេងទៀតចំនួន១០៧។ សម្ព័ន្ធ MKE បានផ្តល់ជូននូវសេវាកម្មធនាគារ សម្រាប់ការវិនិយោគ និងផ្តល់ជូនដំណោះស្រាយផ្សេងៗជូនដល់ស្ថាប័នលក់រាយ ក្រុមហ៊ុនទីផ្សារកណ្តាល និងគ្រឹះស្ថាននានា ដែលទទួលបានការគាំទ្រដោយបណ្តាក្រុមហ៊ុននៅថ្នាក់តំបន់ សាជីវកម្មនៅក្នុងតំបន់អាស៊ាន វិស័យនានា បណ្តាប្រទេសផ្សេងៗ និងការសិក្សាស្រាវជ្រាវម៉ាក្រូ។

ការធានារ៉ាប់រង និង TAKAFUL

ក្រុមហ៊ុនធានារ៉ាប់រង Etiqa គឺជាក្រុមហ៊ុនដែលឈានមុខគេក្នុងពាណិជ្ជសញ្ញានៃអាជីវកម្មធានារ៉ាប់រង និងពាណិជ្ជកម្ម Takaful នៅក្នុងតំបន់អាស៊ាន ដែលផ្តល់ជូនសេវាធានារ៉ាប់រងអាយុជីវិត និងសេវាធានារ៉ាប់រងទូទៅសម្រាប់ក្រុមគ្រួសារ និងគម្រោង Takaful តាមរយៈភ្នាក់ងារចែកចាយប្រមាណជាង ១០.០០០នាក់ ៤៦សាខា និង១៧ការិយាល័យ។ គម្រោងនេះក៏មានតាមបណ្តាញធនាគារដៃគូឈ្មួញកណ្តាល ប្រមាណជាង ៤៩០ (សាខា សហការណ៍ ជើងសា និងប្រព័ន្ធអនឡាញ) ដែលឆ្លងកាត់តាមប្រទេសម៉ាឡេស៊ី ប្រទេសសិង្ហបុរី ប្រទេសឥណ្ឌូនេស៊ី ប្រទេសហ្វីលីពីន និងប្រទេសកម្ពុជា។

ការគ្រប់គ្រងទ្រព្យសកម្ម

សម្ព័ន្ធ Maybank Asset Management Group Berhad (MAMG) មានដំណើរការប្រតិបត្តិការនៅក្នុងប្រទេសម៉ាឡេស៊ី ប្រទេសសិង្ហបុរី និងប្រទេសឥណ្ឌូនេស៊ី ដែលមានការផ្តល់នូវការវិនិយោគតាមបែបឥស្លាម និងដំណោះស្រាយលើការវិនិយោគជំនួសសំរាប់សាជីវកម្ម ស្ថាប័ន និងវិនិយោគិន ព្រមទាំងបង្កើនតម្លៃក្នុងលក្ខខណ្ឌជាបុគ្គល។

ប្រតិបត្តិការអន្តរជាតិ

ធនាគារ មេយប៊ែង សិង្ហបុរី

ធនាគារ មេយប៊ែង សិង្ហបុរី ជាបុត្រសម្ព័ន្ធសាជីវកម្មសម្រាប់ប្រតិបត្តិការនៅក្នុងប្រទេសសិង្ហបុរី ដែលត្រូវបានទទួលស្គាល់ថាជាធនាគារក្នុងស្រុកដ៏សំខាន់មួយ (D-SIB) ដែលមានបុព្វសិទ្ធិស្មើនឹងធនាគារពាណិជ្ជកម្មពេញលេញ (QFB)។ ធនាគារ មេយប៊ែង សិង្ហបុរី (MSL) ធ្វើប្រតិបត្តិការជាអាជីវកម្មខ្នាតតូច និងពាណិជ្ជកម្មនៅក្នុងតំបន់សេវាកម្មចំនួន២៨កន្លែង និងមានម៉ាស៊ីនអេធីអឹមប្រមាណជាង ២០០ម៉ាស៊ីន ដែលមានទីតាំងនៅទូទាំងប្រទេសសិង្ហបុរីដូចជាផ្នែកមួយនៃបណ្តាញចែកចាយម៉ាស៊ីនដកប្រាក់ (ATM) ដល់ធនាគាររបស់សិង្ហបុរី ចំនួន៦ ដែលទទួលបាន សិទ្ធិពាណិជ្ជកម្មពេញលេញ។ ទន្ទឹមនឹងនេះ សាខានៃធនាគារ មេយប៊ែង សិង្ហបុរី មានដំណើរការជាសាជីវកម្ម និងស្ថាប័ន សរុបចំនួន៩សាខា។ ធនាគារមេយប៊ែង សិង្ហបុរីបានផ្តល់ប្រាក់ចំណេញទៅដល់សម្ព័ន្ធមុនពេលបង់ពន្ធចំនួន៦,៧% និងតណាទានដុលចំនួន២៨,9% សម្រាប់សារពើពន្ធឆ្នាំ ២០២០នេះ។

ធនាគារ មេយប៊ែង ឥណ្ឌូនេស៊ី

ធនាគារមេយប៊ែង ឥណ្ឌូនេស៊ី ជាធនាគារពាណិជ្ជកម្មធំជាងគេមួយនៅក្នុងប្រទេសឥណ្ឌូនេស៊ីដោយផ្អែកលើទ្រព្យសកម្ម និងបានចុះបញ្ជីក្នុងទីផ្សារ ភាគហ៊ុននៃប្រទេសឥណ្ឌូនេស៊ី។ ធនាគារមួយនេះបានផ្តល់សេវាកម្ម និងផលិតផលតាមរយៈ ធនាគារកិច្ចបុគ្គល ធនាគារកិច្ចមិនបុគ្គល និងធនាគារកិច្ចពាណិជ្ជសកល តាមរយៈ បណ្តាញសាខាចំនួន ៣៦១សាខា (រួមបញ្ចូលទាំងសាខា Shariah ចំនួន១៦សាខា និងសាខានៅទីក្រុងម៉ុមបៃ ចំនួន១សាខា) និងម៉ាស៊ីនអេធីអឹម ចំនួន ១.៤២៨គ្រឿង ដោយរួមបញ្ចូលទាំងម៉ាស៊ីនដាក់ប្រាក់។ ធនាគារ មេយប៊ែង ឥណ្ឌូនេស៊ីបានផ្តល់ប្រាក់ចំណេញទៅដល់សម្ព័ន្ធមុនពេលបង់ពន្ធចំនួន ៧,៧% និងតណាទានដុលចំនួន ៥,៩% សម្រាប់សារពើពន្ធឆ្នាំ ២០២០នេះ។

ធនាគារ មេយប៊ែង ចិន

ធនាគារមេយប៊ែង ចិន ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៦២ជាមួយសាខាដំបូងនៅទីក្រុងហុងកុងហើយបានពង្រីកខ្លួនជាបន្តបន្ទាប់ទៅកាន់ទីក្រុងសៀងហៃ ទីក្រុងប៉េកាំង ទីក្រុងគុនមីង និងទីក្រុងសិនជិន។ ធនាគារមេយប៊ែង ចិន បានផ្តល់នូវសេវាកម្មធនាគារកិច្ចខ្នាតធំ ដល់បណ្តាសាជីវកម្មធំៗនានានៅក្នុងទីក្រុងហុងកុង និងតំបន់ចិនដីគោក ដែលភាគច្រើនជាសាជីវកម្មនៅក្នុងតំបន់អាស៊ានជាពិសេស សាជីវកម្មចិននិងហុងកុងដែលមានប្រតិបត្តិការនៅក្នុងតំបន់ និងគម្រោងគ្រឹះស្ថានហិរញ្ញវត្ថុនានា។ ធនាគារ មេយប៊ែង នៅទីក្រុងហុងកុង ក៏បានផ្តល់នូវសេវាកម្មធនាគារកិច្ចពិសេសដល់អតិថិជនលំដាប់ខ្ពស់របស់យើងផងដែរ។

ធនាគារ មេយប៊ែង ហ្វីលីពីន

ធនាគារមេយប៊ែង ហ្វីលីពីន ជាធនាគារពាណិជ្ជមួយត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៧ ដែលផ្តល់សេវាកម្មឥណទានដល់បុគ្គល និងអាជីវកម្មខ្នាតធំ តាមសាខាសរុប ចំនួន៦៥សាខានៅទូទាំងប្រទេសហ្វីលីពីន។

ធនាគារ មេយប៊ែង ទីក្រុងញ៉ូវយ៉ក

ធនាគារ មេយប៊ែង ទីក្រុងញ៉ូវយ៉ក ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៨៤ហើយបានផ្តល់នូវសេវាកម្មធនាគារកិច្ចខ្នាតធំ ដែលផ្តោតសំខាន់លើការផ្តល់ហិរញ្ញវត្ថុ សម្រាប់ការពង្រីកដើមទុន តម្រូវការសម្រាប់អាជីវកម្មគម្រោងហិរញ្ញវត្ថុ ការជួញដូរហិរញ្ញវត្ថុ និងការផ្ទេរប្រាក់ ទៅកាន់ម្ចាស់សហគ្រាស។

ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី

ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៣ និងបានចុះបញ្ជីពាណិជ្ជកម្មក្នុងស្រុកនៅឆ្នាំ២០១២ ជាមួយបណ្តាញសាខាចំនួន២១សាខា នៅទូទាំងប្រទេសកម្ពុជា។ ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ីបានផ្តល់សេវាកម្មហិរញ្ញវត្ថុដល់អតិថិជនក្នុងស្រុកដូចជា ឥណទានបុគ្គល ឥណទានសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម និងសហគ្រាសខ្នាតធំ។

ធនាគារ មេយប៊ែង វៀតណាម

ធនាគារ មេយប៊ែង វៀតណាម ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៥និងមានបណ្តាញសាខាចំនួន២ ដែលមានទីតាំងនៅទីក្រុងហូជីមិញ និងទីក្រុងហាណូយ ហើយបានផ្តល់សេវាកម្មធនាគារពាណិជ្ជកម្មខ្នាតធំ ដោយរួមបញ្ចូលទាំងការផ្តល់ហិរញ្ញវត្ថុ សម្រាប់ពង្រីកដើមទុន តម្រូវការដើមទុនសម្រាប់ អាជីវកម្មពាណិជ្ជកម្ម និងផលិតផលជួញដូរ រូបិយប័ណ្ណបរទេស (FX) ដល់អតិថិជនក្នុងតំបន់។

ធនាគារ មេយប៊ែង មីយ៉ាន់ម៉ា

ធនាគារ មេយប៊ែង មីយ៉ាន់ម៉ា គឺជាធនាគារម៉ាឡេស៊ីដំបូងគេបង្អស់ ដែលបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃមីយ៉ាន់ម៉ានៅក្នុងឆ្នាំ២០១៥។ ធនាគារ មេយប៊ែង មីយ៉ាន់ម៉ា បានផ្តល់សេវាកម្មធនាគារកិច្ចខ្នាតធំរួមបញ្ចូលទាំងការ ផ្តល់ហិរញ្ញវត្ថុសម្រាប់ ការពង្រីកដើមទុន តម្រូវការសម្រាប់អាជីវកម្ម គម្រោងហិរញ្ញវត្ថុ ហិរញ្ញវត្ថុពាណិជ្ជកម្ម និងការផ្ទេរប្រាក់ ទៅកាន់អតិថិជនថ្នាក់តំបន់ ជាពិសេសនៅជុំវិញ តំបន់ អាស៊ាន។

ធនាគារ មេយប៊ែង ឡាវ

ធនាគារ មេយប៊ែង ឡាវ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០១២ និងមានបណ្តាញសាខាចំនួន២ដែលមានទីតាំងនៅទីក្រុងវៀតទៀងហើយបានផ្តល់សេវាកម្មធនាគារពាណិជ្ជសម្រាប់ហិរញ្ញវត្ថុពាណិជ្ជកម្ម និងការផ្ទេរប្រាក់ទៅកាន់សហគ្រាសខ្នាតតូច និងមធ្យមក៏ដូចជាដល់អតិថិជនសាជីវកម្មកម្រិតកណ្តាល នៅក្នុងប្រទេស និងអតិថិជនសាជីវកម្មនៅតំបន់អាស៊ាន។

ធនាគារ មេយប៊ែង ប្រ៊ុយណេ

ធនាគារ មេយប៊ែង ប្រ៊ុយណេ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៦០ និងមានបណ្តាញសាខាចំនួន២ ដែលមានទីតាំងនៅ Bander Seri Begawan និងនៅ Seria ហើយបានផ្តល់ជូនសេវាកម្មធនាគារកិច្ចខ្នាតតូច និងពាណិជ្ជកម្ម គ្រប់ប្រភេទរួមបញ្ចូលទាំងសេវាកម្មបញ្ជាំ ហិរញ្ញវត្ថុពាណិជ្ជកម្មនិងការផ្ទេរប្រាក់ទៅក្រៅប្រទេស។

ធនាគារ មេយប៊ែង ទីក្រុងឡុងដ៍

ធនាគារ មេយប៊ែង ទីក្រុងឡុងដ៍ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៦២ ហើយបានផ្តល់នូវសេវាកម្មធនាគារកិច្ចខ្នាតធំដល់អតិថិជន នៃ សហគ្រាសនៅក្នុងតំបន់អាស៊ាន និងគ្រឹះស្ថានហិរញ្ញវត្ថុ ដែលផ្តោតសំខាន់លើការផ្តល់ហិរញ្ញវត្ថុសម្រាប់ការពង្រីកដើមទុនតម្រូវការ សម្រាប់អាជីវកម្ម រតនាគារនិងការជួញដូរហិរញ្ញវត្ថុ។ យើងក៏បានផ្តល់ជូននូវសេវាកម្ម និងផលិតផលហិរញ្ញវត្ថុ ដែលអនុលោមទៅតាមច្បាប់ Shariah ដល់សាជីវកម្ម និងអតិថិជនលំដាប់ធំរបស់យើងដែរ។

រចនាសម្ព័ន្ធរបស់ សម្ព័ន្ធធនាគារ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

Maybank

MALAYAN BANKING BERHAD

COMMERCIAL BANKING

- **ISLAMIC BANKING**
  - 100% Maybank Islamic Berhad (Islamic Banking)
- 98.54%* PT Bank Maybank Indonesia Tbk (Banking)
  - 99.99% PT Maybank Indonesia Finance (Multi-financing)
  - 68.55% PT Wahana Ottomitra Multiartha Tbk (Multi-financing)
- 99.98% Maybank Philippines, Incorporated (Banking)
- 100% Maybank (Cambodia) Plc (Banking)
- 100% Maybank Singapore Limited (Banking)
- 18.78% MCB Bank Limited (Banking)
- 20% An Binh Commercial Joint Stock Bank (Banking)
- 19.70% Uzbek Leasing International A.O. (Leasing)

INSURANCE & TAKAFUL

- 100% Etiqa International Holdings Sdn Bhd (Investment Holding)
  - 69.05% Maybank Ageas Holdings Berhad (Investment Holding)
    - 100% Etiqa General Insurance Berhad (General insurance business)
    - 100% Etiqa Family Takaful Berhad (Family Takaful and investment-linked businesses)
    - 100% Etiqa Life Insurance Berhad (Life insurance and investment-linked businesses)
    - 100% Etiqa General Takaful Berhad (General Takaful business)
    - 100% Etiqa Insurance Pte Ltd (General insurance and life insurance businesses)
    - 100% Etiqa Life International (L) Limited (Offshore investment-linked business)
    - 100% Etiqa Offshore Insurance (L) Limited (Bureau Services)
  - 79.87% PT Asuransi Etiqa Internasional Indonesia (General insurance business)
  - 95.24%@ Etiqa Life and General Assurance Philippines Inc (General insurance and life insurance businesses)
  - 100%*** Etiqa General Insurance (Cambodia) Plc (General insurance business)
  - 100%*** Etiqa Life Insurance (Cambodia) Plc (Life insurance and investment-linked businesses)
  - 100% Etiqa Digital Solutions Sdn Bhd# (Other IT, business management consultancy/support services)

INVESTMENT BANKING

- 100% Maybank International Holdings Sdn Bhd (Investment Holding)
  - 100% Maybank Kim Eng Holdings Limited (Investment Holding)
    - 100% Maybank Kim Eng Securities Pte Ltd (Dealing in Securities)
    - 83.50% Maybank Kim Eng Securities (Thailand) Public Company Limited (Dealing in Securities)
    - 100% Maybank Kim Eng Capital, Inc. *(formerly known as Maybank ATR Kim Eng Capital Partners, Inc.)* (Corporate Finance & Financial and Investment Advisory)
      - 100% Maybank ATR Kim Eng Securities Inc (Dealing in Securities)
    - 99.78%@@ PT Maybank Kim Eng Sekuritas (Dealing in Securities)
    - 100% Maybank Kim Eng Securities (London) Limited (Dealing in Securities)
    - 100% Maybank Kim Eng Securities USA Inc (Dealing in Securities)
    - 100% Kim Eng Securities (Hong Kong) Limited (Dealing in Securities)
    - 100% Kim Eng Securities India Private Limited (Dealing in Securities)
    - 100% Maybank Kim Eng Securities Limited (Dealing in Securities)
    - Other Subsidiaries
- 100% Maybank Investment Bank Berhad (Investment Banking)
  - 35.33% Anfaal Capital^ (Investment Banking)
  - Other Subsidiaries

ASSET MANAGEMENT

- 80% Maybank Asset Management Group Berhad (Investment Holding)
  - 100% Maybank Asset Management Sdn Bhd (Fund Management)
    - 99% PT Maybank Asset Management (Fund Management)
    - 100% Amanah Mutual Berhad (Fund Management)
  - 100% Maybank Islamic Asset Management Sdn Bhd (Fund Management)
  - 100% Maybank Private Equity Sdn Bhd (Private Equity Investments)
    - 100% MAM DP Ltd (Fund Management)
  - 100% Maybank Asset Management Singapore Pte Ltd (Fund Management)

OTHERS

- 100% Maybank Trustees Berhad (Trustee Services)
- 100% Maybank Shared Services Sdn Bhd (IT Shared Services)
  - 100%** MBB Labs Pte Ltd (IT Development Services)
- 100% BinaFikir Sdn Bhd (Business/Economic consultancy and advisory)
- Other Subsidiaries

Notes:

All the following references are available in the Maybank Malaysia Annual Report accessible via www.maybank.com

1. This chart is not the complete list of Maybank subsidiaries and associates. Companies that are not shown include those that are dormant, under liquidation, have ceased operations, or are property investment or nominee services companies. For the complete list please refer to Note 66: Details of Subsidiaries, Deemed Controlled Structured Entities, Associates and Joint Ventures in the Financial Book.
2. Where investment holding companies are omitted, shareholdings are shown as effective interest.

* Effective interest held by the Group. Refer to Note 66, footnote 14, on page 262 in the Financial Book for the details.

** 0.01% is held by Dourado Tora Holdings Sdn Bhd.

*** 99.998% is held by Etiqa International Holdings Sdn Bhd.

^ Joint Venture.

\# New subsidiary incorporated in Malaysia. Refer to Note 18(i), page 93 in the Financial Book for the details.

@ Effective interest held by the Group. 54.66% is held by Etiqa International Holdings Sdn Bhd and 40.58% is held by Maybank Kim Eng Capital, Inc.

@@ Effective interest held by the Group. 85% is held by Maybank Kim Eng Holdings Limited and 15% is held by PT Maybank Indonesia Finance (14.78% effective interest held by the Group).

រចនាសម្ព័ន្ធ
របស់ធនាគារ

ជាតុ ម៉ូហាម៉ាដ ហានីហ សូអឌី

នាយកប្រតិបត្តិ

ដឹកនាំការរីកចម្រើន និងយុទ្ធសាស្ត្រអាជីវកម្មគ្រប់ប្រភេទរបស់ធនាគារទាំងមូល និងធានានូវការផ្តល់ជូនគុណតម្លៃរយៈពេលវែង ជូនដល់ភាគទុនិក អតិថិជន និយោជិត និងភាគីពាក់ព័ន្ធទាំងអស់។

មុខងារអាជីវកម្ម

នាយកដ្ឋានសេវាហិរញ្ញវត្ថុសហគមន៍

លោក វ៉ែ សោភ័ណ

នាយក នាយកដ្ឋានសេវាហិរញ្ញវត្ថុសហគមន៍

ដឹកនាំ ការរីកចម្រើននៃអាជីវកម្ម និងទិសដៅយុទ្ធសាស្ត្រ នៃនាយកដ្ឋានសេវាហិរញ្ញវត្ថុសហគមន៍ ដែលរួមមាន ឥណទានអាជីវកម្មខ្នាតតូច និងមធ្យម ឥណទានបុគ្គល សេវាកម្ម Premier Wealth មូលនិធិ ប្រាក់បញ្ញើ សេវាកម្មធានារ៉ាប់រង Bancassurance ធនាគារកិច្ចបែបនិមិត្ត និង អាជីវកម្មទូទាត់ អាជីវកម្មបំណុល គ្រប់គ្រងបណ្តាញសាខា និងការគ្រប់គ្រងគុណភាពទ្រព្យសកម្ម។

នាយកដ្ឋានធនាគារកិច្ច និងសាជីវកម្ម

លោក ត្រួច សត្យា

នាយក នាយកដ្ឋានធនាគារកិច្ច និងសាជីវកម្ម

ដឹកនាំ ការរីកចម្រើននៃអាជីវកម្ម និងទិសដៅយុទ្ធសាស្ត្រ នៃនាយកដ្ឋានធនាគារកិច្ច និងសាជីវកម្ម ដែលរួមមានធនាគារសាជីវកម្ម (រួមបញ្ចូលទាំង គ្រឹះស្ថានហិរញ្ញវត្ថុ) ធនាគារពាណិជ្ជកម្ម ធនាគារកិច្ចសាជីវកម្មខ្នាតតូច និងមធ្យម និងប្រតិបត្តិការធនាគារ។

នាយកដ្ឋានទីផ្សារសកល

កញ្ញា ហុង ស្រីទូន

នាយិកា នាយកដ្ឋានទីផ្សារសកល - ឥណ្ឌូចិន

គ្រប់គ្រង និងត្រួតពិនិត្យផ្នែកទីផ្សារមូលបត្រ រតនាគារ ប្រឹក្សាយោបល់លើប្រតិបត្តិការសាច់ប្រាក់ និងការប្តូររូបិយប័ណ្ណបរទេស។

មុខងារប្រតិបត្តិការ

នាយកដ្ឋានហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រ

លោក អេក្ងាន់ ចានី

នាយក នាយកដ្ឋានហិរញ្ញវត្ថុ - ឥណ្ឌូចិន

បង្កើតយុទ្ធសាស្ត្រសម្រាប់ធនាគារយៈពេលវែង និងដឹកនាំការធ្វើផែនការហិរញ្ញវត្ថុ គម្រោងថវិកា និងរបាយការណ៍និយ័តកម្មហិរញ្ញវត្ថុ និងការគ្រប់គ្រងមូលធន និងសន្ទនីយភាព ដើម្បីធានាថាធនាគារនឹងបន្តរីកចម្រើនប្រកបដោយចីរភាព។

នាយកដ្ឋានធនធានមនុស្ស

លោកស្រី ហ្គាសរីន ចាន់ អាប់ឌុលឡា

នាយិកា នាយកដ្ឋានធនធានមនុស្ស - ឥណ្ឌូចិន

កសាង និងថែរក្សា យុទ្ធសាស្ត្រធនធានមនុស្ស ដែលប្រកបដោយការច្នៃប្រឌិត និងមានអត្ថន័យ បង្កើត និងរៀបចំគោលនយោបាយ ដើម្បីអភិវឌ្ឍ និងផ្តល់ភាពលើកកម្ពស់ដល់និយោជិត ដែលមានសមត្ថភាពខ្ពស់ ក្នុងការបន្តជំរុញដល់ការរីកចម្រើននៃអាជីវកម្មរបស់ធនាគារ ប្រកបដោយចីរភាព។

នាយកដ្ឋានគ្រប់គ្រង ហានិភ័យ

លោក អ៊ុង ឃុក ជីន

នាយក នាយកដ្ឋានគ្រប់គ្រងហានិភ័យ- ឥណ្ឌូចិន

បង្កើតយុទ្ធសាស្ត្រ និងដឹកនាំការគ្រប់គ្រងហានិភ័យសហគ្រាស ក្នុងធនាគារ និងបន្តអនុវត្តការគ្រប់គ្រងហានិភ័យយ៉ាងសកម្ម និងត្រៀមលក្ខណៈគ្រប់គ្រាន់ ដើម្បីរួមចំណែកក្នុងការគាំទ្រដល់ការសម្រេចឲ្យបាននូវចក្ខុវិស័យរបស់ធនាគារ។

នាយកដ្ឋានប្រតិបត្តិការអាជីវកម្ម

លោក ឃូ អេង ហ្វ

នាយក នាយកដ្ឋានប្រតិបត្តិការអាជីវកម្ម

បង្កើត និងអភិវឌ្ឍយុទ្ធសាស្ត្រប្រតិបត្តិការរបស់ធនាគារ និងពិនិត្យមើលការផ្តល់ជូននូវគុណភាពសេវាកម្មទាំងមូលដើម្បីគាំទ្រដល់ការសម្រេចនូវចក្ខុវិស័យ និងបេសកកម្មរបស់ធនាគារ ដែលរួមបញ្ចូលទាំងការពង្រឹងបច្ចេកវិទ្យាដើម្បីអាចប្រកួតប្រជែងនៅក្នុងទីផ្សារ។

នាយកដ្ឋានកិច្ចការក្រុមហ៊ុន និងទំនាក់ទំនងសាជីវកម្ម

លោកស្រី ហ្គាសរីន ចាន់ អាប់ឌុលឡា

នាយិកា នាយកដ្ឋានកិច្ចការក្រុមហ៊ុន និងទំនាក់ទំនងសាជីវកម្ម

កសាង និងដឹកនាំការអនុវត្តកិច្ចការក្រុមហ៊ុន សេវាកម្មផ្នែកច្បាប់ ពាណិជ្ជសញ្ញា ទំនាក់ទំនងសាជីវកម្ម ទំនាក់ទំនងទីផ្សារ គុណភាពសេវាកម្ម និងដឹកនាំផែនការការអនុវត្តទំនួលខុសត្រូវសង្គម របស់ធនាគារ។

លេខាធិការក្រុមហ៊ុន

លោកស្រី ហ្គាសរីន ចាន់ អាប់ឌុលឡា

លោក ឡុង សុម៉ារិទ្ធ

លេខាធិការក្រុមហ៊ុន

ដឹកនាំមុខងារលេខាធិការរបស់ក្រុមហ៊ុន និងផ្តល់ប្រឹក្សាលើការអនុវត្ត និងច្បាប់ស្តីពីអភិបាលកិច្ចក្រុមហ៊ុន។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង

លោក សុខ ចំណូតារ

នាយក នាយកដ្ឋានសវនកម្មផ្ទៃក្នុង

ដឹកនាំសវនកម្មផ្ទៃក្នុង ក្នុងការពង្រឹង និងការពារគុណតម្លៃរបស់ធនាគារ តាមរយៈការផ្តល់ជូននូវការធានាលើគោលដៅ និងហានិភ័យនានា ផ្តល់ប្រឹក្សា និងការយល់ឃើញលើលទ្ធផលសវនកម្ម។

នាយកដ្ឋានប្រតិបត្តិតាម

លោកស្រី ឈូ សុរិន្ទី

នាយិកា នាយកដ្ឋានប្រតិបត្តិតាម

ពិនិត្យមើល ក្របខណ្ឌការងាររបស់ធនាគារ ដើម្បីធានាថាការងារទាំងនោះនឹងប្រតិបត្តិតាមច្បាប់ និងបទបញ្ញត្តិនានា។

📖 សម្រាប់ព័ត៌មានបន្ថែម សូមអានទំព័រទី៣៨។

សារសំខាន់ពី
ប្រធានក្រុមប្រឹក្សាភិបាល

អានតូនី ប្រេនអេឡាម

> ធនាគារ មេយប៊ែងនៅតែរក្សាបាននូវសន្ទុះដ៏ខ្លាំងលើសូចនាករចម្បងៗ និងជំរុញកិច្ចផ្តួចផ្តើមមួយចំនួនដើម្បីជាការឆ្លើយតបលើបម្រែបម្រួលនៃឥរិយាបទ តម្រូវការ និងការរំពឹងទុករបស់អតិថិជន។

ជាការពិតណាស់ ដើម្បីបកស្រាយពីសមិទ្ធិផលក្នុងឆ្នាំ២០២០ របស់ធនាគារ មេយប៊ែង ពួកយើងត្រូវយកវាមកដាក់ទន្ទឹមនឹងការរាតត្បាតនៃជំងឺកូវីដ១៩ និងលទ្ធផលនៃវិបត្តិសុខភាពសាធារណៈ និងសេដ្ឋកិច្ចដែលបានកើតឡើង។ ក្នុងរយៈពេល ៦០ឆ្នាំនៃប្រវត្តិរបស់សម្ព័ន្ធធនាគារ មេយប៊ែង និងរយៈពេល ២៧ឆ្នាំរបស់ធនាគារ មេយប៊ែង នៅប្រទេសកម្ពុជា ពួកយើងបានបង្ហាញអំពីភាពរឹងមាំរបស់ពួកយើង ក្នុងការជំនះលើវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈការផ្តល់សេវាកម្មដោយក្រមសីលធម៌ និងការយកចិត្តទុកដាក់លើមតិរបស់អតិថិជនរួមទាំងសហគមន៍ផងដែរ។ ការបំពេញតម្រូវការរបស់ភាគីពាក់ព័ន្ធទាំងឡាយរបស់ពួកយើង គឺជាបេសកកម្មរបស់ធនាគារ មេយប៊ែង ក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុ ប្រកបដោយអរិយភាព។ ការប្តេជ្ញាដ៏ពិសេសនេះ គឺជាភាពខុសប្លែករបស់ពួកយើងពីធនាគារដទៃ ដែលបង្ហាញជាភស្តុតាងក្នុងគ្រាលំបាកនៃឆ្នាំ២០២០នេះ។

ក្នុងកំឡុងពេលការរាតត្បាតនៃជំងឺកូវីដ១៩ ធនាគារ មេយប៊ែងបានបំពេញកាតព្វកិច្ច ដើម្បីគាំទ្រដល់អតិថិជន និយោជិត និងសហគមន៍របស់ខ្លួន។ ធនាគារ មេយប៊ែងរួមជាមួយនឹងស្ថាប័នធនាគារដទៃនៅក្នុងវិស័យនេះ អនុវត្តន៍យន្តការពន្យាការបង់ឥណទានបណ្តោះអាសន្ន ក្រោមការណែនាំរបស់ធនាគារជាតិនៃកម្ពុជា ដែលបានជួយសម្រាលបន្ទុកជាច្រើនដល់ប្រជាជនកម្ពុជា ដែលរងគ្រោះដោយការរាតត្បាតជាសកលនៃជំងឺកូវីដ១៩នេះ។ ស្ថិតក្រោមវិធានការណ៍ "ការបត់បែនទៅតាមកាលៈទេសៈ រក្សាស្ថេរភាព យុទ្ធសាស្រ្ត" របស់ធនាគារពួកយើង បានធ្វើការយ៉ាងសកម្មនៅដើមខែមីនា ឆ្នាំ២០២០ ដើម្បីការពារសុខភាព និងសុខុមាលភាពរបស់និយោជិត និងអតិថិជនរបស់ពួកយើង បន្ថែមពីនេះពួកយើងក៏បានចាប់ផ្តើមប្រមូលផ្តុំគណៈគ្រប់គ្រងវិបត្តិប្រចាំធនាគារផងដែរ។ ឆ្លងកាត់រយៈពេលមិនប្រាកដប្រជានេះ ធនាគារបានសហការយ៉ាងជិតដិតជាមួយរាជរដ្ឋាភិបាលកម្ពុជា ស្ថាប័ននិយ័តករ និងអាជ្ញាធរដទៃទៀត ដើម្បីផ្តល់កម្លាំងជំនួយសង្គ្រោះបន្ទាន់ដល់និយោជិតជួរមុខ និយោជិតសុខាភិបាល និងសហគមន៍ដែលជួបការលំបាក។ ធនាគារក៏សហការយ៉ាងជិតដិតជាមួយ នឹងអតិថិជនរបស់ពួកយើងក្នុងការផ្តល់ការប្រឹក្សាផ្នែកហិរញ្ញវត្ថុ រួមទាំងផ្តល់ជំនួយលើការកំណត់គោលដៅក្នុងការទូទាត់ឥណទាន និងការរៀបចំឥណទានឡើងវិញ ជាមួយនឹងការកំណត់ពេលវេលាឡើងវិញសម្រាប់ការសងឥណទាន ដល់អតិថិជនរងផលប៉ះពាល់នៃការរាតត្បាតជាសកលនេះ។ ស្ថិតក្រោមការគាំទ្រពីស្រ្តីតម្បាញ ដែលបានទទួលការបណ្តុះបណ្តាលពីកម្មវិធីស្រ្តី និងតម្បាញរបស់ធនាគារ មេយប៊ែង និងដោយរួមជាមួយនឹងកិច្ចសហការជាមួយដៃគូររបស់ពួកយើងគឺអង្គការសូត្រពណ៌កម្ពុជា ធនាគារពួកយើងក៏បានចូលរួមយ៉ាងសកម្មក្នុងគម្រោងផលិតម៉ាស់ ដើម្បីកាត់បន្ថយការរាតត្បាតនៃជំងឺកូវីដ១៩ ទាំងក្នុងប្រទេស និងក្នុងតំបន់។

ការចូលរួមនេះ ត្រូវបានពង្រីកបន្ថែមដោយកិច្ចផ្តួចផ្តើម "អំណោយនៃក្តីស្រឡាញ់" ដែលម៉ាស់សូត្រត្បាញដោយដៃរបស់ជនជាតិខ្មែរ ត្រូវបានផ្តល់ជូនទៅរដ្ឋលេខាធិការដ្ឋានអាស៊ាន គឺមានអត្ថន័យលើសុច្ឆន្ទៈ និងសាមគ្គីភាពទូទាំងតំបន់ ដែលជានិមិត្តរូបនៃក្តីសង្ឃឹម និងការបួងសួងរបស់ស្រ្តីតម្បាញរបស់ពួកយើងទៅកាន់សមាជិកអាស៊ានទាំង១០។ ការចូលរួមចំណែកផ្តល់ម៉ាស់ទៅដល់ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានបង្ហាញគាំទ្រទៅលើការខិតខំប្រឹងប្រែង ក្នុងការបើកសាលារដ្ឋ ដើម្បីផ្តល់សេវាអប់រំឡើងវិញដោយភាពប្រុងប្រយ័ត្ន ក្នុងការពារសិស្សានុសិស្ស គ្រូបង្រៀន និយោជិត និងក្រុមគ្រួសាររបស់ពួកគេផងដែរ។

ក្នុងនាមជាក្រុមហ៊ុនសាជីវកម្មមួយ ពួកយើងមានទំនួលខុសត្រូវចំពោះម្ចាស់ភាគហ៊ុនរបស់ពួកយើងក្នុងការរកប្រាក់ចំណេញប្រកបដោយចីរភាព។ ទោះយ៉ាងណាក៏ដោយ វាមានសារៈសំខាន់ដូចគ្នាចំពោះពួកយើងក្នុងនាមជាធនាគារ ដែលត្រូវធានាឲ្យបាននូវដំណើរការទៅមុខ និងចីរភាពដល់អ្នកទទួលសេវាកម្មពីពួកយើងផងដែរ។

សារសំខាន់ពីប្រធានក្រុមប្រឹក្សាភិបាល

តម្លាភាពដើម្បីប្រយោជន៍សង្គម

មូលនិធិធនាគារ មេយ៉ាបែង ដែលជាស្ថាប័នមនុស្សធម៌នៃសម្ព័ន្ធធនាគារ មេយ៉ាបែងសហការជាមួយប្រទេសនានា បានដាក់ចេញនូវកិច្ចផ្តួចផ្តើមជាច្រើន ដើម្បីគាំទ្រដល់សហគមន៍ទទួលផលប៉ះពាល់ នៅតាមបណ្តាប្រទេសនានា ដែលពួកយើងមានប្រតិបត្តិការ។ កម្មវិធីលេចធ្លោមួយក្នុងចំណោមកម្មវិធីសំខាន់ៗនោះ គឺកម្មវិធីស្ត្រី និងតម្លាភាពរបស់ធនាគារ មេយ៉ាបែង ដែលស្ត្រីត្រូវបានបណ្តុះបណ្តាលឲ្យផលិតវាយនភណ្ឌប្រពៃណី ដើម្បីទទួលបានឯករាជ្យភាពផ្នែកហិរញ្ញវត្ថុ។

ក្នុងពេលកង្វះខាតនូវម៉ាស់ ក្រោយពីការអនុវត្តលើនីតិវិធីប្រតិបត្តិការស្តង់ដារនៅក្នុងតំបន់ ដែលនាំឲ្យតម្លៃកើនឡើងនោះ ស្ត្រីតម្លាភាព ២៥០នាក់របស់ពួកយើងនៅប្រទេសកម្ពុជា បានប្តេជ្ញាក្នុងការផលិតម៉ាស់សូត្រដែលត្បាញដោយដៃ ហើយមានតម្លៃសមរម្យ និងអាចប្រើប្រាស់ឡើងវិញបាន។ ពួកគេផលិតបានម៉ាសសូត្រដែលត្បាញដោយដៃចំនួន ៧៥.០០០ ត្រឹមចុងឆ្នាំ ដែលជួយបំពេញតម្រូវការមួយចំណែកធំ។

នាយកប្រតិបត្តិនៃមូលនិធិធនាគារ មេយ៉ាបែង បានថ្លែងសុន្ទរកថាថា វាពិតជាអស្ចារ្យណាស់ ដែលពួកយើងមិនត្រឹមតែគាំទ្រដល់ជីវភាពរស់នៅរបស់ស្ត្រី តាមរយៈកម្មវិធីរបស់ពួកយើងទេ ប៉ុន្តែពួកយើងក៏បានជួយលើកកម្ពស់ស្ត្រីទាំងនោះ ក្នុងការចូលរួមដ៏មានអត្ថន័យមួយលើ "ការប្រយុទ្ធប្រឆាំង នឹងការគំរាមកំហែងដ៏ធំបំផុត ដែលពិភពលោកកំពុងជួបប្រទះ"។

ការបង្កើតគុណតម្លៃក្នុងកំឡុងពេលនៃការរីករាលដាល

ជំងឺកូវីដ១៩ បានធ្វើអោយមានការរឹតត្បិតលើការប្រាស្រ័យទាក់ទងគ្នា និងការធ្វើដំណើរ ដែលបានរាំងស្ទះដំណើរការអាជីវកម្មទូទាំងសកលលោក។ ទោះបីជាយ៉ាងក្តី ការរីកចម្រើនក្នុងការជំរុញយុទ្ធសាស្ត្រស្នូលរបស់ធនាគារនៅតែសម្រេចបាន ក្នុងឆ្នាំ២០២០នេះ។ បើទោះជាមានសម្ពាធនៃកម្រិតការប្រាក់ចំណេញសុទ្ធ និងការថយចុះនៃសកម្មភាពអាជីវកម្ម ក្នុងអំឡុងពេលសេដ្ឋកិច្ចធ្លាក់ចុះក៏ដោយ ធនាគារ មេយ៉ាបែង នៅតែរក្សាបាននូវសន្ទុះដ៏ខ្លាំងលើសូចនាករចម្បងៗ និងជំរុញកិច្ចផ្តួចផ្តើមមួយចំនួន ដើម្បីជាការឆ្លើយតបលើបម្រែបម្រួលនៃឥរិយាបទ តម្រូវការ និងការរំពឹងទុករបស់អតិថិជន។ ពួកយើងមានសេចក្តីសោមនស្សរីករាយក្នុងការចែករំលែកថា ធនាគារពួកយើងបានសម្រេចលទ្ធផលគួរឲ្យកោតសរសើរ ដោយទទួលបានប្រាក់ចំណេញមុនបង់ពន្ធចំនួន ២៨,១ លានដុល្លារអាមេរិក (ឆ្នាំ២០១៩៖ ៣៣,៩ លានដុល្លារអាមេរិក) និងទទួលបានកំណើនឥណទានប្រចាំឆ្នាំ ដល់ទៅពីរខ្ទង់ធៀបទៅឆ្នាំមុនគឺចំនួន ១៣,៣% ឬ ៨៩,៦ លានដុល្លារអាមេរិក។

ការគ្រប់គ្រងម៉ត់ចត់លើតារាងតុល្យការ គាំទ្រដល់ភាពរឹងមាំនៃមូលនិធិ និងជំហរនៃសន្ទនីយភាពរបស់ធនាគារ។ វិន័យតឹងរឹងលើគុណភាពមូលធន ជាលទ្ធផលធ្វើឲ្យធនាគារទទួលបានអនុបាតសោធនភាពស្មើនឹង ២០,៦% (ឆ្នាំ២០១៩៖ ២០,៥%) ខ្ពស់ជាងកម្រិតកំណត់របស់និយ័តករ ១៥%។ ពួកយើងមានភាពជឿជាក់លើកម្រិតដើមទុនរបស់យើង រួមទាំងមូលធនបម្រុង ដែលនាំឲ្យធនាគារអាចទាញយកអត្ថប្រយោជន៍លើកំណើនប្រាក់ចំណេញយ៉ាងច្រើន ពីឱកាសដែលមានក្នុងប្រទេសកម្ពុជា។

ធនាគារក៏បានចាត់វិធានការប្រុងប្រយ័ត្ន និងម៉ឺងម៉ាត់ក្នុងការទទួលស្គាល់ការបាត់បង់តណាទាន ដែលរំពឹងទុកដែលបណ្តាល មកអំពីការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ ដោយធានាបាននូវជំហរដើមទុនរឹងមាំ។ ពួកយើងបានធ្វើឲ្យប្រសើរឡើងនូវយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ ដើម្បីដោះស្រាយនូវវិបត្តិ ដែលកាន់តែធ្ងន់ធ្ងរដូចជានិន្នាការនៃការកើនឡើងនៃជំងឺកូវីដ១៩ តាមរយៈយុទ្ធសាស្ត្រ ដែលផ្តោតលើឌីជីថល ចីរភាព និងការផ្លាស់ប្តូរនៃការធ្វើការ។ ពួកយើងមានគម្រោងការជាក់លាក់ ក្នុងការបង្កើតប្រភពចំណូលផ្សេងៗរបស់ពួកយើង និងជំរុញឲ្យមានជម្រើសផ្សេងៗជាច្រើនទៀត ក្នុងការផ្តល់សេវាកម្មទៅកាន់អតិថិជនរបស់ពួកយើង។

ចាប់តាំងពីជំងឺកូវីដ១៩ មានវត្តមាននៅដើមឆ្នាំ២០២០មកនោះ ក្រុមប្រឹក្សាភិបាលតែងតែមានកិច្ចពិភាក្សា ជាមួយគណៈគ្រប់គ្រងញឹកញាប់ជាងមុន ហើយជំនួបប្រជុំនេះបានបន្តរហូតមកទល់ឆ្នាំ២០២១នេះផងដែរ។ ក្រុមប្រឹក្សាភិបាលបានកំណត់យកគោលដៅចម្បងក្នុងការពិភាក្សា ទៅលើការធានាដល់សុខុមាលភាព និងសុវត្ថិភាពរបស់និយោជិត និងអតិថិជនរបស់យើង ជាមួយនឹងការបន្តដំណើរប្រតិបត្តិការរបស់ធនាគារ បូកទាំងលទ្ធភាព និងគុណភាពសេវាកម្មទៅកាន់អតិថិជនរបស់ពួកយើង។ ក្រុមប្រឹក្សាភិបាលបានបន្តលះបង់ពេលវេលាយ៉ាងច្រើន លើការរៀបចំយុទ្ធសាស្ត្ររបស់ធនាគារ ដោយផ្តោតសំខាន់ទៅលើផលប៉ះពាល់នៃជំងឺកូវីដ១៩ ដើម្បីជាជំនួយចាំបាច់សម្រាប់អតិថិជន និងមូលធនក៏ដូចជាទាំងតួនាទីត្រូវបំពេញរបស់ពួកយើងក្នុងវិស័យធនាគារក្នុងគ្រាដ៏លំបាកនេះ។

ការតម្រង់ទិសដៅប្រកបដោយយុទ្ធសាស្ត្រ និងចីរភាព

ការវិវត្តនៃនយោបាយ បទប្បញ្ញត្តិ និងសេដ្ឋកិច្ចនៅប្រទេសកម្ពុជា បានជះឥទ្ធិពលផ្ទាល់លើបរិបទវិស័យធនាគារក្នុងប្រទេស។ យន្តការដែលពួកយើងអនុវត្ត ដើម្បីឆ្លើយតបទៅការដើរចេញក្រោយនៃស្ថានភាពម៉ាក្រូហិរញ្ញវត្ថុនេះ បានបង្ហាញពីភាពជាអ្នកដឹកនាំ ប្រកបដោយភាពបត់បែន និងរហ័សរហួនដែលតំណាងឲ្យធនាគារ មេយ៉ាបែង។ ស្ថិតនៅស្ថានភាពគួរឲ្យទាក់ទាញក្នុងទីផ្សារ រួមនឹងការបន្តប្តេជ្ញារបស់សមាជិករបស់ធនាគារ មេយ៉ាបែង ក្រុមប្រឹក្សាភិបាលមានការជឿជាក់ថា ធនាគាររបស់ពួកយើងនៅតែត្រៀមខ្លួនគ្រប់គ្រាន់ ក្នុងការដោះស្រាយបញ្ហាប្រឈម និងបន្តផ្តល់តម្លៃដល់ភាគីពាក់ព័ន្ធ។ វិស័យធនាគារនៅតែជាវិស័យប្រមូលផ្តុំដោយហានិភ័យ ដូច្នេះពួកយើងក៏នៅតែបន្តប្រុងប្រយ័ត្នខ្ពស់ ទៅលើការគ្រប់គ្រងនិងវិនិច្ឆ័យលើហានិភ័យ។

ភាពរឹងមាំ ដែលបានបង្ហាញយ៉ាងច្បាស់លាស់ដោយធនាគារ មេយ៉ាបែង ក្នុងឆ្នាំ២០២០ គឺសម្រេចបានដោយគោលនយោបាយ និងយុទ្ធសាស្ត្រត្រឹមត្រូវ ដែលផ្តោតសំខាន់លើជំនួយប្រកបដោយចីរភាពរបស់ភាគីពាក់ព័ន្ធរបស់ពួកយើង។ ចីរភាពរបស់ធនាគារ មេយ៉ាបែង គឺផ្អែកតាមការបូកបញ្ចូលគ្នានូវគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច (ឬ "ESG") ទៅក្នុងការសម្រេចចិត្តសំខាន់ៗ។ ឆ្នាំ២០២០ ជាឆ្នាំដែលឈានទៅកាន់ការសម្រេចគោលដៅនេះ ដោយពួកយើងបានសង្កេតឃើញថា មានការសង្កត់ធ្ងន់លើ ESG ជាមួយនឹង ការផ្តល់បទពិសោធន៍ល្អឲ្យអតិថិជន និងការបំលែងខ្លួនជាលក្ខណៈឌីជីថល នៅក្នុងយុទ្ធសាស្ត្រ ៥ឆ្នាំថ្មីរបស់ពួកយើង ហៅកាត់ថា M25។ ការវិវឌ្ឍន៍លើ ESG នេះ ទើបតែចាប់ផ្តើមនៅវគ្គចុងក្រោយនៃយុទ្ធសាស្ត្រចីរភាពប្រាំឆ្នាំមុននេះរបស់ពួកយើងហៅថា 20/20 ដែលផ្អែកលើសរសៃស្តម្ភ ៣ គឺសមាគមន៍ និងប្រជាពលរដ្ឋ សមាជិករបស់ពួកយើង និងភាពងាយស្រួលក្នុងការទទួលបានផលិតផល និងសេវាកម្មរបស់ពួកយើង ហើយជាលទ្ធផលជោគជ័យជាច្រើនតាមរយៈគម្រោងជួយដល់សមាគមន៍ ការបម្រើសេវាកម្មតាមលក្ខណៈឌីជីថល និងការដាក់គោលដៅក្នុងការអភិវឌ្ឍកម្លាំងពលកម្ម។

ឆ្នាំ២០២១ គឺជាឆ្នាំដំបូងនៃការអនុវត្ត យុទ្ធសាស្ត្រ M25 ហើយពួកយើងបានត្រៀមខ្លួនរួចជាស្រេចដើម្បីធ្វើឲ្យជែនការទាំងនេះ ក្លាយទៅជាការអនុវត្តតាមរយៈឌីជីថល និងការវិភាគទិន្នន័យ ដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់ និងផ្តល់សេវាកម្មជូនដល់អតិថិជនរបស់ពួកយើង ស្របពេលដែលពួកយើងបន្តចាប់យកឱកាសអាជីវកម្មថ្មីៗ។

សារសំខាន់ពីប្រធានក្រុមប្រឹក្សាភិបាល

ដោយបានកំណត់ពាក្យចីរភាព ជាអាទិភាពមួយក្នុងយុទ្ធសាស្ត្រទាំង៣ នៃយុទ្ធសាស្ត្រ M25 ធនាគារនឹងផ្តោតខ្លាំងលើការបញ្ចូល គោលគំនិតចីរភាពក្នុងវប្បធម៌របស់ខ្លួន។ គោលដៅអភិវឌ្ឍន៍ទាំងនោះមានដូចជា ការកម្លាយខ្លួនទៅរកភាពស្ថិតស្ថេរជាងមុនលើផ្នែកសេដ្ឋកិច្ច តាមរយៈការគ្រប់គ្រងគ្រប់ជ្រុងជ្រោយទៅលើហានិភ័យរបស់ ESG និងការសម្រេចបាននូវការផ្តល់សេវាកម្មហិរញ្ញវត្ថុ ប្រកបដោយចីរភាព ការរួមបញ្ចូលផ្នែកហិរញ្ញវត្ថុ ការលើកកម្ពស់សមត្ថភាពរបស់សង្គម ក៏ដូចជាការពង្រឹងលើអភិបាលកិច្ច និងការគ្រប់គ្រងលើឥទ្ធិពលលើផ្នែកបរិស្ថាន និងសង្គមទៅតាមខ្សែសង្វាក់សេវាកម្មពួកយើងដែរ។ នេះត្រូវបានឆ្លុះបញ្ចាំងគ្រប់ក្រុមហ៊ុនសម្ព័ន្ធ រួមទាំងកម្ពុជាដែរ។ ពួកយើងត្រូវតែត្រៀមខ្លួនប្រឈមមុខ នឹងពិភពលោកមួយ ដែលការងើបឡើងវិញនៃសេដ្ឋកិច្ចមានភាពខុសប្លែកខ្លាំងជាងមុន និងពឹងផ្អែកខ្លាំងលើបច្ចេកវិទ្យា។ មិនថាអង្គភាពណាមួយទេ ត្រូវតែពន្យាកាលវិភាគខ្លួនក្នុងការកម្លាយខ្លួនដោយសារឥទ្ធិពលនៃការរាតត្បាតជំងឺកូវីដ១៩។ ការសម្រេចលទ្ធផលជូនភាគីពាក់ព័ន្ធអាចទទួលជោគជ័យបាន ដរាបណាទាមទារឲ្យមានការអនុវត្តដោយប្រសិទ្ធិភាពខ្ពស់តាមរយៈគោលដៅដែលកំណត់ដ៏ហ្មត់ចត់។ ធនាគារ មេយប៉ែង បានបង្ហាញកំណត់ត្រាល្អមួយ តាមរយៈការផ្លាស់ប្តូរនៅប៉ុន្មានឆ្នាំចុងក្រោយនេះ និងមិនថាស្ថានភាពខាងក្រៅមានភាពមិនប្រាកដប្រជាយ៉ាងណាក្តី ក៏ក្រុមប្រឹក្សាភិបាលមានភាពជឿជាក់ថា ធនាគារនៅតែអាចផ្តល់តម្លៃដល់ភាគីពាក់ព័ន្ធប្រកបដោយចីរភាព។

ដំណើរប្រាំឆ្នាំទៅមុខរបស់ពួកយើង នឹងបន្តតាមបេសកម្មស្នូលរបស់ពួកយើងគឺ ផ្តល់សេវាកម្មហិរញ្ញវត្ថុប្រកបដោយអរិយភាព និងការយកអតិថិជន និងសហគមន៍ជាចម្បងចំពោះរឿងគ្រប់យ៉ាងដែលពួកយើងបានធ្វើ។ ទាំងនេះមិនត្រឹមតែជាក្រមសីលធម៌នោះទេ វាក៏រឿងមួយសមហេតុផលក្នុងការធ្វើអាជីវកម្មផងដែរ។ អតិថិជនសព្វថ្ងៃមិនដូចកាលពី ១០ឆ្នាំមុននោះទេ ពួកគាត់មានចំណេះដឹង សមត្ថភាព និងវាងវៃជាងមុន។ ខណៈពេល ដែលចំនួនគ្រឹះស្ថានផ្តល់សេវាកម្មហិរញ្ញវត្ថុកំពុងកើនឡើងជាលំដាប់ អតិថិជនអាចមានជម្រើស ជ្រើសយកធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុបច្ចេកទេសណា ដែលបំពេញសេវាកម្មស្របតាមតម្រូវការ និងតម្លៃរបស់ពួកគាត់ ហើយអាចធ្វើឲ្យពួកគាត់ទទួល បានបទពិសោធន៍ល្អបំផុត។ ធនាគារបន្តខិតខំបំពេញតម្រូវការលើផ្នែកបច្ចេកវិទ្យា សង្គមកិច្ច និងបរិស្ថានតាមការរំពឹងទុក ក្នុងនាមជាគ្រឹះស្ថានដឹកនាំហិរញ្ញវត្ថុក្នុងតំបន់។

ការផ្តោតលើអភិបាលកិច្ចល្អ

ជាមូលដ្ឋាន សមិទ្ធិផលលើផ្នែកហិរញ្ញវត្ថុ និង ESG គឺត្រូវផ្អែកសំខាន់លើអភិបាលកិច្ចល្អ។ ដើម្បីធានាបាននូវការអនុវត្តអភិបាលកិច្ចល្អបំផុត ពួកយើងតែងតែពិនិត្យមើល និងធ្វើបច្ចុប្បន្នភាពលើគោលនយោបាយរបស់ពួកយើងជាបន្តបន្ទាប់។ ក្នុងឆ្នាំ២០២០ ពួកយើងបានពង្រឹងគោលនយោបាយប្រឆាំងអំពើសុំសំណូក និងអំពើពុករលួយ ដើម្បីដោះស្រាយ និងគ្រប់គ្រងហានិភ័យនៃការសុំសំណូក និងអំពើពុករលួយគ្រប់ប្រតិបត្តិការទាំងក្នុងនិងក្រៅរបស់ធនាគារ មេយប៉ែង។ ពួកយើងក៏បានសម្រេចលទ្ធផលគួរឲ្យកត់សម្គាល់ ក្នុងការពង្រឹងសមត្ថភាពប្រឆាំង នឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (ហៅកាត់ថា "AML/CFT") ដោយចាប់ផ្តើមពីការដាក់ឲ្យមានកម្មវិធីអនុលោមតាមបទប្បញ្ញត្តិច្បាប់ជាមូលដ្ឋាន ដែលបានត្រូវអនុវត្តពេញលេញក្នុងឆ្នាំ២០២០។ កម្មវិធីនេះ បង្កើតឡើងពីគំនិតផ្តួចផ្តើមសំខាន់ៗ ក្នុងការអនុលោមតាមបទប្បញ្ញត្តិច្បាប់ ក្នុងគោលបំណងទទួលបានលទ្ធផលដូចខាងក្រោម៖

- បង្កើនសមត្ថភាពទាំងអង្គភាពអាជីវកម្ម និងអង្គភាពប្រតិបត្តិតាម ដើម្បីពង្រឹងលទ្ធភាព AML/CFT របស់ពួកយើង ដើម្បីធានាថាធនាគារអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធទាំងអស់ ហើយអាជីវកម្មត្រូវបានអនុវត្តន៍ប្រកបដោយក្រមសីលធម៌។
- បន្ថែមវគ្គបណ្តុះបណ្តាល និងការយល់ដឹង ដើម្បីលើកកម្ពស់ជាបន្តបន្ទាប់ លើវប្បធម៌អនុលោមភាពឲ្យរឹងមាំ ដែលជំរុញស្មារតីនៃការទទួលខុសត្រូវដល់និយោជិតទាំងអស់ឲ្យមានការប្រុងប្រយ័ត្នខ្ពស់ចំពោះការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ហើយដើរតួនាទីសកម្មក្នុងការថែរក្សាទំនុកចិត្តសាធារណៈនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ។
- ពិនិត្យឡើងវិញជាប្រចាំ និងលើកកម្ពស់ដំណើរការ ដើម្បីបង្កើនប្រសិទ្ធភាព ក្នុងការស្វែងរក និងការពារសកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។
- បង្កើតក្រុមការងារឯកទេសកណ្តាល ដើម្បីគាំទ្រលើមុខងារកំណត់ AML/CFT នៅពេលដែលពួកយើងទាក់ទង នឹងអតិថិជន។

យើងក៏បន្តការពារ សុខមាលភាពរបស់សមាជិកពួកយើង ក្នុងវេលាការរាតត្បាតថ្មីៗនេះ និងសង្កត់ធ្ងន់លើការកសាង និងពង្រឹងសមត្ថភាព សម្របតាមការរស់នៅធម្មតា តាមបែបគន្លងថ្មី តាមរយៈកម្មវិធីសិក្សា និងអភិវឌ្ឍផ្សេងៗ។ និយោជិតធនាគារ មេយប៉ែងមួយចំនួន អាចជ្រើសយកការបម្រើការងារចល័តបានតាមកម្មវិធីរៀបចំបម្រើការងារចល័ត ដែលសាកល្បងក្នុងឆ្នាំ ២០២០ និងកំណត់ដាក់ជាផ្លូវការក្នុងឆ្នាំ ២០២១។ ការលើកស្ទួយជំនាញរបស់សមាជិកពួកយើង នៅតែជាអាទិភាពចម្បង ដោយពួកយើងសង្កេតឃើញតាមការផ្តល់ឱកាសសិក្សាដល់ និយោជិតទាំងអស់របស់ពួកយើង ទោះជាកំពុងមានការរាតត្បាតមួយនេះក៏ដោយ។

សេចក្តីថ្លែងអំណរគុណ

ឆ្នាំ២០២០ ជាឆ្នាំដ៏ពិសេសមួយរបស់ពួកយើង វាគឺជាឆ្នាំនៃការប្រារព្ធខួបទី៦០ឆ្នាំ នៃសម្ព័ន្ធធនាគារ មេយប៉ែង ប៉ុន្តែអ្វីដែលពួកយើងអាចធ្វើបានក្នុងឆ្នាំ ភាគច្រើនគឺផ្តោតលើកិច្ចខិតខំប្រឹងប្រែង ដើម្បីថែរក្សាសុខុមាលភាពរបស់ពួកយើង និងភាគីពាក់ព័ន្ធទាំងអស់។ នៅក្នុងកំណត់សម្គាល់នេះ ខ្ញុំសូមថ្លែងអំណរគុណដល់ សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ចំពោះការគាំទ្រ និងការប្តេជ្ញាចិត្តខ្ពស់បំផុតនៅក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះ ហើយខ្ញុំក៏សូមថ្លែងអំណរគុណជាពិសេសដល់គណៈគ្រប់គ្រងចំពោះការតស៊ូ និងការប្តេជ្ញាចិត្តក្នុងឆ្នាំដ៏លំបាកនេះ និងសូមអរគុណ សហការីធនាគារ មេយប៉ែងទាំងអស់ ចំពោះកិច្ចខិតខំប្រឹងប្រែង ការប្តេជ្ញាចិត្ត និងភាពវិជ្ជមានរបស់ពួកគេ ក្នុងអំឡុងពេលដ៏លំបាកមួយនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់អ្នកពាក់ព័ន្ធដទៃទៀតរបស់យើងដូចជា និយ័តករ អតិថិជន ដៃគូអាជីវកម្ម និងសហគមន៍ សម្រាប់ការគាំទ្រទាំងអស់ ដែលលោកអ្នកបានផ្តល់ឲ្យធនាគារ មេយប៉ែង ដែលធ្វើឲ្យពួកយើងបោះជំហានឆ្ពោះទៅសម្រេចចក្ខុវិស័យរបស់ពួកយើងគឺ "សម្រេចគោលបំណងរបស់អាស៊ីជាមួយពួកអ្នក ខណៈពេល ដែលផ្តល់សេវាកម្មហិរញ្ញវត្ថុ ប្រកបដោយអរិយភាព"។ ក្នុងការកត់ចំណាំដ៏ពិសេសមួយនេះ ខ្ញុំសូមឆ្លៀតឱកាស ដើម្បីថ្លែងអំណរគុណ និងកោតសរសើរចំពោះការណែនាំ និងការគាំទ្រ ដែលពួកយើងបានទទួលពី ធនាគារជាតិ នៃកម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក។ ពួកយើង សង្ឃឹមថា ភាគីពាក់ព័ន្ធទាំងអស់ នឹងបន្តគាំទ្រ និងបង្ហាញអំពីភក្តីភាពនានា ដែលធានាបានថា ធនាគារ មេយប៉ែង នៅប្រទេសកម្ពុជា នៅតែបន្តផ្តល់នូវការរីកចម្រើន ប្រកបដោយតុល្យភាព ចីរភាព និងកំណើនរួមក្នុងឆ្នាំ ២០២១ និងតទៅមុខទៀត។

សារសំខាន់ពី ឯកឧត្តមប្រតិបត្តិ

ជាតុ ម៊ូហាមាដ ហានីវ ស៊ូហាឌី

> “អាទិភាពធំៗចំនួន២ របស់ពួកយើង ក្នុងកំឡុងពេល នៃការរាតត្បាតនេះ គឺការការពារសុខុមាលភាពរបស់ និយោជិត និង អតិថិជនរបស់ពួកយើង។”

ឆ្នាំ២០២០ គឺជាឆ្នាំដ៏កម្រមួយ ដែលពួកយើងបានជួបបញ្ហាប្រឈមជាច្រើន ហើយបានជៈឥទ្ធិពលដល់គ្រប់ផ្នែកទាំងអស់នៃសហគមន៍ ដែលពួកយើងមានវត្តមាន ដែលប្រការនេះបានធ្វើឲ្យប៉ះពាល់ដល់ជីវភាពប្រជាជន វិស័យពាណិជ្ជកម្មទាំងអស់ក៏ដូចជា វិស័យធនាគារផងដែរ។ នៅធនាគារ មេយវ៉ៃង ក្នុងកំឡុងពេលនៃវិបត្តិជំងឺរាតត្បាតកូវីដ១៩នេះ ដោយផ្អែកទៅលើបេសកកម្មរបស់ពួកយើងក្នុងការផ្តល់នូវសេវាហិរញ្ញវត្ថុ ប្រកបដោយអរិយ្យភាព ពួកយើងបានផ្តោតការយកចិត្តទុកដាក់ក្នុងការចាត់វិធានការផ្សេងៗ ដើម្បីធានាដល់ការការពារផលប្រយោជន៍របស់ភាគីពាក់ព័ន្ធទាំងអស់ដូចជា និយោជិត អតិថិជន ដៃគូពាណិជ្ជកម្ម និងស្ថាប័ននិយ័តករផ្សេងទៀត។

ខ្ញុំជឿជាក់ថា ការបង្កើតវិធានការទាំងនេះ ដែលបានអនុវត្តដោយធនាគារ មេយវ៉ៃង ជាលក្ខណៈស្ថាប័ន ទាំងមូលដែលខ្ញុំ នឹងធ្វើសេចក្តីបញ្ជាក់លម្អិតបន្ថែម ក្នុងកំណត់សម្គាល់របស់ខ្ញុំ ដែលបានជួយសមាជិកនៃសហគមន៍ជាច្រើនឲ្យទ្រទ្រង់ និងបន្តការរស់នៅក្នុងអំឡុងពេលដ៏ពិបាកនេះ។

ការវិនិយោគ ដែលពួកយើងបានធ្វើ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះក្នុងប្រព័ន្ធ និងជាគំរូអាជីវកម្ម ដែលបានបង្ហាញពីសមត្ថភាពរបស់ពួកយើងក្នុងការសម្របខ្លួនយ៉ាងឆាប់រហ័ស ក្នុងពេលទទួលរងផលប៉ះពាល់នៃការរាតត្បាតជាសកលនេះ។ ទន្ទឹមនឹងនេះផងដែរ ពួកយើងនៅតែរក្សាគោលការណ៍ និងផ្តោតជាអាទិភាពយុទ្ធសាស្ត្ររបស់ពួកយើងពេញមួយឆ្នាំសម្រាប់ឆ្នាំ ២០២០ ទៅលើគន្លឹះសំខាន់ៗនៃពាណិជ្ជកម្ម ដែលធ្វើឲ្យអាជីវកម្មរីកចម្រើន ដោយយកចិត្តទុកដាក់ និងការគ្រប់គ្រងគុណភាពទ្រព្យសម្បត្តិប្រកប ដោយប្រសិទ្ធភាព និងចីរភាពនៅក្នុងការទទួលបានប្រាក់ចំណេញ ដោយបន្តក្នុងការគ្រប់គ្រងគុណភាពនៃទ្រព្យសម្បត្តិ។ ជាលទ្ធផល ពួកយើងបានចុះបញ្ជីត្រឹម ២៦bps សម្រាប់តំណាងមិនដំណើរការចំនួន ២,៣៦%។ ប្រសិទ្ធិភាពនៃការគ្រប់គ្រងលើការចំណាយរបស់ពួកយើងក៏ជារបៀបចីរភាពដ៏សំខាន់មួយផងដែរ ក្នុងការធានាដល់ ការចំណាយផ្សេងៗឲ្យចំគោលដៅ ក្នុងការជួយជ្រោមជ្រែងទៅដល់ ស្ថេរភាពនៃដំណើរប្រតិបត្តិការធនាគារ។

ការធ្វើការរួមគ្នា

វិធានការសំខាន់ ដែលប្រកាសដោយ ធនាគារជាតិនៃកម្ពុជា ក្នុងខែមីនា ឆ្នាំ២០២០ គឺគោលការណ៍ណែនាំស្តីពីការរៀបចំតំណាងឡើងវិញ ដើម្បីធានានូវប្រសិទ្ធិភាពនៃប្រាក់កម្ចី ដែលរៀបចំឡើងដោយធនាគារ និងស្ថាប័នហិរញ្ញវត្ថុ ដោយផ្តោតសំខាន់លើវិស័យ ដែលរងផលប៉ះពាល់ខ្លាំង។ ដើម្បីបន្ថយសម្ពាធលើស្ថាប័នហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានបន្ធូរបន្ថយទុនបម្រុង និងសាច់ប្រាក់ក៏ដូចជាបែងចែកចំណាត់ថ្នាក់ និងការផ្តល់ប្រាក់កម្ចី។ ដោយហេតុការរៀបចំតំណាងឡើងវិញជិតបញ្ចប់ សមាគមន៍ធនាគារនៅកម្ពុជា និងសមាគមន៍មីក្រូហិរញ្ញវត្ថុកម្ពុជាបានសម្រេចប្រកាសពន្យារពេលដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។

សម្រាប់ធនាគារ មេយវ៉ៃង ដែលស្ថិតនៅក្នុងបេសកកម្មក្នុងការផ្តល់នូវសេវាហិរញ្ញវត្ថុ ប្រកបដោយអរិយ្យភាព ផ្តល់អាទិភាពដល់សុខុមាលភាពហិរញ្ញវត្ថុដល់អតិថិជនរបស់ពួកយើង ក្នុងអំឡុងពេលដ៏ស្មុគស្មាញនេះ។ ជាក់ស្តែង ដោយដឹងពីតម្រូវការហិរញ្ញវត្ថុរបស់បុគ្គល ឬអាជីវកម្មដែលត្រូវការជំនួយ ធនាគារ មេយវ៉ៃង បានចាប់ផ្តើមផ្តល់ជំនួយទាក់ទងនឹងការរៀបចំតំណាង និងការកំណត់ពេលវេលាឡើងវិញ សម្រាប់ការសងតំណាងដែលរងផលប៉ះពាល់ពីការរាតត្បាតជាសកលមុនពេលដែលគោលការណ៍ស្តីពីការរៀបចំតំណាងឡើងវិញត្រូវបានប្រកាស។

ពួកយើង ក៏បានសហការជាមួយធនាគារសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាតាមរយៈ គម្រោងសហហិរញ្ញប្បទានខ្នាតតូច និងមធ្យម ដើម្បីសម្រួលដល់ការផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងមធ្យម ប្រកបដោយប្រសិទ្ធិភាព និងចីរភាព ដើម្បីគាំទ្រដល់សហគ្រាសធុនតូច និងមធ្យមក្នុងស្រុក ដើម្បីកំណើនសេដ្ឋកិច្ច និងជំរុញសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាក្នុងអំឡុងពេលដ៏លំបាកនេះ។

សារសំខាន់ពីនាយកប្រតិបត្តិ

ទំនួលខុសត្រូវចេញពីចិត្ត

ដោយសារវត្តមានរបស់ពួកយើងនៅក្នុងប្រទេសចិន និងក្នុងនាមជាសម្ព័ន្ធធនាគារមួយ បានធ្វើអោយពួកយើងយល់ដឹងនូវភាពធ្ងន់ធ្ងរនៃជំងឺនេះពេលដែលបានផ្ទុះឡើងមក។ ឆ្លើយតបនឹងប្រតិកម្មរហ័សពួកយើង បានដាក់នូវគំនិតផ្តួចផ្តើមចលនាការពារ និងការស្មានទុកជាមុននូវបញ្ហាប្រឈម ដែលនឹងកើតឡើង។ បន្ថែមលើការពង្រឹងក្របខ័ណ្ឌគ្រប់គ្រងចីរភាពអាជីវកម្មរបស់ពួកយើង បានអភិវឌ្ឍផែនការការពារនិយោជិត និងអតិថិជនរបស់ពួកយើងផងដែរ។

យើងបានចាប់ផ្តើម បំបែកនិងបែងចែកក្រុមការងារក្នុងការដំណើរការប្រតិបត្តិការនៅដើមខែមីនា ឆ្នាំ២០២០ ដើម្បីបន្តរក្សាអាជីវកម្មក្នុងពេលមានឧប្បត្តិហេតុផ្សេងៗ ស្របពេលដែលការរឹតបន្តឹងចលនាឬបទបញ្ជាផ្សេងៗ ត្រូវបានកំណត់ដោយអាជ្ញាធរក្នុងគោលបំណងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ១៩។

អាទិភាពសំខាន់បំផុតសម្រាប់ពួកយើង ក្នុងអំឡុងពេលការរាតត្បាតជាសកលនេះ គឺការការពារសុខុមាលភាពរបស់និយោជិត និងអតិថិជនរបស់ពួកយើង។ ដើម្បីទប់ទល់ជាមួយនឹងបញ្ហានេះ គឺមានតែនិយោជិតរបស់ធនាគារ មេយប៊ែង ផ្នែកប្រតិបត្តិការសំខាន់ៗដែលតម្រូវឲ្យបំពេញតួនាទីរបស់ខ្លួននៅតាមសាខា។ ដើម្បីរក្សានូវសុវត្ថិភាពនិយោជិត និងអតិថិជន ពួកយើងបានប្រកាន់ខ្ជាប់យ៉ាងតឹងរឹងនូវ រាល់នីតិវិធីប្រតិបត្តិការស្តង់ដារតាមការណែនាំ ដូចជាការត្រួតពិនិត្យលើកម្តៅ ការផ្តល់នូវសម្ភារៈការពារ និងទឹកអាល់កុលសម្លាប់មេរោគ ក៏ដូចជារក្សានូវគម្លាតសុវត្ថិភាព។ ឈានចូលដល់ក្នុងឆ្នាំ២០២១ ពួកយើងក៏បានបន្តការសម្របសម្រួលផ្សេងៗ និងបានបន្តលើកទឹកចិត្តដល់និយោជិតរបស់ពួកយើង ឲ្យចូលរួមក្នុងចាក់វ៉ាក់សាំងរបស់រដ្ឋាភិបាលក្នុងការការពារ។ ពួកយើង ក៏បានលើកទឹកចិត្តអតិថិជនឲ្យប្រើប្រាស់សេវាកម្មតាមប្រព័ន្ធឌីជីថលរបស់ពួកយើងដើម្បីបំពេញតម្រូវការធនាគាររបស់ពួកគេ ជំនួសឲ្យការមកសាខាផ្ទាល់។ ជាលទ្ធផល ពួកយើងទទួលបានការកើនឡើងនៃប្រតិបត្តិការ និងបរិមាណការប្រើប្រាស់តាមប្រព័ន្ធឌីជីថលផ្សេងៗរបស់ពួកយើងដូចជាអ៊ីនធឺណែត និងកម្មវិធីធនាគារតាមអ៊ីនធឺណែត Maybank2u ក៏ដូចជាប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ Maybank2e ។

ទាក់ទងនឹងផ្នែកហិរញ្ញវត្ថុ ដែលខ្ញុំបានបញ្ជាក់ពីខាងដើម ពួកយើងបានផ្តល់ជូនអតិថិជន ក្នុងការសម្រួលនូវការបង់សងប្រាក់កម្ចីជាពិសេស សម្រាប់វិស័យ ដែលរងផលប៉ះពាល់ខ្លាំង ស្របតាមការកំណត់ដោយអាជ្ញាធរ រួមទាំងការចូលរួមរបស់ពួកយើងនៅក្នុងគម្រោងសហហិរញ្ញប្បទានពិសេស សម្រាប់សហគ្រាសធុនតូច និងមធ្យម ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារ សហគ្រាសធុនតូច និងមធ្យមកម្ពុជា ដែលគ្រប់គ្រងដោយ រដ្ឋាភិបាលក្នុងការជួយដល់ផ្នែកសំខាន់ៗនៃសេដ្ឋកិច្ច។

ពួកយើងបានផ្សារភ្ជាប់ទំនាក់ទំនងជាមួយអតិថិជនសាជីវកម្មរបស់ពួកយើងយ៉ាងសកម្ម ដើម្បីបន្ថែមជំនួយហិរញ្ញវត្ថុតាមគោលការណ៍ការរៀបចំឥណទានឡើងវិញ និងការកំណត់ពេលវេលាឡើងវិញសម្រាប់ការសងឥណទាន ដែលស្របទៅនឹងតម្រូវការរបស់ពួកគេ។ យើងក៏បានតាមដានក៏ដូចជា រំលឹកក្នុងការផ្តល់ជំនួយជូនដល់អតិថិជន ដែលងាយរងផលប៉ះពាល់យ៉ាងជិតដិតជាទីបំផុត។

ដើម្បីធានាបាននូវភាពគ្រប់គ្រាន់មូលធនសាច់ប្រាក់ និងគុណភាពទ្រព្យសម្បត្តិត្រូវបានគ្រប់គ្រងយ៉ាងល្អ ពួកយើងបានពង្រឹងគណៈកម្មាធិការគ្រប់គ្រងគុណភាពទ្រព្យសម្បត្តិដើម្បីពិចារណា និងអនុវត្តយុទ្ធសាស្ត្រទាក់ទងឥណទានរហ័ស។ អតីតភាព ពួកយើងបានផ្តោតសំខាន់លើការបម្លែងសាច់ប្រាក់ងាយស្រួល និងកម្រិតមូលធនបានផ្តល់ឲ្យពួកយើងនូវឱកាស ដើម្បីឆ្លើយតបនឹងការរាតត្បាតជាសកលពីជំហរនៃកម្លាំង។ ខណៈពេលដែលមនុស្សជាច្រើន គិតថាពួកយើងកំពុងប្រយ័ត្នប្រយែងហួសហេតុ នៅក្នុងជំហរដើមទុនរបស់ពួកយើង យុទ្ធសាស្ត្ររបស់យើងបានបង្ហាញថាមានភាពយុត្តិធម៌នៅពេល ដែលការរាតត្បាតជាសកលនេះ ដែលមិនចេះចប់អាចកើតឡើង និងមានឥទ្ធិពលយូរអង្វែង។

នៅក្នុងផ្នែកសហគមន៍ ពួកយើងបានផ្តល់នូវជំនួយហិរញ្ញវត្ថុដល់រាជរដ្ឋាភិបាល ក្នុងកិច្ចប្រឹងប្រែងប្រយុទ្ធប្រឆាំង នឹងការរាតត្បាតជាសកល សម្រាប់ការទិញឧបករណ៍ការពារ បរិក្ខារពេទ្យ ឧបករណ៍តេស្ត និងគំនិតផ្តួចផ្តើមផ្សេងៗ ដើម្បីកាត់បន្ថយប្រព័ន្ធថែទាំ និងបន្ទុកគ្រូពេទ្យជួរមុខក៏ដូចជា ជួយដល់សហគមន៍ ដែលរងគ្រោះរួមទាំងជំនួយទិញវ៉ាក់សាំងជំងឺកូវីដ១៩។ ពួកយើងក៏បានចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការជួយដល់ជនរងគ្រោះដោយសារទឹកជំនន់នៅរដូវវស្សា ដែលបង្កការលំបាកយូរមកហើយនៅមុនពេល ដែលសហគមន៍កំពុងប្រឈមនឹងបញ្ហា ដែលបណ្តាលមកពីការរាតត្បាតជាសកល។

ពួកយើងបានសហការយ៉ាងសកម្មជាមួយដៃគូកម្មវិធីស្ត្រី និងតម្បាញរបស់ពួកយើងគឺអង្គការសូត្រពណ៌កម្ពុជា ក្នុងការគាំទ្រកិច្ចផ្តួចផ្តើមផលិតម៉ាសសូត្រ ដែលត្បាញដោយដៃចំនួនជាង ១១០.០០០ ធ្វើអំពីកប្បាស និងសូត្រសុទ្ធ ដើម្បីជួយទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ១៩ នៅក្នុងប្រទេស និងតំបន់។ កិច្ចផ្តួចផ្តើមនេះត្រូវបានបង្ហាញនៅក្នុងអាស៊ាន គឺការប្រគល់ "អំណោយនៃសេចក្តីស្រឡាញ់" ម៉ាសសូត្រ ដែលត្បាញដោយដៃ ត្រូវបានប្រគល់ជូនលេខាធិការអាស៊ាន ដែលមានសារសុច្ឆន្ទៈ និងការបង្ហាញសាមគ្គីភាពឥតព្រំដែន ដែលជានិមិត្តរូបនៃក្តីសង្ឃឹម និងការអធិដ្ឋានរបស់ស្ត្រីតម្បាញ សម្រាប់ប្រទេសសមាជិកអាស៊ានទាំង១០ ។ ពួកយើងបានគាំទ្រគំនិតផ្តួចផ្តើមនេះបន្ថែមទៀតជាមួយនឹងការផ្តល់ជូនម៉ាសសូត្រដែលត្បាញដោយដៃចំនួន ៦.០០០ ដល់ក្រសួងអប់រំ យុវជន និងកីឡា ដោយភ្ជាប់ជាមួយនឹងការបើកសាលារដ្ឋឡើងវិញ ដើម្បីគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងកិច្ចខិតខំប្រឹងប្រែង ក្នុងការបន្តសេវាកម្មអប់រំ សម្រាប់ក្មេងជំនាន់ក្រោយ ខណៈពេល ដែលមានការប្រុងប្រយ័ត្នចាំបាច់ ដើម្បីការពារសិស្ស គ្រូបង្រៀន និយោជិត និងក្រុមគ្រួសាររបស់ពួកគេ។ កិច្ចផ្តួចផ្តើមនេះក៏បានផ្តល់នូវឱកាសសេដ្ឋកិច្ចបន្ថែម សម្រាប់អ្នកតម្បាញកម្ពុជា ដែលភ្ជាប់ទៅនឹងបេសកកម្មទូទៅរបស់រដ្ឋាភិបាល ឆ្ពោះទៅរកការជំរុញកំណើនសេដ្ឋកិច្ច និងជួយសហគមន៍ឲ្យក្រោកឡើងវិញពីផលរំខានដែលមិនធ្លាប់មានពីមុនមក ដែលបណ្តាលមកពីជំងឺកូវីដ១៩។

ជាងនេះទៅទៀត ស្របតាមការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាក្នុងការលើកកម្ពស់នៃកម្រិតចំណេះដឹងផ្នែកហិរញ្ញវត្ថុ ក្នុងចំណោមប្រជាជនកម្ពុជា កម្មវិធីបណ្តុះបណ្តាលចំណេះដឹងផ្នែកហិរញ្ញវត្ថុ CashVille Kidz ដែលទទួលបានពានរង្វាន់ពី ធនាគារ មេយប៊ែង ត្រូវបានបង្ហាញ នៅលើទម្រង់ឌីជីថលនៃការសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា។ កិច្ចផ្តួចផ្តើមនេះ គឺជាការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើនការសិក្សាតាមរយៈប្រព័ន្ធអ៊ីនធឺណែត ដែលសាលារៀនជាច្រើន ត្រូវបានបិទ ក្នុងពេលការរាតត្បាតពីជំងឺកូវីដ១៩។ ទម្រង់សិក្សាតាមប្រព័ន្ធឌីជីថលរបស់ក្រសួង បានក្លាយជាបណ្តាញចែកចាយចំណេះដឹងដ៏សំខាន់សម្រាប់ប្រទេស។ ត្រលប់ទៅកាន់ខែមករាឆ្នាំ ២០២០ មុនពេលផ្ទុះជំងឺកូវីដ១៩ នៅកម្ពុជា យើងបានអបអរសាទរសមិទ្ធិផលនានា របស់សាលារៀន លោកគ្រូអ្នកគ្រូ និងសិស្សក្នុងការជំរុញ និងលើកស្ទួយចំណេះដឹងផ្នែកហិរញ្ញវត្ថុជាមួយនឹងការរៀបចំ កម្មវិធីបណ្តុះបណ្តាលចំណេះដឹងផ្នែកហិរញ្ញវត្ថុ CashVille Kidz នៅអគារមេយប៊ែង ថៅវើរ។

ការជួយគ្រោះវិបត្តិប្រកបដោយទាន់ពេល

ជំងឺកូវីដ១៩ បានបំផ្លិចបំផ្លាញគ្រួសារ និងអាជីវកម្មជាច្រើននៅក្នុងប្រទេសកម្ពុជា។ ការរងនូវផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចកម្ពុជា ពេញមួយឆ្នាំនៃឆ្នាំ២០២០ មានការជះឥទ្ធិពលទៅលើការធ្លាក់ចុះ ក្នុងការបង្កើនឥណទាន ក៏ដូចជាចំណូលរបស់ក្រុមហ៊ុនផងដែរ។ កម្រិតទាបនៃការប្រាក់ ដែលបានផ្តល់ជូននៅតែបន្តរងផលប៉ះពាល់ទៅលើប្រាក់ចំណេញរបស់ធនាគារ រួមទាំងចំណូលការប្រាក់សរុប និងប្រាក់ចំណេញ។ ភាពអសកម្មនៃការនាំចេញ និងការចាប់ផ្តើមមានកំណើនឡើងវិញ ក៏នៅមានភាពមិនច្បាស់លាស់ ជាពិសេសសម្រាប់អតិថិជន ដែលគ្រប់គ្រងលើពាណិជ្ជកម្ម។ ការរងផលប៉ះពាល់ពីកត្តាខាងក្រៅនេះ បានឆ្លុះបញ្ចាំងមកលើហិរញ្ញវត្ថុធនាគារ និងបរិយាកាសនៃសេដ្ឋកិច្ច ដែលបានផ្លាស់ប្តូរក្នុងឆ្នាំ ២០២០។

ពួកយើង បានទប់ទល់នឹងវិបត្តិមួយនេះ ជាមួយនឹងកម្លាំងនៃមូលធនដែលពួកយើងមាន។ អនុបាតដើមទុនរបស់ពួកយើង គឺលើសពីតម្រូវការបទប្បញ្ញត្តិអប្បបរមា ដែលធានាថាពួកយើងបន្តផ្តល់អាទិភាព។នៅឆ្នាំ ២០២០ ប្រាក់ចំណេញមុនកាត់សារពើពន្ធ បានចុះនៅត្រឹម ២៤,១ លានដុល្លារអាមេរិក ជាមួយនឹងការធ្លាក់ចុះពីមួយឆ្នាំទៅមួយឆ្នាំ ចំនួន ២៨,៨%។ ធនាគារ បានបន្តផ្តល់ប្រាក់ចំណេញវិជ្ជមានក្នុងចន្លោះពេល ដែលកំណើនរបស់ធនាគារនៅតែបន្តអវិជ្ជមាន។ លើសពីនេះ កំណើននៃប្រាក់កម្ចី គឺមានការកើនឡើង គួរឲ្យកត់សម្គាល់ ដែលរក្សាបាននូវកំណើនប្រាក់កម្ចី ពីមួយឆ្នាំទៅមួយឆ្នាំចំនួន ១៣,៣% និងសមាមាត្រដើមទុនគ្រប់គ្រាន់ចំនួន ២០,៦%ដែលលើសពីតម្រូវការរបស់បទបញ្ញត្តិ។ ខណៈពេល ដែលអត្រាការប្រាក់ទាប និង ផលប៉ះពាល់នៃការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ នៅតែបន្តជាបញ្ហាប្រឈម។ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ត្រូវបានគេរំពឹងទុកថា នឹងមានការងើបឡើងវិញនៅក្នុងឆ្នាំ២០២១ ដែលគាំទ្រដោយការដាក់ចេញនូវកម្មវិធីចាក់ថ្នាំបង្ការ។

ធនាគារ បានទទួលរងនូវការប៉ះពាល់នៃជំងឺកូវីដ១៩ ដែលមានការថយចុះចំនួន ១,៨ លានដុល្លារអាមេរិក។ ទ្រព្យសកម្មរបស់ធនាគារ នៅតែមានភាពរឹងមាំ ដែលលើសពី ៩២% បើធៀបទៅនិងការទូទាត់សង ដែលផ្តល់ជូនដល់អតិថិជន នៅពេលចាប់ផ្តើមមានការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ ដែលមានការថយចុះជាងការរំពឹងទុកមុនរបស់ពួកយើង។

សារសំខាន់ពីនាយកប្រតិបត្តិ

> ដោយតែងតែយកការគិតគូចំពោះអតិថិជន និងសហគមន៍របស់ពួកយើង ជាស្នូលនៃការធ្វើប្រតិបត្តិការ និងការអនុវត្តការងារផ្សេងៗតាមគន្លងនៃគុណតម្លៃរបស់ពួកយើង ពួកយើង នឹងបន្តកសាងអនាគតប្រកបដោយចីរភាពសម្រាប់មនុស្សជំនាន់ក្រោយ។

ការបំលែងខ្លួនជាលក្ខណៈឌីជីថល និងការផ្តល់ជូនសេវាធនាគារ ដ៏ប្រសើរ

ក្នុងកំឡុងពេលដែល ការខិតខំ និងធនធានដែលបានបញ្ជូនទៅកាន់ការផ្លាស់ប្តូរថ្មី ពួកយើងបានជំរុញយកនៅការប្រើប្រាស់ប្រព័ន្ធឌីជីថលយ៉ាងពេញលេញ ដើម្បីគាំទ្រដល់កម្មវិធីថ្មី នូវការធ្វើការតភ្ជាប់ទៅកាន់អតិថិជនរបស់ពួកយើង។ ប្រព័ន្ធឌីជីថលរបស់ពួកយើង ធ្វើការផ្តល់ទៅកាន់អតិថិជន ក្នុងការធ្វើប្រតិបត្តិការសេវាកម្មធនាគារ តាមរយៈប្រព័ន្ធអ៊ីនធឺណែត ដោយមិនតម្រូវឲ្យអតិថិជនអញ្ជើញមកកាន់សាខារបស់ធនាគារឡើយ។

ស្របតាមគោលបំណងរបស់ពួកយើង ក្នុងការលើកកម្ពស់បទពិសោធន៍អតិថិជន ពួកយើងបានពង្រីកនូវប្រតិបត្តិការធនាគារចល័តតាមរយៈកម្មវិធីធនាគារតាមអ៊ីនធឺណែត Maybank2u របស់ធនាគារ រួមជាមួយនឹងចំណុចប្រើប្រាស់ថ្មី ក៏ដូចជាបទពិសោធន៍ថ្មីទៅកាន់អ្នកប្រើប្រាស់ ដែលផ្តល់នូវភាពសាមញ្ញ និងភាពងាយស្រួលក្នុងការប្រើប្រាស់ ដែលជាហេតុធ្វើអោយអតិថិជនរបស់ពួកយើងមានភាពរីករាយ នឹងទទួលយកនូវបទពិសោធន៍ថ្មីនេះ ក្នុងការធ្វើប្រតិបត្តិការ សេវាកម្មធនាគារតាមប្រព័ន្ធអ៊ីនធឺណែត។ ក្នុងរយៈពេលមួយឆ្នាំនេះ ពួកយើងក៏បានបន្ថែមនូវមុខងារនានាដល់កម្មវិធីធនាគារចល័តរបស់យើងផងដែរ។

ក្នុងឆ្នាំនេះដែរ ពួកយើងក៏បានពង្រីកសេវាធនាគាររូបវន្តបុគ្គលជាន់ខ្ពស់ Maybank Premier ជាមួយនឹងការបើកកន្លែងទទួលភ្ញៀវពិសេស នៅទីតាំងទី៣ ដែលមានទីតាំងនៅសាខាទួលគោក ក្នុងរាជធានីភ្នំពេញ ដើម្បីបម្រើជូននូវសេវាកម្ម ដល់អតិថិជនរបស់ធនាគារ មេយប៊ែង ឲ្យកាន់តែមានភាពប្រសើរឡើង ក៏ដូចជាការបញ្ជាក់ពីការប្តេជ្ញាចិត្តរយៈពេលវែងរបស់ធនាគារ មេយប៊ែងនៅក្នុងប្រទេសកម្ពុជាផងដែរ។

ការតម្រង់ទិសដៅប្រកបដោយយុទ្ធសាស្ត្រ និងចីរភាព

ឆ្នាំ២០២០ គឺជាឆ្នាំសំខាន់សម្រាប់ធនាគារ មេយប៊ែង ទៅលើហេតុផលពីរសំខាន់ៗ។ នៅឆ្នាំ២០២០នេះ ពួកយើងបានប្រារព្ធពិធីអបអរសាទដែលធនាគារ មេយប៊ែង បានបម្រើសេវាកម្មជូនដល់អតិថិជនចំនួន ៦០ឆ្នាំកន្លងមកនេះ និងបន្ថែមពីនេះ គឺក្នុងគោលបំណង ដែលពួកយើងបានបង្កើតនូវយុទ្ធសាស្ត្រ សម្រាប់បម្រើសេវាកម្មជូនដល់អតិថិជន នាពេល ៦០ឆ្នាំខាងមុខនេះបន្តទៅទៀត។

នៅខែមករា ឆ្នាំ២០២១ នេះធនាគារ មេយប៊ែង បានបើកដំណើរការនូវយុទ្ធសាស្ត្រ M25 ដែលជាផែនការរយៈពេល៥ឆ្នាំ ដែលនឹងមកជំនួសធនាគារ មេយប៊ែង ២០២០។ វាត្រូវបានដាក់បញ្ចូលយ៉ាងរហ័សទៅលើប្រតិបត្តិការទូទាំងសាខា នៅក្នុងប្រទេសកម្ពុជា។ បេសកកម្មរបស់ពួកយើង គឺផ្តោតសំខាន់ទៅលើផ្នែកសេវាកម្មហិរញ្ញវត្ថុ ប្រកបដោយអរិយ្យភាព ឆ្លៀតក្នុងឱកាសនេះក្នុងការរៀបចំយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំខាងមុខ ក៏ដូចជាការចោតជាសំនួរទៅកាន់ខ្លួនយើងថា តើឃ្លាមួយនេះ មានអត្ថន័យយ៉ាងណា រួមនឹងការត្រួតពិនិត្យឡើងវិញនូវសំណើរតម្លៃរបស់ពួកយើង នៅក្នុងប្រទេសកម្ពុជា។ ក្នុងនាមជាសម្ព័ន្ធធនាគារ ពួកយើងបានឯកភាព ថាបេសកកម្មក៏ដូចជាគោលបំណងអំពីសេចក្តីថ្លែងការណ៍ គឺស្តីអំពីការកសាងទំនាក់ទំនង ដោយផ្អែកលើការទំនុកចិត្តទៅកាន់ភាគីពាក់ព័ន្ធទាំងអស់ និងចីរភាពនៅពេលអនាគតសម្រាប់គ្រប់ៗគ្នា។

ពួកយើង ក៏បានដឹងហើយអំពីសារៈសំខាន់នៃគោលបំណងរបៀបវារៈស្តីអំពីចីរភាពរបស់ធនាគារយើង។ ដូច្នេះហើយទើបពួកយើង បានធ្វើការផ្លាស់ប្តូរជាមូលដ្ឋាន ដោយរួមបញ្ចូលចីរភាពទៅក្នុងទិសដៅអាជីវកម្មរួមរបស់ពួកយើង និងចាត់ទុកវាជាយុទ្ធសាស្ត្រអាទិភាពផងដែរ។ ជំងឺកូវីដ១៩ ក៏បានជះឥទ្ធិពលវិជ្ជមានមកលើដំណើរចីរភាព វាបានជំរុញឲ្យមានការវាយតម្លៃឡើងវិញនូវអ្វី ដែលពិតជាមានសារៈសំខាន់សម្រាប់ពួកយើង និងទៅលើការគ្រប់គ្រងបញ្ហាធំៗ ដែលបានកើតមាននៅលើពិភពលោក។ វិធីសាស្ត្រ ដែលពួកយើងប្រើ គឺដើម្បីគាំទ្រដល់សហគមន៍ដែលមានន័យថាការបម្រើ សេវាកម្មជូនដល់អតិថិជន គឺមានភាពសំខាន់ជាជាងការទទួលបានប្រាក់ចំណេញ។ ការដែលធ្វើបែបនេះ ត្រូវបានឆ្លុះបញ្ចាំង នៅក្នុងការធ្វើការវាយតម្លៃលើការងារចម្បងៗ នៅកម្រិតសម្ព័ន្ធធនាគារ តាមរយៈការកែសម្រួលលើបញ្ហាចម្បងកាលពីមុន និងធ្វើការកំណត់បញ្ហាចម្បងថ្មី។ យោងទៅតាមការវាយតម្លៃចម្បងទាំងនេះ ក្រុមប្រឹក្សាផ្នែកចីរភាពនៃសម្ព័ន្ធធនាគារ បានដឹកនាំឲ្យមានរបៀបវារៈថ្មីមួយទៀត ដោយបង្កើតបាននូវការផ្លូចផ្តើមជាយុទ្ធសាស្ត្រជាច្រើន ដែលផ្តោតលើសរសរស្តម្ភគោលចំនួនបី ដែលមានគោលដៅផ្តល់នូវតទ្ធិពលក្នុងរយៈពេលយូរអង្វែង។ ដោយតែងតែយកការគិតគូចំពោះអតិថិជន និងសហគមន៍របស់ពួកយើង ជាស្នូលនៃការធ្វើប្រតិបត្តិការ និងការអនុវត្តការងារផ្សេងៗ តាមគន្លងនៃគុណតម្លៃរបស់ពួកយើង ពួកយើង នឹងបន្តកសាងអនាគតប្រកបដោយចីរភាព សម្រាប់មនុស្សជំនាន់ក្រោយ។

តាមការពិតតាំងពីដើមឆ្នាំមកម្ល៉េះ ពួកយើង បានចាប់ផ្តើមសម្លឹងមើល ដោយមានការបង្កើតជាដៃគូសហការវិនិយោគរវាង សម្ព័ន្ធធនាគារ មេយប៊ែង និងសម្ព័ន្ធក្រុមហ៊ុន មេយប៊ែង គីមអេង រួមជាមួយនឹងគណៈកម្មការមូលបត្រកម្ពុជា ដើម្បីធ្វើការលើក្របខណ្ឌសហប្រតិបត្តិការ និងក្របខណ្ឌជំនួយបច្ចេកទេស ដើម្បីជំរុញនូវកំណើនទីផ្សារមូលធនរបស់កម្ពុជា។ ភាពជាដៃគូសហការនេះ សម្ព័ន្ធក្រុមហ៊ុន មេយប៊ែង គីមអេង រួមជាមួយ និងគណៈកម្មការមូលបត្រកម្ពុជា និងសហការលើគ្រប់វិស័យ ក្នុងគោលបំណងអភិវឌ្ឍន៍ទីផ្សារមូលធនរបស់ប្រទេសកម្ពុជា រួមមានការចែករំលែកទៅលើការអនុវត្ត និងស្តង់ដាទៅលើវិស័យគ្រប់គ្រងហានិភ័យ អភិបាលកិច្ចសាជីវកម្ម និងការប្រតិបត្តិតាម ការអភិវឌ្ឍផលិតផល និងប្រព័ន្ធរបាយការណ៍ស្តង់ដា សម្រាប់ហិរញ្ញវត្ថុ និងគណនេយ្យ។

> ឈានចូលឆ្នាំ២០២១ ពួកយើង បានបន្តធ្វើការសម្របសម្រួលផ្សេងៗ និងបន្តលើកទឹកចិត្តដល់និយោជិតរបស់ពួកយើង ដើម្បីចូលរួមក្នុងកម្មវិធីចាក់វ៉ាក់សាំងកូវីដ១៩ របស់រាជរដ្ឋាភិបាល និងរួមចំណែកជាកម្លាំងចលករក្នុងការការពារ និងសង្គ្រោះជីវិត។

សារសំខាន់ពីនាយកប្រតិបត្តិ

ទស្សនវិស័យសម្រាប់ឆ្នាំ២០២១

មុនពេលដែលជំងឺកូវីដ១៩ បានរីករាលដាល សេដ្ឋកិច្ចនៃប្រទេសកម្ពុជា គឺមានភាពរឹងមាំខ្លាំង។ វិបត្តិសេដ្ឋកិច្ចពិភពលោក ដែលបណ្តាលមកអំពីការរាតត្បាតជាសកលមិនដូចអ្វីផ្សេងទៀត ដែលពួកយើងបានឆ្លងកាត់ពីមុនមកនោះទេ ពួកយើងបានធ្វើការដោះស្រាយនូវភាពមិនច្បាស់លាស់ជាច្រើន ដែលភាគច្រើនគឺផ្តោតលើទស្សនវិស័យរយៈពេលខ្លី ច្រើនជាងរយៈពេលមធ្យម។

ធនាគារ មេយប៉ែង នៅតែបន្តប្តេជ្ញាក្នុងការបម្រើសេវាកម្ម រួមទាំងការអភិវឌ្ឍនានា ជូនអតិថិជនរបស់ពួកយើង ក៏ដូចជាសហគមន៍ អ្វីដែលសំខាន់នោះ គឺការផ្តល់ជូននូវការរៀបចំឡើងវិញនូវកម្ចីរបស់អតិថិជន ដែលប្រឈមនឹងបញ្ហាហិរញ្ញវត្ថុទៅលើអាជីវកម្មរបស់ពួកគេ ដែលបានរងឥទ្ធិពលពីជំងឺកូវីដ១៩ ដោយមានការជ្រោមជ្រែងពី រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា និង ធនាគារជាតិនៃកម្ពុជាផងដែរ។

ខណៈពេល ដែលរង់ចាំឲ្យការចាក់វ៉ាក់សាំង ត្រូវបានផ្តល់ជូនប្រជាជនយ៉ាងទូលំទូលាយរហូតដល់ឆមាសទី២ នៃឆ្នាំ២០២១នោះ ការរួមចំណែករបស់យើង បានផ្តល់ជាមូលដ្ឋានសម្រាប់ការចាប់ផ្តើមងើបឡើងវិញនៃសេដ្ឋកិច្ចប្រកបដោយភាពរឹងមាំ និងចីរភាពជាបណ្តើរៗ បន្ទាប់ពីពួកយើង បានឆ្លងកាត់នូវពេលវេលាលំបាកជាច្រើននៅដើមឆ្នាំ២០២១នេះ។ ខ្ញុំជឿជាក់ថា នៅពេលដែលប្រជាជនរបស់យើងកំពុងតែផ្សាំខ្លួន ហើយសេដ្ឋកិច្ចកំពុងតែងើបឡើងវិញនោះបន្តិចម្តងៗនោះ ការគាំទ្ររបស់ពួកយើងជាបន្តបន្ទាប់ នឹងចូលរួមចំណែកដល់គោលនយោបាយម៉ាក្រូ ដែលបានរំពឹងឲ្យឃើញអំពីវិសាលភាពនៃការងើបឡើងវិញក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ នៅពេលដែលជំងឺកូវីដ១៩ ត្រូវបានបញ្ចប់ទៅ។

ទោះបីជាបរិយាកាសនៃសេដ្ឋកិច្ច និងប្រតិបត្តិការត្រូវបានផ្លាស់ប្តូរយ៉ាងខ្លាំង ក៏យុទ្ធសាស្ត្រពួកយើង នៅតែមានភាពរឹងមាំជាបន្ត។ ជាការពិតណាស់ យុទ្ធសាស្ត្រទាំងនេះ ត្រូវបានពិនិត្យ និងកែសម្រួលនៅក្នុងកំឡុងពេលមានវិបត្តិនេះ។ យុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំរបស់ពួកយើង នឹងជួយឲ្យពួកយើង ឈានទៅដល់គោលដៅហិរញ្ញវត្ថុ ដែលត្រូវបានកែសំរួលដោយសំណុំអាទិភាព និងការផ្ទូចផ្តើមថ្មីនានា។ ពួកយើង សូមបញ្ជាក់ជាថ្មីម្តងទៀត នូវការប្តេជ្ញាចិត្តរបស់ពួកយើង ក្នុងការផ្តល់ប្រាក់ចំណេញទ្ធេដងលើភាគហ៊ុនសម្រាប់រយៈពេល ៥ឆ្នាំខាងមុខ ដល់ម្ចាស់ភាគហ៊ុនរបស់ពួកយើង បូករួមនឹងការរក្សាអនុបាតសោធនភាពប្រកបដោយគុណភាព។ ធនាគារ នឹងបន្តផ្តល់ជូននូវផែនការវិនិយោគ ដើម្បីធានាបាននូវគុណភាពសេវាកម្មដ៏ល្អប្រសើរ និងឧត្តមភាពនៃប្រតិបត្តិការ។

ការថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងអំណរគុណចំពោះនិយោជិតធនាគារ មេយប៉ែង ទាំងអស់ ដែលបានបន្តការប្តេជ្ញាចិត្តក្នុងការចូលរួម ដោយមិនខ្លាចនឿយហត់ចំពោះប្រតិបត្តិការរបស់ធនាគារក្នុងឆ្នាំកន្លងមក រួមទាំងឆ្នាំនេះដែរ។ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអតិថិជន រួមទាំងម្ចាស់ភាគហ៊ុនរបស់ពួកយើង ចំពោះការជឿទុកចិត្ត ភាពស្មោះត្រង់ ការគាំទ្រ ដែលបានផ្តល់ដល់ពួកយើងក្នុងឆ្នាំដ៏លំបាកបំផុតនេះ។

ចំពោះដៃគូសហការ និងសហគមន៍ ខ្ញុំសូមកោតសរសើរចំពោះការខិតខំប្រឹងប្រែង និងកិច្ចសហប្រតិបត្តិការក្នុងកិច្ចខិតខំប្រឹងប្រែងមកកាន់ពួកយើង។ ខ្ញុំមានទំនុកចិត្ត ហើយក៏រង់ចាំបន្តដំណើរទៅមុខទៀត ដើម្បីខិតខំប្រឹងប្រែងក្នុងការទទួលបាននូវការរីកចម្រើនបន្ថែមទៀត។

ជាចុងក្រោយខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះការណែនាំ និងការប្រឹក្សាដ៏ប្រពៃ ដែលបានផ្តល់ ដោយសមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារ មេយប៉ែង ខេមបូឌា និងអង្គភាពផ្សេងៗទៀត ដែលមាននៅក្នុងក្រុមរួមទាំងអង្គភាពនិយ័តករ ជាពិសេស គឺធនាគារជាតិ នៃកម្ពុជា។

សូមអរគុណ!

ដំណោះស្រាយក្នុងស្ថានភាពនៃការរាតត្បាតជំងឺកូវីដ១៩

នៅពេល ដែលសញ្ញាដំបូងនៃជំងឺកូវីដ១៩ ត្រូវបានប្រកាសឡើងជាលើកដំបូង ពួកយើង បានប្រញាប់ដាក់ឲ្យប្រើប្រាស់នូវដំណើរការផែនការបន្តអាជីវកម្មរបស់ពួកយើង នៅដើមខែមករា ឆ្នាំ២០២០ មកម្លេះ។ គណៈកម្មាធិការគ្រប់គ្រងផែនការបន្តអាជីវកម្មរបស់ពួកយើង បានធ្វើការបន្តត្រួតពិនិត្យរាល់ការវិវត្ត នៃស្ថានភាពមេរោគនេះ។ ចាប់តាំងពីពេលនោះមក ពួកយើង បានកំណត់អាទិភាពរបស់យើង ដើម្បីការពារភាពធន់នៃប្រតិបត្តិការ និងសុខុមាលភាពភាគីពាក់ព័ន្ធរបស់ពួកយើង។

វិធានការនានា ត្រូវបានដាក់ចេញជាបណ្តើរៗ នៅទូទាំងប្រតិបត្តិការរបស់ពួកយើង ដើម្បីធានានូវសុវត្ថិភាពដល់អតិថិជន និងនិយោជិតរបស់ពួកយើង ហើយកំឡុងពេលនេះ ពួកយើង ខិតខំរក្សាសេវាកម្មប្រកបដោយគុណភាពជាមួយនឹងភាពរអាក់រអួលតិចបំផុត។ ពួកយើង បានផ្តល់ការគាំទ្រដល់អតិថិជនកម្ចីរបស់ពួកយើង នៅកំឡុងពេលដែលមានភាពមិនប្រាកដប្រជានេះ ដោយផ្តល់នូវដំណោះស្រាយហិរញ្ញវត្ថុ ដែលមានស្ថេរភាព ដើម្បីជួយឲ្យពួកគាត់ អាចជៀសផុតនូវបញ្ហានានា នៅក្នុងអាជីវកម្មរបស់ពួកគាត់។ ជាមួយនឹងស្មារតីប្រកបដោយការទទួលខុសត្រូវ ពួកយើង បានជួយដល់កិច្ចខិតខំប្រឹងប្រែង ដើម្បីទប់ស្កាត់ការរីករាលដាលនៃវីរុសមួយនេះ តាមរយៈការរួមចំណែកនានា ជាជំនួយដល់ក្រុមការងារជួរមុខ ដើម្បីកាត់បន្ថយបន្ទុកលើប្រព័ន្ធថែទាំសុខភាពក៏ដូចជាផ្តល់ជំនួយសង្គ្រោះដល់សហគមន៍ដែលជួបការលំបាក។

ទោះបីជាស្ថិតនៅក្នុងភាពមិនប្រាកដប្រជា ដែលមិនធ្លាប់មានពីមុនមកក៏ដោយ ប៉ុន្តែរឿងមួយ ដែលពួកយើង អាចជឿជាក់បានជានិច្ច ក្នុងការដោះស្រាយនូវការលំបាកផ្សេងៗ នៅក្នុងឆ្នាំនេះ គឺបេសកកម្មសេវាហិរញ្ញវត្ថុប្រកបដោយអរិយ្យភាព។ ដោយសារការជំរុញនេះហើយ ទើបពួកយើង សម្រេចចិត្តធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីជួយគាំទ្រដល់អ្នកពាក់ព័ន្ធទាំងអស់ ដោយមិនទុកនរណាម្នាក់ចោលឡើយ។

អតិថិជន

- បានផ្តល់ជំនួយហិរញ្ញវត្ថុ និងការគាំទ្រនានា ដល់អតិថិជន ដែលរងផលប៉ះពាល់ ដែលចាប់ផ្តើមនៅចុងខែមីនា ឆ្នាំ២០២០ តាមរយៈការផ្អាកការសងប្រាក់កម្ចី ក៏ដូចជាការរៀបចំឥណទានឡើងវិញ និងការកំណត់ពេលវេលាសងឥណទានឡើងវិញ។
- បានចូលរួមក្នុងគម្រោងសហហិរញ្ញប្បទានពិសេស ក្នុងភាពជាដៃគូជាមួយធនាគារធុនតូច និងមធ្យម នៅក្នុងប្រទេសកម្ពុជា ដែលជាការផ្តួចផ្តើមហិរញ្ញវត្ថុថ្នាក់ជាតិ ដែលដឹកនាំដោយរាជរដ្ឋាភិបាលកម្ពុជា ដោយរួមសហការជាមួយធនាគារពាណិជ្ជកម្ម និងមីក្រូហិរញ្ញវត្ថុ ដើម្បីគាំទ្រសហគ្រាសធុនតូច និងមធ្យម នៅក្នុងឧស្សាហកម្មអាទិភាព។
- ការទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយអតិថិជន បានជួយឲ្យពួកយើង អាចធ្វើការណែនាំអំពីជម្រើសនានា សម្រាប់ជំនួយហិរញ្ញប្បទាន ស្របពេលដែលពួកយើងខិតខំបន្តលើកទឹកចិត្តអតិថិជនឲ្យធ្វើប្រតិបត្តិការតាមអ៊ីនធឺណែត ដើម្បីកាត់បន្ថយការធ្វើប្រតិបត្តិការដោយផ្ទាល់នៅតាមបណ្តាសាខា ស្របទៅតាមការណែនាំនៃការរីតបន្តឹងការធ្វើដំណើរ។
- ពួកយើងបានពន្លឿនការកែលម្អ និងដាក់ឲ្យប្រើប្រាស់ផលិតផល និងសេវាកម្មហិរញ្ញវត្ថុតាមអ៊ីនធឺណែតយ៉ាងពេញលេញ ដើម្បីឲ្យអតិថិជនអាចបំពេញតម្រូវការសេវាធនាគារប្រចាំថ្ងៃរបស់ពួកគាត់ពីចម្ងាយ ដោយមានការរអាក់រអួលតិចតួចបំផុត។
- ចំពោះការធ្វើប្រតិបត្តិការ ដោយផ្ទាល់នៅតាមបណ្តាញសាខា ពួកយើងបានធ្វើការបាញ់សម្អាតមេរោគយ៉ាងទៀងទាត់។ ពួកយើងធានាបាននូវការប្រតិបត្តិតាមគោលការណ៍ប្រតិបត្តិស្តង់ដារ ដោយអនុវត្តន៍វិធានការណ៍ការពារគម្លាតពីគ្នានៅតាមកន្លែងដែលអតិថិជនរងចាំ ក៏ដូចជាការប្រើប្រាស់ឧបករណ៍ការពារដូចជារបាំងមុខ និងទឹកលាងសម្អាតដៃ។

សម្រាប់ព័ត៌មានបន្ថែមអំពី នាយកដ្ឋានសេវាហិរញ្ញវត្ថុសហគមន៍ នៅទំព័រទី២៦ ការផ្តល់ជូនគុណភាពសេវាកម្មនៅទំព័រទី ៣០ និងរបាយការណ៍ស្តីអំពីចីរភាព នៅទំព័រទី៥៣។

និយ័តករ

- យោងទៅតាមការណែនាំរបស់និយ័តករ ស្តីអំពីជំនួយហិរញ្ញប្បទាន ពួកយើង៖
  - បានបង្កើតក្របខណ្ឌថ្មីៗ និងគោលការណ៍ណែនាំស្តីអំពីប្រាក់កម្ចី ដែលរួមមានការវាយតម្លៃសមត្ថភាពរបស់អតិថិជនកម្ចីសម្រាប់ធ្វើការទូទាត់សំណង ទម្រង់ហានិភ័យ ការរៀបចំឥណទានឡើងវិញ និងការកំណត់ពេលវេលាសងឥណទានឡើងវិញ និងតម្រូវការទ្រព្យបញ្ចាំនានា ដើម្បីឆ្លើយតបបានយ៉ាងឆាប់រហ័ស និងប្រកបដោយភាពបត់បែន ដល់តម្រូវការរបស់អតិថិជនកម្ចី ដែលទទួលរងផលប៉ះពាល់។
  - បានបង្កើតក្រុមការងារ ដើម្បីពិចារណា និងអនុវត្តន៍យុទ្ធសាស្ត្រលើឥណទាន ដែលមានភាពរហ័ស ស្របពេលដែលរក្សាបាននូវមូលធនគ្រប់គ្រាន់ សន្ទនីយភាព និងគុណភាពទ្រព្យសកម្មរបស់ធនាគារ។
  - បង្កើនការយកចិត្តទុកដាក់របស់គណៈកម្មាធិការគ្រប់គ្រងគុណភាពទ្រព្យសកម្ម ដើម្បីធ្វើការដឹកនាំសម្របសម្រួល និងធានាឲ្យមានការអនុវត្តយុទ្ធសាស្ត្រ និងកម្មវិធីប្រកបដោយប្រសិទ្ធភាព និងកម្មវិធីពន្យាពេលនៃការសងកម្ចីរបស់ធនាគារ។
  - បន្តធ្វើស្ត្រេសតេស្ត និងការវិភាគនានា ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៅក្នុងបរិបទប្រតិបត្តិការ ដើម្បីធានានូវភាពធន់ជាទូទៅ។
- ធនាគារ មេយវើង បន្តផ្តល់អាទិភាពលើភាពរឹងមាំនៃដើមទុន និងសន្ទនីយភាព ព្រមទាំងអនុវត្តបានយ៉ាងល្អ លើសពីការកំណត់អប្បបរមានៃបទប្បញ្ញត្តិ ទោះបីជាជំនួយដើមទុន និងសន្ទនីយភាពនេះ អាចធ្វើឡើងទៅបានក្នុងវិស័យធនាគារ តាមរយៈរូបភាពនៃការផ្តល់កម្ចី មានលក្ខណៈទាបជាងការកំណត់នៃសន្ទនីយភាព។

សម្រាប់ព័ត៌មានបន្ថែមអំពី ទស្សនៈឆ្លុះបញ្ចាំងរបស់នាយកនាយកដ្ឋានហិរញ្ញវត្ថុ នៅទំព័រទី២៨ និងនាយកដ្ឋានគ្រប់គ្រងហានិភ័យ នៅទំព័រទី៣១។

ដំណោះស្រាយក្នុងស្ថានភាពនៃការរាតត្បាតជំងឺកូវីដ១៩

សហគមន៍

- បានចូលរួមវិភាគទានជូនដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្តួចផ្តើមរបស់រដ្ឋាភិបាលក្នុងការដោះស្រាយស្ថានភាពជំងឺកូវីដ១៩ ដើម្បីធ្វើការទិញឧបករណ៍ការពារ ឧបករណ៍មន្ទីរពេទ្យ ឧបករណ៍តេស្តរកជំងឺកូវីដ១៩និងគំនិតផ្តួចផ្តើមផ្សេងៗ ដើម្បីកាត់បន្ថយប្រព័ន្ធថែទាំសុខភាព និងជនដែលងាយប្រឈមមុខ ក៏ដូចជាជួយសហគមន៍ដែលងាយរងគ្រោះ។
- បានចូលរួមវិភាគទានមួយចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការជួយដល់ជនរងគ្រោះដោយទឹកជំនន់ ដែលបណ្តាលឲ្យមានការលំបាកជាយូរមកហើយ នៅពេលដែលសហគមន៍កំពុងប្រឈមនឹងបញ្ហាដែលបណ្តាលមកពីការរាតត្បាតនៃជំងឺនេះ។
- ពួកយើង ក៏បានរួមចំណែកក្នុងការសម្របសម្រួល ដើម្បីអនុញ្ញាតិឲ្យសាធារណៈជន ចូលរួមជួយដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រមូលមូលនិធិ ដើម្បីទិញវ៉ាក់សាំងការពារជំងឺកូវីដ១៩ ។
- ផ្តល់ការគាំទ្រដល់ស្ត្រីតម្បាញកម្ពុជា ដែលបានទទួលការបណ្តុះបណ្តាលក្រោមកម្មវិធីស្ត្រី និងតម្បាញរបស់ធនាគារ មេយប៉ែង តាមរយៈការសហការជាមួយដៃគូអនុវត្តន៍កម្មវិធីរបស់ពួកយើង អង្គការសូត្រពណ៌ ក្នុងប្រទេសកម្ពុជាតាមរយៈការផលិត ម៉ាស់សូត្រដែលត្បាញដោយដៃផ្ទាល់ប្រមាណជាង ១១០,០០០ ម៉ាស់ដែលធ្វើពីកប្បាស និងសូត្រសុទ្ធ ដើម្បីជួយសម្រួលដល់ស្ថានភាពលំបាកនៃការរីករាលដាលនៃជំងឺកូវីដ១៩នៅក្នុងប្រទេស និងក្នុងតំបន់។
- តាមរយៈការសហការជាមួយមូលនិធិធនាគារមេយប៉ែងពួកយើងបានផ្តល់ជូនម៉ាស់សូត្រដែលត្បាញដោយដៃជូនទៅលេខាធិការដ្ឋានអាស៊ានដែលមានសារសុឆន្ទៈនិងបង្ហាញពីភាពសាមគ្គីភាពដែលឆ្លងកាត់ព្រំដែនហើយជានិមិត្តរូបនៃក្តីសង្ឃឹម និងជាការអធិដ្ឋានរបស់ស្ត្រីតម្បាញសម្រាប់សមាជិកអាស៊ានទាំង១០ប្រទេស ។
- ពួកយើងក៏បានផ្តល់ជូន ម៉ាស់សូត្រដែលត្បាញដោយដៃចំនួន ៦,០០០ម៉ាស់ ដល់ក្រសួងអប់រំ យុវជន និងកីឡា ដោយភ្ជាប់ជាមួយនឹងការបើកសាលារដ្ឋឡើងវិញ ដើម្បីគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីបន្តសេវាកម្មអប់រំ សម្រាប់យុវជនជំនាន់ក្រោយជាពិសេសកុមារ ខណៈពេលដែលមានការប្រុងប្រយ័ត្នជាចាំបាច់ ដើម្បីការពារសិស្ស គ្រូបង្រៀន និយោជិត និងក្រុមគ្រួសាររបស់ពួកគេ។ គំនិតផ្តួចផ្តើមនេះ ក៏បានផ្តល់នូវឱកាសសេដ្ឋកិច្ចបន្ថែម សម្រាប់អ្នកតម្បាញកម្ពុជា ដែលបានស្របទៅនឹងបេសកកម្មទូទៅរបស់រដ្ឋាភិបាលឆ្ពោះទៅរកការជំរុញកំណើនសេដ្ឋកិច្ច និងជួយសហគមន៍ឲ្យក្រោកឡើងវិញ ពីការរំខានដែលមិនធ្លាប់មានពីមុនមក ដែលបណ្តាលមកពីជំងឺកូវីដ១៩។
- ស្របតាមកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការលើកកម្ពស់កម្រិតចំណេះដឹងផ្នែកហិរញ្ញវត្ថុក្នុងចំណោមប្រជាជនកម្ពុជា ដែលជាកម្មវិធីចំណេះដឹងផ្នែកហិរញ្ញវត្ថុ CashVille Kidz ដែលជាកម្មវិធីទទួលបានពានរង្វាន់របស់ធនាគារ មេយប៉ែង ត្រូវបានបង្ហាញនៅលើវេទិការឌីជីថលរបស់ក្រសួងអប់រំ យុវជន និងកីឡា។ កម្មវិធីនេះ ត្រូវបានផ្តួចផ្តើម ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ ក្រសួងអប់រំយុវជន និងកីឡា ដើម្បីបង្កើនការសិក្សាតាមរយៈអ៊ីនធឺណេតក្នុងកំឡុងពេលរាតត្បាតនេះ ដែលបណ្តាលឲ្យមានការបិទសាលារៀនជាច្រើនលើក ដើម្បីទប់ស្កាត់ការផ្ទុះឡើងនៃជំងឺនេះ។ វេទិការៀនឌីជីថលរបស់ក្រសួងបានក្លាយជាបណ្តាញចែកចាយ ចំណេះដឹងដ៏សំខាន់មួយសម្រាប់ប្រជាជន នៅក្នុងប្រទេស។

សម្រាប់ព័ត៌មានបន្ថែមអំពី នាយកដ្ឋានសេវាហិរញ្ញវត្ថុសហគមន៍ នៅទំព័រទី២៦ និងរបាយការណ៍ស្តីអំពីចីរភាព នៅទំព័រទី៥៣។

និយោជិត

- មុនពេលដែលជំងឺកូវីដ១៩ ត្រូវបានប្រកាសថាជាជំងឺរាតត្បាតមកម្ល៉ោះ ពួកយើងបានបង្កើត និងអនុវត្តន៍នូវក្របខណ្ឌនានា នៅកម្រិតសម្ព័ន្ធធនាគារ មេយប៉ែងទាំងមូលក្នុងការរៀបចំត្រៀមសម្រាប់ប្រយុទ្ធប្រឆាំងនឹងមេរោគរាតត្បាតនេះ និងបានបន្តរៀបចំផែនការបន្តអាជីវកម្មរបស់ពួកយើង។ ដើម្បីកាត់បន្ថយហានិភ័យ និងគ្រប់គ្រងទំហំនៃការឆ្លងជំងឺកូវីដ១៩ រាល់វិធានការផ្សេងៗរបស់ពួកយើងត្រូវបានណែនាំដោយគោលការណ៍សំខាន់ៗចំនួនបួន រួមមាន៖
  - ការធ្វើការនៅដោយឡែក និងឆ្ងាយពីគ្នា
  - ការព្យាយាមកាត់បន្ថយ ប្រសិនបើមិនអាចបំបាត់ចោលទាំងស្រុងនៃការឆ្លងក្នុងចំណោមនិយោជិតធ្វើការ
  - រក្សាអនាម័យខ្ពស់ និងការអនុវត្តប្រកបដោយសុវត្ថិភាពនៅកន្លែងធ្វើការ
  - ធានានូវការថែរក្សាសុខភាព និងសុវត្ថិភាពរបស់និយោជិត ក្រុមគ្រួសារ អតិថិជន និងសហគមន៍ក៏ដូចជាការបន្តប្រតិបត្តិការរបស់យើង។

- ការផ្តួចផ្តើមសំខាន់ៗមួយចំនួនរួមមាន៖
  - គោលនយោបាយធ្វើដំណើរទាំងការដាក់កម្រិត ឬហាមឃាត់និយោជិតពីការធ្វើដំណើរកម្សាន្ត និងការងារ។
  - ការបំបែកការធ្វើប្រតិបត្តិការទៅតាមការិយាល័យ ធ្វើការនៅទីតាំងជំនួស និងធ្វើការពីគេហដ្ឋាន។
  - ការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដារយ៉ាងតឹងរឹងរួមមាន ការរក្សាគម្លាតពីគ្នា ការប្រើប្រាស់ឧបករណ៍ការពារនានា ការត្រួតពិនិត្យសុខភាព សេចក្តីប្រកាសអំពីការធ្វើដំណើរ និងការពន្យាពេលរៀបចំកម្មវិធីទាំងអស់ ដែលតម្រូវឲ្យមានការចូលរួមដោយផ្ទាល់។
  - ពន្លឿនការអនុវត្តគោលនយោបាយ និងការងារ ដែលអាចបត់បែនបាន ក្នុងការជួយសម្រួលដល់ការធ្វើការចល័ត និងការដាក់ចេញនូវហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ដែលមានភាពចាំបាច់។
  - បានកំណត់ប្រតិបត្តិការតាមបណ្តាញសាខាឡើងវិញ ដោយធ្វើការកាត់បន្ថយចំនួនម៉ោងធ្វើការរបស់ធនាគារ និងចំនួននិយោជិតស្របពេល ដែលធានាឲ្យបាននូវកម្រិតសេវាកម្មនៅដដែល។
  - បានបង្កើតក្រុមការងារគាំទ្រប្រតិបត្តិការបន្ទាន់ផ្នែកធនធានមនុស្ស នៃសម្ព័ន្ធធនាគារ ២៤ម៉ោងក្នុង ៧ថ្ងៃ ក៏ដូចជាក្រុមការងារធនធានមនុស្សក្នុងប្រទេស និងបន្តគ្រប់គ្រងអាជីវកម្ម ហើយនិងចេញសេចក្តីណែនាំជាទៀងទាត់រួមទាំងសៀវភៅណែនាំកន្លែងធ្វើការរបស់និយោជិត។
  - ផ្តួចផ្តើមឲ្យមានការសិក្សា តាមរយៈប្រព័ន្ធអ៊ីនធឺណែត និងការចូលរួមរបស់និយោជិតជាប្រចាំ ដើម្បីលើកកម្ពស់សុខមាលភាពផ្លូវចិត្ត កាយសម្បទា និងសមត្ថភាពការងាររបស់និយោជិត។ សេវាកម្មប្រឹក្សាយោបល់ ក៏ត្រូវបានផ្តល់ជូនដល់និយោជិតសម្រាប់ការគាំទ្រផ្លូវចិត្តផងដែរ។
  - ការដាក់ឲ្យប្រើប្រាស់នូវកន្លែងធ្វើការតាមបែបគន្លងថ្មី ដើម្បីត្រួតពិនិត្យ និងធានាឲ្យបាននូវការប្រតិបត្តិយ៉ាងតឹងរឹង នូវរាល់វិធានការណ៍ ដែលដាក់ឲ្យអនុវត្តដោយធនាគារ។

សម្រាប់ព័ត៌មានបន្ថែមអំពី នាយកដ្ឋាន ធនធានមនុស្ស នៅទំព័រទី៣២។

យុទ្ធសាស្ត្រ
របស់ពួកយើង

សមិទ្ធិផលសំខាន់ៗរបស់ធនាគារ មេយប៊ែងក្នុងឆ្នាំ២០២០

ក្នុងការសម្រេចឲ្យបាននូវគោលដៅ "**ការសម្រេចគោលបំណងរបស់អាស៊ីជាមួយលោកអ្នក**" យុទ្ធសាស្ត្រ ធនាគារ មេយប៊ែង ២០២០ គឺជាត្រីវិស័យក្នុងការចង្អុលផ្លូវរបស់ពួកយើងក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ។ នៅក្នុងអំឡុងពេលនេះ ធនាគារ មេយប៊ែង បានពង្រឹងមូលដ្ឋានគ្រឹះរបស់ខ្លួនប្រកបដោយចីរភាពក្នុងរយៈពេលវែង ជាពិសេសតាមរយៈការវិនិយោគលើប្រព័ន្ធឌីជីថល និងការកសាងសមត្ថភាព។

- បាននាំមកនូវដំណោះស្រាយឌីជីថលឈានមុខគេជាច្រើន ដែលរួមមានកម្មវិធីធនាគារចល័ត និងធនាគារតាមអ៊ីនធឺណែត Maybank2u និងប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ Maybank2E
- បានបង្កើនសមត្ថភាពនិយោជិត ដែលមានជំនាញខ្ពស់តាមរយៈកម្មវិធី FutureReady របស់ពួកយើង
- បានបង្កើតសមត្ថភាពច្នៃប្រឌិតថ្មីតាមរយៈមន្ទីរពិសោធន៍ធនាគារ មេយប៊ែង
- បង្កើតភាពជាដៃគូយុទ្ធសាស្ត្រ ជាមួយស្ថាប័ននានា ដើម្បីបង្កើតនូវគុណតម្លៃរបស់ពួកយើង

ជាភស្តុតាងក្នុងកិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅកាន់ឌីជីថល ពួកយើង បានបង្កើនសមត្ថភាពឌីជីថលរបស់ពួកយើង ដើម្បីគាំទ្រដល់អតិថិជន និងសហគមន៍របស់ពួកយើងក្នុងអំឡុងពេលការចាប់ផ្តើមនៃការរាតត្បាតជាសកលនៅក្នុងឆ្នាំ២០២០។ មូលដ្ឋានគ្រឹះនេះ បានកំណត់ជាទីតាំង ដើម្បីឲ្យពួកយើងនៅតែអាចរក្សាភាពពាក់ព័ន្ធផ្សេងៗទៅនឹងការប្រកួតប្រជែង និងគោលដៅចីរភាពរយៈពេលវែង។

ជម្រើសដៃគូធនាគារបស់សហគមន៍

ដើម្បីក្លាយជា ស្ថាប័នហិរញ្ញវត្ថុបុគ្គល និងសាជីវកម្ម ដែលឈានមុខគេនៅប្រទេសកម្ពុជា ដែលផ្តោតលើការបង្កើតមូលដ្ឋានរបស់យើងនៅក្នុងតំបន់ ភាពឯកទេសលើវិស័យធនាគារ និងឱកាសក្នុងការរីកចម្រើននៅប្រទេសកម្ពុជា និងអាស៊ាន។

ចំនួនអ្នកចុះឈ្មោះប្រើ ប្រាស់កម្មវិធីធនាគារចល័ត និងធនាគារតាមអ៊ីនធឺណែត Maybank2u នៅប្រទេសកម្ពុជា

ច្រើនជាង
៣៥.000
អ្នកប្រើប្រាស់ក្នុងឆ្នាំ២០២០

ច្រើនជាង
១២.000
អ្នកប្រើប្រាស់ក្នុងឆ្នាំ២០១៦

ចំនួនប្រតិបត្តិការសរុប តាមរយៈធនាគារចល័ត និងធនាគារតាមអ៊ីនធឺណែត Maybank2u ជាលក្ខណៈបុគ្គល

ច្រើនជាង
៤,៥លាន
ប្រតិបត្តិការនៅក្នុងឆ្នាំ២០២០

ច្រើនជាង
៩៦0.000
ប្រតិបត្តិការនៅក្នុងឆ្នាំ២០១៦

ចំនួនទឹកប្រាក់ដែលត្រូវបានប្រតិបត្តិការតាមរយៈធនាគារចល័ត និងធនាគារតាមអ៊ីនធឺណែត Maybank2u ជាលក្ខណៈបុគ្គល

ច្រើនជាង
១៣៣លានដុល្លារ
ទឹកប្រាក់ដែលត្រូវបានប្រតិបត្តិការក្នុងឆ្នាំ២០២០

ច្រើនជាង
0,៨ លានដុល្លា
ទឹកប្រាក់ដែលត្រូវបានប្រតិបត្តិការក្នុងឆ្នាំ២០១៦

ពានរង្វាន់

- ពានរង្វាន់ ធនាគារអន្តរជាតិល្អបំផុត នៅប្រទេសកម្ពុជាឆ្នាំ២០២0 ពី Asiamoney Best Bank Awards 2020
- ពានរង្វាន់ ធនាគារកិច្ចបុគ្គលឆ្នើមបំផុត (ប្រចាំប្រទេសកម្ពុជា) ពី Retail Banker International Asia Trailblazer Awards 2020
- ពានរង្វាន់ ធនាគារកិច្ចបុគ្គលឆ្នើមបំផុត ប្រចាំប្រទេសកម្ពុជាឆ្នាំ២0២0 ពី Global Business Outlook Awards 2020
- ពានរង្វាន់ ធនាគារកិច្ចបុគ្គលឆ្នើមបំផុតឆ្នាំ២0២0 ពី Global Economic Awards 2020
- ពានរង្វាន់ ធនាគារកិច្ចបុគ្គលឆ្នើមបំផុត ប្រចាំប្រទេសកម្ពុជាឆ្នាំ២0២0 ពី The Global Banking Finance Awards 2020
- ពានរង្វាន់ ធនាគារផ្នែកគំនិតផ្តួចផ្តើមទំនួលខុសត្រូវសង្គមឆ្នើមបំផុត ពី Retail Banker International Asia Trailblazer Awards 2020
- ពានរង្វាន់ ធនាគារទំនួលខុសត្រូវផ្នែកសង្គមសកម្មបំផុត ប្រចាំប្រទេសកម្ពុជា ឆ្នាំ២0២0 ពី Global Business Outlook Awards 2020
- ពានរង្វាន់ ធនាគារទំនួលខុសត្រូវសង្គមឆ្នើមបំផុត ឆ្នាំ២0២0 ពី The Global Economic Awards 2020
- ពានរង្វាន់ ធនាគារទំនួលខុសត្រូវសង្គមឆ្នើមបំផុត ប្រចាំប្រទេសកម្ពុជា ឆ្នាំ២0២0 ពី The Global Banking Finance Awards 2020

ប្រាក់បញ្ញើ

ប្រាក់បញ្ញើរបស់ពួកយើង បានកើនឡើងប្រមាណជា ៤៩,៣% ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ដោយសារការគ្រប់គ្រងការទំនាក់ទំនងជាមួយអតិថិជន ប្រកបដោយប្រសិទ្ធភាព និងការរៀបចំពិនិត្យមើលគណនីធនាគាររបស់អតិថិជន ស្របតាមបទបញ្ជាគ្តិនានា នៅទូទាំងបណ្តាញសាខា និងបណ្តាញចែកចាយនានារបស់ពួកយើង។

ឆ្នាំ២0២0
១,0៦ប៊ីលានដុល្លារ

ឆ្នាំ២0១៦
0,៧១ ប៊ីលានដុល្លារ

ឥណទាន

កំណើនឥណទាន បានកើនឡើងប្រមាណជា ៣៨,២% ក្នុងរយៈពេល ៥ឆ្នាំ។

ឆ្នាំ២0២0
0,៧៦ប៊ីលានដុល្លារ

ឆ្នាំ២0១៦
0,៥៥ប៊ីលានដុល្លារ

ការដាក់ឲ្យប្រើប្រាស់នូវកម្មវិធី ធនាគារកិច្ចចល័ត Maybank2u KH ដែលត្រូវបានរចនាថ្មីស្រឡាងរបស់យើង

- ចូលមើលគណនីបានយ៉ាងឆាប់រហ័ស ដោយគ្រាន់តែធ្វើការស្កេនក្រយៅដៃ ឬស្កេនមុខ
- ពិនិត្យមើលសមតុល្យ និងប្រវត្តិប្រតិបត្តិការ
- ផ្ទេរប្រាក់ទៅធនាគារ មេយប៊ែង ឬ ទៅបណ្តាធនាគារផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា តាមរយៈការផ្ទេរប្រាក់តាមអ៊ីនធឺណែត ឬ ប្រព័ន្ធផ្ទេរប្រាក់រហ័ស
- បង់វិកយបត្រតាមអ៊ីនធឺណែត ទៅលើថ្លៃទឹកភ្លើង អ៊ីនធឺណែត ប័ណ្ណឥណទាន បុព្វលាភធានារ៉ាប់រង និងវិក្កយបត្រផ្សេងជាច្រើនទៀត
- បញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទដៃដោយស្វ័យប្រវត្តិ ឬប្រើលេខកូដ
- ដកប្រាក់ពីម៉ាស៊ីនដកប្រាក់ ATM ឬម៉ាស៊ីនដក និងដាក់ប្រាក់ របស់ធនាគារ មេយប៊ែងដោយមិនប្រើប័ណ្ណ។

គុណតម្លៃ T.I.G.E.R របស់យើង ត្រូវបានប្រើប្រាស់ជាគោលការណ៍ណែនាំ ដើម្បីផ្តល់ការលើកទឹកចិត្តដល់ការអនុវត្តដែលបង្កើតបាន ជាវប្បធម៌ដ៏លេចធ្លោតែមួយគត់របស់យើង។

ការធ្វើការជាក្រុម
ពួកយើងធ្វើការរួមគ្នា ជាក្រុមដោយ ផ្អែកលើការគោរព និងសេចក្តីថ្លៃថ្នូរចំពោះគ្នាទៅវិញទៅមក។

ភាពសុចរិត
ពួកយើងធ្វើការប្រកបដោយភាពស្មោះត្រង់វិជ្ជាជីវៈ និងក្រមសីលធម៌នៅក្នុង ការដោះស្រាយបញ្ហារបស់ពួកយើង។

យុទ្ធសាស្ត្ររបស់ពួកយើង

យុទ្ធសាស្ត្រ៥ឆ្នាំខាងមុខរបស់ធនាគារ មេយប៊ែង M25

M25 គឺជាយុទ្ធសាស្ត្រដែលមានរយៈពេលវែងបន្ទាប់របស់ធនាគារ មេយប៊ែង ដែលឆ្ពោះទៅរកឆ្នាំ២០២៥ខាងមុខ ដើម្បីសម្រេចឲ្យបាននូវគោលបំណង យុទ្ធសាស្ត្រផែនការ និងលទ្ធផលសម្រាប់រយៈពេល៥ឆ្នាំខាងមុខរបស់ពួកយើង។ តាមរយៈយុទ្ធសាស្ត្រM25 គោលបំណងរបស់ពួកយើង គឺធ្វើការពង្រឹងទៅលើវិធីសាស្ត្រ ដែលពួកយើងធ្វើការផ្តោតបន្ថែមទៅលើការច្នៃប្រឌិតផ្នែកឌីជីថល ដើម្បីបង្កើតនូវគុណភាពសេវាកម្មឈានមុខគេ ស្របពេលដែលយើងធ្វើការពង្រឹងគ្រប់ផ្នែកនៃអាជីវកម្មរបស់ពួកយើង ដើម្បីឲ្យពួកយើងត្រៀមខ្លួនរួចជាស្រេចសម្រាប់ថ្ងៃអនាគត (FutureReady) ដើម្បីចាប់យកនូវឱកាសរីកចម្រើនថ្មីៗ។ ជាមួយនឹងការផ្តល់នូវយន្តការប្រកបដោយចីរភាពរបស់ពួកយើង យើងក៏មានបំណងធ្វើការផ្លាស់ប្តូរយ៉ាងសកម្មចំពោះគំរូ និងគោលនយោបាយប្រតិបត្តិការរបស់ពួកយើង ដែលនឹងមានគុណតម្លៃនៅក្នុងរយៈពេលវែង។

នៅពេល ដែលពួកយើងជំរុញការផ្លាស់ប្តូរទាំងនេះ ទៅលើផ្នែកឌីជីថល និងប្រកបដោយចីរភាព យុទ្ធសាស្ត្រM25 នឹងត្រូវប្រតិបត្តិ ដោយស្របទៅតាម គោលបំណងរួមរបស់យើង គឺសេវាហិរញ្ញវត្ថុប្រកបដោយអរិយភាព ដែលត្រូវបានពន្យល់ដូចខាងក្រោម៖

សេវាហិរញ្ញវត្ថុប្រកបដោយអរិយភាព

ក្នុងនាមដែលពួកយើង ជាបេះដូងនៃសហគមន៍ ពួកយើងនឹង៖

១ បង្កើតនូវសេវាកម្មហិរញ្ញវត្ថុ ដែលមានភាពសាមញ្ញ ងាយយល់ និងងាយស្រួលក្នុងការប្រើប្រាស់

២ កសាងភាពជាដៃគូ ដែលមានទំនុកចិត្តខ្ពស់ សម្រាប់អនាគតប្រកបដោយចីរភាពជាមួយគ្នា

៣ ផ្តល់ជូនសេវាកម្មដល់អតិថិជនគ្រប់គ្នា ប្រកបដោយសេចក្តីគោរព សេចក្តីថ្លៃថ្នូរ ស្មើភាព និងភាពសុចរិត

សម្រាប់ភាគីពាក់ព័ន្ធរបស់ពួកយើង

អតិថិជន
- គុណភាពសេវាកម្ម កម្រិតឈានមុខគេ
- ភាពងាយស្រួល ក្នុងការប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុ (ឌីជីថល និងរូបវន្តបុគ្គល)
- លក្ខខណ្ឌ និងតម្លៃស្មើភាពនៅក្នុងទីផ្សារ និងការប្រឹក្សា ដោយផ្អែកលើតម្រូវការ
- ការធ្វើឲ្យការគាំទ្រ ទៅជាការអនុវត្តប្រកបដោយចីរភាព

ភាគទុនិក
- ការទទួលបានមកវិញប្រកបដោយទំនួលខុសត្រូវ និងចីរភាព
- អភិបាលកិច្ចមានភាពខ្លាំង និងតម្លាភាព

និយោជិត
- ការទទួលបានមកវិញប្រកបដោយទំនួលខុសត្រូវ និងចីរភាព
- អភិបាលកិច្ចមានភាពខ្លាំង និងតម្លាភាព

និយ័តករ
- អ្នកមានជំនាញស្តង់ដារ នៅក្នុងវិស័យ
- មានវិជ្ជាជីវៈ និងក្រមសីលធម៌ក្នុងការប្រកបអាជីវកម្ម

សហគមន៍
- បរិយាប័ន្នហិរញ្ញវត្ថុ និងការលើកកម្ពស់
- ការប្តេជ្ញាចិត្ត នៃការអនុវត្តប្រតិបត្តិការ ដើម្បីសេដ្ឋកិច្ចដែលមានការកាត់បន្ថយកាបូន

រចនាសម្ព័ន្ធរបស់សម្ព័ន្ធធនាគារ M25

ដោយផ្អែកលើគោលបំណងរបស់ពួកយើង រចនាសម្ព័ន្ធរបស់សម្ព័ន្ធធនាគារ M25 នឹងក្លាយទៅជាមគ្គុទេសណែនាំយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំខាងមុខ ដែលត្រូវបានដឹកនាំដោយ**អាទិភាពសំខាន់ៗរបស់សម្ព័ន្ធធនាគារ** ដែលរួមមានការពង្រឹងផ្នែកឌីជីថល ការបង្កើនគុណតម្លៃថ្មីៗ និងការជំរុញឲ្យមានការអភិវឌ្ឍនានាប្រកបដោយចីរភាព ដើម្បីទទួលបាននូវផលចំណេញធៀប នឹងមូលធន ប្រកបដោយចីរភាព គុណភាពសេវាកម្មដល់អតិថិជន ដែលទទួលបានការចាប់អារម្មណ៍ខ្ពស់ និងភាពជាអ្នកដឹកនាំ ផ្នែកគោលនយោបាយស្តីអំពី បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ប្រចាំតំបន់។ **ការជំរុញឲ្យមានយុទ្ធសាស្ត្រក្នុងការធ្វើអាជីវកម្ម** គឺជាការបង្ហាញច្បាស់លាស់នូវគោលបំណងយុទ្ធសាស្ត្រ សម្រាប់អាជីវកម្មរបស់ពួកយើង ដែលដំណើរការដោយគោរពតាម**គុណតម្លៃ TIGER របស់ពួកយើង**។

M25

សេវាហិរញ្ញវត្ថុប្រកបដោយអរិយភាព

ផលចំណេញធៀប នឹងមូលធន (ROE) ប្រកបដោយចីរភាព	គុណភាពសេវាកម្មអតិថិជន ដែលទទួលបានការចាប់អារម្មណ៍ខ្ពស់	ភាពជាអ្នកដឹកនាំនៃគោលនយោបាយស្តីអំពីបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ប្រចាំតំបន់

អាទិភាពយុទ្ធសាស្ត្ររបស់សម្ព័ន្ធធនាគារ

ការពង្រឹងផ្នែកឌីជីថល

ការវិវត្តខ្លួនពីស្ថាប័នផ្តល់សេវាកម្មហិរញ្ញវត្ថុ ទៅជាដៃគូក្នុងការរស់ប្រចាំថ្ងៃ របស់អតិថិជនរបស់ពួកយើង ដោយផ្អែកលើការវិភាគទិន្នន័យកម្រិតខ្ពស់ ប្រព័ន្ធ និងវេទិកាដែលមានភាពធន់ ដែលត្រូវបានដំណើរការ ដោយវប្បធម៌នៃភាពរហ័សរហួន និងការរៀបចំខ្លួនសម្រាប់ថ្ងៃអនាគត (FutureReady)។

ការបង្កើនគុណតម្លៃថ្មីៗ

ការផ្តួចផ្តើមនៃការផ្លាស់ប្តូរនានា ដែលធ្វើឲ្យមានលទ្ធផលល្អប្រសើរជាងការប្រកបអាជីវកម្មជាប្រចាំរបស់ពួកយើង និងអាចជួយឲ្យពួកយើងអាចចាប់យកឱកាសនៃការរីកចម្រើនថ្មី នៅក្នុងវិស័យឌីជីថល ចីរភាព អាជីវកម្មខ្នាតតូចនិងមធ្យម និងទ្រព្យសម្បត្តិ ដោយមានគោលដៅបង្កើតនូវគុណតម្លៃ ដែលមានភាពប្រកួតប្រជែងក្នុងរយៈពេលវែង។

ចីរភាព

ការជំរុញឲ្យមានការផ្លាស់ប្តូរ ដើម្បីឲ្យពិភពលោកកាន់តែមានភាពល្អប្រសើរ និងជាដៃគូសម្រាប់ភាគីពាក់ព័ន្ធរបស់ពួកយើង ដើម្បីសម្រេចបាននូវភាពរីកចម្រើន ដែលប្រកបដោយចីរភាព ដោយផ្តោតលើការផ្លាស់ប្តូរ ដែលមានទំនួលខុសត្រូវលើសេដ្ឋកិច្ច ដែលមានការកាត់បន្ថយកាបូន ការលើកកម្ពស់សហគមន៍របស់ពួកយើង និងការបង្កើតជាឧទាហរណ៍ជាក់ស្តែងលើការអនុវត្តអភិបាលកិច្ចល្អ។

ការជំរុញឲ្យមានយុទ្ធសាស្ត្រក្នុងការធ្វើអាជីវកម្ម

ធនាគារអាស៊ាន ដែលទទួលបានទំនុកចិត្ត	អ្នកដឹកនាំជាសកលផ្នែកហិរញ្ញវត្ថុអ៊ីស្លាម	ក្រុមហ៊ុន ធានារ៉ាប់រង ដែលឈានមុខក្នុងអាស៊ាន

គុណតម្លៃ T.I.G.E.R របស់យើង

G — **ការរីកចម្រើន**
ពួកយើង ចង់បាននូវការរីកចម្រើន និងការច្នៃប្រឌិតខ្ពស់។

E — **ឧត្តមភាព និងប្រសិទ្ធភាព**
ពួកយើង ប្តេជ្ញាចិត្តក្នុងការផ្តល់នូវប្រតិបត្តិការដ៏ឆ្នើម និងសេវាកម្មល្អប្រសើរបំផុត។

R — **ការកសាងទំនាក់ទំនង**
ពួកយើង កសាងភាពជាដៃគូក្នុងរយៈពេលវែង និងផ្តល់ផលប្រយោជន៍ជូនដៃគូទៅវិញទៅមក។

បរិបទនៃ
ប្រតិបត្តិការរបស់យើង

ឆ្នាំនេះ គឺត្រូវបានចាត់ទុកថាជាឆ្នាំ ដែលមានបម្រែបម្រួលយ៉ាងខ្លាំង និងសំខាន់មួយ ដែលធ្វើឲ្យមានការផ្លាស់ប្តូរជាច្រើននៅក្នុងប្រតិបត្តិការអាជីវកម្មរបស់យើង ដែលតម្រូវឲ្យពួកយើង មានភាពប្រុងប្រយ័ត្នយ៉ាងខ្ពស់ ដើម្បីសម្របខ្លួនតាមបរិបទថ្មីយ៉ាងឆាប់រហ័ស ស្របពេលដែលពួកយើង ក៏នៅតែបន្តក្នុងការផ្តល់សេវាកម្ម និងបង្កើនគុណតម្លៃជូនដល់ភាគីពាក់ព័ន្ធរបស់យើងនៅក្នុងស្ថានភាពដែលលំបាកមួយនេះផងដែរ។

ជម្រើសដៃគូធនាគាររបស់សហគមន៍ នៅប្រទេសកម្ពុជា

ផលប៉ះពាល់លើប្រតិបត្តិការ៖

- ការប្រកួតប្រជែងទៅលើអត្រាការប្រាក់ទាប ដែលធ្វើឲ្យប៉ះពាល់ដល់ប្រាក់ចំណេញទាប និងការបង្រួមនៃកម្រិតចំណេញពីការប្រាក់សុទ្ធ រួមទាំង កម្រិតចំណេញពីការប្រាក់សុទ្ធ និងការធ្លាក់ចុះនៃប្រាក់ចំណេញដែលនាំឲ្យប្រាក់ចំណូលទាបពីសកម្មភាពឥណទាន។
- ការធ្លាក់ចុះអាជីវកម្ម និងសេដ្ឋកិច្ចជាសកលដោយសារតែការរីករាលដាលនៃជំងឺរាតត្បាត ដែលបណ្តាលឲ្យអាជីវកម្មធ្លាក់ចុះ និងកម្សោយនៃគុណភាពទ្រព្យសកម្ម។
- ការកើនឡើងនូវតម្រូវការដើម្បីគាំទ្រ និងធានាចីរភាពរបស់សហគ្រាសធុនតូច និងមធ្យមនៅចំពេលមានការផ្ទុះឡើងជំងឺរាតត្បាត ដោយសារកត្តាទាំងនេះ គឺជាចលករដ៏សំខាន់ក្នុងការជំរុញសេដ្ឋកិច្ចរបស់ប្រទេស។
- ការហាមឃាត់ក្នុងការធ្វើដំណើរ និងបញ្ហាវាំងស្នះដល់សេដ្ឋកិច្ចដោយសារការរីករាលដាលនៃជំងឺកូវីដ១៩ ដែលបង្កឲ្យមានផលរំខាននៅក្នុងវិស័យទេសចរណ៍ អាកាសចរណ៍ ប្រេងកាត និងឧស្ម័ន អចលនទ្រព្យ និងសំណង់ដែលនាំឲ្យមានផលប៉ះពាល់លើគុណភាពទ្រព្យសកម្ម។
- ការកាត់បន្ថយចំនួនអតិថិជន ដែលមកកាន់សាខាក្នុងការធ្វើប្រតិបត្តិការ និងការធ្វើប្រតិបត្តិការតាមរយៈអន្តរការី និងអតិថិជន។
- បង្កើនការយល់ដឹង ក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុអំពីតម្រូវការ ដើម្បីគាំទ្រដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលហៅកាត់ថា “SDGs”។
- ការកើនឡើងនូវតម្រូវការផ្នែកហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងសមត្ថភាពនៃការបង្កើតថ្មី ដើម្បីដំណើរការប្រតិបត្តិការរបស់យើងស្របតាមគន្លងថ្មីនៃការរស់នៅ និងគួបផ្សំជាមួយការប្រកួតប្រជែងកាន់តែខ្លាំង ពីការរំខាននានាទាំងផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ។
- ការដាក់ឲ្យប្រើប្រាស់នូវប្រព័ន្ធឌីជីថល និងការទូទាត់ដោយមិនកាន់សាច់ប្រាក់ ដោយសារការផ្ទុះឡើងជំងឺរាតត្បាត តម្រូវឲ្យមានភាពរហ័សរហួន និងភាពធន់ទៅលើសមត្ថភាព និងហេដ្ឋារចនាសម្ព័ន្ធផ្នែកឌីជីថល ដើម្បីជួយសម្រួលដល់តម្រូវការអតិថិជន និងសហគមន៍។
- ការកើនឡើងនូវការប្រកួតប្រជែងផ្នែកឌីជីថល គួបផ្សំនឹងការវិវត្តថ្មីៗនៃតម្រូវការតម្រូវការនិយ័តកម្ម និងការអភិវឌ្ឍទៅលើប្រព័ន្ធបច្ចេកវិទ្យា (ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ធនាគារ ប្តូរគ័ន និងគំរូ នៃការធ្វើការងារ គ្រប់ទីកន្លែង និងឬគេហដ្ឋាន) ដែលទាំងអស់នេះ តម្រូវឲ្យយើងត្រូវបន្តសម្របសម្រួល និងបង្កើតយន្តការថ្មីៗដែល អាចឲ្យយើងនៅតែរក្សាផលិតកម្ម និងបន្តអាជីវកម្មបាន។

ហានិភ័យ និងឱកាស៖

- ការកើនឡើងនូវតម្រូវការទៅលើដំណោះស្រាយហិរញ្ញវត្ថុ ប្រកបដោយភាពច្នៃប្រឌិត សម្រាប់អតិថិជនដែលស្ថិតនៅក្នុងថ្នាក់កណ្តាល រហូតដល់សហគ្រាសធុនតូច និងមធ្យម ដែលជាចលករសំខាន់មួយសម្រាប់សហគមន៍អាស៊ាន និងប្រទេសកម្ពុជា។
- ផលប៉ះពាល់លើសេដ្ឋកិច្ច ដែលរំខានទៅដល់ជីវភាពរបស់ប្រជាជននៅក្នុងសហគមន៍ និងធ្វើឲ្យពួកគាត់ខកខានក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ។
- ការផ្តល់ការអនុគ្រោះដល់អតិថិជន ដែលនាំឲ្យមានផល់ប៉ះពាល់ដល់ការគ្រប់គ្រងទ្រព្យសម្បត្តិ។
- ឱកាសនៃការរីកចម្រើនតូចចង្អៀតទៅលើវិស័យមួយចំនួនដូចជាការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនិងសុខាភិបាល។
- ការបន្តក្នុងការពង្រីកប្រព័ន្ធបច្ចេកវិទ្យាសម្រាប់តម្រូវការ ដែលកំពុងកើនឡើងរបស់អតិថិជន។
- ឱកាសក្នុងការបង្កើតនូវដំណោះស្រាយដែលមានការដាក់បញ្ចូល ឲ្យស្របទៅនឹងតម្រូវការរបស់អតិថិជន។
- គោលការណ៍ស្តីពីបរិស្ថាន សង្គម និងអភិបាលកិច្ច ត្រូវបានចាត់ទុកជាចំណុចសំខាន់ក្នុងវិស័យហិរញ្ញវត្ថុ ដោយសារតែអាជីវកម្ម និងការវិនិយោគជាច្រើនផ្តោតទៅរបៀបវារៈចីរភាព។
- ការស្វែងរកភាពជាដៃគូក្នុងតំបន់ និងពិភពលោក ដើម្បីបង្កើន និងបង្កើតសមត្ថភាពរបស់យើង។
- ការពង្រឹងសុវត្ថិភាព និងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធឌីជីថល ក៏ដូចជាវិធីសាស្ត្រ ដើម្បីការពារ និងដោះស្រាយការគំរាមកំហែងតាមប្រព័ន្ធអ៊ីនធឺណែត ការបត់បែនទៅតាមតម្រូវការរបស់អតិថិជន។
- ការកើនឡើងនូវតម្រូវការចាំបាច់សម្រាប់ការពន្លឿនផ្នែកឌីជីថល ដើម្បីធ្វើឲ្យអតិថិជនអាចធ្វើប្រតិបត្តិការធនាគារ នៅក្នុងបរិបទការរស់នៅតាមបែបគន្លងថ្មី។
- ការប្រកាន់ខ្ជាប់ និងប្រតិបត្តិនូវការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព និងវិធានការក្នុងការកាត់បន្ថយ ហានិភ័យ ក៏ដូចជាការការពារ នៅពេលដែលប្រព័ន្ធប្រតិបត្តិការមានបញ្ហា។

ដំណោះស្រាយរបស់យើង៖

- នៅតែរក្សាការប្រុងប្រយ័ត្នក្នុងការគ្រប់គ្រងគុណភាពទ្រព្យសកម្ម ដូចជាការបង្កើតគណៈកម្មការគ្រប់គ្រង គុណភាពទ្រព្យសម្រាប់ការពន្លឿនក្នុងការពិនិត្យ និងសម្រេច ក្នុងកំឡុងពេលនៃជំងឺកូវីត១៩។
- នៅតែបន្តការប្រាស្រ័យទាក់ទងជាមួយនឹងអតិថិជនឲ្យបានទៀតទាត់ និងសកម្ម ក៏ដូចជាការបង្កើតប្រព័ន្ធ ឌីជីថលថ្មីៗដោយផ្អែកលើតម្រូវការចាំបាច់របស់អតិថិជន និងកម្មវិធីផ្សេងៗទៀត ដែលអាចគ្រប់គ្រងទិន្នន័យបាន។
- ពង្រីកនូវវិសាលភាព នៃប្រព័ន្ធឌីជីថលដោយការកែលម្អ នៃប្រព័ន្ធដំណើរការដោយផ្ទាល់ តាមរយៈ SPT និងការរៀបចំរាល់ប្រតិបត្តិការទាំងនៅទីស្នាក់ការកណ្តាល និងលទ្ធភាពនៃរដ្ឋបាលឥណទាន។
- ផ្តល់ជូននូវដំណោះស្រាយហិរញ្ញវត្ថុ ដែលអាចទទួលយកបាន និងមានតម្លៃសមរម្យ តាមរយៈការផ្តល់សហឥណទាន ដែលបានបង្កើតដោយរដ្ឋាភិបាល និងគម្រោងជំនួយហិរញ្ញវត្ថុសម្រាប់ទប់ស្កាត់ជំងឺកូវីដ១៩។
- នៅតែបន្តការប្រាស្រ័យទាក់ទងជាមួយនឹងអតិថិជនឲ្យបានទៀតទាត់ និងសកម្ម ក្នុងការផ្តល់ជូនដំណោះស្រាយដែលពាក់ព័ន្ធពិសេស ដែលអាចកំណត់សញ្ញាណនៃគុណភាពទ្រព្យសកម្ម និងគម្រោងនៃការកាត់បន្ថយហានិភ័យ។
- ពង្រីកចំនួនអតិថិជនលើវិស័យនានា ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រនៃការពង្រីកទីផ្សារ។
- បន្តពង្រឹងប្រព័ន្ធប្រតិបត្តិការទូទាត់សាច់ប្រាក់ក្នុងតំបន់ និងកម្រិតសេវាកម្មហិរញ្ញប្បទានពាណិជ្ជកម្ម ដើម្បីកាត់ បន្ថយផលប៉ះពាល់។
- បន្តអភិវឌ្ឍគោលការណ៍ស្តីអំពីបរិស្ថាន សង្គម និងអភិបាលកិច្ច និងការចូលរួមឱកាសនានា ដែលពាក់ព័ន្ធ គោលការណ៍ស្តីអំពីបរិស្ថាន សង្គម និងអភិបាលកិច្ច។
- បន្តជំរុញការរៀបចំហេដ្ឋារចនាសម្ព័ន្ធនៃបច្ចេកវិទ្យាព័ត៌មានវិទ្យា និងសុវត្ថិភាព ដើម្បីការពារទិន្នន័យអតិថិជន រក្សាប្រតិបត្តិការឲ្យនៅតែមានភាពរឹងមាំដោយមានកំណើនប្រតិបត្តិការ និងការការពារការគំរាមកំហែងផ្នែកអ៊ីនធឺណែតផ្សេងៗទៀត។
- ចាប់ដៃគូរសហការផ្នែកឌីជីថល ដើម្បីផ្តល់សេវាកម្មប្រតិបត្តិការធនាគារ ដែលប្រកបដោយភាពងាយស្រួលសម្រាប់អតិថិជន (ដូចជាការផ្តួចផ្តើមបាគង ដែលអាចធ្វើផ្ទេរប្រាក់ទាំងក្នុងស្រុក និងក្រៅប្រទេស តាមរយៈការចាប់ដៃគូរជាមួយនឹងភ្នាក់ងារទូទាត់ផ្សេងៗ)
- បន្តការយកចិត្តទុកដាក់ក្នុងការបង្កើត និងផ្តល់សេវាកម្មផ្សេងៗទៀត សម្រាប់អតិថិជន ដែលអាចធ្វើឲ្យពួកគេ មានភាពងាយស្រួលក្នុងការប្រើប្រាស់សេវាកម្មធនាគារប្រចាំថ្ងៃ ដោយរួមបញ្ចូលទាំង ការបន្ថែមមុខងារ នៃម៉ាស៊ីនអេធីអឹម ការដាក់ពង្រាយម៉ាស៊ីនដក និងដាក់ប្រាក់ស្វ័យប្រវត្តិ សេវាកម្មធនាគារតាមអ៊ីនធឺណែត Maybank2u និងការកែលម្អការគ្រប់គ្រងសាច់ប្រាក់ Maybank2e។

បរិបទនៃប្រតិបត្តិការរបស់យើង

ទស្សនវិស័យ និងអាទិភាពសម្រាប់ឆ្នាំ២០២១៖

ការផ្ទុះឡើងជំងឺរាតត្បាត ត្រូវបានរំពឹងថានឹងបន្តជះឥទ្ធិពលដល់សេដ្ឋកិច្ចពិភពលោករហូតដល់ការចាក់វ៉ាក់សាំងបានពេញលេញ។ ទោះបីជាយ៉ាងណាការក៏ដោយ ការផ្លាស់ប្តូរ និងភាពបត់បែនទៅតាមកាលៈទេសៈរបស់អតិថិជនបានបង្កើតឲ្យមានឱកាសតូចមួយ នៅក្នុងវិស័យជាក់លាក់មួយជាពិសេស គឺវិស័យនៃប្រព័ន្ធឌីជីថល។

ខណៈពេល ដែលវិស័យឧស្សាហកម្ម និងការផ្លាស់ប្តូរឥរិយាបថរបស់អតិថិជនទៅរកការរស់នៅតាមបែបគន្លងថ្មី នៅប្រទេសកម្ពុជាមានការរីកចម្រើនជាមធ្យម ហើយនៅក្នុងតំបន់អាស៊ានវិញ ត្រូវបានគេរំពឹងទុកថា នឹងមានការផ្លាស់ប្តូរកំណែទម្រង់សេដ្ឋកិច្ច និងការកែសម្រួលគោលការណ៍រូបិយវត្ថុ ដើម្បីជួយជ្រោមជ្រែង និងសម្របសម្រួលដល់ អ្នកប្រើប្រាស់ទូទៅ និងអ្នកប្រកបអាជីវកម្ម។ ការជំរុញឲ្យមានសេវាកម្មហិរញ្ញវត្ថុ គឺត្រូវធ្វើឡើងដើម្បីប្រកួតប្រជែងយ៉ាងខ្លាំងពីសំណាក់ ស្ថាប័នហិរញ្ញវត្ថុ ដែលមិនស្ថិតនៅក្នុងវិស័យធនាគារ។

ជាមួយនឹងផ្នត់គំនិតនេះ ពួកយើងនៅតែប្តេជ្ញាចិត្ត ដើម្បីផ្តល់ជូននូវដំណោះស្រាយ ដែលផ្តោតលើអតិថិជនដែលប្រកបដោយប្រសិទ្ធិភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជន និងសហគមន៍។ កត្តាទាំងនេះ គឺរួមបញ្ចូលទាំងការអភិវឌ្ឍ លើទេពកោសល្យរបស់យើង ដើម្បីបណ្តុះផ្នត់គំនិតឲ្យផ្តោតលើអតិថិជន បង្កើតឲ្យមានភាពរហ័សរហួនក្នុងការចាប់យកឱកាសពាណិជ្ជកម្ម និងពង្រឹងប្រព័ន្ធឌីជីថលរបស់យើង ស្របពេលដែលពួកយើង នៅតែអាចគ្រប់គ្រងគុណភាពទ្រព្យសកម្ម។

ពួកយើង នៅតែផ្តោតការយកចិត្តទុកដាក់យ៉ាងសកម្មជាមួយអតិថិជនរបស់យើង ដើម្បីកាត់បន្ថយផលប៉ះពាល់ខណៈពេលដែលយើង នៅបន្តផ្តល់ដំណោះស្រាយហិរញ្ញវត្ថុ ដែលមានលក្ខណៈចម្រុះ និងច្នៃប្រឌិត។ ពួកយើង នឹងបន្តពង្រឹងភាពរឹងមាំនៃតារាងតុល្យភាពរបស់យើងតាមរយៈការពង្រីកបន្ថែមវិស័យសម្រាប់វិនិយោគ ការពន្លឿនការវិនិយោគទៅលើប្រព័ន្ធឌីជីថល និងបង្កើនលំហូរក្នុងតំបន់ និងក្រៅប្រទេស ដែលមានឥទ្ធិពលលើការតភ្ជាប់តំបន់អាស៊ានរបស់យើង។

ការប្រកួតប្រជែងនៅក្នុងសម័យកាលប្រព័ន្ធឌីជីថល បានកើនឡើងកាន់តែខ្លាំងឡើងជាមួយនឹងការផ្លាស់ប្តូរបរិបទទាំងស្រុង ដែលបង្កឡើងដោយជំងឺរាតត្បាត។ កត្តានេះ មានសារៈសំខាន់យ៉ាងខ្លាំង ដោយពួកយើងដាក់ចេញនូវវិធានការដែលពាក់ព័ន្ធផ្សេងទៀត ដែលអាចឲ្យយើងសម្របខ្លួនទៅនឹងគំរូអាជីវកម្មថ្មី។ និងឱកាសទាញយកបង្កើតគុណតម្លៃដើម្បីឆ្លើយតបនឹងតម្រូវការរបស់អ្នកប្រើប្រាស់នៅក្នុងស្ថានភាពទាំងនេះ ខណៈពេលដែលអាចរក្សាបាននូវភាពរឹងមាំនៃប្រតិបត្តិការ។

ទស្សនៈឆ្លុះបញ្ចាំងរបស់នាយក
នាយកដ្ឋានហិរញ្ញវត្ថុ

ទទួលបានប្រាក់ចំណេញមុនពន្ធល្អ ចំនួន **២៤,១** លានដុល្លារអាមេរិក (ធៀបឆ្នាំ២០១៩៖ ៣៣,៩ លានដុល្លារអាមេរិក)

អនុបាតនៃប្រាក់ចំណេញលើកម្រៃសេវាសុទ្ធ ប្រាក់ធៀប នឹងប្រាក់ចំណេញប្រតិបត្តិការបន្ត លើសពី ២០% ដែលស្មើនឹង **២១,៨%**

រក្សាបានប្រសិទ្ធភាពនៃគុណភាពទ្រព្យសកម្ម ដោយអនុបាតឥណទានមិនដំណើរការស្ថិតនៅ **២,៣៧%** (ធៀបឆ្នាំ២០១៩៖ ២,៦៣%)

រក្សាគុណភាពនៃដើមទុននិងសាច់ប្រាក់ តាមរយៈអនុបាតសាធនភាពចំនួន **២០,៦%** និងអនុបាតសន្ទនីយភាពចំនួន **១៥៣,៣%**

ដោយមានការរាតត្បាតជាសកលនៃវីរុសកូវីដ-១៩ នៅប្រទេសកម្ពុជា និងស្របពេលជាមួយនឹងការផ្លាស់ប្តូរបទបញ្ជា និងគោលការណ៍ថ្មីៗ បានធ្វើឲ្យស្ថានភាពប្រជាជនកម្ពុជាជួបភាពលំបាក និងប្រឈមយ៉ាងខ្លាំង។ ដើម្បីបន្តដំណើរទៅមុខនៅក្នុងបរិបទនេះ ធនាគារមេយវ៉ៃង (ខេមបូឌា) ភីអិលស៊ី (“ធនាគារ”) បានយកចិត្តទុកដាក់នៅក្នុងការកាត់បន្ថយហានិភ័យប្រតិបត្តិការអាជីវកម្ម ដែលនៅតែរក្សាគោលជំហរដោយភាពម៉ឺងម៉ាត់ រក្សាគុណភាពនៃមូលធន និងសន្ទនីយភាព ស្របពេលដែលយើងបានបន្តជួយសម្រួលសម្រួលដល់អតិថិជនរបស់យើង ដែលកំពុងទទួលរងផលប៉ះពាល់ ដែលបណ្តាលមកពីការរាតត្បាតជាសកលនេះ។ សមិទ្ធិផលហិរញ្ញវត្ថុរបស់យើងនៅឆ្នាំ ២០២០ បានឆ្លុះបញ្ចាំងវិបត្តិ ដែលយើងបានប្រឈម ហើយការចំណាយរបស់យើងបានកើនឡើងលើសពីការព្រៀងទុក ដោយសារការធ្វើប្រតិបត្តិការអាជីវកម្មក្នុងស្ថានភាពដ៏លំបាក មួយនេះ។ ទោះបីជាមានបញ្ហាប្រឈមទាំងនេះក៏ដោយ យើងនៅតែទទួលបានការីកចម្រើនល្អក្នុងការអនុវត្តយុទ្ធសាស្ត្រ របស់យើងដោយរក្សាបាននូវតារាងតុល្យការរឹងមាំជាមួយគ្នាផងដែរ។ សមិទ្ធិផលរបស់យើងនៅតែរក្សាបន្តតាមការរំពឹងទុកបើទោះជាមានផលប៉ះពាល់ ដោយវីរុសកូវីត១៩ក៏ដោយ។ ជាលទ្ធផល ធនាគារយើងនៅតែទទួលបានប្រាក់ចំណេញ មុនពន្ធ ដែលគួរឲ្យកត់សម្គាល់ចំនួន ២៤,១ លានដុល្លារអាមេរិក (ធៀបឆ្នាំ២០១៩៖ ៣៣,៩ លានដុល្លារអាមេរិក)។

ចាប់តាំងពីការចាប់ផ្តើមនៃវិបត្តិនេះ យើងបានតាមដានផលប៉ះពាល់ដោយការរាតត្បាតជាសកលជារៀងរាល់ថ្ងៃ បង្កើតសារដាស់តឿនសម្រាប់និយោជិត ពង្រឹងវិធានការការពារ បង្ការពីករណីផ្សេងៗទៀត ហើយលើសពីនេះទៀត គឺយើងស្តាប់មតិអតិថិជនរបស់យើង។

ការវិភាគរបាយការណ៍ លទ្ធផលលើផលចំណេញសម្រាប់ឆ្នាំសារពើពន្ធ២០២០

សេចក្តីសង្ខេបចំណេញខាត	២០២០ ពាន់ដុល្លារ	២០១៩ ពាន់ដុល្លារ	ធៀបនឹងឆ្នាំចាស់
ចំណូលពីការប្រាក់សុទ្ធ	**៣៥.៥១៤**	៣៩.៤៥៥	(១០,០០%)
ចំណូលថ្លៃសេវា និងកម្រៃជើងសារនិង ចំណូលផ្សេងៗសុទ្ធ	**៩.៨៧៨**	១១.៩៨៩	(១៧,៦១%)
ចំណូលប្រតិបត្តិការសុទ្ធសរុប	**៤៥.៣៩៣**	៥១.៤៤៣	(១១,៧៦%)
ចំណាយហិរញ្ញវត្ថុ	(**៩៨៧**)	(៧៩១)	១២,១៤%
ចំណាយរដ្ឋបាលទូទៅ	(**១៨.៥៦៣**)	(២០.៨៩៧)	(១១,១៧%)
ចំណូលប្រតិបត្តិការមុនការធ្វើសំវិធានធន	**២៥.៩៤២**	២៩.៧៥៥	(១២,៨១%)
សំវិធានធនលើ ឥណទានបាត់បង់សុទ្ធ	(**១.៧៩៧**)	៤.១៤៦	(១៤៣,៣៤%)
ប្រាក់ចំណេញមុនបង់ពន្ធ	**២៤.១៤៦**	៣៣.៩០១	(២៨,៧៧%)
ប្រាក់ចំណេញសុទ្ធ	**១៨.៥៧៩**	២៦.៨៩៣	(៣០,៩២%)

ការសម្រេចបានឆ្ងាស់ដៃប្រកបដោយចីរភាពនៅក្នុងបរិបទប្រកួតប្រជែង

- ចំណូលពីការប្រាក់សុទ្ធធ្លាក់ចុះធៀប នឹងឆ្នាំចាស់ចំនួន ១០% ស្មើនឹងទឹកប្រាក់ចំនួន ៣៥,៥ លានដុល្លារអាមេរិក (ឆ្នាំ២០១៩៖ ៣៩,៥ លានដុល្លារអាមេរិក) ដោយសារការពង្រឹងគុណភាពតារាងតុល្យការ ដែលមានកំណើនឥណទានដុលប្រចាំឆ្នាំចំនួន ១៣,៣% (ឆ្នាំ២០១៩៖ ១៧,២%)។ យ៉ាងណាមិញ ចំណូលពីការប្រាក់សុទ្ធត្រូវបានធ្លាក់ចុះដោយសារការកាត់បន្ថយនៃកម្រិតការប្រាក់ពី១៨bps មកត្រឹម ២,៦៨%។
- ការកាត់បន្ថយកម្រិតចំណូលការប្រាក់ គឺយោងតាមយុទ្ធសាស្ត្រចម្បងរបស់យើងក្នុងការបង្កើនប្រាក់រៀល និងធានាគុណភាពសន្ទនីយសាច់ប្រាក់ ដោយធ្វើកម្ចីលើចំណុលបន្ទាប់បន្សំ ដែលនាំឲ្យកម្រិតចំណេញទាប។ ជាលទ្ធផល ធនាគារ បានសម្រេចនូវគោលដៅលើប្រាក់កម្ចី ជាប្រាក់រៀលតាមការកំណត់របស់និយតករ និងរក្សាបាននូវគុណភាពសន្ទនីយសាច់ប្រាក់រឹងមាំនៅពេលជាមួយគ្នាផងដែរ។
- ចំណូលថ្លៃសេវាកម្រៃជើងសារ ធ្លាក់ចុះប្រចាំឆ្នាំចំនួន ១៧,៦១% មកត្រឹមចំនួន ៩,៩ លានដុល្លារអាមេរិក (ធៀបឆ្នាំ២០១៩៖ ១២លានដុល្លារអាមេរិក) បណ្តាលមកពីភាពរាំងស្ទុះនៃដំណើរការប្រតិបត្តិការអាជីវកម្មរបស់អតិថិជនក្នុងអំឡុងពេលឆមាសទី២ នៃឆ្នាំ២០២០។
- ស្របគ្នា នឹងការធ្លាក់ចុះលើសកម្មភាពអាជីវកម្មទូទាត់របស់ធនាគារ ចំណាយរដ្ឋបាលទូទៅបានកាត់បន្ថយចំនួន ១១,១៧% ក្នុងឆ្នាំ២០២០។
- ឥណទានរំពឹង នឹងបាត់បង់សុទ្ធត្រូវបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ចដោយសារការរាតត្បាតជាសកលនៃវីរុសកូវីដ-១៩។
- រួមជាមួយការកាត់បន្ថយនៃកម្រិតការប្រាក់ និងការធ្វើសំវិធានធនដោយប្រុងប្រយ័ត្នលើឥណទានរំពឹង នឹងបាត់បង់ ស្ថិតក្នុងស្ថានការនៃវីរុសកូវីដ-១៩។ ប្រាក់ចំណេញមុនបង់ពន្ធរបស់យើងមានក្នុងធ្លាក់ចុះប្រមាណ២៩% មកត្រឹមចំនួន២៤,១ លានដុល្លារអាមេរិក (ធៀបឆ្នាំ២០១៩៖៣៣,៩ លានដុល្លារអាមេរិក)។
- ផលចំណេញធៀប នឹងមូលធនបន្តរក្សាបានល្អ នៅចំនួន១១,០២% (ធៀបឆ្នាំ២០១៩៖១៦,២%)។

ការវិភាគតារាងតុល្យការនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

សមិទ្ធិផល និងរបាយការណ៍ហិរញ្ញវត្ថុរបស់យើង ឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងទាំងឡាយ ហើយក៏បង្ហាញថាគំរូអាជីវកម្មរបស់ធនាគារ មេយវ៉ៃងនៅតែមានភាពរឹងមាំទោះបីស្ថិតក្នុងស្ថានភាពមិនប្រាកដប្រជាមួយនេះក៏ដោយ។

ធនាគារបន្តរីកចម្រើនតារាងតុល្យការប្រកបដោយភាពម៉ឺងម៉ាត់

ធនាគារ មេយវ៉ៃងមានកំណើនឥណទានដុលចំនួន ១៣,៣% (ធៀបឆ្នាំ២០១៩៖១៧,២%) ដល់ចំនួន៧៦៤,១លានដុល្លារអាមេរិក។ ការរីកចម្រើននេះជំរុញជាចម្បងដោយអាជីវកម្មសម្រាប់អ្នកប្រើប្រាស់ចំនួន៨០,៣% នៃឥណទានសរុបរបស់ធនាគារ មេយវ៉ៃង។ ផលប័ត្រអាជីវកម្មលក់រាយមានដូចជា កម្ចីទិញគេហដ្ឋាន និងផលប័ត្រ អាជីវកម្មខ្នាតតូច និងមធ្យម។

កំណើនយ៉ាងលឿននៃអាជីវកម្មលក់រាយ គឺស្របតាមចក្ខុវិស័យរបស់ធនាគារ “ជម្រើសដៃគូធនាគាររបស់សហគមន៍”។



ទស្សនៈឆ្លុះបញ្ចាំងរបស់នាយកនាយកដ្ឋានហិរញ្ញវត្ថុ

កាត់បន្ថយទទួលប្រាក់បញ្ញើការប្រាក់ថ្លៃ ដើម្បីសម្រួលថ្លៃដើមធនាគារ

យន្តការមួយក្នុងយុទ្ធសាស្ត្រឆ្នាំ២០២០ របស់យើង គឺធ្វើការកាត់បន្ថយលើកំណើនជាលំដាប់នៃចំណាយមូលនិធិខ្ពស់ពីការទទួលប្រាក់បញ្ញើពីអតិថិជន ដែលអត្រាប្រាក់បញ្ញើទាំងនោះត្រូវបានត្រួតពិនិត្យ និងកែប្រែឡើងវិញ ដើម្បីគ្រប់គ្រងប្រាក់ចំណេញឲ្យល្អប្រសើរ និងដោះស្រាយស្ថានភាពទីផ្សារក្នុងពេលតែមួយ។ យន្តការនេះបានបណ្តាលឲ្យមានការកាត់បន្ថយប្រាក់បញ្ញើរបស់អតិថិជនទូទៅដល់ចំនួន -៦,៧% ធៀបឆ្នាំចាស់(ឆ្នាំ២០១៩៖ + ១៦,២%)។

ធនាគារ បន្តប្រើប្រាស់មូលនិធិផលប័ត្ររបស់ខ្លួនដោយមានប្រសិទ្ធភាព តាមរយៈការទាញយកតម្លៃឲ្យអស់ពីលទ្ធភាពពីចំណាយលើប្រភពមូលនិធិ ខណៈពេលដែលធានាបានថា ប្រភពមូលនិធិមានភាពចម្រុះ។ ស្ថិតក្រោមស្ថានការនៃវីរុសកូវីដ-១៩ ប្រាក់បញ្ញើចរន្តធ្លាក់ចុះប្រចាំឆ្នាំចំនួន ២៣% មកត្រឹម ៦៣៧ លានដុល្លារអាមេរិក (ឆ្នាំ២០១៩៖ ៧២៦ លានដុល្លារអាមេរិក) ចំណែកឯប្រាក់បញ្ញើមានកាលកំណត់វិញមានកំណើនចំនួន ៥% លើដល់ចំនួន ៣៦៨ លានដុល្លារអាមេរិក (២០១៩៖ ៣៥១ លានដុល្លារអាមេរិក)។

ប្រាក់បញ្ញើសរុប (លានដុល្លារអាមេរិក)



ការរក្សាគុណភាពទ្រព្យសកម្មដោយការគ្រប់គ្រងហានិភ័យបែបបុរេសកម្ម

ធនាគារ បានផ្តោតយកចិត្តទុកដាក់ទៅលើ យន្តការគ្រប់គ្រងគុណភាពទ្រព្យសកម្មរបស់ខ្លួន ដើម្បីធានាបាននូវគុណភាព ទ្រព្យសកម្មចាប់តាំងពីដំណើរការដំបូងពេលទទួលបានអតិថិជន។ ដោយវិធីសាស្ត្រនេះបានបង្ហាញនូវប្រសិទ្ធភាពយ៉ាងខ្លាំងជាមួយនឹងភស្តុតាងនៃភាពប្រសើរឡើងលើអនុបាតនៃឥណទានមិនដំណើរការបានធ្លាក់ចុះដល់ ២,៣៦% (ឆ្នាំ២០១៩៖ ២,៦៣%)។

ចំណាយ

យុទ្ធសាស្ត្រផ្តោតលើការកាត់បន្ថយចំណាយរបស់យើងនៅតែបន្ត។ ក្នុងឆ្នាំ២០២០ ខណៈពេលដែលយើងប្រឈម នឹងស្ថានការមិនច្បាស់លាស់ យើងសម្រេចបាននូវការជំរុញឲ្យចំណាយប្រចាំឆ្នាំមានភាពប្រសើរឡើង បានចំនួន ១១%។ ការកាត់បន្ថយចំណាយនេះ អាចសម្រេចបានតាមរយៈ កិច្ចផ្តួចផ្តើមទាំងផ្នែកនិយោជិត និងផ្នែកដ៏ទៃទៀត ជាមួយគ្នាផងដែរ យើងក៏បន្តឃើញថាមានដំណោះស្រាយ ថ្មីៗ ដើម្បីកាត់បន្ថយចំណាយដើម និងបង្កើនប្រសិទ្ធភាព។

ការគ្រប់គ្រងមូលធន និងសន្ទនីយភាពដោយមានប្រសិទ្ធភាព

១. ការគ្រប់គ្រងដើមទុន

សូចនាករដ៏សំខាន់សម្រាប់វាស់វែងភាពគ្រប់គ្រងនៃដើមទុន គឺអនុបាតសោធនភាព ដោយផ្អែកមូលធនផ្ទាល់សុទ្ធធៀប នឹងទ្រព្យសកម្ម ដែលបានថ្លឹងតាមកម្រិតហានិភ័យ ដែលអត្រានេះមិនអាចតិច ជាង១៥%នោះទេ។ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២០ អនុបាតសោធនភាពរបស់ធនាគារ មានអត្រារហូតដល់ ២០,៦% ដែលមានដើមទុនថ្នាក់ទី១ស្មើ ១៤,៧% និងដើមទុនថ្នាក់ទី២ស្មើ ៥,៩%។ លើសពីនេះទៀត ក្រុមហ៊ុនមេបានផ្តល់ជា បំណុលបន្ទាប់បន្សំថ្មីសម្រាប់ធនាគារ ប្រើប្រាស់បន្ថែមជាដើមទុនបង្វិលចំនួន ៤៥លានដុល្លារអាមេរិក។ ទាំងនេះបានបង្កភាពងាយស្រួលដល់ប្រតិបត្តិការប្រចាំថ្ងៃ និងសម្រួលដល់ការអនុម័តតាមបទប្បញ្ញត្តិរបស់ធនាគារ ដោយវាធ្វើឲ្យដើមទុនថ្នាក់ទី២ មានភាពប្រសើរឡើងពីឆ្នាំ២០១៩ ចំនួន ១,២%។

អនុបាតសំខាន់ៗ	ឆ្នាំសារពើពន្ធ ២០២០	ឆ្នាំសារពើពន្ធ ២០១៩
មូលធនថ្នាក់ទី១	**១៤,៧%**	១៧,៥%
មូលធនបន្ទាប់បន្សំ ថ្នាក់ទី២	**៥,៩%**	៤,៧%
អនុបាតសោធនភាព	**២០,៦%**	២២,២%
មូលនិធិផ្ទាល់សុទ្ធ (គិតជាលានដុល្លារ)	**១៩៣**	១៨៧,៦
ទ្រព្យសកម្ម ដែលបានថ្លឹងតាមកម្រិតហានិភ័យ (គិតជាលានដុល្លារ)	**៩៣៥,៨**	៨៤៦,៥

២. ការគ្រប់គ្រងសន្ទនីយភាព

តាមរយៈគន្លឹះមូលនិធិយុទ្ធសាស្ត្ររបស់ ធនាគារ មេយប៉ែងពួកយើងបានរក្សាបាននូវសូចនាករហានិភ័យសាច់ប្រាក់ងាយ ស្រួល ដែលមានស្ថេរភាព ជាមួយអនុបាតសន្ទនីយភាព ១៥៣,៣% ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ខ្ពស់ជាងកម្រិតកំណត់ របស់ធនាគារជាតិ ១០០%។ សូចនាករសន្ទនីយភាពមួយទៀត គឺអនុបាតឥណទានធៀបនឹងប្រាក់បញ្ញើស្មើនឹង ៧៥,៦៣% (២០១៩៖ ៦៣,១%)។ អនុបាតឥណទានធៀប នឹងប្រាក់បញ្ញើនេះបានឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងរបស់ ធនាគារក្នុងការកាត់បន្ថយចំណាយ និងបង្កើនទ្រព្យសកម្មលើឥណទាន ដែលមានគុណភាពខ្ពស់។

ដោយយើងបានអនុវត្តន៍រាល់វិធានការទាំងអស់ក្នុងឆ្នាំ២០២០ យើងបានជឿជាក់ថា យើងនឹងមានវិធានការរឹងមាំសម្រាប់ការ បើកដំណើការឡើងវិញ ហើយនឹងមានសន្ទុះលឿនបើទោះជាយើងស្ថិតនៅក្នុងវិបត្តិនេះ។

អនុបាតសំខាន់ៗ	ឆ្នាំសារពើពន្ធ ២០២០	ឆ្នាំសារពើពន្ធ ២០១៩
កំណើន ឬការធ្លាក់ចុះនៃប្រាក់បញ្ញើចរន្ត និងប្រាក់បញ្ញើសន្សំ	(**១២,២%**)	៦៧,៣%
អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ	**៧៥,៦៣%**	៦៣,១%
អនុបាតសន្ទនីយភាព	**១៥៣,៣%**	១៣៤,៣%

ឆ្ពោះទៅមុខ

បញ្ហាប្រឈម ដែលជះឥទ្ធិពលលើស្ថានការប្រតិបត្តិការក្នុងកំឡុងឆ្នាំ ២០២០ គឺមានការប៉ះពាល់យ៉ាងខ្លាំងដល់ធនាគារ។ ទោះបីជាយ៉ាងណាក៏ដោយ ការឆ្លើយតបយ៉ាងឆាប់រហ័ស និងខិតខំយ៉ាងសកម្មរបស់យើងបានផ្តល់ឱកាសឲ្យធនាគារ វិនិយោគលើយុទ្ធសាស្ត្រសំខាន់ៗ មុនពេលមានការរាតត្បាតជាសកល។ ធនាគារបានសម្របខ្លួនដោយជោគជ័យទៅនឹងបញ្ហាប្រឈម ដែលបានជួបប្រទះ ដោយបន្តផ្តោតលើការសម្រេចលទ្ធផលតាមរយៈយុទ្ធសាស្ត្រ ជាពិសេសបន្តកាត់បន្ថយចំណាយ ធ្វើការបញ្ចេញផលិតផលប្រាក់កម្ចីថ្មី សម្រាប់សហគ្រាសធុនតូច និងមធ្យម និងខិតខំកែលម្អទម្រង់ អាជីវកម្មរបស់យើងជាមួយគ្នានឹងការបន្តគាំទ្រដល់អតិថិជន សហសេវិក និងសហគមន៍។

ឆ្ពោះទៅឆ្នាំ២០២១ ទោះបីជាយើងបានស្វែងយល់អំពីភាពចាំបាច់នៃការរឹតបន្តឹង និងផលពិបាកនៃបញ្ហាប្រឈមខណៈពេល ដែលយើងចាប់ផ្តើមឆ្នាំថ្មី យើងរំពឹងទុកថាបញ្ហាទាំងនោះនឹងមិនមាន ផលប៉ះពាល់ដល់យើងខ្លាំងទេ ព្រោះតែដំណើរការល្អប្រសើរ នៃការចាក់វ៉ាក់សាំងនៅប្រទេសកម្ពុជា។ យើងមានដើមទុនគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការងើបឡើងវិញនៃសេដ្ឋកិច្ច ហើយយើងក៏កំពុងវិនិយោគលើសមត្ថភាពបច្ចេកវិទ្យា និងគម្រោងផ្សេងៗតាមសំណើរអតិថិជន ដោយបន្តកាត់បន្ថយការចំណាយ និងធានាបាននូវមូលនិធិរឹងមាំ និងរក្សាកម្រិតសន្ទនីយភាពតាមក្របខណ្ឌកំណត់។ យើងប្តេជ្ញា ក្នុងការអភិវឌ្ឍកេរ្តិ៍ឈ្មោះអាជីវកម្មរយៈពេលវែងរបស់យើង ប្រកបដោយទំនួលខុសត្រូវ ដើម្បីបម្រើអតិថិជនរបស់យើងឲ្យល្អប្រសើរ និងផ្តល់ប្រាក់ចំណេញប្រកប ដោយចីរភាពដល់ម្ចាស់ភាគហ៊ុនរបស់យើង។

ទោះបីជាមានផលវិបាកធ្ងន់ធ្ងរពីវីរុសកូវីដ-១៩នៅក្នុងឆ្នាំ ២០២០ ក៏បាននាំមកនូវសញ្ញាគួរឲ្យពេញចិត្តផងដែរ ឆ្លុះបញ្ចាំងតាមរយៈយុទ្ធសាស្ត្ររបស់យើងបានចាប់ផ្តើម បង្ហាញលទ្ធផលបណ្តើរៗ។ ម្យ៉ាងទៀតទោះជាបញ្ហាទាំងនេះនឹងបន្តក្នុងឆ្នាំ ២០២១ក៏ដោយ ប៉ុន្តែយើងមានភាពរឹងមាំជាងមុន ក្នុងការប្រឈមមុខនឹងវា។ យើងនឹងបន្ត យកចិត្តទុកដាក់លើការគ្រប់គ្រងចំណាយ និងធានាថាយើងនឹងត្រឡប់មកបង្កើនប្រាក់ចំណេញប្រកបដោយចីរភាព។ ចំណុចនេះ នៅតែជាការផ្តោតសំខាន់របស់យើង។

នាយកដ្ឋាន សេវាហិរញ្ញវត្ថុសហគមន៍

សមិទ្ធិផលសំខាន់ៗនៅក្នុងឆ្នាំ២០២០

លើកដំណើរការ ផ្នែកអាជីវកម្មខ្នាតតូច និងមធ្យមបានដោយជោគជ័យជាមួយនឹងកម្មវិធីផ្តល់សេវាឥណទាន ប្រកបដោយភាពងាយស្រួលបន្ថែម លើការគាំទ្រដល់ផ្នែកអាជីវកម្មខ្នាតតូច និងមធ្យម ផ្នែកបុគ្គល ដែលកំពុងធ្វើប្រតិបត្តិការនិងបន្តជំរុញដល់ការកសាងភាពឈានមុខនៅក្នុងវិស័យអាជីវកម្មខ្នាតតូច និងមធ្យមរបស់យើង។

ការបើកដំណើរការដោយជោគជ័យ ក្នុងការផ្តល់សេវាឥណទានរថយន្ត ដែលជាផ្នែកមួយ នៃយុទ្ធសាស្ត្ររួម ដើម្បីពង្រីកបន្ថែមការផ្តល់ជូនសេវាកម្មរបស់ពួកយើង នៅក្នុងផ្នែកឥណទានបុគ្គល។

តែលម្អឡើងវិញនូវ កម្មវិធីធនាគារចល័ត Maybank2u (M2U) លើការរចនា និងបទពិសោធន៍កម្រិតពិភពលោករបស់យើង និងការផ្តល់ជូននូវមុខងារកាន់តែសម្បូរបែប និងផ្តល់ភាពងាយស្រួល ក្នុងការប្រើប្រាស់សេវាកម្មទូទាត់នានា ដូចជាការបញ្ចូលទឹកប្រាក់ទូរស័ព្ទ និងការបង់វិក្កយបត្រ។

គាំទ្រ និងចូលរួមក្នុងការផ្លួចផ្តើមសំខាន់ៗរបស់ ធនាគារជាតិនៃកម្ពុជា ដើម្បីលើកកម្ពស់ ក្នុងការប្រើប្រាស់ប្រាក់រៀលជាតិ និងការកសាងជាប្រព័ន្ធទូទាត់ប្រាក់បែបឌីជីថល ដូចជាប្រព័ន្ធផ្ទេរប្រាក់បាគង និងប្រព័ន្ធផ្ទេរប្រាក់បាគងទៅក្រៅប្រទេស។

ឥណទានគេហដ្ឋានមាន កំណើនយ៉ាងខ្លាំង ដែលនាំអោយឥណទាននេះក្លាយជាចំណែកគោល ដ៏សំខាន់មួយនៃភាពជោគជ័យរួម របស់ធនាគារនៅក្នុងឆ្នាំ២០២០ ស្រពេលដែលយើងនៅតែបន្តរក្សាគុណភាពនៃទ្រព្យសកម្ម។

ចំនុចផ្តោតសំខាន់ៗនៅក្នុងឆ្នាំ២០២០

រក្សាខ្លាប់ខ្លួនចំពោះបេសកកម្មរបស់យើង - សេវាហិរញ្ញវត្ថុប្រកបដោយអរិយភាព និងស្ថិតនៅជិតអតិថិជន ដើម្បីជួយជ្រោមជ្រែងអតិថិជនគ្រប់ពេលវេលា

នៅពេលដែលជំងឺរាតត្បាតកូវីដ១៩ ចាប់ផ្តើមវាយប្រហារចូលក្នុងប្រទេសកម្ពុជា ក៏ដូចជាវិស័យសេដ្ឋកិច្ច ពួកយើង បានចាត់វិធានការចាំបាច់ ដោយផ្តល់ជូននូវការរៀបចំឥណទាន និងការកំណត់ពេលវេលាសងឡើងវិញ ក៏ដូចជាទម្រង់នៃការសងត្រឹមតែការប្រាក់ ឬការពន្យារយៈពេលទូទាត់ប្រាក់រហូតដល់៦ខែ ជូនដល់អតិថិជនរបស់ពួកយើង ដែលទទួលរងផលប៉ះពាល់ដោយសារជំងឺកូវីដ១៩។ នៅចុងឆ្នាំនេះ ពួកយើង បានផ្តល់ជូនអតិថិជនផ្នែកឥណទានបុគ្គល និងអតិថិជនផ្នែកអាជីវកម្មខ្នាតតូច និងមធ្យមលក់រាយ សរុបច្រើនជាង២០០នាក់។ បន្ថែមពីលើនេះ ពួកយើង ក៏បានធ្វើប្រតិបត្តិការក្នុងការរៀបចំឥណទានឡើងវិញ ទៅតាមលក្ខខណ្ឌនៃឥណទាននីមួយៗផងដែរ។ ដើម្បីធានាបាននូវសុវត្ថិភាព និងសុខុមាលភាពដល់អតិថិជន និងនិយោជិតរបស់ពួកយើងនោះ ពួកយើង បានអនុវត្តវិធានការការពារ និងបង្ការយ៉ាងសកម្ម ដូចជា ការរក្សាគម្លាត ការស្អេនសីតុណ្ហភាព ការលាងសម្អាតដៃ ការពាក់ម៉ាស់ការពារជាប្រចាំ និងការស្កេន QRកូដ នៅទូទាំងសាខាទាំង២១ និងការិយាល័យកណ្តាល ដោយប្រតិបត្តិតាមគោលការណ៍ និងការណែនាំរបស់ ក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាល។

នៅតែបន្តផ្តល់ជូនអតិថិជននូវប្រតិបត្តិការហិរញ្ញវត្ថុ និងសេវាកម្មហិរញ្ញវត្ថុក្នុងអំឡុងពេលដ៏លំបាកនេះ

ពួកយើង នៅតែប្តេជ្ញាគាំទ្រការីកចម្រើនផ្នែកសេដ្ឋកិច្ចនៅកម្ពុជា តាមរយៈការពង្រីកដំណោះស្រាយហិរញ្ញវត្ថុ ទៅកាន់អតិថិជនទាំងផ្នែកអាជីវកម្មខ្នាតតូច និងមធ្យម និងផ្នែកឥណទានបុគ្គល ស្របពេលដែលពួកយើង បានពង្រឹងបន្ថែមទៅលើសមត្ថភាពផ្នែកឌីជីថល ដើម្បីផ្តល់ភាពងាយស្រួល ដល់អតិថិជនក្នុងការទូទាត់ និងការធ្វើប្រតិបត្តិការផ្សេងៗ។ ទាំងនេះ បានបង្ហាញ តាមរយៈការចាប់ផ្តើមដំណើរការ នៃឥណទានអាជីវកម្មខ្នាតតូច និងមធ្យម ឥណទានរថយន្ត និងការកែលម្អរូបរាងថ្មីនូវកម្មវិធីធនាគារចល័ត M2U ជាមួយនឹងមុខងារទូទាត់ដ៏សំបូរបែប។ ពួកយើង នៅតែបន្តផ្តល់ឥណទានដល់អាជីវកម្មរបស់អតិថិជន ដែលអាចបន្តដំណើរការបាន ឬរងផលប៉ះពាល់តិចតួចពីជំងឺរាតត្បាតដើម្បីឲ្យពួកគេអាចយកទៅប្រើប្រាស់សម្រាប់ទិញគេហដ្ឋាន ឬប្រើប្រាស់គម្រោងឥណទានបន្ថែមដើម្បីទ្រទ្រង់អាជីវកម្ម។ លើសពីនេះ ពួកយើង បានចូលរួមក្នុងគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ដែលគាំទ្រដោយរាជរដ្ឋាភិបាល តាមរយៈធនាគារសហគ្រាសធុនតូច និងមធ្យម ដើម្បីជួយជំរុញកំណើនសេដ្ឋកិច្ច ដោយការផ្តល់ឥណទានអាជីវកម្មខ្នាតតូច និមធ្យមនៅក្នុងវិស័យគោលដៅជាមួយនឹងដំណោះស្រាយហិរញ្ញវត្ថុ ដែលមានតម្លៃទាប។

ឆ្ពោះទៅរកគុណភាពសេវាកម្មសម្រាប់អតិថិជនដ៏ល្អឥតខ្ចោះ ដោយបន្តការវិនិយោគក្នុងការកសាងសមត្ថភាព និងលទ្ធភាពពង្រីកវិសាលភាពនៃប្រព័ន្ធឌីជីថលរបស់យើង

ដោយទទួលស្គាល់នូវតម្រូវការរបស់អតិថិជន និងសាធារណៈជនដែលកំពុងសម្របខ្លួនតាមបទដ្ឋាន និងរបត់ថ្មី ពួកយើង បានបង្កើនការវិនិយោគ និងការផ្តោតសំខាន់ទៅលើការពង្រឹងសមត្ថភាពប្រព័ន្ធឌីជីថលរបស់យើង ដោយបានបង្ហាញតាមរយៈការកែលម្អរូបរាងថ្មីនៃកម្មវិធីធនាគារចល័ត M2U ការបន្ថែមមុខងារបញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទដៃ មុខងារទូទាត់វិក្កយបត្រទឹក និងការបន្តសហការជាមួយដៃគូនានាលើសេវាកម្មទូទាត់វិក្កយបត្រ ជាមួយនឹងបន្ថែមមុខងារនៃការទូទាត់ ដកប្រាក់ជារូបិយប័ណ្ណប្រាក់រៀល ទៅក្នុងកម្មវិធីធនាគារចល័ត M2U និងម៉ាស៊ីនដកប្រាក់។ ពួកយើង ក៏កំពុងចាប់ផ្តើមដំណើរការនូវយុទ្ធនាការ ដើម្បីលើកទឹកចិត្តដល់អតិថិជនរបស់យើង ក្នុងការចុះឈ្មោះប្រើប្រាស់ និងការបន្តធ្វើប្រតិបត្តិការតាមអ៊ីនធឺណែតផងដែរ។ នៅចុងឆ្នាំនេះ ពួកយើងសង្កេតឃើញនូវអតិថិជន ដែលបានចុះឈ្មោះប្រើប្រាស់កម្មវិធីធនាគារចល័ត M2U កើនឡើងយ៉ាងខ្លាំងរហូតដល់ ២៧% និងអ្នកប្រើប្រាស់សកម្ម ក្នុងការធ្វើប្រតិបត្តិការកើនឡើងដល់ ១៦%។ ពួកយើង ក៏បានចាប់ផ្តើមការផ្លួចផ្តើមឌីជីថលសំខាន់នានាមួយចំនួនផ្សេងទៀត ដែលរំពឹងទុកថានឹងចាប់ផ្តើមដំណើរការនៅឆ្នាំក្រោយ។

នាយកដ្ឋានសេវាហិរញ្ញវត្ថុសហគមន៍

បន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយអតិថិជនរបស់ពួកយើងលើសពីការធ្វើប្រតិបត្តិការ និងការដាក់ប្រាក់សន្សំ ដោយបន្ថែមនូវការផ្តល់ជូនការការពារក្នុងកំឡុងពេលនៃជំងឺរាតត្បាត

ដើម្បីបំពេញតម្រូវការរបស់អតិថិជនទូទៅ ក៏ដូចជាអតិថិជន Premier និងដើម្បីសម្រេចសេចក្តីប្រាថ្នារបស់យើងក្នុងនាមជា ជម្រើសដៃគូធនាគារបស់សហគមន៍ នៅប្រទេសកម្ពុជា ពួកយើង បានចាប់ផ្តើម ភាពជាដៃគូចែកចាយជាមួយក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតអេទិកា (ខេមបូឌា) និងក្រុមហ៊ុនធានារ៉ាប់រងទូទៅអេទិកា (ខេមបូឌា) ដើម្បីផ្តល់ជូនអតិថិជនរបស់យើង នូវការធានារ៉ាប់រងហិរញ្ញវត្ថុ និងជម្រើសសន្សំឲ្យបាន គ្រប់ជ្រុងជ្រោយ ក៏ដូចជាការធានារ៉ាប់រងទៅលើការធ្វើដំណើរ គ្រោះអគ្គិភ័យ និងគ្រោះថ្នាក់ផ្ទាល់ខ្លួននៅក្នុងរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្តនានា ដោយផ្តែកលើបទពិសោធន៍ ជំនាញ និងភាពស៊ីសង្វាក់គ្នាលើប្រតិបត្តិការអាជីវកម្ម ដែលធនាគារ និងក្រុមហ៊ុនអេទិកា បានធ្វើការជាដៃគូជាមួយគ្នាជាច្រើនឆ្នាំកន្លងមក នៅក្នុងប្រទេសម៉ាឡេស៊ី និងបណ្តាប្រទេសដទៃទៀតក្នុងតំបន់។

សមិទ្ធិផលសំខាន់ៗ

ប្រាក់ចំណេញនៃ ប្រតិបត្តិការរបស់នាយកដ្ឋានសេវាហិរញ្ញវត្ថុសហគមន៍ មានកំណើនរហូតដល់ ៦,២ភាគរយ ដែលមានតម្លៃស្មើនឹង ៤២,១ លានដុល្លារអាមេរិក បានពី៖

- ការកើនឡើងនូវប្រាក់ចំណូលមធ្យមមាន ២,១% ដែលភាគច្រើនបានមកពីប្រាក់ចំណូលនៃការប្រាក់។
- ការគ្រប់គ្រងថ្លៃដើមសមរម្យ និងមានវិធានការណ៍ប្រកបដោយភាពប្រយ័ត្នប្រយែង ដែលជាលទ្ធផលនាំដល់ការកាត់បន្ថយការចំណាយសរុបបានដល់ ៧,២% ស្របពេលដែលការចំណាយរបស់យើងសមាមាត្រជាមួយនឹងប្រាក់ចំណូលមានការកើនឡើងដល់ទៅ ២,៨% ។
- កំណើនឥណទាន ដែលមានគុណភាពចំនួន ១១,២% ដែលមួយផ្នែកធំបានពីការរីកចម្រើនយ៉ាងខ្លាំងនៃឥណទាន ស្ទើរតែ ២៩% ពីឥណទានគេហដ្ឋាន និងឥណទានអាជីវកម្មខ្នាតតូច និងមធ្យម ដែលទើបបើកដំណើរការថ្មីៗនេះ។
- សម្រេចបាននូវឥណទានជាប្រាក់រៀលលើសពី១០% នៃឥណទានសរុបរបស់យើង ដែលស្របទៅនឹងបទបញ្ញាត្តិដែលដាក់ចេញដោយនិយ័តករ ស្របពេលដែលកំពុងបន្តដំណើរការនូវភាពរឹងមាំរបស់យើង ក្នុងការប្រមូលប្រាក់បញ្ញើជាប្រាក់រៀល សម្រាប់គាំទ្រឥណទានជាប្រាក់រៀល។
- រក្សាប្រាក់បញ្ញើចរន្ត និងសន្សំ ដែលមានស្ថេរភាពល្អរហូតដល់ជាង៦០% នៃប្រាក់បញ្ញើសរុប ។

បន្តពង្រឹងបន្ថែមនូវការផ្តល់ជូនផលិតផល និងប្រព័ន្ធឌីជីថល ដើម្បីផ្តល់ជូននូវជម្រើសដ៏សម្បូរបែប និងភាពងាយស្រួលដល់អតិថិជន៖

- បើកដំណើរការក្នុងការផ្តល់ឥណទានរថយន្ត នៅក្នុងទីផ្សារបានដោយជោគជ័យ ដើម្បីផ្តល់នូវដំណោះស្រាយហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត ជូនដល់អតិថិជនដែលមានស្រាប់ និងអតិថិជនថ្មីរបស់ពួកយើង។ ការបើកដំណើរការឥណទាននេះបានបញ្ជាក់ពីការតាំងចិត្ត និងការប្តេជ្ញាចិត្តរយៈពេលវែង ក្នុងការកសាងវត្តមានរបស់យើងឲ្យកាន់តែរឹងមាំលើផ្នែកសេវាកម្មធនាគារបុគ្គល។
- ការដាក់ឲ្យប្រើប្រាស់នូវកម្មវិធីធនាគារចល័ត M2U ដ៏ថ្មីស្រឡាងជាមួយនឹងមុខងារទាក់ទាញ រួមទាំងការផ្តល់នូវភាពងាយស្រួលដល់ការទូទាត់ប្រាក់ដ៏សម្បូរបែប ដូចជាមុខងារបញ្ចូលទឹកប្រាក់ទូរស័ព្ទ និងការទូទាត់វិក្កយបត្រផ្សេងៗ។ ទាំងនេះ បាននាំឲ្យមានកំណើនអ្នកចុះឈ្មោះប្រើប្រាស់ និងកំណើនអ្នកធ្វើប្រតិបត្តិការគួរឲ្យកត់សម្គាល់ ដែលជាលទ្ធផលនៃការកើនឡើងនូវប្រតិបត្តិការរូបិយវត្ថុមានចំនួនរហូតដល់ ៦៣%។
- ការងារបន្ថែមផ្សេងទៀត ត្រូវបានចាប់ផ្តើម ដើម្បីពង្រីកមុខងារទូទាត់របស់កម្មវិធីធនាគារចល័ត M2U តាមរយៈភាពជាដៃគូជាមួយអ្នកផ្តល់សេវាកម្មផ្សេងៗ និងការចូលរួមក្នុងការទូទាត់ដែលពាក់ព័ន្ធទៅនឹងប្រព័ន្ធអេកូឡូស៊ីក្នុងការទូទាត់ប្រាក់តាមប្រព័ន្ធអ៊ីនធឺណែតឲ្យកាន់តែទូលំទូលាយ។

ពិនិត្យឡើងវិញនូវយុទ្ធសាស្ត្របណ្តាញសាខារបស់យើង ដើម្បីធានាថាប្រតិបត្តិការនៅតែរក្សាភាពល្អប្រសើរ ផ្តល់ការស្វាគមន៍ និងស្ថិតក្នុងទីតាំងយុទ្ធសាស្ត្រ ដែលមានសកម្មភាពសេដ្ឋកិច្ច៖

- ផ្លាស់ប្តូរទីតាំងសាខាមួយក្នុងចំណោមសាខាសំខាន់ៗរបស់យើង នៅតំបន់ទួលគោក ទៅកាន់តំបន់សក្តានុពលមួយ ដែលមានទីតាំងធំទូលាយ ដើម្បីបំពេញតាមតម្រូវការ និងតាមកំណើននៃសេចក្តីចង់បានរបស់អតិថិជនរបស់យើង និងរៀបចំខ្លួនសម្រាប់ការរីកចម្រើននៃអាជីវកម្មនាពេលខាងមុខ។ ការផ្លាស់ប្តូរនេះ បានអនុញ្ញាតឲ្យយើងដំឡើងនូវម៉ាស៊ីនបម្រើសេវាកម្មដោយស្វ័យប្រវត្តិ ច្រើនបន្ថែមទៀត និងបើកដំណើរការនូវកន្លែងទទួលអតិថិជនផ្ទាល់ Premier Wealth មួយបន្ថែមទៀត។ អតិថិជន Premier របស់យើងអាចប្រើប្រាស់សេវាកម្មធនាគារដ៏ប្រណិតរបស់យើង និងអាចជួបទំនាក់ទំនងជាមួយប្រធានផ្នែកទំនាក់ទំនង Premier របស់យើង ដែលមានទីតាំងនៅជិតកន្លែងរស់នៅ ឬធ្វើការដើម្បីបំពេញតម្រូវការហិរញ្ញវត្ថុ និងសេវាកម្មធនាគារ។ អតិថិជនរបស់យើង ក៏អាចដាក់ប្រាក់បញ្ញើ ឬដកប្រាក់នៅតាមម៉ាស៊ីនបម្រើសេវាកម្មអតិថិជនដោយស្វ័យប្រវត្តិរបស់យើង បាន២៤ម៉ោងក្នុងមួយសប្តាហ៍ ផងដែរ។
- ពួកយើង បានធ្វើការកែលម្អឡើងវិញនូវសាខាចំនួន៣ ដូចជាសាខាតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ សាខាបឹងកេងកងទីមួយ និងសាខាក្រុងសួង ដើម្បីបង្កើនភាពល្អប្រសើរ ដោយស្របតាមការរចនារូបរាង និងបទពិសោធន៍សេវាកម្មដូចគ្នា នៅទូទាំងសាខារបស់ធនាគារ មេយប៊ែង ទាំងក្នុងស្រុក និងក្នុងតំបន់។
- ដើម្បីធានាបាននូវសុវត្ថិភាព និងសុខុមាលភាពរបស់អតិថិជន និងនិយោជិតរបស់យើង នៅក្នុងបរិបទថ្មីនេះ ដែលត្រូវបានបង្កឡើងដោយជំងឺរាតត្បាតកូវីដ១៩ ពួកយើង បានអនុវត្តការការពារចាំបាច់ និងវិធានការការពារ និងបង្កានានានៅទូទាំងបណ្តាញសាខា តាមការប្រតិបត្តិស្តង់ដារ តម្រូវដោយក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាល។ ទាំងនេះ រួមបញ្ចូលការវាស់សីតុណ្ហភាព ការស្តេន QRកូដ ការធ្វើអនាម័យដោយអាកុលលាងដៃ និងការពាក់ម៉ាស់ការពារ នៅពេលចូល ឬស្ថិតនៅក្នុងបរិវេណធនាគាររបស់យើង។

ទស្សន: វិស័យ និងអាទិភាពសម្រាប់ឆ្នាំ ២០២១

ទស្សន: វិស័យសម្រាប់ឆ្នាំ២០២១ នៅតែជាការប្រឈមមួយ នៅពេលដែលការរីករាលដាលនៃជំងឺរាតត្បាតកូវីដ១៩ នៅតែបន្តបង្កើតការរំខាន និងផ្តល់សម្ពាធយ៉ាងខ្លាំងដល់ប្រព័ន្ធថែទាំសុខភាពសាធារណៈ និងស្ថានភាពសេដ្ឋកិច្ច ស្របពេលដែលអាជីវកម្មនិងប្រជាជនកំពុងសម្របខ្លួនក្នុងការធ្វើប្រតិបត្តិការ ប្រកបការងារ និងការរស់នៅតាមបទដ្ឋានថ្មី។ ដើម្បីទប់ទល់នឹងឧបសគ្គ ដែលយើងមិនធ្លាប់ជួបពីមុនមក ពួកយើងបានប្រកាន់ភ្ជាប់នូវវិធីសាស្ត្របានយ៉ាងសកម្ម និងចាំបាច់ ដើម្បីគ្រប់គ្រងអាជីវកម្ម ដោយពង្រឹងការចូលរួមរបស់យើងជាមួយនឹងអតិថិជន និងដៃគូ នៅក្នុងឆ្នាំ២០២១នេះ ដោយសំរិតសំរាំងយុទ្ធសាស្ត្រក្នុងការអនុវត្តគម្រោងសំខាន់ៗឲ្យបានរលូន ប្រយោជន៍ដើម្បីបង្កើន និងពង្រឹងការផ្តល់ជូននូវប្រព័ន្ធឌីជីថលរបស់យើង។

អាទិភាពសម្រាប់ឆ្នាំ ២០២១៖

- បន្តរក្សាតារាងសមតុល្យ និងគ្រប់គ្រងគុណភាពទ្រព្យសកម្មរបស់យើង ដោយយកចិត្តទុកដាក់ក្នុងការពង្រឹងការចូលរួមជាមួយអតិថិជន និងការផ្តល់ជំនួយក្នុងករណីចាំបាច់ដល់អតិថិជន ដែលគួរតែទទួលបានក្នុងកំឡុងពេលដ៏លំបាកនេះ។
- ផ្តោតលើវិស័យសំខាន់ៗ ដែលនៅតែរក្សាភាពរឹងមាំ ឬក៏មានសភាពធន់ ជាពិសេសក្នុងការផ្តល់ឥណទានបុគ្គល និងការផ្តល់ឥណទានអាជីវកម្មខ្នាតតូច និងមធ្យម ដើម្បីបង្កើនកំណើនឥណទានរបស់យើង។
- ការផ្ទួចផ្តើមសំខាន់ៗ ដើម្បីផ្តល់ជូននូវគុណភាពសេវាកម្មសម្រាប់អតិថិជនដ៏ល្អឥតខ្ចោះ នៅគ្រប់ផ្នែកទាំងអស់ ស្របពេលដែលកំពុងពង្រឹងសេវាកម្ម Premier ដោយផ្តល់អានុភាពទៅលើការទំនាក់ទំនង និងបទពិសោធន៍ដ៏សំបូរបែបនៅតាមទីផ្សារផ្សេងៗគ្នា។
- នាំមកជូននូវសមត្ថភាពឌីជីថលរបស់យើងទៅដល់កម្រិតថ្មីមួយ ជាមួយការបំពាក់នូវម៉ាស៊ីនបម្រើសេវាកម្មអតិថិជនដោយស្វ័យប្រវត្តិ បន្ថែមទៀត ដើម្បីឲ្យអតិថិជនរបស់យើង អាចប្រើប្រាស់ក្នុងការធ្វើប្រតិបត្តិការទូទៅបានគ្រប់ពេលវេលា ទន្ទឹមនឹងនេះយើងក៏បានដាក់ពង្រាយម៉ាស៊ីនអេធីអឹមនៅតាមតំបន់ផ្សេងៗបន្ថែមទៀត ដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការប្រើប្រាស់ផងដែរ។
- បន្តពង្រឹង និងពង្រីកមុខងារទូទាត់ប្រាក់របស់កម្មវិធីធនាគារចល័ត M2U ដើម្បីឲ្យអតិថិជនអាចធ្វើប្រតិបត្តិការធនាគារតាមតម្រូវការរបស់ពួកគេបានគ្រប់ពេល និងគ្រប់ទីកន្លែង។

នាយកដ្ឋាន ធនាគារកិច្ច និង សាខីចកម្ម

សមិទ្ធិផលសំខាន់ៗនៅក្នុងឆ្នាំ២០២០

- រក្សាផលិតភាពការងារឲ្យ នៅតែមានកម្រិតខ្ពស់ ដោយបានបង្ហាញ តាមរយៈ ប្រាក់ចំណេញមុនបង់ពន្ធ នៃនិយោជិតម្នាក់ៗ បើធៀបទៅនឹង ឆ្នាំ២០១៩។
- បើកដំណើរការ ផលិតផលធនាគារ អាជីវកម្មខ្នាតតូច និងមធ្យម បានដោយជោគជ័យ ជាមួយនឹងកម្មវិធីផ្តល់សេវាតណទានបន្ថែម ពីលើផ្នែកតណទានអាជីវកម្មលក់រាយ ខ្នាតតូច និងមធ្យម ដែលសម្រេចបាននូវកំណើនទ្រព្យសកម្មរហូតដល់ ៤៥% ក្នុងវិស័យ អាជីវកម្មខ្នាតតូច និងមធ្យម។
- ឥណទានសរុបប្រចាំឆ្នាំមានកំណើនរហូតដល់ ១៥% ទោះបីជាកំពុងស្ថិត នៅក្នុងការប្រឈមនូវការផ្ទុះឡើងនៃជំងឺរាតត្បាតក៏ដោយ។
- កំណត់ត្រាប្រាក់ចំណូលប្រចាំឆ្នាំ មានការកើនឡើង ១០% ធៀបទៅនឹង ឆ្នាំ២០១៩ ដែលបង្ហាញពីភាពវិជ្ជមាន ជាមួយនឹង លទ្ធផលទ្ធេដងនៃ សមាមាត្រប្រាក់ចំណូល។
- ការផ្តល់ជូន នូវគុណភាពសេវាកម្ម ផ្នែកឌីជីថលប្រសើរជាងមុន ជូន ដល់អតិថិជនសាជីវកម្ម ជាមួយនឹង ការផ្តល់ដំណោះស្រាយ តាមរយៈ ការដាក់ឲ្យប្រើប្រាស់ ដំណោះស្រាយ Host-to-Host ទៅលើMaybank2e (M2E)។

ចំនុចផ្តោតសំខាន់ៗនៅក្នុងឆ្នាំ២០២០

ធ្វើជាដៃគូសហការជាមួយអតិថិជន ដើម្បីឆ្លងកាត់ពេលវេលាដ៏លំបាកនេះ

ពួកយើង នៅតែរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយអតិថិជន សាជីវកម្មរបស់ពួកយើង ដោយផ្តល់ជាជំនួយហិរញ្ញវត្ថុ ក្នុងករណី ដែលចាំបាច់ណាមួយ នៅក្នុងស្ថានភាពដ៏លំបាក និងហានិភ័យ ដែលបង្កឡើងដោយជំងឺរាតត្បាតនេះក៏ដោយ។ ពួកយើង បានផ្តល់ជូននូវដំណោះស្រាយលើការពន្យាពេលទូទាត់សំណង ក៏ដូចជា ជំនួយក្នុងការទូទាត់សង តាមរយៈបែបបទពីរទម្រង់ លើការសង ត្រឹមតែការប្រាក់ ឬការពន្យារយៈពេលទូទាត់ប្រាក់ រហូតដល់៦ខែ និងការរៀបចំឥណទាន ឬការកំណត់ពេលវេលាសងឡើងវិញ ដែលសមស្របទៅតាមតម្រូវការរបស់ពួកគេ។ ពួកយើង ក៏បានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ចំពោះអតិថិជន ដែលងាយរងផលប៉ះពាល់ តាមការផ្តល់ដំណឹងទុកមុន ដើម្បីទទួលបានជំនួយ និងគម្រោងហិរញ្ញវត្ថុទាន់ពេលវេលា។ ត្រឹមខែធ្នូ ឆ្នាំ២០២០ ពួកយើង បានផ្តល់កញ្ចប់ជំនួយហិរញ្ញវត្ថុ ដែលមានតម្លៃសរុបជាង ៦០លានដុល្លារ នៅប្រទេសកម្ពុជា។

ពួកយើង រក្សាជានិច្ចនូវគុណតម្លៃស្នូលរបស់ពួកយើង និងនៅតែជា ដៃគូសេវាហិរញ្ញវត្ថុប្រកបដោយអរិយ្យភាព ចំពោះអតិថិជនសាជីវកម្ម របស់យើងគ្រប់ពេលវេលា។ បន្ថែមទៅលើកញ្ចប់ជំនួយហិរញ្ញវត្ថុ ពួកយើង បានក្លាយជាចំណែកមួយក្នុង ការកាត់បន្ថយហានិភ័យនៃ ការរីករាលដាលនូវជំងឺកូវីដ១៩ ដែលឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត តាមរយៈយុទ្ធនាការផ្សព្វផ្សាយ ពីការផ្ទេរប្រាក់ទៅធនាគារផ្សេង តាមរយៈធនាគារតាមអ៊ីនធឺណែត និងធនាគារចល័ត M2U និងM2E ដើម្បីលើកទឹកចិត្តឲ្យអតិថិជនងាកមកធ្វើប្រតិបត្តិការ តាមអ៊ីនធឺណែត M2U និង M2E ជំនួសឲ្យការប្រតិបត្តិការនៅតាមបញ្ចរនៅធនាគារផ្ទាល់។ យុទ្ធនាការផ្សព្វផ្សាយនេះ ក៏បានជំរុញដល់អតិថិជនក្នុងស្រុក និងអតិថិជនដែលជាម្ចាស់ក្រុមហ៊ុនធ្វើប្រតិបត្តិការ តាមប្រព័ន្ធអ៊ីនធឺណែត ដែលធ្វើឲ្យកំណើនប្រតិបត្តិការនៃ ការផ្ទេប្រាក់ទៅធនាគារផ្សេង តាម M2E កើនឡើងដល់១៥%។

ការរួមបញ្ចូលគ្នានៃ ដំណោះស្រាយផ្នែកហិរញ្ញវត្ថុបែបឌីជីថល ដែលសម្រួលដល់ការគ្រប់គ្រង និងដំណើរការនៃកម្មវិធីធនាគារតាមប្រព័ន្ធអ៊ីនធឺណែត M2E ដែលមានភាពប្រសើរជាងមុន

ស្របតាមការផ្លាស់ប្តូរ ទៅតាមតម្រូវការរបស់អតិថិជន ក្នុងប្រព័ន្ធឌីជីថលពួកយើង បានដាក់ដំណើរការ នូវការពង្រីកសមត្ថភាព Host-to-Host នៃប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ M2E របស់ពួកយើងដែលជួយសម្រួលដល់ អតិថិជនសាជីវកម្ម ក្នុងការគ្រប់គ្រងសាច់ប្រាក់ ដោយស្វ័យប្រវត្តិ (STP) ដោយផ្ទាល់ ពីប្រព័ន្ធHost របស់អតិថិជន សាជីវកម្ម មកកាន់ប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់របស់ពួកយើង។ ដោយសារតែប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ M2E របស់យើង ត្រូវបង្កើតឡើងជាពិសេស សម្រាប់អតិថិជនសាជីវកម្ម ដោយបង្កើននូវ ប្រសិទ្ធភាព និងស្វ័យប្រវត្តិកម្ម ក្នុងការគ្រប់គ្រងលំហូរសាច់ប្រាក់នៅ គ្រប់ពេលវេលា និងគ្រប់ទីកន្លែង ដើម្បីដោះស្រាយនូវភាពស្មុគស្មាញ នានាក្នុងការគ្រប់គ្រងប្រតិបត្តិការ ដែលតម្រូវឲ្យមានភាពបត់បែន និងងាយស្រួល ប្រកបដោយសុវត្ថិភាព និងភាពច្បាស់លាស់នោះ ប្រព័ន្ធ M2E បានជួយសម្រួល ដល់អតិថិជនសាជីវកម្មរបស់យើងយ៉ាងខ្លាំង នៅក្នុងអំឡុងពេលពួកគាត់ភាគច្រើន ធ្វើការពីផ្ទះ ឬកន្លែងការងារ ចល័ត ដោយសារការរាតត្បាតនៃជំងឺកូវីដ១៩នេះ។ ជាលទ្ធផល ចំនួន អតិថិជន ដែលបានចុះឈ្មោះប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ M2E មានការកើនឡើង ក្នុងអត្រាកំណើនប្រចាំឆ្នាំរហូតដល់ ៣១%។

ការគាំទ្រអាជីវកម្មខ្នាតតូច ក្នុងដំណើរវិវត្តខ្លួនទៅជាសាជីវកម្មជាមួយ ការបើកឲ្យដំណើរការនូវផលិតផលធនាគារ ផ្នែកអាជីវកម្មខ្នាតតូច និងមធ្យម

ដោយទទួលស្គាល់ពីតម្រូវការរបស់អតិថិជន អាជីវកម្មខ្នាតតូច ក្នុងការពង្រីកខ្លួន និងដំណើរវិវត្តខ្លួនដើម្បីក្លាយជាសាជីវកម្ម ក្នុងនាមជា ដៃគូផ្នែកហិរញ្ញវត្ថុដែលផ្តល់ទំនុកចិត្ត ពួកយើងបានបើកឲ្យដំណើរការ នូវផលិតផលធនាគារ ផ្នែកអាជីវកម្មខ្នាតតូច និងមធ្យមដោយផ្តោត សំខាន់ទៅលើការផ្តល់សេវាកម្មឥណទាន ជំនួយដល់ការគាំទ្រនៃផ្នែក អាជីវកម្មបុគ្គល និងផ្នែកសាជីវកម្ម។ ផ្នែកអាជីវកម្មខ្នាតតូច និងមធ្យម ដែលទើបនឹងចាប់ផ្តើម មានគោលដៅក្នុងការផ្តល់នូវឥណទាន ដែល មានភាពងាយស្រួល និងសមស្របតាមតម្រូវការអតិថិជន ស្របតាម ការគ្រប់គ្រងហានិភ័យរបស់ធនាគារ។ ដំណើរការនៃផ្នែកអាជីវកម្ម ខ្នាតតូច និងមធ្យមនេះ គឺជាការផ្តោតចម្បងប្រចាំឆ្នាំ២០២០របស់ ធនាគារយើង ដោយបានផ្តល់នូវកំណើនទ្រព្យសកម្ម ដែលមានគុណ ភាព បើទោះបីជាសេដ្ឋកិច្ចមិនមានភាពអំណោយផល ក្នុងអំឡុងពេល នៃការរាតត្បាតក៏ដោយ។

នាយកដ្ឋានធនាគារកិច្ច និងសាជីវកម្ម

ដំណើរឆ្ពោះទៅរកការផ្តល់ជូននូវគុណភាពសេវាកម្មកាន់តែល្អប្រសើរ តាមរយៈការវិនិយោគបន្ថែមទៅលើសមត្ថភាព និងការពង្រីកបន្ថែមផ្នែកឌីជីថល

ដើម្បីបំពេញនូវតម្រូវការជឿនលឿន ដែលកំពុងកើនឡើងរបស់អតិថិជនក្នុងស្រុក និងអតិថិជនសាជីវកម្មក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ពួកគាត់ រួមជាមួយនឹងបទពិសោធន៍ធនាគារកិច្ច នៅទូទាំងតំបន់ និងតំបន់ដែលពាក់ព័ន្ធនានាទាំងអស់ ពួកយើង ប្តេជ្ញានិងផ្តល់នូវដំណោះស្រាយហិរញ្ញវត្ថុយ៉ាងពេញលេញ ទៅលើការវិនិយោគបន្ថែមទៀត ដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ M2E និងធនាគារតាមអ៊ីនធឺណែត M2U ដើម្បីសម្រេចឲ្យបានគោលបំណង ក្នុងការក្លាយខ្លួនជាធនាគារជម្រើសឌីជីថលសម្រាប់អតិថិជនបុគ្គល និងសាជីវកម្ម។

សមិទ្ធផលសំខាន់ៗ

ប្រាក់ចំណេញលើប្រតិបត្តិការរបស់នាយកដ្ឋានធនាគារកិច្ច និងសាជីវកម្ម បានកើនឡើងជាលំដាប់ចំនួន ១២%ស្មើនឹង ២១,២ លានដុល្លារ ដែលបានសន្ទត់ដូចខាងក្រោម៖

- កំណើននៃចំណូលចំនួន ១០,៣% ដែលត្រូវបានរួមចំណែកយ៉ាងសំខាន់ពីចំណូលការប្រាក់។
- ការគ្រប់គ្រងថ្លៃដើមប្រកបដោយប្រសិទ្ធភាព និងវិធានការណ៍យ៉ាងម៉ត់ចត់ ដែលទទួលបានលទ្ធផលក្នុងការកាត់បន្ថយចំណាយសរុបចំនួន ១០,២%។
- កំណើនប្រាក់កម្ចី ចំនួន ១៥,៣% ដែលភាគច្រើនបានមកពីការកើនឡើងយ៉ាងខ្លាំងនៃប្រាក់កម្ចីខ្នាតតូច និងមធ្យមដែលទើបនឹងចាប់ផ្តើម។
- ការរក្សាប្រាក់បញ្ញើសម្រាប់គណនីសន្សំ និងគណនីចរន្តចំនួន ៦០,៣%។

ទស្សនៈ និងអាទិភាពសម្រាប់ឆ្នាំ២០២១

ផលប៉ះពាល់នៃ ជំងឺកូវីដ១៩ នៅតែបន្តកើតមានរហូតដល់ឆ្នាំ២០២១ ដែលបង្កឲ្យមានការយឺតយ៉ាវ និងចុះខ្សោយខាងផ្នែកទីផ្សារទាំងអតិថិជនក្នុងប្រទេស និងសាជីវកម្ម។ ពួកយើង នឹងនៅតែបន្តការយកចិត្តទុកដាក់ និងការចូលរួមយ៉ាងសកម្មជាមួយអតិថិជនរបស់យើង ដើម្បីកាត់បន្ថយផលប៉ះពាល់ រួមទាំងបន្តផ្តល់ឲ្យពួកគាត់នូវសមាហរណកម្ម និងដំណោះស្រាយហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត តាមរយៈដំណោះស្រាយសេវាកម្មធនាគារឌីជីថល M2U និង M2E ដែលអាចឲ្យអតិថិជនរបស់ពួកយើង ធ្វើប្រតិបត្តិការតាមបែបឌីជីថល។ ពួកយើង ក៏នៅតែបន្តពង្រឹងភាពរឹងមាំនៃតារាងតុល្យការរបស់យើង តាមរយៈការត្រួតពិនិត្យយ៉ាងតឹងរឹងនៃការរៀបចំរចនាសម្ព័ន្ធផលប័ត្រឡើងវិញ ដោយសារផលប៉ះពាល់នៃជំងឺកូវីដ១៩ និងការប្រើប្រាស់ វិធីសាស្រ្តជ្រើសរើសយ៉ាងម៉ត់ចត់ ចំពោះព័ត៌មានដែលផ្តល់ដោយអតិថិជនថ្មី។

អាទិភាពសម្រាប់ឆ្នាំ២០២១

- ផ្តោតលើការរីកចម្រើនរបស់អតិថិជនសាជីវកម្ម តាមរយៈដំណោះស្រាយក្នុងការគ្រប់គ្រងសាច់ប្រាក់របស់យើងដូចជាការទូទាត់ប្រាក់ខែ ការប្រមូល និងសេវាកម្មធនាគារតាមអ៊ីនធឺណែត M2U និងប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ M2E។
- ពង្រឹងផែនការគណនីយុទ្ធសាស្រ្ត ដើម្បីគាំទ្រដល់ការបង្កើនព័ត៌មានដល់អតិថិជនថ្មី និងបង្កើនការប្រើប្រាស់ឥណទាន ហើយនិងចាប់យកឱកាសនៃការលក់ផ្សេងទៀត។
- អនុវត្តការត្រួតពិនិត្យយ៉ាងម៉ឺងម៉ាត់នៃការរៀបចំរចនាសម្ព័ន្ធផលបត្រ ដែលរងផលប៉ះពាល់ជាចម្បងដោយជំងឺកូវីដ១៩ និងធានាថាមិនមានការថយចុះគុណភាពឥណទាន និងបរិមាណអាជីវកម្មរបស់អតិថិជនឡើយ។
- បំពេញនូវចន្លោះខ្វះខាត តាមរយៈការចាប់ផ្តើមផលិតផលរបស់ធនាគារ ផ្នែកសហគ្រាសធុនតូចនិងមធ្យម និងបានផ្តល់នូវយុទ្ធសាស្រ្តរបស់ខ្លួន ដើម្បីបម្រើដល់សហគមន៍មូលដ្ឋាន និងជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចរបស់យើង (សហគ្រាសធុនតូច និងមធ្យម)។
- បន្តធ្វើឲ្យប្រសើរឡើងនៅការគ្រប់គ្រងសាច់ប្រាក់ក្នុងតំបន់ (M2E) ដើម្បីបម្រើអតិថិជនក្នុងស្រុក និងអតិថិជនសាជីវកម្មរបស់យើង និងពង្រីកសមត្ថភាព Host-to-Host លើប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ M2E ដែលផ្តល់នូវប្រសិទ្ធភាពកាន់តែប្រសើរ ដោយការបត់បែននៃដំណើរការរៀបចំការងារ សម្រាប់អតិថិជនសាជីវកម្មរបស់យើង ប្រកបដោយភាពងាយស្រួល និងធានាសុវត្ថិភាពក្នុងការគ្រប់គ្រងលំហូរសាច់ប្រាក់របស់ពួកគាត់។

ការផ្តល់ជូន
គុណភាពសេវាកម្ម

ចាប់តាំងពីការបង្កើតឡើងនៅក្នុងឆ្នាំ១៩៦០ ធនាគារ មេយវ៉ៃង តែងប្រកាន់យកនូវគោលបំណងចម្បងមួយ គឺការផ្តល់សេវាកម្មហិរញ្ញវត្ថុ ដែលជួយសម្រួលដល់ការអភិវឌ្ឍជូនដល់ប្រជាជនម៉ាឡេស៊ី និងសហគមន៍អាស៊ាន ដែលរួមមានទាំងប្រទេសកម្ពុជាផងដែរ។ ជាច្រើនឆ្នាំកន្លងមក ការតាំងចិត្តនេះ ត្រូវបានប្រកាន់ខ្ជាប់និងអនុវត្តកាន់តែខ្លាំងឡើង រហូតដល់ក្លាយទៅជាបាវចនារបស់ក្រុមហ៊ុនរបស់ពួកយើង។ ស្របពេល ដែលពួកយើងកំពុងប្រារព្ធខួបលើកទី៦០របស់ពួកយើងនៅក្នុងឆ្នាំ២០២០នេះ វាបានក្លាយ ជាផ្នែកមួយនៃអត្តសញ្ញាណរបស់ពួកយើង។ ពួកយើង បានប្រឈមមុខនឹងបញ្ហាជាច្រើន ដោយសារមេរោគកូវីដ១៩ ក្នុងកំឡុងពេលមួយឆ្នាំពេញហើយពួកយើង ក៏បានបង្ហាញឲ្យឃើញយ៉ាងពិតប្រាកដ នូវការផ្តល់ជូនសេវាហិរញ្ញវត្ថុប្រកបដោយអរិយ្យភាព ក្នុងការគាំទ្រ និងជំនួយនានាលើសពីតម្រូវការធនាគារ។

នៅសម្ព័ន្ធធនាគារ មេយវ៉ៃង ពួកយើង បានគៀងគរមូលនិធិ បានប្រមាណជាង ០.៧៥លានដុល្លារអាមេរិក (៣លានរីងហ្គីត)ហើយតាមរយៈការប្រមូលមូលនិធិនេះ នឹងត្រូវផ្តល់ជូនរួមជាមួយអាហារ និងឧបករណ៍ការពារផ្ទាល់ខ្លួន(PPE) ដល់សហគមន៍ ដែលរងផលប៉ះពាល់នៅក្នុងតំបន់។ ពួកយើង បានបើកដំណើរការ ក្នុងការដាក់ប្រាក់បញ្ជើដើម្បីអត្ថប្រយោជន៍សង្គម ដែលជាចំណែកមួយក្នុងការចូលរួមជួយសម្រួលដល់អ្នកត្រូវការ។ ដោយសារការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា ដែលត្រូវបានបង្កើតឡើងដោយក្រុមការងាររបស់ពួកយើង នៅប្រទេសម៉ាឡេស៊ី និងបាំងកាឡូ ពួកយើងបាននាំមកជូននូវការច្នៃប្រឌិតនានា ដែលជួយឲ្យអាជីវកម្មតូចនានាអាចនៅដំណើរការបាន។ ជាមួយនឹងកម្មវិធី Sama-Sama Lokal ពួកយើងបានមិនត្រឹមតែជួយតភ្ជាប់ឲ្យអាជីវកម្មតូចៗទាំងនេះ ទៅកាន់ក្រុមអតិថិជនគោលដៅ ដោយមិនអស់កម្រៃសេវាកម្មប៉ុណ្ណោះទេ តែពួកយើងក៏បានជួយដល់វិស័យដឹកជញ្ជូនផងដែរ។ នៅក្នុងប្រទេសកម្ពុជា ពួកយើងក៏បានចូលរួមជាមួយ រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្តួចផ្តើមនានា ដើម្បីដោះស្រាយនូវការរីករាលដាលនៃវីរុសកូវីដនេះ តាមរយៈការចូលរួមវិភាគទានផ្នែកហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយផលប៉ះពាល់ដល់ប្រព័ន្ធសុខាភិបាល ដែលកំពុងមានបន្ទុកធ្ងន់ និងកាត់បន្ថយការប្រឈមមុខនានា ដែលជួបប្រទះដោយអ្នកការងារជួរមុខ ដែលបានខិតខំធ្វើការដោយមិនខ្លាចនឿយហត់ ដើម្បីទប់ស្កាត់ការរីករាលដាលនៃវីរុស ក៏ដូចជាជួយឲ្យប្រទេសជាតិ និងប្រជាជនរបស់ខ្លួនវិលត្រឡប់ទៅរកស្ថានភាពធម្មតាវិញ។ ពួកយើង ក៏បានចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រមូលមូលនិធិសម្រាប់ការទិញវ៉ាក់សាំងការពារជំងឺកូវីដ១៩។

អ្វីដែលសំខាន់បំផុត ពួកយើង ខិតខំការពារសុខុមាលភាពរបស់អតិថិជន និងប្រកាន់ខ្ជាប់នូវគោលការណ៍ប្រតិបត្តិស្តង់ដារ នៅតាមបណ្តាសាខារបស់ពួកយើង ហើយទន្ទឹមនឹងការលើកទឹកចិត្តឲ្យមានកិច្ចទំនាក់ទំនងនិងប្រតិបត្តិការតាមរយៈអ៊ីនធឺណែត ឲ្យកាន់តែមានភាពប្រសើរឡើង។

គុណភាពសេវាកម្ម

ជាផ្នែកមួយនៃបេសកកម្មរបស់ពួកយើង គឺការផ្តល់ជូននូវគុណភាពសេវាកម្មដ៏ល្អបំផុត នៅរាល់គ្រប់ទម្រង់នៃប្រតិបត្តិការទាំងអស់របស់ពួកយើង ហើយនៅឆ្នាំនេះ ពួកយើង បានចាប់ផ្តើមការផ្តួចផ្តើមជាច្រើន ដោយផ្នែកលើការស្ទង់មតិ (ត្រូវបានគេស្គាល់ថាជាសម្លេងអតិថិជន) ដែលទទួលបានពីការស្ទង់មតិ ការចូលរួមរបស់អតិថិជនខាងក្រៅ (ECES) ។ ECES គឺជាការវាយតម្លៃកត្តាសំខាន់ៗ ដែលជៈឥទ្ធិពលដល់ឥរិយាបថរបស់អតិថិជនក្នុងដំណើរប្រតិបត្តិការធនាគាររបស់ពួកគាត់ តាមរយៈបណ្តាញទំនាក់ទំនងសាខាផ្សេងៗគ្នារបស់ពួកយើង។ នៅឆ្នាំ២០២០ ពិន្ទុECES និងNet Promoter Score (NPS) របស់ពួកយើង ត្រូវបានកើនឡើង ដែលបង្ហាញឲ្យឃើញអំពីការទទួលស្គាល់របស់ពួកយើង ជាជម្រើសនៃស្ថាប័នហិរញ្ញវត្ថុ នៅក្នុងប្រទេស។ ការកើនឡើងនេះ គឺអាស្រ័យដោយសារតែមានការឆ្លើយតបយ៉ាងទាន់ពេលវេលា និងមានប្រសិទ្ធភាពជូនដល់អតិថិជនរបស់ពួកយើង ដែលរង ផលប៉ះពាល់ដោយជំងឺកូវីដ១៩ដែលរួមមាន៖

- ការផ្តល់ជូននូវដំណោះស្រាយ និងជម្រើសផ្សេងៗលើ ការពន្យាពេលនៃការសងឥណទាន វិធានការ និងកញ្ចប់ជំនួយផ្នែកហិរញ្ញប្បទាន សម្រាប់អតិថិជនកម្ចី ដែលទទួលរងផលប៉ះពាល់។
- ផ្តល់អាទិភាពដល់សុវត្ថិភាពរបស់អតិថិជនជាចម្បង និងផ្តល់ជូននូវគុណភាពសេវាកម្ម ដែលអតិថិជន រំពឹងនឹងទទួលបាន នៅតាមបណ្តា សាខារបស់ពួកយើង ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ប្រតិបត្តិស្តង់ដារ ដូចជាការរក្សាគម្លាតសង្គមជាដើម។
- ពង្រឹងទម្រង់ប្រតិបត្តិការឌីជីថលរបស់ពួកយើង ដែលរួមមានសេវាកម្មតាមអ៊ីនធឺណែត ឬធនាគារចល័ត Maybank2u KH និងMaybank2E ដែលអាចផ្តល់ជូនអតិថិជនបុគ្គល និងសាជីវកម្ម នូវការធ្វើប្រតិបត្តិការសេវាកម្មធនាគារនានា តាមប្រព័ន្ធអ៊ីនធឺណែត។
- ការបណ្តុះបណ្តាលជំនាញបន្ថែមទៀត សម្រាប់និយោជិតជួរមុខ ដើម្បីត្រៀមខ្លួនឲ្យបានល្អសម្រាប់ការធ្វើប្រតិបត្តិការ នៅក្នុងការធ្វើប្រតិបត្តិធម្មតា តាមបែបគន្លងថ្មី។ ក្នុងចំណោមនិយោជិតផ្សេងទៀត ពួកយើងបានផ្តល់នូវមាតិការរៀន ដែលមានទំហំតូចជាងមុន និងពង្រឹងសមត្ថភាពនិយោជិតរបស់ពួកយើង នូវជំនាញក្នុងការដោះស្រាយបញ្ហាបានភ្លាមៗ ដើម្បីកាត់បន្ថយបណ្តឹងផ្សេងៗពីអតិថិជន។

ការខិតខំប្រឹងប្រែងមិនខ្លាចនឿយហត់ ដើម្បីឆ្ពោះទៅរកការគាំទ្រដែលមានគុណភាព

នៅក្នុងឆ្នាំ២០២០ ខណៈពេលដែលការផ្តួចផ្តើមនានាជាច្រើនកំពុងតែបន្ត ពួកយើងក៏បានចាត់វិធានការ ដើម្បីធានាថា ពួកយើង បានត្រៀមខ្លួនយ៉ាងពេញលេញសម្រាប់ការផ្លាស់ប្តូរ ដែលបានកើតឡើងដោយសារជំងឺរាតត្បាត។

មិនត្រឹមតែប៉ុណ្ណោះសូម្បីតែមុនពេល ដែលជំងឺកូវីដ១៩ ត្រូវបានរីករាលដាលដំបូង នៅក្នុងប្រទេសកម្ពុជា ពួកយើងបានចាប់ផ្តើម ធ្វើការបំបែកការធ្វើប្រតិបត្តិការ នៅតាមការិយាល័យរបស់ពួកយើង ទៅតាមបណ្តាញសាខាផ្សេងៗ ដើម្បីកាត់បន្ថយហានិភ័យនៃសេវាកម្ម ដែលអាចបង្កជាភាពរអាក់រអួល។ ពួកយើង ក៏បានធ្វើឲ្យប្រាកដថា ការិយាល័យ និងបណ្តាញសាខារបស់ពួកយើងប្រកាន់ខ្ជាប់នូវ តម្រូវការគម្លាតសង្គម។ គំនូសទីតាំងសម្រាប់ឈរ និងសុវត្ថិភាពនានា ត្រូវបានបង្កើតឡើងនៅតាមជណ្តើរយន្ត ជណ្តើរយោង និងលើឥដ្ឋ ឬវិថីសម្រាប់ដើរ កន្លែងធ្វើការ ត្រូវបានកែសម្រួល និងរៀបចំឡើងវិញ។

ទន្ទឹមនឹងនេះដែរ ក្នុងគោលបំណងដើម្បីកាត់បន្ថយភាពរអាក់រអួលដល់ការងារ ពួកយើង បានពង្រឹងសមត្ថភាព និងហេដ្ឋារចនាសម្ព័ន្ធនានា ដែលអាចអនុញ្ញាតិឲ្យពួកយើង អាចធ្វើការនៅតាមគេហដ្ឋានបាន។ នេះ រួមបញ្ចូលទាំងការដំណើរការនៃបណ្តាញឯកជននិម្មិត (VPNs) ការដំណើរការកុំព្យូទ័រលើតុនិម្មិត អ៊ីម៉ែលចល័ត និងកុំព្យូទ័រយួរដៃ ព្រមទាំងប្រព័ន្ធបច្ចេកវិទ្យានានាក្នុងការធ្វើសន្និសីទនិម្មិតនៅទូទាំងសម្ព័ន្ធ ធនាគារ មេយវ៉ៃង។ ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃបរិមាណនិយោជិតប្រើប្រាស់ ខាងក្រុមការងារប្រតិបត្តិការខាងក្នុងសម្ព័ន្ធធនាគារ របស់ពួកយើង បានដាក់ឲ្យប្រើប្រាស់នូវប្រព័ន្ធចូលដំណើរការពីចម្ងាយថ្មីមួយទៀតឈ្មោះថា “mWorks” ដែលអាចអនុញ្ញាតិឲ្យនិយោជិតចូលប្រើអ៊ីម៉ែល ឆ្មើរ/ក្សាទុកឯកសារ និងចូលទៅកាន់កម្មវិធីប្រើប្រាស់នានា តាមរយៈហេដ្ឋារចនាសម្ពន្ធ័កុំព្យូទ័រនិម្មិត (VDI) ដើម្បីការពារទិន្នន័យសាជីវកម្ម និងកម្មសិទ្ធិបញ្ញារបស់ធនាគារក្នុងកំឡុងពេលនេះ។

ប្រព័ន្ធសុវត្ថិភាពតាមអ៊ីនធឺណែត គឺត្រូវបានយកចិត្តទុកដាក់កាន់តែខ្លាំង និងកាន់តែបន្ទាន់ជាងមុន ស្របពេលដែលមានការកាន់ឡើងខ្លាំងចំពោះអតិថិជន ដែលចូលទៅធ្វើប្រតិបត្តិការឌីជីថល ហើយនិយោជិតរបស់ពួកយើងកាន់តែច្រើន ធ្វើការបម្រើសេវាកម្មពីចម្ងាយផងដែរ។ ប៉ុន្មានឆ្នាំមកនេះ ពួកយើង បានអភិវឌ្ឍសមត្ថភាពការពារសុវត្ថិភាព តាមប្រព័ន្ធអ៊ីនធឺណែតកាន់តែខ្លាំងឡើងៗ និងក្របខណ្ឌសន្តិសុខព័ត៌មានវិទ្យានានា យ៉ាងទូលំទូលាយ។ ទោះយ៉ាងណាក៏ដោយ ទាំងនេះ នឹងត្រូវពង្រឹងបន្ថែមជាបន្តទៀត ខណៈពេលដែលមេរោគរាតត្បាតនេះ មានការគំរាមកំហែងថ្មីៗ ដែលកំពុងបន្តកើតមាន។ នៅកម្រិតសម្ព័ន្ធធនាគារ ពួកយើង ក៏បានពន្លឿនការកែលម្អ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យារួមទាំងការបន្តធ្វើឲ្យប្រសើរឡើង នូវប្រព័ន្ធមជ្ឈមណ្ឌលទិន្នន័យសង្គ្រោះគ្រោះមហន្តរាយ ដែលទើបបង្កើតថ្មីរបស់ពួកយើង។ ទាំងនេះគឺជាកិច្ចខិតខំប្រឹងប្រែង ដែលបានរួមចំណែកសម្រាប់ពួកយើង ដែលអាចរក្សាបាននូវប្រតិបត្តិការធនាគារតាមអ៊ីនធើណែត ស្របតាមតម្រូវការនៃបទប្បញ្ញត្តិតឹងរឹងទៅលើបញ្ហាប្រតិបត្តិនានា ដែលមិនបានគ្រោងទុកមុន នៅតាមបណ្តាប្រទេសនានា ដែលសម្ព័ន្ធធនាគារកំពុងធ្វើប្រតិបត្តិការ ដែលរួមមានប្រទេសកម្ពុជាផងដែរ។

នាយកដ្ឋាន
គ្រប់គ្រងហានិភ័យ

បើទោះបីជាការរីករាលដាលនៃជំងឺកូវីដ១៩ បានបង្កើតនូវការប្រឈមជាច្រើនដល់អតិថិជនរបស់ពួកយើង ធនាគារ មេយប៊ែង បានខិតខំប្រឹងប្រែងយ៉ាងសកម្មបន្ថែមទៀត ដើម្បីធានាឲ្យបានថា អតិថិជនរបស់ពួកយើង នៅតែអាចបន្តធ្វើប្រតិបត្តិការធនាគាររបស់ខ្លួនដោយរលូន នៅក្នុងបរិបទដ៏លំបាកនេះ។ ជាមួយនឹងបញ្ហាប្រឈមថ្មីៗ នាយកដ្ឋានគ្រប់គ្រងហានិភ័យ បានប្ដេជ្ញាពង្រឹងប្រតិបត្តិការរបស់យើងឲ្យកាន់តែខ្ពស់ជាងមុន ដើម្បីកាត់បន្ថយ និងដោះស្រាយហានិភ័យ ដែលកើតឡើង។

ការផ្ដោតសំខាន់ៗក្នុងឆ្នាំ២០២០

គាំទ្រដល់តម្រូវការហានិភ័យរបស់ធនាគារ ដោយគ្រប់គ្រងភាពមិនប្រាកដប្រជាដែលបានកើតឡើង ពីការរាតត្បាតជាសកល នៃជំងឺកូវីដ១៩

នាយកដ្ឋានគ្រប់គ្រងហានិភ័យ បានអនុវត្តផែនការសកម្មភាព ជាអាទិភាពមួយចំនួន ដោយផ្ដោតលើការគ្រប់គ្រង ភាពមិនច្បាស់លាស់ ដែលបង្កឡើងពី សម្ពាធហានិភ័យសេដ្ឋកិច្ច ជាមួយនឹងអន្តរកាល ឆ្ពោះទៅរកបរិយាកាសប្រតិបត្តិការបែបគន្លងថ្មី ការគិតគូរតុល្យភាពហានិភ័យ ដើម្បីធានាឲ្យបាននូវភាពធន់នៃអាជីវកម្ម។

សមិទ្ធិផល៖

កិច្ចប្រជុំទាក់ទងនឹង ផែនការគ្រប់គ្រង និងបន្តអាជីវកម្ម ដែលបានរៀបចំឡើងដោយ ក្រុមការងារ នៃគណៈគ្រប់គ្រងវិបត្តិ ត្រូវបានបង្កើតឡើងឲ្យមានវិធានការទូទាំងបណ្ដាញប្រតិបត្តិការរបស់ពួកយើង តាំងពីមុនពេលដែលវីរុសកូវីដ១៩ ចាប់ផ្ដើមរីករាតត្បាតជាសកលមកម្ល៉េះ។ ពួកយើង បានពិនិត្យមើលអំពីទិដ្ឋភាពទូទៅ ដើម្បីសិក្សាពីការគ្រប់គ្រងវិបត្តិ ហើយក៏បានធ្វើការវាយតម្លៃរហ័សទាន់ពេល ទៅលើផ្នែកដែលអាចរងផលប៉ះពាល់ខ្លាំង ពីការផ្ទុះឡើង នៃជំងឺនេះ។ បន្ថែមពីនេះ ពួកយើងបានបង្កើតឧបករណ៍វាយតម្លៃអនុគ្រោះការបង់ឥណទាន ឬគុណភាពទ្រព្យសកម្ម ដើម្បីពិនិត្យ និងតាមដានទៅលើ អតិថិជន ដែលទទួលបានការលើកលែងជាបណ្ដោះអាសន្ន នូវការបង់ឥណទាន និងដើម្បីកំណត់បញ្ហាចម្បង នៃបញ្ហាគុណភាពទ្រព្យសកម្ម។ ប្រការនេះ អាចជួយកំណត់អត្តសញ្ញាណអតិថិជន ដែលសាកសមក្នុងការទទួលបានជំនួយចំពោះការទូទាត់ប្រាក់ និងបង្កើតការការពារ ដ៏សមស្របមួយ ដើម្បីគ្រប់គ្រងផលប៉ះពាល់ដែលអាចកើតឡើងមានក្រោយករណីលើកលែងការបង់ឥណទាន ជាបណ្ដោះអាសន្នត្រូវបានបញ្ចប់។

ពង្រឹងភាពធន់នៃប្រតិបត្តិការ

ពួកយើង បានធ្វើការផ្ដោតលើការគំរាមគំហែងតាមប្រព័ន្ធអ៊ីនធឺណែត ភាពធន់នៃហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាការបាត់បង់/លួចទិន្នន័យ និងការរំខាននានា តាមរយៈបណ្ដាញនានា សេវាកម្មអាជីវកម្ម ការទំនាក់ទំនង និងរបៀបវីរៈឌីជីថលរបស់ធនាគារទាំងមូល។ ការផ្ដោតទាំងនេះ គឺភាគច្រើនពាក់ព័ន្ធទៅនឹងកម្រិត និងភាពញឹកញាប់នៃការធ្វើប្រតិបត្តិការតាមរយៈអ៊ីនធឺណែត ដែលបណ្ដាលមកពីការរាតត្បាត។

សមិទ្ធិផល៖

ដើម្បីសម្រេចបាននូវការការពារទៅលើប្រតិបត្តិការរបស់យើង ប្រឆាំងទៅនឹងការខាតបង់យ៉ាងធ្ងន់ធ្ងរ ឬការរំខានក្នុងការផ្ដល់សេវាកម្មជូនអតិថិជន ពួកយើង បានរៀបចំឲ្យមានការសិក្សាយ៉ាងលម្អិត ទៅលើហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធព័ត៌មានវិទ្យា និងប្រព័ន្ធប្រតិបត្តិការ ដែលត្រូវបានអនុវត្តជាញឹកញាប់ ដោយអ្នកជំនាញផ្នែកព័ត៌មានវិទ្យារបស់យើង។ ពួកយើង ក៏បានបន្តធ្វើវិសោធនកម្ម និងពង្រឹងគោលនយោបាយ និងនិតិវិធីក្នុងការគ្រប់គ្រងហានិភ័យ តាមប្រព័ន្ធអ៊ីនធឺណែត ដើម្បីការពារទិន្នន័យសំខាន់ៗរបស់អតិថិជន និងធានាឲ្យបាននូវការការពារ ទិន្នន័យប្រកបដោយសុចរិតភាព និងមានលក្ខណៈស្តង់ដារ។ ក្របខណ្ឌការពារសុវត្ថិភាពតាម ប្រព័ន្ធអ៊ីនធើណែត និងក្របខណ្ឌគ្រប់គ្រងហានិភ័យតាមប្រព័ន្ធបច្ចេកវិទ្យា របស់ពួកយើង ត្រូវបានរៀបចំឲ្យសមស្របទៅនឹងហានិភ័យតាមប្រព័ន្ធអ៊ីនធឺណែត ដែលកំពុងរីកចម្រើន ក្នុងកំឡុងពេលរីករាតត្បាតនៃជំងឺកូវីដ ១៩ នៅក្នុងប្រទេសកម្ពុជា។

ការជំរុញសកម្មភាព នៃការយល់ដឹងពីហានិភ័យ

ពួកយើង បានបន្តបង្កើតផលចំណេញក្រោយធៀបនឹងកត្តាហានិភ័យ និងធ្វើឲ្យការគ្រប់គ្រងផលប័ត្រសកម្ម ប្រសើរឡើង ដោយប្រតិបត្តិតាមដំណើរការឌីជីថល របស់ធនាគារ តាមរយៈ៖

- ការបង្កើនប្រសិទ្ធភាពតារាងតុល្យភាព ដោយអនុវត្តនូវ ប្រព័ន្ធគ្រប់គ្រងយ៉ាងផលប័ត្រសកម្ម ពីថ្នាក់លើចុះរហូត ដល់ថ្នាក់ក្រោមដើម្បីផលចំណេញក្រោយធៀបនឹង កត្តាហានិភ័យ។
- ធ្វើការកំណត់លើការចាប់យកឱកាស ដោយធៀបជាមួយនឹងកត្តាហានិភ័យ និងចំណែកគោលដៅធៀបនឹងកត្តាឱកាស និងគោលដៅតាមរយៈការគ្រប់គ្រង ទៅលើផលប័ត្រសកម្ម ពីថ្នាក់ក្រោមរហូតដល់ថ្នាក់លើ ផ្អែកលើការវិភាគទិន្នន័យ។

សមិទ្ធិផល៖

ការចាប់យកគោលដៅ នៃគុណតម្លៃ សម្រាប់ការធ្វើឲ្យមានប្រសិទ្ធភាព ក្នុងការគ្រប់គ្រងតារាងតុល្យការ គឺនៅរក្សាបាននូវភាពទូលំទូលាយ ដែលរួមបញ្ចូលយុទ្ធសាស្ត្របង្កើនទិន្នផល ការបង្កើនប្រសិទ្ធភាព ទ្រព្យ ដែលមានកម្រិតហានិភ័យ ប្រសិទ្ធភាពមូលធនយុទ្ធសាស្ត្រសន្ទនីយភាព និងមូលនិធិដ៏ល្អបំផុត និងការគ្រប់គ្រងហានិភ័យអត្រាការប្រាក់។ ផលប្រយោជន៍ នៃការវិភាគលើការបែងចែកផលប័ត្រសម្រាប់ការធ្វើយុទ្ធសាស្ត្រទទួលប្រាក់បញ្ញើ ដើម្បីជួយសម្រួលដល់ផលចំណេញរយៈពេលវែង។ ករណីប្រើប្រាស់ការវិភាគទិន្នន័យ បានជំរុញឲ្យមានការកំណត់នៃឱកាសអាជីវកម្មថ្មីៗ ដោយផ្អែកទៅលើចរន្តប្រតិបត្តិការនានា ទំនាក់ទំនងដាក់បញ្ញើ និងការវិភាគផលប័ត្រនៃប្រាក់កម្ចី។

ការគាំទ្រយន្តការគោលនយោបាយស្ដីអំពីបរិស្ថាន សង្គម និងអភិបាលកិច្ច របស់ធនាគារ មេយប៊ែង ដើម្បីផ្សព្វផ្សាយពីយន្តការអាជីវកម្មប្រកបដោយចីរភាព

ពួកយើង នៅតែបន្តការកែសម្រួលលើគោលនយោបាយស្ដីអំពីបរិស្ថាន សង្គម និងអភិបាលកិច្ច តាមរយៈគោលនយោបាយ របស់សម្ព័ន្ធធនាគារ មេយប៊ែង។ ពួកយើង ក៏នៅតែបន្តការចូលរួមជាមួយភាគីពាក់ព័ន្ធ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់ នៃគោលនយោបាយស្ដីអំពីបរិស្ថាន សង្គម និងអភិបាលកិច្ច និងឱកាសដែលកើតចេញ អំពីសកម្មភាពផ្ដល់កម្ចីនានារបស់យើង។

សមិទ្ធិផល៖

ពួកយើង ប្រើប្រាស់នូវលក្ខណៈវិនិច្ឆ័យរបស់សម្ព័ន្ធធនាគារ មេយប៊ែង លើកម្រិតហានិភ័យ ដែលអាចទទួលយកបាន ពីការគ្រប់គ្រងព្រៃឈើ និងការកាប់ឈើ ដើម្បីធ្វើជាស្តង់ដារសម្រាប់វាយតម្លៃលើចង្វាក់ផលិតកម្មនៃវិស័យគ្រប់គ្រងព្រៃឈើទាំងមូល។ ក្រុមត្រួតពិនិត្យលើវិស័យពាក់ព័ន្ធនឹងគោលនយោបាយស្ដីអំពីបរិស្ថាន សង្គម និងអភិបាលកិច្ចរបស់សម្ព័ន្ធធនាគារ មេយប៊ែង បាននឹងកំពុងធ្វើការស្វែងយល់បន្ថែមអំពីឧស្សាហកម្មផ្សេងៗទៀត ដូចជា ឧស្សាហកម្មថាមពល ប្រេងកាត និងឧស្ម័ន វិស័យសំណង់ និងអចលនទ្រព្យ។

ទស្សនៈវិស័យ និងអាទិភាពសម្រាប់ឆ្នាំ២០២១

ពួកយើង រំពឹងថាបរិបទប្រតិបត្តិការ និងសេដ្ឋកិច្ចនឹងនៅតែមិនមានភាពនឹងនរ ដោយសារតែផលប៉ះពាល់នៃការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ លើគំរូអាជីវកម្ម និងការរំខានខ្សែសង្វាក់ផលិតកម្មរបស់អតិថិជនរបស់ពួកយើង។ ទាក់ទិននឹងបញ្ហានេះ អាទិភាពសំខាន់ៗរបស់ពួកយើង ក្នុងឆ្នាំ២០២១រួមមាន៖

១. ជំរុញសកម្មភាពគ្រប់គ្រងហានិភ័យដែលអាចធ្វើបាន ដោយផ្ដល់នូវអនុសាសន៍ និងផែនការសមស្រប ដើម្បីគ្រប់គ្រងគុណភាពទ្រព្យសកម្ម និងកំណត់ប្រភពចំណូលថ្មី ដើម្បីបង្កើតឥណទានដែលប្រកបដោយគុណភាព ខណៈពេលដែលគ្រប់គ្រងទ្រព្យសកម្ម ដែលមានស្រាប់។ ការគ្រប់គ្រងនេះ បានរួមបញ្ចូលនូវការពឹងផ្អែកលើឧបករណ៍គ្រប់គ្រងអនុបាតសោធនភាព និងហានិភ័យ រួមជាមួយនឹងការលើកកម្ពស់ការស្តុកទិន្នន័យរបស់ពួកយើង ដើម្បីធ្វើស្វ័យប្រតិកម្មលើប្រព័ន្ធរបាយការណ៍។

២. ដាក់ឲ្យប្រើប្រាស់កម្មវិធីយុទ្ធសាស្ត្រគ្រប់គ្រងទិន្នន័យ ដើម្បីពង្រឹងការគ្រប់គ្រងទិន្នន័យ និងធានាការប្រើប្រាស់ទិន្នន័យ ដែលទាក់ទងទៅនឹងហានីភ័យ ប្រកបដោយគុណភាពខ្ពស់ ។

៣. ដាក់ឲ្យប្រើប្រាស់នូវវិធីសាស្ត្រគ្រប់គ្រងហានិភ័យយ៉ាងសកម្មបន្ថែមទៀត និងបង្កប់នូវការយល់ដឹងប្រកបដោយចីរភាពទៅក្នុងយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យរបស់ពួកយើង ក៏ដូចជាយុទ្ធសាស្ត្រ អាជីវកម្មផ្សេងៗទៀត។

ឆ្ពោះទៅ
ធនធានមនុស្ស

ខណៈដែលពួកយើងបន្តការប្តេជ្ញាចិត្តក្នុង "ការអភិវឌ្ឍធនធានមនុស្សលំដាប់ពិភពលោក ដើម្បីទទួលបានសមិទ្ធិផលស្តង់ដារលំដាប់ពិភពលោក" តាមរយៈយុទ្ធសាស្ត្រ និងគោលដៅផ្លាស់ប្តូររបស់នាយកដ្ឋានធនធានមនុស្សរបស់ពួកយើង ការរីករាលដាលនៃជំងឺកូវីដ១៩ បានបំផុសនូវការប្តេជ្ញាចិត្តជាថ្មីលើកិច្ចការអាទិភាព និងជំរុញនូវការផ្តួចផ្តើមផ្សេងៗជាច្រើន ដើម្បីធានាថា និយោជិត និងស្ថាប័នរបស់ពួកយើង នៅតែទទួលបានជោគជ័យក្នុងបរិបទគន្លងថ្មី។ ពួកយើង តែងតែផ្តោតសំខាន់លើសុវត្ថិភាព ការយកចិត្តទុកដាក់រួមទាំងបរិយាកាសកន្លែងធ្វើការ ការរៀបចំឡើងនូវដំណោះស្រាយផ្សេងៗ ដើម្បីអាចឲ្យនិយោជិតរបស់ពួកយើងជំនះបានក្នុងគ្រាដ៏លំបាក និងមិនទៀងទាត់នេះ។ ហើយអ្វីដែលសំខាន់ គឺពួកយើងនៅតែរក្សាបាននូវទំនាក់ទំនង ការចូលរួម និងផលិតភាពដ៏ល្អពីនិយោជិតរបស់ពួកយើង ឆ្លើយតបនឹងសមិទ្ធិផលដែលរំពឹងទុកដើម្បីចីរភាពអាជីវកម្ម។

សម្ព័ន្ធ ធនាគារ មេយ៉ូបែង ត្រូវបានដាក់បានបញ្ចូលក្នុងបញ្ជីក្រុមហ៊ុនសមិទ្ធិផលឈានមុខគេនៃ Willis Towers Watson (WTW) 2020 តាមគំរូ បទដ្ឋានអន្តរជាតិជាលើកទី៥ តាំងពីឆ្នាំ២០១០ មកម្ល៉េះ។ នេះ ជាការទទួលស្គាល់ដ៏គួរឲ្យសាទរជាលក្ខណៈអន្តរជាតិ ដែលបង្ហាញឲ្យឃើញថា ធនាគារ មេយ៉ូបែង គឺជាស្ថាប័ន ដែលសម្រេចបានលទ្ធផលហិរញ្ញវត្ថុឈានមុខ រួមផ្សំជាមួយនឹងការប្តេជ្ញាចិត្តដ៏ភ្លៀវភ្លា និងការផ្តោតសំខាន់ទៅលើ បទពិសោធន៍របស់និយោជិត។

គោលដៅផ្លាស់ប្តូរធនធានមនុស្សចំនួន៦ចំនុច នៃនាយកដ្ឋានធនធានមនុស្ស

- កសាងភាពជាអ្នកដឹកនាំដ៏អស្ចារ្យ និងបណ្តុះបណ្តាលនិយោជិត
- ទទួលបានកម្រិតផលិតភាពលំដាប់ថ្នាក់ពិភពលោក
- កសាងកម្លាំងពលកម្មដែលមានជំនាញវិជ្ជាជីវៈផ្នែកបច្ចេកវិទ្យា ភាពច្នៃប្រឌិត និងរហ័សរហួន
- កសាងភាពជាអ្នកដឹកនាំក្នុងវិស័យសេវាហិរញ្ញវត្ថុ
- បង្កើតក្រមសីលធម៌ជាសកល
- បង្កើតបរិយាកាសការងារដែលមានការយកចិត្តទុកដាក់ អត្ថន័យ និងភាពទាក់ទាញ

យុទ្ធសាស្ត្រចម្បងទាំង៦ចំនុច

- កន្លែងការងារសម្រាប់ពេលអនាគត
- ប្រសិទ្ធភាពការងារនាពេលអនាគត
- អ្នកដឹកនាំក្នុងយុគសម័យឌីជីថល
- ប្រសិទ្ធភាពនៃការប្រើប្រាស់ទិន្នន័យនិយោជិត
- សុខភាព និងសុខមាលភាពនៅកន្លែងធ្វើការ
- ការបង្កើនផលិតភាពដ៏ខ្ពស់

ចំណុចផ្តោតសំខាន់ៗសម្រាប់ឆ្នាំ២០២០

ការអនុញ្ញាតឲ្យធ្វើការពីផ្ទះ (WFH) ជាមួយនឹង ការរៀបចំការងារដែលមានភាពបត់បែន (FWA)

យុទ្ធសាស្ត្រចម្បង

ចាប់តាំងពីជំងឺរាតត្បាតកូវីដ១៩ ចាប់ផ្តើមរាតត្បាតក្នុងប្រទេសកម្ពុជានៅដើមឆ្នាំ២០២០មក ពួកយើង ចាប់ផ្តើមអនុវត្តយុទ្ធសាស្ត្រ ការបែងចែកកន្លែងការងារ និងប្រតិបត្តិការ (LSO) និងសម្រួលការអនុវត្តការធ្វើការពីផ្ទះ (WFH) សម្រាប់និយោជិតមុខងារផ្សេងៗ ដែលមិនធ្វើការដោយពឹងផ្អែកលើប្រព័ន្ធស្នូល (NCBF) លើកលែង តែនិយោជិតមុខងារ ដែលចាំបាច់ត្រូវធ្វើការក្នុងការិយាល័យ ដើម្បីសុវត្ថិភាព និងសុខុមាលភាពរបស់និយោជិត អតិថិជន និងសហគមន៍របស់ពួកយើង សមស្របនឹងការគ្រប់គ្រងនិរន្តរភាពនៃអាជីវកម្ម។ កត្តានេះ បានជំរុញដល់ការអនុវត្តគោលនយោបាយការធ្វើការងារ មានភាពបត់បែនរួមមាន គោលនយោបាយ រៀបចំការងារមានភាពបត់បែន (FWA) ដែលមានស្រាប់ ដែលអនុញ្ញាតិឲ្យនិយោជិតរបស់ពួកយើងបន្តសម្រេចការងាររបស់ខ្លួនពីផ្ទះរបស់ពួកគេ។

ពួកយើង បានចាប់ផ្តើមតាមដានចំនួននិយោជិតធ្វើការពីផ្ទះ តាំងពីការផ្តើមនៃការរាតត្បាតនេះមកម្ល៉េះ ហើយក៏បន្តអនុវត្តរហូតមកដល់បច្ចុប្បន្ន ដែល នេះជាផ្នែកមួយជំរុញដល់ការទទួលយកផ្នត់គំនិតធ្វើការពីចម្ងាយ (Remote-First Mentality) ស្របនឹងតុល្យភាពនៃតម្រូវការប្រតិបត្តិការ អាជីវកម្មរបស់ពួកយើង។ ជាមួយគ្នានេះដែរ ពួកយើងត្រូវប្រាកដថា នីតិវិធីប្រតិបត្តិតាមស្តង់ដារ (SOPs) គម្លាតសង្គមត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន សម្រាប់និយោជិតធ្វើការក្នុងការិយាល័យ។

ជាងនេះទៅទៀត ពួកយើងក៏បានដាក់ចេញនូវ គោលនយោបាយធ្វើការចល័ត MWA ដោយកំណត់និយោជិតមានមុខងារ/តួនាទីអាចធ្វើការពីចម្ងាយ អនុញ្ញាតិឲ្យនិយោជិតធ្វើការពីផ្ទះ ធ្វើការក្នុងការិយាល័យ និងបែងចែកក្រុមការងារទៅតាមទីតាំងផ្សេងៗ។ បន្តពង្រឹងភាពធន់ និងលទ្ធផលរបស់ស្ថាប័ន ស្របនឹងការពារសុវត្ថិភាព និងសុខុមាលភាពរបស់និយោជិត។ គោលនយោបាយធ្វើការចល័ត MWA គឺជាជំហានមួយឆ្ពោះទៅកាន់តម្រូវការចម្រុះ របស់និយោជិតពួកយើង ដូចដែលពួកយើងទទួលយកកន្លែងការងារសម្រាប់ពេលអនាគត ដោយរក្សាបាននូវការផ្តល់ជូនគុណភាពសេវាកម្មល្អជូនដល់អតិថិជន និងប្រសិទ្ធភាពប្រតិបត្តិការ។

ការបែងចែកកន្លែងការងារ និងប្រតិបត្តិការ LSO ត្រូវបានអនុវត្តទាំងនិយោជិតមុខងារចាំបាច់សម្រាប់ប្រតិបត្តិការអាជីវកម្ម (CBF) និងនិយោជិតមុខងារមិនចាំបាច់សម្រាប់ប្រតិបត្តិការអាជីវកម្ម (NCBF) បើទោះបីជាភាពចាំបាច់នេះ រួមបញ្ចូល គណៈគ្រប់គ្រងសំខាន់ៗ និងនិយោជិតមុខងារ ដែលត្រូវធ្វើការដោយផ្ទាល់ដល់ការផ្តល់ជូនគុណភាពសេវាកម្ម និងផ្នែកប្រតិបត្តិការចម្បងរបស់ធនាគារ។ គួររំលឹកដែរថា អត្រានិយោជិត ធ្វើការពីផ្ទះទទួលមានចន្លោះពី ១0% ទៅ ២0% ក្នុងឆ្នាំ២0២0។

ការចូលរួម និងការគ្រប់គ្រងជាច្រើនទម្រង់ ត្រូវបានបង្កើតឡើងដើម្បីទ្រទ្រង់និយោជិតចល័តរបស់ពួកយើង ហើយក៏ដើម្បីឲ្យប្រាកដថា ពួកគេនៅតែបន្ត ភ្ជាប់ទំនាក់ទំនង។ និយោជិតទាំងនោះ ក៏ត្រូវបានកំណត់នូវការរំពឹងទុក និងលទ្ធផលការងារដោយមានការព្រមព្រៀងគ្នា ហើយយ៉ាងហោចណាស់ ពួកគេត្រូវជួបជាមួយអ្នកគ្រប់គ្រងរបស់ពួកគេដោយផ្ទាល់ឬតាមរយៈប្រព័ន្ធអនឡាញ ក្នុងមួយសប្តាហ៍ម្តង ដើម្បីពិភាក្សាពីលទ្ធផលការងារ បន្ទាប់មក ត្រូវកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងលទ្ធផលការងារនិយោជិត (myHR2u Conversation Log)។

ចំណុចផ្ដោតសំខាន់ៗសម្រាប់ឆ្នាំ២០២០ (បន្ត)

ការអនុញ្ញាតឲ្យធ្វើការពីផ្ទះ (WFH) ជាមួយនឹង ការរៀបចំការងារដែលមានភាពបត់បែន (FWA) (បន្ត)

យុទ្ធសាស្ត្រចម្បង

ដោយសារតែនិយោជិតទទួលយកការធ្វើការបែបគន្លងថ្មី ហេតុនេះ ការគ្រប់គ្រង តាមដាន និងវាយតម្លៃលទ្ធផលការងាររបស់ពួកគេឲ្យកាន់តែ មានប្រសិទ្ធភាពខ្ពស់រឹតតែសំខាន់។ ដូច្នេះហើយ ធនាគារលើកទឹកចិត្តដល់និយោជិត និងអ្នកគ្រប់គ្រងផ្ទាល់ត្រូវមានទំនាក់ទំនងគ្នាជា ការសន្ទនាគ្នាញឹកញាប់ សម្រាប់មតិយោបល់ និងការពង្រឹងបន្ថែមភ្លាមៗ។ ការសន្ទនាទាំងនេះ ត្រូវកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងលទ្ធផលការងារនិយោជិត Conversation Log ភ្លាមៗ ដើម្បីត្រួតពិនិត្យ និងតាមដាន ជំរុញដល់ភាពជាម្ចាស់នៃការគ្រប់គ្រងលទ្ធផលការងារ រវាងនិយោជិត និងអ្នកគ្រប់គ្រងផ្ទាល់កាន់តែប្រសើរ។ ក្នុងឆ្នាំ ២០២០ លើសពី ២០០ សន្ទនារវាងនិយោជិត និងអ្នកគ្រប់គ្រងផ្ទាល់ ត្រូវបានកត់ត្រា។

ពួកយើងបានផ្ដើមអនុវត្តកម្មវិធី ភាពរហ័សរហួននៃការធ្វើការនៅផ្ទះ Agility@Home ដើម្បីសម្រួលដល់និយោជិតចល័ត ដោយផ្ដល់ជាដំបូន្មាន និងការអនុវត្តល្អៗទាក់ទងនឹងកត្តាជំរុញការសហការ និងផលិតភាព ជំនាញគ្រប់គ្រងពេលវេលា និងយុទ្ធសាស្ត្រទំនាក់ទំនងជាក្រុម ដើម្បីធ្វើឲ្យក្រុមធ្វើការងារចល័តសហការគ្នាកាន់តែប្រសើរឡើង។

ការរក្សាសុវត្ថិភាព និងការរស់នៅក្នុងបរិបទគន្លងថ្មីជាមួយកម្មវិធីផ្ដួចផ្ដើមនានាស្ដីអំពីសុខុមាលភាព និងសុខភាព

យុទ្ធសាស្ត្រចម្បង

ជាមួយនឹងបរិបទគន្លងថ្មី ដែលតម្រូវឲ្យនិយោជិតរក្សាគម្លាតសង្គម និងធ្វើការពីចម្ងាយ ការគាំទ្រដល់ផ្នែកសុខុមាលភាពរបស់ពួកគេ រឹតតែមានសារៈសំខាន់ និងចាំបាច់។ ដូច្នេះហើយ ពួកយើង បានបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់សុខភាពផ្លូវចិត្ត ផ្លូវកាយ ផ្លូវអារម្មណ៍ និងការធ្វើលំហាត់ប្រាណដោយដាក់បញ្ចូលក្នុងគោលនយោបាយរបស់ពួកយើង។ គំនិតផ្ដួចផ្ដើមទាំងនេះ រួមមាន៖

- **លើកកម្ពស់វិធានការត្រឹមត្រូវដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ១៩**

  ពួកយើង បានដាក់ចេញនូវ**វិធានសុខភាព និងសុវត្ថិភាព** និង**គោលការណ៍ស្ដង់ដារប្រតិបត្តិយ៉ាងតឹងរឹង ដើម្បីទប់ស្កាត់ហានិភ័យ ដែលបង្កដោយវីរុសកូវីដ១៩** ក៏ដូចជាលើកកម្ពស់ការរស់នៅ និងការធ្វើការងារប្រកបដោយសុវត្ថិភាពខ្ពស់ និងកាន់តែមានន័យ។ បន្ថែមពីនេះទៅទៀត ពួកយើងក៏បានអនុវត្ត ការសច្ចា My Pledge ដើម្បីលើកកម្ពស់ឥរិយាបទសុវត្ថិភាព ហើយក៏ជាការកំណត់នូវគំរូទង្វើត្រឹមត្រូវ សម្រាប់និយោជិតធនាគារ មេយប៊ែង និងសហគមន៍របស់ពួកយើង។ ពួកយើងបានចាប់ផ្ដើមអនុវត្តការសច្ចា #ខ្ញុំនឹងរក្សាសុវត្ថិភាព **(#iWillStaySafe)** នៅខែមេសាឆ្នាំ ២០២០ និង #ការសច្ចារបស់និយោជិតធនាគារមេយប៊ែង **(#MaybankersPledge)** នៅខែកញ្ញា ឆ្នាំ២០២០។ លើសពីនេះទៀត ពួកយើងនៅតែបន្តផ្ដល់ព័ត៌មាន និងដំបូន្មានដល់និយោជិត អំពីស្ថានភាពជំងឺកូវីដ១៩ ហើយបន្តគាំទ្រពួកគេ ដែលអាចឲ្យពួកគេនៅតែទទួលបាននូវសុវត្ថិភាព ផលិតភាពការងារ និងការចូលរួម ក៏ដូចជាសមយុទ្ធនៃការរស់នៅ និងការធ្វើការងារក្នុងកំឡុងពេលនៃការរីករាលដាលនៃវីរុសកូវីដ១៩នេះផងដែរ។

- **ការរក្សាបាននូវការចូលរួម ការលើកទឹកចិត្ត និងសុខភាពល្អដល់និយោជិត**

  ការផ្សព្វផ្សាយកម្មវិធីផ្សេងៗ ដូចជា **ការប្រកួតប្រជែង #និយោជិតធនាគារមេយប៊ែងធ្វើការពីផ្ទះ (#MaybankersWFH Challenge) #ការទទួលយកការរស់នៅបែបគន្លងថ្មី (#AcingtheNewNormal Challenge)** កម្មវិធី**ហាត់ប្រាណតាមប្រព័ន្ធអនឡាញ និងការជជែកតាមប្រព័ន្ធ Webinars** ដែលត្រូវបានរៀបចំដោយ សម្ព័ន្ធធនាគារ មេយប៊ែង ជួយឲ្យនិយោជិតទទួលបានចំណេះដឹង និងគន្លឹះក្នុងការថែរក្សាសុខភាពផ្លូវចិត្ត និងរាងកាយល្អ និងលើកទឹកចិត្តពួកគាត់ធ្វើជាម្ចាស់លើសុខុមាលភាពរបស់ខ្លួន។

- **ការផ្ដល់ជំនួយដល់និយោជិត**

  ក្នុងខែកុម្ភៈ ឆ្នាំ២០២០ **ក្រុមការងារសង្គ្រោះបន្ទាន់សម្រាប់និយោជិត** (GHC SES) ត្រូវបានបង្កើតឡើង ហើយប្រតិបត្តិការ ២៤/៧ ជាមជ្ឈមណ្ឌលទំនាក់ទំនងតែមួយគត់ ទ្រទ្រង់និយោជិតទូទាំងសម្ព័ន្ធធនាគារ មេយប៊ែង ទាក់ទងនឹងវីរុសកូវីដ១៩។ ចំពោះធនាគារ មេយប៊ែង ក៏បានបង្កើតមជ្ឈមណ្ឌលទំនាក់ទំនងដូចគ្នា គ្រប់គ្រងដោយនាយកដ្ឋានធនធានមនុស្ស (MCP HC) និងក្រុមការងារគ្រប់គ្រងចីរភាពអាជីវកម្ម (BCM) ដែលអនុញ្ញាតិឲ្យនិយោជិតទាំងអស់ អាចទំនាក់ទំនងសម្រាប់ជំនួយផ្សេងៗ។ បន្ថែមពីនេះទៅទៀត ពួកយើងក៏បានដាក់ឲ្យដំណើរការនូវ**ខ្សែទូរស័ព្ទបន្ទាន់**សម្រាប់និយោជិតទូទាំងសម្ព័ន្ធធនាគារ មេយប៊ែង អាចទាក់ទងសម្រាប់ជំនួយផ្នែកស្មារតីដល់និយោជិត និងក្រុមគ្រួសាររបស់ពួកគាត់ តាមរយៈក្រុមការងារ GHC SES / ក្រុម MCP HC / BCM របស់ពួកយើង។

ឆាយកដ្ឋានធនធានមនុស្ស

ចំណុចផ្តោតសំខាន់ៗសម្រាប់ឆ្នាំ២០២០ (បន្ត)

ការយកចិត្តទុកដាក់ និងការអរគុណ តាមរយៈការចូលរួមពីថ្នាក់ដឹកនាំ

យុទ្ធសាស្ត្រចម្បង

ការទំនាក់ទំនង និងការចូលរួមតាមមធ្យោបាយផ្សេងៗ ត្រូវបានធ្វើឡើងដើម្បីអាចឲ្យថ្នាក់ដឹកនាំភ្ជាប់ទំនាក់ទំនងជាមួយនិយោជិតបាន។ មធ្យោបាយទំនាក់ទំនងអនឡាញខាងក្រោមនេះ អនុញ្ញាតិឲ្យគណៈកម្មាធិការប្រតិបត្តិភ្ជាប់ទំនាក់ទំនងជាមួយនិយោជិត ដើម្បីជានាបាននូវការចូលរួម និងការលើកកម្ពស់សុខុមាលភាពរបស់និយោជិត មានដូចជា៖

- កិច្ចប្រជុំគណៈគ្រប់គ្រង (Management Offsite) ជារៀងរាល់ពាក់កណ្តាលឆ្នាំ ចូលរួមដោយគណៈគ្រប់គ្រងពីការិយាល័យកណ្តាល មុខងារសាជីវកម្ម និងប្រធានសាខាទាំងអស់ ជាកិច្ចប្រជុំអំពីយុទ្ធសាស្ត្រ និងត្រួតពិនិត្យសមិទ្ធិផលឆ្លុះបញ្ចាំងពីសមិទ្ធិផលរបស់ស្ថាប័នទាំងមូល និងពិភាក្សាអំពីគម្រោងប្រតិបត្តិជាយុទ្ធសាស្ត្រ ក៏ដូចជាពង្រឹងចំណងមេត្រីភាពក្នុងចំណោមថ្នាក់ដឹកនាំ។
- កិច្ចប្រជុំនិយោជិត (Staff Townhall) ជារៀងរាល់ពាក់កណ្តាលឆ្នាំ បានផ្តល់ឱកាសដល់និយោជិតយល់ដឹងពីសមិទ្ធិផល គំនិតផ្តួចផ្តើម និងផែនការយុទ្ធសាស្ត្ររបស់ស្ថាប័ន ជាពិសេសទាក់ទងនឹងដំណោះស្រាយបញ្ហានានាទាក់ទងនឹងជំងឺកូវីដ១៩ ដែលអនុញ្ញាតឲ្យនិយោជិតស្វែងរកភាពច្បាស់លាស់នៅនឹងកន្លែងពីសម្ព័ន្ធធនាគារ និងគណៈកម្មាធិការប្រតិបត្តិរបស់ធនាគារ មេយវ៉ៃង នៅកម្ពុជា។

កម្មវិធីប្រគល់រង្វាន់ប្រចាំឆ្នាំ២០២០របស់ធនាគារ មេយវ៉ៃង នៅកម្ពុជាតាម Zoom

- កម្មវិធីប្រគល់រង្វាន់ប្រចាំឆ្នាំ ត្រូវបានប្រារព្ធឡើងក្នុងគោលបំណងទទួលស្គាល់ ផ្តល់រង្វាន់ និងអបអរសាទរដល់និយោជិតឆ្នើម ក៏ដូចជាជំរុញឲ្យមានការផ្សារភ្ជាប់ និងការលើកទឹកចិត្តកាន់តែខ្លាំងឡើងចំពោះនិយោជិតទាំងអស់។
- កិច្ចពិភាក្សាជាមួយ C-Suite (CWC) និងកម្មវិធី Group EXCO Mentoring សម្រាប់និយោជិតសំខាន់ៗ ត្រូវបានធ្វើឡើង ដែលអនុញ្ញាតិឲ្យនិយោជិតសំខាន់ៗ បន្តទទួលបានការសន្ទនាដ៏មានឥទ្ធិពលជាមួយគណៈកម្មាធិការប្រតិបត្តិនៃសម្ព័ន្ធធនាគារ (Group EXCO) និងដើម្បីពង្រឹងសមត្ថភាពផ្ទាល់ខ្លួន និងវិជ្ជាជីវៈឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ការកសាង និងអភិវឌ្ឍសមត្ថភាពនិយោជិតក្នុងបរិបទគន្លងថ្មី តាមរយៈកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍនិយោជិត

យុទ្ធសាស្ត្រចម្បង

នៅដើមខែមីនា ឆ្នាំ២០២០ កម្មវិធី #LearningNeverStops ត្រូវបានដាក់បញ្ចូលឲ្យដំណើរការនៅរៀងរាល់សប្តាហ៍ ដើម្បីជួយដល់និយោជិតទាំងអស់ រក្សាការផ្តោតលើភាពវិជ្ជមាន និងផលិតភាព បន្ថែមលើចីរភាពនៃការពង្រឹងជំនាញ និងសមត្ថភាពរបស់និយោជិត ខណៈដែលអនុញ្ញាតិឲ្យពួកគេអាចបន្តការរៀនសូត្រពីគ្រប់ទីកន្លែង។ វាគឺជាប្រព័ន្ធបណ្តុះបណ្តាលចល័ត ដែលអាចឲ្យនិយោជិតទាំងអស់ចូលទៅកាន់កម្មវិធីអប់រំដ៏ទូលំទូលាយ និងសំបូរបែប ដែលផ្តល់ជូនដោយអ្នកជំនាញផ្ទៃក្នុង និងអ្នកជំនាញក្នុងវិស័យពាក់ព័ន្ធ។

ពួកយើង បានបញ្ចូលនូវកម្មវិធីកម្សាន្តមួយចំនួន ដូចជា ពិន្ទុសិក្សា និងតារាងលទ្ធផលបណ្តុះបណ្តាល ដើម្បីជំរុញឲ្យមានការប្រកួតប្រជែងក្នុងការរៀនសូត្រ។ និយោជិតទាំងអស់ ត្រូវបានលើកទឹកចិត្តឲ្យបញ្ចូលសកម្មភាពសិក្សារបស់ខ្លួន បំលែងជា ពិន្ទុសិក្សា ដើម្បីតាមដានជំនាញ និងចំណេះដឹងដែលពួកគេបានទទួល។ ពិន្ទុសិក្សា ក៏ត្រូវបានប្រើប្រាស់សម្រាប់វាស់វែងពីវឌ្ឍនភាព និងលទ្ធផលសិក្សារបស់ពួកគេផងដែរ។

សូម្បីតែនៅក្នុងគ្រាលំបាកក៏ដោយ និយោជិតទាំងអស់ បន្តបង្ហាញអំពីឆន្ទៈ និងភាពបត់បែននៅក្នុងការរៀនសូត្រលើជំនាញឌីជីថលថ្មីៗ តាមរយៈកម្មវិធី FutureReady (FR) ដែលជួយទ្រទ្រង់គោលបំណងរបស់ធនាគារ ក្នុងការក្លាយទៅជាជម្រើសធនាគារឌីជីថលដ៏ល្អបំផុត (Digital Bank of Choice)។ ក្នុងឆ្នាំទីបីនេះ កម្មវិធីត្រៀមខ្លួនសម្រាប់អនាគត (FR) ផ្តោតទៅលើសមិទ្ធិផលអាជីវកម្មសម្រេចបានតាមរយៈជំនាញឌីជីថល។

- យោងតាមទិន្នន័យទទួលបានពីកម្មវិធីអភិវឌ្ឍជំនាញវិភាគក្នុងឆ្នាំ ២០១៩ ពួកយើង បានសហការជាមួយនឹងសាលាធុរកិច្ចល្បីៗក្នុងពិភពលោក ក្នុងការអភិវឌ្ឍកម្មវិធីវិភាគអនឡាញ ដែលមានឈ្មោះថា AI Learning Hub សម្រាប់ធនាគារ។
- កម្មវិធីវិភាគថ្មីៗជាច្រើន ដូចជា R Programming, Structured Query Language (SQL) និង Python Programming ត្រូវបានបង្កើតឡើង និងបង្រៀនតាមប្រព័ន្ធអនឡាញ ដើម្បីជំរុញឲ្យនិយោជិតអាចអនុវត្តការងារប្រចាំថ្ងៃកាន់តែមានប្រសិទ្ធភាព និងផលិតភាពខ្ពស់។
- ក្នុងឆ្នាំ២០២០នេះ ពួកយើងក៏បានដាក់បញ្ចូលនូវកម្មវិធីការធ្វើទីផ្សារឌីជីថលរបស់ពួកយើង ដើម្បីបង្កើនការលក់ ពង្រឹងទំនាក់ទំនងជាមួយអតិថិជន និងកសាងទំនុកចិត្តកាន់តែល្អប្រសើរផងដែរ។

នាយកដ្ឋានធនធានមនុស្ស

ចំណុចផ្ដោតសំខាន់ៗសម្រាប់ឆ្នាំ២០២០ (បន្ត)

ការបង្កើនភាពចម្រុះ និងការដាក់បញ្ចូល

យុទ្ធសាស្ត្រចម្បង

ការអភិវឌ្ឍជាក់ស្ដែង បានទទួលជោគជ័យចាប់តាំងពីសម្ព័ន្ធធនាគារ មេយប៊ែង បានចាប់ផ្ដើមដំណើរផ្លាស់ប្ដូររបស់ពួកយើងក្នុងឆ្នាំ២០០៩ ទាក់ទិននឹង ភាពចម្រុះ និងការដាក់បញ្ចូល។ តាំងពីពេលនោះមក ពួកយើងបាន និងកំពុងធានានូវការតាមដានប្រចាំខែអំពី ភាពចម្រុះ និងយេនឌ័រ តាមរយៈបណ្ដុំទិន្នន័យធនធានមនុស្ស (Human Capital Dashboard) របស់ពួកយើង ដើម្បីពិនិត្យ និងដាក់ចេញសកម្មភាពអនុវត្តន៍ផ្អែកលើទិន្នន័យជាក់ស្ដែងដោះស្រាយនូវអតុល្យភាពនានា។ តាមរយៈកម្មវិធីការបង្កើនភាពចម្រុះ និងការដាក់បញ្ចូលរបស់ សម្ព័ន្ធធនាគារ Group Inclusiveness and Diversity Agenda (GIDA) Framework ដែលបានផ្ដើមអនុវត្តន៍ក្នុងឆ្នាំ២០១៤ កិច្ចខិតខំប្រឹងប្រែងមួយនេះត្រូវបានពន្លឿន ហើយបង្ហាញជាលទ្ធផលតាមរយៈការវាស់វែង ដែលបានបង្ហាញនៅលើប័ណ្ណគ្រប់គ្រងលទ្ធផលការងាររបស់គណៈកម្មាធិការប្រតិបត្តិ(EXCO Scorecard)។

ពួកយើង ក៏ធានាផងដែរថា ការអនុវត្តការងារគ្រប់គ្រងទេពកោសល្យនិយោជិតរបស់ពួកយើង គឺមានការដាក់បញ្ចូល ហើយកាន់តែឆ្លើយតបនឹងយុទ្ធសាស្ត្រគ្រប់គ្រងទេពកោសល្យនិយោជិត និងយុទ្ធសាស្ត្រអាជីវកម្ម ដែលនឹងជួយធនាគារសម្រេចនូវគោលដៅអាជីវកម្មរបស់ពួកយើង ព្រមទាំងតាមដានយ៉ាងល្អិតល្អន់តាមរយៈសូចនាករទេពកោសល្យចម្បងៗ ដែលរួមមានជាអាទិ៍ ការសម្រេចបាននូវការបន្តមុខតំណែងសំខាន់ៗចំពោះគណៈគ្រប់គ្រងលើមុខងារបេសកកម្ម និងប្រតិបត្តិការ អត្រាបំពេញមុខតំណែងទំនេរផ្ទៃក្នុងសម្រាប់មុខតំណែងអ្នកគ្រប់គ្រង និយោជិតដែលអាចបន្តមុខតំណែងបានភ្លាមៗ អត្រាស្ត្រីនៅក្នុងមុខតំណែងថ្នាក់គ្រប់គ្រង។ល។

ទស្សនវិស័យ និងអាទិភាពសម្រាប់ឆ្នាំ ២០២១

ដើម្បីជួយដល់ធនាគារក្នុងការសម្រេចគោលដៅយុទ្ធសាស្ត្រ M25 របស់ពួកយើង អាទិភាពសម្រាប់ឆ្នាំ២០២១ របស់នាយកដ្ឋានធនធានមនុស្ស នឹងផ្ដោតទៅលើការអភិវឌ្ឍទេពកោសល្យនិយោជិតតាមរយៈការអនុវត្តកន្លែងធ្វើការល្អ និងហេដ្ឋារចនាសម្ព័ន្ធលំដាប់ពិភពលោក។

ពួកយើង ប្ដេជ្ញាផ្ដល់នូវកន្លែងធ្វើការ ដែលធានាអនាគតភាពសម្រាប់និយោជិត សមស្របនឹងការធានាលើការយកចិត្តទុកដាក់អំពីបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ត្រូវបានដាក់បញ្ចូល ទៅក្នុងគ្រប់គំនិតផ្ដួចផ្ដើមទាំងអស់របស់ពួកយើង ស្របទៅតាមបេសកកម្មរបស់ធនាគារ មេយប៊ែង ក្នុងការផ្ដល់ជូននូវសេវាកម្មហិរញ្ញវត្ថុ ប្រកបដោយអរិយភាព និងដឹកនាំដោយតម្លៃស្នូល (Key Thrusts) របស់ពួកយើង ដូចខាងក្រោម៖

- កន្លែងធ្វើការសម្រាប់ពេលអនាគត - ការប្រកាន់ខ្ជាប់នូវវិធីសាស្ត្រធ្វើការងារដែលកាន់តែមានប្រសិទ្ធភាពខ្ពស់ រួមបញ្ចូលទាំង ការកែសម្រួល និងការរៀបចំឡើងវិញនូវអាជីវកម្ម និងរចនាសម្ព័ន្ធ។
- ប្រសិទ្ធភាពការងារនាពេលអនាគត - ពន្លឿនការអភិវឌ្ឍ និងផលិតភាពនៃនិយោជិតរបស់ពួកយើង ដូចជាការបង្កើនកម្មវិធីបណ្ដុះបណ្ដាល និងកម្មវិធីសុខុមាលភាពនិយោជិត។
- ហេដ្ឋារចនាសម្ព័ន្ធនៃអនាគតភាព - ផ្ដល់នូវវេទិកា ដំណើរការ និងឧបករណ៍ប្រកបដោយការច្នៃប្រឌិតខ្ពស់ ដើម្បីធានានិយោជិតទាំងអស់ត្រូវទ្រទ្រង់ដោយហេដ្ឋារចនាសម្ព័ន្ធដ៏ត្រឹមត្រូវ ដែលអាចឲ្យពួកគេសម្រេចបានលទ្ធផលកាន់តែធំធេង។

ពួកយើង នឹងបន្តពន្លឿនការត្រៀមលក្ខណៈរបស់ពួកយើង ដែលអាចជំរុញឲ្យនិយោជិតកាន់តែច្រើន ទទួលបានវិធីសាស្ត្រក្នុងការធ្វើការងារនានា តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាទំនើបៗ។ កន្លែងធ្វើការតាមបែបគន្លងថ្មី នៅក្នុងចក្ខុវិស័យសម្រាប់ធនាគារ មេយប៊ែង នឹងត្រូវបង្កើតឡើងដោយការរួមបញ្ចូលគ្នាពី និយោជិតធ្វើការក្នុងទីតាំងផ្ទាល់ និយោជិតបែងចែកទៅតាមទីតាំង និងនិយោជិតធ្វើការពីផ្ទះ។

លោក អាឆតូនី ប្រេនអេឡាម
អភិបាលមិនប្រតិបត្តិឯករាជ្យ
ប្រធានក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល

លោក ហ្សាវីហ្សាហ្វីន ខាលឡីត
អភិបាលមិនប្រតិបត្តិឯករាជ្យ

លោក ស្តេនសឺ លី
អភិបាលមិនប្រតិបត្តិឯករាជ្យ

ជាកុ ហាមី រុលឡា ប៊ូហាន់
អភិបាលមិនប្រតិបត្តិមិនឯករាជ្យ

លោក ស៊ូន ស៊ូ ឡុង
អភិបាលមិនប្រតិបត្តិមិនឯករាជ្យ

ក្រុមប្រឹក្សាភិបាល

លោក អានគូនី ប្រេនអេឡាម
អភិបាលមិនប្រតិបត្តិឯកភាជ្ស
ប្រធានក្រុមប្រឹក្សាភិបាល

តែងតាំង៖ ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៨

កម្រិតវប្បធម៌ / វិជ្ជាជីវៈ៖
- អនុបណ្ឌិត ផ្នែកគ្រប់គ្រងអាជីវកម្ម (ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម អន្តរជាតិ) ពីសាកលវិទ្យាល័យ New York សហរដ្ឋអាមេរិក
- បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ សេវាកម្មបរទេស ពីសាកលវិទ្យាល័យ Georgetown សហរដ្ឋអាមេរិក

បទពិសោធន៍៖
មានបទពិសោធន៍ជាង៣០ឆ្នាំ ក្នុងតំណែងថ្នាក់ដឹកនាំជាន់ខ្ពស់ នៅក្នុងស្ថាប័នផ្សេង៦ដូចជា នាយកផ្នែកគ្រប់គ្រងហានិភ័យ នៅ PT Bank Central Asia Tbk និងជាអភិបាលឯកភាជ្សនៅ PT Sarana Menara Nusantara Tbk និង Citibank ក៏ដូចជាបម្រើការជាទីប្រឹក្សាដល់ប្រធានក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុន Indonesian Bank Restructuring Agency និងជាស្នងការនៃ PT Bank International Indonesia។

បច្ចុប្បន្នជាអភិបាល នៅក្នុងសម្ព័ន្ធធនាគារ មេយប៉ែង ក៏ដូចជាក្រុមហ៊ុនសាជីវកម្ម និងក្រុមហ៊ុនមហាជនមួយចំនួនដូចជា៖
- អភិបាលនៃសម្ព័ន្ធធនាគារ មេយប៉ែង
- អភិបាលនៃធនាគារ មេយប៉ែង សិង្ហបុរី

លោក ហ្សារីហ្សាហ្ទូឌីន ខាលឡីត
អភិបាលមិនប្រតិបត្តិឯកភាជ្ស

តែងតាំង៖ ថ្ងៃ២៩ ខែមីនា ឆ្នាំ២០១៩ AC RMC

កម្រិតវប្បធម៌ / វិជ្ជាជីវៈ៖
- សហជីវិននៃវិទ្យាស្ថានគណនេយ្យករធម្មនុញ្ញ នៅចក្រភពអង់គ្លេស

បទពិសោធន៍៖
មានបទពិសោធន៍ជាង៣០ឆ្នាំ ក្នុងផ្នែកធនាគារកិច្ច និងកិច្ចការក្រុមហ៊ុន និងធនាគារកណ្តាលប្រទេសម៉ាឡេស៊ី (Bank Negara Malaysia)។ លោកធ្លាប់បម្រើការជាអភិបាល ផ្នែកទំនាក់ទំនងយុទ្ធសាស្ត្រ នៅមជ្ឈមណ្ឌលហិរញ្ញវត្ថុឥស្លាមម៉ាឡេស៊ីអន្តរជាតិ។ លោក ក៏ជាថ្នាក់ដឹកនាំម្នាក់ដែលបានរួមចំណែកក្នុងការបង្កើតក្រុមហ៊ុនPengurusan Danaharta Nasional Bhd។

បច្ចុប្បន្នជាអភិបាល នៅក្នុងសម្ព័ន្ធធនាគារ មេយប៉ែង ក៏ដូចជាក្រុមហ៊ុនសាជីវកម្ម និងក្រុមហ៊ុនមហាជនមួយចំនួនដូចជា៖
- អភិបាលនៃ សម្ព័ន្ធ ធនាគារ មេយប៉ែង
- អភិបាលនៃ MCB Bank Ltd (ប៉ាគីស្ថាន)
- អភិបាលនៃ Maybank Islamic Berhad
- អភិបាលនៃ Marine & General Berhad

លោក ស្តេនសឺ លី
អភិបាលមិនប្រតិបត្តិឯកភាជ្ស

តែងតាំង៖ ថ្ងៃ២៣ ខែមីនា ឆ្នាំ២០១២ AC RMC

កម្រិតវប្បធម៌ / វិជ្ជាជីវៈ៖
- សហជីវិននៃវិទ្យាស្ថានគណនេយ្យករធម្មនុញ្ញ នៅចក្រភពអង់គ្លេស និង Wales
- សមាជិកនៃវិទ្យាស្ថានគណនេយ្យករនៃប្រទេសម៉ាឡេស៊ី

បទពិសោធន៍៖
មានបទពិសោធន៍ជាង៣០ឆ្នាំ ក្នុងផ្នែកធនាគារកិច្ច ដោយធ្លាប់បម្រើការនៅក្នុងតំណែងជាថ្នាក់ដឹកនាំជាន់ខ្ពស់ជាច្រើន នៅក្នុងធនាគារ មេយប៉ែង និងក្រុមប្រឹក្សាភិបាលនៃធនាគារ មេយប៉ែង។

បច្ចុប្បន្នជាអភិបាល នៅក្នុងសម្ព័ន្ធធនាគារ មេយប៉ែង ក៏ដូចជាក្រុមហ៊ុនសាជីវកម្ម និងក្រុមហ៊ុនមហាជនមួយចំនួនដូចជា៖
- អភិបាលនៃ ធនាគារ មេយប៉ែង សិង្ហបុរី
- អភិបាលនៃ Boardroom Pte Ltd

ជាតុ ហាមី រុលឡា ប៊ូហាន់
អភិបាលមិនប្រតិបត្តិមិនឯកភាជ្ស

តែងតាំង៖ ថ្ងៃ២៣ ខែមីនា ឆ្នាំ២០១២ AC RMC

កម្រិតវប្បធម៌ / វិជ្ជាជីវៈ៖
- អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យ International Islamic ប្រទេសម៉ាឡេស៊ី
- សញ្ញាបត្រផ្នែកគណនេយ្យពីវិទ្យាស្ថាន Mara Institute of Technlogy ប្រទេសម៉ាឡេស៊ី
- ធនាគារិកផ្នែកបុគ្គល ដែលត្រូវបានទទួលស្គាល់លក្ខណៈអន្តរជាតិពី London Executive Management – International Academy of Retail Banker

បទពិសោធន៍៖
មានបទពិសោធន៍ជាង២០ឆ្នាំ ក្នុងផ្នែកធនាគារកិច្ចបុគ្គល។ បច្ចុប្បន្នកំពុងកាន់តំណែងជាប្រធានស្តីទីជាន់ខ្ពស់ និងជានាយកផ្នែកសេវាកម្ម ហិរញ្ញវត្ថុសហគមន៍ នៃធនាគារ មេយប៉ែង។

លោក ស៊ូន ស៊ូ ឡុង
អភិបាលមិនប្រតិបត្តិមិនឯកភាជ្ស

តែងតាំង៖ ថ្ងៃ៣១ ខែមីនា ឆ្នាំ២០១៥ AC RMC

កម្រិតវប្បធម៌ / វិជ្ជាជីវៈ៖
- បរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យក្រុងឡុងដ៍
- សហជីវិនគណនេយ្យករ នៃវិទ្យាស្ថានChartered Accountants នៅចក្រភពអង់គ្លេស និងWales

បទពិសោធន៍៖
ធ្លាប់កាន់តំណែងជាន់ខ្ពស់ជាច្រើននៅក្នុងធនាគារ នៅប្រទេសម៉ាឡេស៊ី និងសិង្ហបុរី លើផ្នែកធនាគារកិច្ចផ្នែកវិនិយោគ ធនាគារកិច្ចពាណិជ្ជកម្ម និងធនាគារកិច្ចបែបឥស្លាម។ បច្ចុប្បន្ន គឺជានាយកប្រតិបត្តិនៃធនាគារ មេយប៉ែង រៀតណាម។

សេចក្តីអះអាង៖
អភិបាលទាំងអស់ មិនមាន៖
- ទំនាក់ទំនងជាលក្ខណៈគ្រួសារជាមួយអភិបាលណាម្នាក់ និង / ឬភាគទុនិកសំខាន់របស់ធនាគារ មេយប៉ែង (ខេមបូឌា) ភីអិលស៊ី
- ទំនាស់ផលប្រយោជន៍ជាមួយធនាគារ មេយប៉ែង (ខេមបូឌា) ភីអិលស៊ី ហើយក៏មិនធ្លាប់បានប្រព្រឹត្តនូវបទល្មើសអ្វីឡើយ។

សមាជិកភាពនៃគណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាលនៃធនាគារ មេយប៉ែង៖

AC គណៈកម្មាធិការសវនកម្ម
RMC គណៈកម្មាធិការគ្រប់គ្រងហានិភ័យ
ប្រធានក្រុមប្រឹក្សាភិបាល
សមាជិក

គណៈកម្មាធិការ
ប្រតិបត្តិ



គណៈកម្មាធិការប្រតិបត្តិ

๑ ជាតុ ម៉ូហាមាដ ហានីវស៊ូអេឌី
នាយកប្រតិបត្តិ

๒ លោក វ័ត្ត សោភ័ណ
នាយក នាយកដ្ឋានសេវាហិរញ្ញវត្ថុសហគមន៍

๓ លោក ត្រួច សត្យា
នាយក នាយកដ្ឋានធនាគារកិច្ច និងសាជីវកម្ម

๔ កញ្ញា ហុង ស្រីឆន
នាយិកា នាយកដ្ឋានទីផ្សារសកល - ឥណ្ឌូចិន

๕ លោក អេក្វាន់ ជីន ចានី
នាយក នាយកដ្ឋានហិរញ្ញវត្ថុ - ឥណ្ឌូចិន

๖ លោក អ៊ុង ឃុក ជីន
នាយក នាយកដ្ឋានគ្រប់គ្រងហានិភ័យ- ឥណ្ឌូចិន

๗ លោកស្រី ហ្គាសរីន ចាន់ អេប់ឌុលឆ្បា
នាយិកា នាយកដ្ឋានធនធានមនុស្ស - ឥណ្ឌូចិន / នាយិកា នាយកដ្ឋានកិច្ចការក្រុមហ៊ុន និងទំនាក់ទំនងសាជីវកម្ម

๘ លោក ឃូ អេង ហួ
នាយក នាយកដ្ឋានប្រតិបត្តិការអាជីវកម្ម

សេចក្តីអះអាង៖
គណៈកម្មាធិការប្រតិបត្តិ មិនមានទំនាក់ទំនងជាលក្ខណៈគ្រួសារ ជាមួយនឹងសមាជិកក្រុមប្រឹក្សាភិបាល និង/ឬភាគទុនិកសំខាន់របស់ធនាគារ មេយវ៉ៃង (ខេមបូឌា) ភីអិលស៊ី ពុំមានទំនាស់ផលប្រយោជន៍ជាមួយធនាគារ មេយវ៉ៃង (ខេមបូឌា) ភីអិលស៊ី ហើយក៏មិនធ្លាប់បានប្រព្រឹត្តនូវបទល្មើសអ្វីឡើយ ពុំមានការផ្តន្ទាទោស ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ និងពុំមានការទទួលទណ្ឌកម្ម ឬការពិន័យពីស្ថាប័នពាក់ព័ន្ធ នៅអំឡុងឆ្នាំសារពើពន្ធ។

គណៈកម្មាធិការប្រតិបត្តិ

ដាតុ ម៉ូហាមាដ ហានីហ្វស៊ូអាឌី

នាយកប្រតិបត្តិ

តែងតាំង៖ ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៨

កម្រិតវប្បធម៌ / វិជ្ជាជីវៈ៖

- បញ្ចប់ការសិក្សាផ្នែកធនាគារ ច្បាប់ហិរញ្ញវត្ថុក្រុមហ៊ុន និងមូលប័ត្រពីសាកលវិទ្យាល័យ UiTM
- បញ្ចប់កម្មវិធីគ្រប់គ្រងជាន់ខ្ពស់ ពីសាលាINSEAD Business School, Fontainbleu ប៉ារីស
- អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យWales រដ្ឋCardiff
- សហព័ន្ធប្រឹក្សាយោបល់អន្តរជាតិ ដែលជាអ្នកផ្តល់ប្រឹក្សាយោបល់ ដែលទទួលបានការបណ្តុះបណ្តាល។

បទពិសោធន៍៖

បទពិសោធន៍ជាង៤០ឆ្នាំ ទៅលើការងារគ្រប់ផ្នែកនៃធនាគារកិច្ចពាណិជ្ជកម្ម នៃសម្ព័ន្ធធនាគារមេយប៊ែង រួមមានការគ្រប់គ្រងប្រតិបត្តិការសាខារហូតដល់ការគ្រប់គ្រងជាន់ខ្ពស់ លើការបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រព្រមទាំង ត្រូវបានតែងតាំងជាគណៈកម្មាធិការសវនកម្មផ្ទៃក្នុង នៃសម្ព័ន្ធធនាគារ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសម្បត្តិ និងលទ្ធកម្ម និងជាអភិបាលនៃក្រុមប្រឹក្សាភិបាលនៃ Maybank Trustees Berhad។

លោក រ័ត្ន សោភ័ណ

នាយក នាយកដ្ឋានសេវាហិរញ្ញវត្ថុសហគមន៍

តែងតាំង៖ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨

កម្រិតវប្បធម៌ / វិជ្ជាជីវៈ៖

- អនុបណ្ឌិតផ្នែកនីតិប្រៀបធៀប និងអន្តរជាតិ នៅសាកលវិទ្យាល័យជាតិសិង្ហបុរី (NUS) ជាសហជីវិនអាស៊ាន
- បរិញ្ញាប័ត្រច្បាប់ ផ្នែកច្បាប់ពាណិជ្ជកម្ម និងរដ្ឋបាលអាជីវកម្ម នៅក្នុងកម្មវិធីបរិញ្ញាប័ត្រ ដែលបង្កើតឡើង ដោយសាកលវិទ្យាល័យជាតិគ្រប់គ្រង និងសាកលវិទ្យាល័យសាន់ហ្វ្រាន់ស៊ីសស្កូ (USF)។

បទពិសោធន៍៖

បទពិសោធន៍ជាង ១៥ឆ្នាំ នៅក្នុងវិស័យហិរញ្ញវត្ថុផ្នែកធនាគារកិច្ច និងធានារ៉ាប់រង ដែលរួមមានអាជីវកម្មនិយោជិតប្រតិបត្តិការ និងព័ត៌មានវិទ្យាព្រមទាំងហានិភ័យ និងការប្រតិបត្តិតាម។ កាលពីមុន លោក ធ្លាប់កាន់តំណែងជាន់ខ្ពស់ នៅលើផ្នែកធនាគារកិច្ចបុគ្គល និងប្រតិបត្តិការធនាគារ។

លោក គ្រួច សត្យា

នាយក នាយកដ្ឋានធនាគារកិច្ច និងសាជីវកម្ម

តែងតាំង៖ ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧

កម្រិតវប្បធម៌ / វិជ្ជាជីវៈ៖

- បរិញ្ញាបត្រផ្នែកគ្រប់គ្រងអាជីវកម្ម គណនេយ្យ និងហិរញ្ញវត្ថុពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ប្រទេសកម្ពុជា
- អនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម (ហិរញ្ញវត្ថុ) ពីសាកលវិទ្យាល័យ Charles Sturt សហប្រតិបត្តិការជាមួយវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រទេសកម្ពុជា។

បទពិសោធន៍៖

បទពិសោធន៍ជាង២០ឆ្នាំ នៅក្នុងផ្នែកធនាគារកិច្ច និងធ្លាប់កាន់តំណែងជាន់ខ្ពស់សំខាន់ៗ ជាច្រើន ដែលរួមមានផ្នែកលក់ ការគ្រប់គ្រងទំនាក់ទំនងជាមួយអតិថិជន ការគ្រប់គ្រងហានិភ័យ និងផលប័ត្រ ដែលមានបញ្ហា (Distressed Portfolio) និងការគ្រប់គ្រងហានិភ័យឥណទាន។ កាលពីមុន ធ្លាប់កាន់តំណែងជាន់ខ្ពស់នៅផ្នែក ពាណិជ្ជកម្ម និងធនាគារកិច្ចសារជីវកម្ម ព្រមទាំងឥណទាន និងកម្ចី។

កញ្ញា ហុង ស្រីនួន

នាយិកា នាយកដ្ឋានទីផ្សារសកល - ឥណ្ឌូចិន

តែងតាំង៖ ថ្ងៃទី១ ខែមករា ឆ្នាំ២០២០

កម្រិតវប្បធម៌ / វិជ្ជាជីវៈ៖

- អនុបណ្ឌិតផ្នែកគណនេយ្យ និងហិរញ្ញវត្ថុនៃសាកលវិទ្យាល័យ Melbourne។

បទពិសោធន៍៖

បទពិសោធន៍ជាង១០ឆ្នាំ នៅលើផ្នែករតនាគារ ការជួញដូរ រូបិយប័ណ្ណហិរញ្ញវត្ថុបរទេស និងទីផ្សាររូបិយវត្ថុ។ កាលពីមុន កញ្ញាធ្លាប់កាន់តំណែងជាន់ខ្ពស់ជា នាយិកាផ្នែកហិរញ្ញវត្ថុ និងជានិយិកាផ្នែករតនាគារ។

លោក អ៊ឹង យុក ជីន

នាយក នាយកដ្ឋានគ្រប់គ្រងហានិភ័យ- ឥណ្ឌូចិន

តែងតាំង៖ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨

កម្រិតវប្បធម៌ / វិជ្ជាជីវៈ៖

- បរិញ្ញាប័ត្រផ្នែកសេដ្ឋកិច្ច នៃសាកលវិទ្យាល័យម៉ាឡាយ៉ា (University Malaya) ប្រទេសម៉ាឡេស៊ី។

បទពិសោធន៍៖

បទពិសោធន៍ជាង៣០ឆ្នាំ លើផ្នែកគ្រប់គ្រងឥណទាន និងហានិភ័យ។ លោកធ្លាប់កាន់តំណែង ជាថ្នាក់ដឹកនាំជាន់ខ្ពស់ ជានាយក នៃនាយកដ្ឋានហានិភ័យ នៃធនាគារមេយប៊ែង ហ្វីលីពីន និងជានាយកគម្រោងពិសេស និងអន្តរជាតិ នៃនាយកដ្ឋានគ្រប់គ្រងហានិភ័យ នៃសម្ព័ន្ធធនាគារ មេយប៊ែង។

លោក អេក្វាន់ ប៊ីន ចានី

នាយក នាយកដ្ឋានហិរញ្ញវត្ថុ - ឥណ្ឌូចិន

តែងតាំង៖ ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៨

កម្រិតវប្បធម៌ / វិជ្ជាជីវៈ៖

- បរិញ្ញាបត្រផ្នែកគណនេយ្យ និងហិរញ្ញវត្ថុនៅសាកលវិទ្យាល័យ Liverpool John Moores និងសាលាពាណិជ្ជកម្ម Dublin Business ប្រទេសអៀរឡង់
- សហជីវិននៃ Association of Chartered Certified Accounts (FCCA) ចក្រភពអង់គ្លេស
- សមាជិកគណនេយ្យករ នៃវិទ្យាស្ថានគណនេយ្យម៉ាឡេស៊ី។

បទពិសោធន៍៖

បទពិសោធន៍ជាង១៩ឆ្នាំ លើសវនកម្ម គណនេយ្យ និងហិរញ្ញវត្ថុ ដោយបានបម្រើការនៅតាមស្ថាប័នសវនកម្ម និងហិរញ្ញវត្ថុជាច្រើននានា។ ធ្លាប់កាន់តំណែងជាន់ខ្ពស់ ជាប្រធានស្តីទី ផ្នែកប្រតិបត្តិការហិរញ្ញវត្ថុ និងរតនាគារនៅធនាគារវិនិយោគមេយប៊ែង និងនាយកផ្នែកអាជីវកម្មថ្នាក់តំបន់ដើម្បីជួយគាំទ្រដល់ក្រុមហ៊ុន Maybank Kim Eng។ កាលពីមុន ធ្លាប់បម្រើការជានាយក នាយកដ្ឋានហិរញ្ញវត្ថុនិងជាក្រុមប្រឹក្សាភិបាលនៃសម្ព័ន្ធក្រុមហ៊ុន Maybank ATR Kim Eng ប្រទេសហ្វីលីពីន។

លោកស្រី ហ្គាសរីន ចាន់ អាប់ឌុលឡា

នាយិកា នាយកដ្ឋានធនធានមនុស្ស - ឥណ្ឌូចិន
នាយិកា នាយកដ្ឋានកិច្ចការក្រុមហ៊ុន និងទំនាក់ទំនងសាជីវកម្ម

តែងតាំង៖ ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៧ /
ថ្ងៃទី២ ខែមេសា ឆ្នាំ២០១២

កម្រិតវប្បធម៌ / វិជ្ជាជីវៈ៖

- អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម នៃសាកលវិទ្យាល័យ Bath ចក្រភពអង់គ្លេស
- បរិញ្ញាបត្រផ្នែកអប់រំ (មគ្គុទេសក៍ និងផ្តល់ប្រឹក្សា) សាកលវិទ្យាល័យ Putra ប្រទេសម៉ាឡេស៊ី
- វិញ្ញាបនបត្រទំនាក់ទំនងឧស្សាហកម្ម នៃវិទ្យាស្ថានគ្រប់គ្រងម៉ាឡេស៊ី
- វិញ្ញាបនបត្រគ្រប់គ្រងផលិតផលទីផ្សារ សមាគមនៃផលិតផលទីផ្សារអន្តរជាតិ និងការគ្រប់គ្រងសហរដ្ឋអាមេរិក។

បទពិសោធន៍៖

បទពិសោធន៍ជាង២០ឆ្នាំ លើផ្នែកទំនាក់ទំនងក្រុមហ៊ុន ទំនាក់ទំនងទីផ្សារ គុណភាពសេវាកម្ម អភិបាលកិច្ច និងធនធានមនុស្ស ដែលបញ្ចូលទាំងការគ្រប់គ្រងការផ្លាស់ប្តូរ ការទំនាក់ទំនងនិយោជិត ការប្រាស្រ័យទាក់ទងជាមួយនិយោជិត និងការចូលរួមរបស់និយោជិត។

លោក យូ អេង ហូ

នាយក នាយកដ្ឋានប្រតិបត្តិការអាជីវកម្ម

តែងតាំង៖ ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥

កម្រិតវប្បធម៌ / វិជ្ជាជីវៈ៖

- សញ្ញាបត្រវិជ្ជាជីវៈឥណទាន (CCP - អតិថិជន) វិទ្យាស្ថានធនាគារិក ប្រទេសម៉ាឡេស៊ី។

បទពិសោធន៍៖

បទពិសោធន៍ជាង៣០ឆ្នាំ លើវិស័យធនាគារកិច្ច ដែលរួមមានផ្នែកលក់ ប្រតិបត្តិការសាខា ប្រតិបត្តិការជួញដូរហិរញ្ញវត្ថុ និងរដ្ឋបាលឥណទាន។

របាយការណ៍ស្តីពី
អភិបាលកិច្ចក្រុមហ៊ុន

ក្រុមប្រឹក្សាភិបាលនៃធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី (ដែលតទៅនេះហៅថា "ក្រុមប្រឹក្សាភិបាល") ជឿជាក់ថាអភិបាលកិច្ចល្អ អាចធ្វើឲ្យប្រតិបត្តិការរបស់ធនាគារកាន់តែមានប្រសិទ្ធភាព ធ្វើឲ្យប្រសើរឡើងក្នុងការទទួលបានដើមទុន កាត់បន្ថយហានិភ័យ និងសម្រួលដល់ការត្រួតពិនិត្យអាជីវកម្ម ការគ្រប់គ្រង ក៏ដូចជាប្រតិបត្តិការរបស់ធនាគារ នៅក្នុងរយៈពេលដ៏វែងឆ្ងាយ។ អភិបាលកិច្ចល្អ អាចជួយបង្កើននូវតម្លាភាពនិងគណនេយ្យភាពនៅក្នុងធនាគារ និងចូលរួមក្នុងបង្កើតគុណតម្លៃប្រកបដោយអត្ថន័យសម្រាប់ភាគីពាក់ព័ន្ធ។ ការផ្ទុះឡើងនៃជំងឺកូវីដ១៩ កាលពីដើមឆ្នាំ២០២០ បាននាំមកនូវឧបសគ្គមួយចំនួនដល់ក្រុមប្រឹក្សាភិបាល ក្នុងការធានាឲ្យបានថា ក្រុមអភិបាលកិច្ច នៅតែបន្តភាពរឹងមាំ និងអាចឆ្លើយតបនឹងតម្រូវការក្នុងការផ្លាស់ប្តូរបរិយាកាសនៃប្រតិបត្តិការ។ ក្នុងន័យនេះ ក្រុមប្រឹក្សាភិបាល នៅតែខិតខំប្រឹងប្រែងក្នុងការដោះស្រាយ ឧបសគ្គទាំងឡាយ គឺដើម្បីធានាឲ្យបានថា ធនាគារ អាចសម្រេចបាននូវ គោលដៅក្នុងការក្លាយខ្លួនជាធនាគារឈានមុខនៅអាស៊ាន ដើម្បីបំពេញមហិច្ឆតារបស់អតិថិជនក្នុងតំបន់ និងតភ្ជាប់ពួកគាត់ទៅឱកាសក្នុងតំបន់អាស៊ី និងពិភពលោក។

ជាសក្ខីភាពលើការខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាភិបាល សម្ព័ន្ធធនាគារ មេយប៊ែង បានទទួលនូវជ័យលាភីលើការងារអភិបាលកិច្ចល្អ ពីសំណាក់ Minority Shareholders Watch Group (MSWG) ក្នុងឆ្នាំ ២០២០ រួមមាន៖

១. ពានរង្វាន់លើអភិបាលកិច្ច និងសមិទ្ធិផល

២. ពានរង្វាន់លើការអភិវឌ្ឍអភិបាលកិច្ច

៣. ជាក្រុមហ៊ុន ក្នុងចំណោមក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតឈានមុខទាំង ៣ក្នុងប្រទេសម៉ាឡេស៊ី

៤. ជាក្រុមហ៊ុន ក្នុងចំណោមក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតឈានមុខទាំង ២០នៅអាស៊ាន

៥. ពានរង្វាន់ ASEAN Asset Class

ពួកយើង មានសេចក្តីសោមរីករាយចំពោះការទទួលស្គាល់ទាំងនេះ និងបន្តខិតខំប្រឹងប្រែងក្នុងនាមជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតឈានមុខ លើផ្នែកអភិបាលកិច្ចល្អនៅប្រទេសម៉ាឡេស៊ី និងអាស៊ាន។

ធនាគារ មានតួនាទីចាំបាច់ក្នុងការគោរពតាមបទបញ្ញត្តិប្រកបដោយភាពពេញលេញ ហើយក្រុមប្រឹក្សាភិបាល ត្រូវធានាឲ្យបានថាគោលនយោបាយស្តីអំពី អភិបាលកិច្ចដ៏មានគុណភាពរបស់ធនាគារ ត្រូវរៀបចំឡើង ហើយត្រូវបានធ្វើ បច្ចុប្បន្នភាពយោងតាមបទបញ្ញត្តិពាក់ព័ន្ធនឹងអភិបាលកិច្ច ដែលមានជាធរមាន។ គោលនយោបាយស្តីពីអភិបាលកិច្ចរបស់ធនាគារ ត្រូវបានរៀបចំឡើងដោយប្រតិបត្តិតាមលក្ខន្តិកៈនៃក្រុមហ៊ុន ការអនុវត្តល្អ គោលនយោបាយ និងគោលការណ៍ដូចជា៖

១. ច្បាប់ស្តីអំពី សហគ្រាសពាណិជ្ជកម្ម

២. ប្រកាសស្តីអំពី អភិបាលកិច្ចរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា និង

៣. រចនាសម្ព័ន្ធនៃអភិបាលកិច្ចក្រុមហ៊ុនរបស់សម្ព័ន្ធធនាគារ មេយប៊ែង

របាយការណ៍នេះ នឹងបង្ហាញដោយសង្ខេបអំពីរចនាសម្ព័ន្ធនៃអភិបាលកិច្ចក្រុមហ៊ុន ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (សម្រាប់ឆ្នាំ២០២០)។



របាយការណ៍ស្តីពីអភិបាលកិច្ចក្រុមហ៊ុន

ភាពជាអ្នកដឹកនាំ និងប្រសិទ្ធភាពនៃក្រុមប្រឹក្សាភិបាល

តួនាទីរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលដឹកនាំ និងត្រួតពិនិត្យសកម្មភាពពាណិជ្ជកម្ម និងកិច្ចការផ្សេងៗរបស់ធនាគារ តាមរយៈការពិនិត្យ និងសម្រេចលើយុទ្ធសាស្ត្រ និងគោលការណ៍សំខាន់ៗរបស់ធនាគារ។ ក្រុមប្រឹក្សាភិបាល ក៏មានតួនាទីបង្កើតគុណតម្លៃរបស់ធនាគារ និងអនុម័ត លើបទដ្ឋានផ្សេងៗ ដើម្បីធានាឲ្យបានថា ការប្រតិបត្តិរបស់ធនាគារប្រព្រឹត្តិទៅដោយសុក្រិតភាព និងប្រតិបត្តិតាមច្បាប់ និងបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធ។ តួនាទី និងភារៈកិច្ចរបស់ក្រុមប្រឹក្សាភិបាល មានចែងលម្អិត នៅក្នុងលក្ខន្តិកៈក្រុមប្រឹក្សាភិបាលធនាគារ។

ក្រុមប្រឹក្សាភិបាល ជឿជាក់ថា ភាពជោគជ័យនៃយុទ្ធសាស្ត្ររបស់ធនាគារ ទាមទារនូវភាពស៊ីសង្វាក់គ្នារវាងយុទ្ធសាស្ត្រ និងអភិបាលកិច្ចល្អ។ អាស្រ័យហេតុនេះ ប្រព័ន្ធដែលមានភាពរឹងមាំក្នុងការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង ត្រូវបានរៀបចំឡើង ដើម្បីធានាឲ្យបានថា កម្រិតហានិភ័យរបស់ធនាគារ ត្រូវបានកំណត់ ហើយហានិភ័យ ដែលបានកំណត់ត្រូវបានវិភាគ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។

ក្រៅពីការកំណត់ផែនការយុទ្ធសាស្ត្រ និងការបង្កើតនូវគុណតម្លៃរបស់ធនាគារ ក្រុមប្រឹក្សាភិបាល ក៏មានតួនាទីតាមដាន លើការអនុវត្តផែនការយុទ្ធសាស្ត្ររបស់គណៈគ្រប់គ្រងធនាគារ និងរបាយការណ៍ហិរញ្ញវត្ថុជាប្រចាំ។ ទោះបីជាក្រុមប្រឹក្សាភិបាល បានផ្តោតការយកចិត្តទុកដាក់លើការរីកចម្រើន ក្នុងរយៈពេលវែងក៏ដោយ តែក៏អាចធានាបានថាគណៈគ្រប់គ្រងមានសមត្ថភាព ក្នុងការថ្លឹងថ្លែងឲ្យមានសមតុល្យរវាង គោលដៅរយៈពេលខ្លី និងគោលដៅរយៈពេលវែង។ ក្រុមប្រឹក្សាភិបាល តែងតែយកចិត្តទុកដាក់លើភារកិច្ច និងការពិចារណាលើផលប៉ះពាល់ ដែលកើតឡើងពីសេចក្តីសម្រេចរបស់ខ្លួនមកលើភាគីពាក់ព័ន្ធរួមមាន និយោជិត ម្ចាស់ភាគហ៊ុន អតិថិជន និងសហគមន៍ជាដើម។

ក្រុមប្រឹក្សាភិបាល បានរៀបចំផែនការជាក់លាក់ក្នុងការធ្វើសេចក្តីសម្រេច ដូចមានចែងលម្អិត នៅក្នុងលក្ខន្តិកៈរបស់ក្រុមប្រឹក្សាភិបាលធនាគារ។

អភិបាលកិច្ចនៅក្នុងបរិបទកូវីដ១៩

ចាប់តាំងពីមានការរីករាលដាលនៃជំងឺកូវីដ១៩ កាលពីឆ្នាំមុន ក្រុមប្រឹក្សាភិបាល បានតាមដានយ៉ាងម៉ត់ចត់ មិនត្រឹមតែលើផលប៉ះពាល់លើសេដ្ឋកិច្ចរបស់សកលលោក និងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារប៉ុណ្ណោះទេ ហើយថែមទាំងបានពិនិត្យលើស្ថានភាពសុខភាព និងសុខមាលភាពរបស់និយោជិតធនាគារ នៅក្នុងតំបន់ផងដែរ។ ក្រុមប្រឹក្សាភិបាល បានដោះស្រាយបញ្ហាចំពោះមុខ ដែលពាក់ព័ន្ធនឹងវិធីសាស្ត្រ ក្នុងការបន្តផ្តល់សេវាកម្មជូនដល់អតិថិជនខណៈក្នុងបរិយាកាសដ៏លំបាកនេះ។ មាតិកា និងប្រធានបទ ដែលបានលើកយកមកពិភាក្សា នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការបស់ក្រុមប្រឹក្សាភិបាល ត្រូវបានកែសម្រួល ដើម្បីឆ្លើយតបទៅនឹងបញ្ហា និងឧបសគ្គដែលកើតដោយសារជំងឺរាតត្បាតនេះ។ រួមទាំងការដោះស្រាយលើ តម្រូវការឲ្យការបំពេញការងារនៅតាមផ្ទះទូទាំងតំបន់ ក៏ដូចជាដាក់ឲ្យអនុវត្តន៍នូវវិធានការណ៍ជាច្រើន ក្នុងការជួយដល់អតិថិជន ដែលរងផលប៉ះពាល់។

ដោយពិនិត្យឃើញថា មានតម្រូវការ ក្នុងការប្រាស្រ័យទាក់ទងឲ្យកាន់តែជិត ជាមួយនឹងគណៈគ្រប់គ្រងនៅក្នុងពេលមានវិបត្តិនេះ សមាជិកក្រុមប្រឹក្សាភិបាល គណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល បានអនុញ្ញាត ក្នុងការជជែកពិភាក្សាលើបញ្ហាសំខាន់ៗបានគ្រប់ពេលវេលា។ កិច្ចប្រជុំពិសេស ត្រូវបានរៀបចំឡើង នៅពេលចាំបាច់។ ស្របតាមបទដ្ឋានអប្បបរិមាស្តីពីនីតិវិធីប្រតិបត្តិការ កិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល ត្រូវបានរៀបចំឡើងតាមអនឡាញ។ ក្នុងករណីទាមទារឲ្យមាននូវសេចក្តីសម្រេច បន្ទាន់បង្ខំរបស់ក្រុមប្រឹក្សាភិបាល គឺធ្វើឡើងតាមរយៈសេចក្តីសម្រេចជាលាយលក្ខអក្សរ។ ដោយឡែក ក្រុមប្រឹក្សាភិបាល ដែលមានបំណងបញ្ជាក់បន្ថែម គឺមានទំនាក់ទំនងយ៉ាងសកម្ម ក្នុងការជាមួយគណៈគ្រប់គ្រង ក្នុងស្រាយបំភ្លឺ។

សេចក្តីលម្អិតលើសកម្មភាពជាច្រើន ដែលបានអនុវត្តន៍ដោយធនាគារ ដើម្បីដោះស្រាយបញ្ហា ដែលកើតឡើងដោយសារជំងឺកូវីដ១៩ សូមយោងតាមដំណោះស្រាយក្នុងស្ថានភាពនៃការរាតត្បាតជំងឺកូវីដ១៩ នៅទំព័រទី ១៨។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

ក្នុងចំណោមប្រធានបទ និងផែនការយុទ្ធសាស្ត្រដែលត្រូវបានពិនិត្យ ពិភាក្សា និងអនុម័តដោយក្រុមប្រឹក្សាភិបាលក្នុងឆ្នាំ២០២០ រួមមាន៖

យុទ្ធសាស្ត្រ	ការគ្រប់គ្រងហានិភ័យ ការប្រតិបត្តិតាម និងពិនិត្យឡើងវិញ	អភិបាលកិច្ច
• យុទ្ធសាស្ត្រពាណិជ្ជកម្ម សម្រាប់នាយកដ្ឋាននីមួយៗរបស់ធនាគារ • ផែនការហិរញ្ញវត្ថុ និងពាណិជ្ជកម្មរបស់ធនាគារសម្រាប់ឆ្នាំ២០២១ • យុទ្ធសាស្ត្រ និងផែនការរយៈពេលវែង M២៥ • យុទ្ធសាស្ត្រស្តីអំពី SME+ និងក្រមប្រតិបត្តិ • កម្ចីយានយន្ត • កម្ចីដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានទទួលប្រាក់បញ្ញើ • ផែនការហិរញ្ញវត្ថុ២០២០ដល់២០២២ • យុទ្ធសាស្ត្រស្តីអំពីចីរភាព និងទំនួលខុសត្រូវសង្គម	• របាយការណ៍ផ្នែកគ្រប់គ្រងហានិភ័យរបស់នាយកនាយកដ្ឋានគ្រប់គ្រងហានិភ័យ • របាយការណ៍ស្តីអំពីកម្រិតហានិភ័យ សម្រាប់ឆ្នាំ២០២០ • របាយការណ៍ហានិភ័យប្រចាំត្រីមាស និងរបាយការណ៍ដំណើការវាយតម្លៃមូលធន • ផែនការសកម្មភាពអំពីការប្រឆាំង នឹងការសម្អាតប្រាក់ និងការប្រឆាំងហិរញ្ញប្បទានភេរវកម្ម • ការអនុវត្តគោលនយោបាយ ស្តីអំពីការផ្តល់សេវាជូនអតិថិជនដោយស្មើភាព • គោលនយោបាយស្តីអំពីការគ្រប់គ្រង និងការចែករំលែកព័ត៌មានអតិថិជន • ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០២០ • នាយកដ្ឋានផ្នែកច្បាប់ ការឆ្លុះបញ្ចាំងផលប៉ះពាល់ និងបញ្ហាប្រឈម នឹងជំងឺកូវីដ១៩	• ការវាយតម្លៃប្រសិទ្ធភាពក្រុមប្រឹក្សាភិបាល • ប្រាក់លើកទឹកចិត្ត (កម្រិតប្រាក់បំណាច់ប្រចាំឆ្នាំ និងការតំឡើងប្រាក់បៀវត្ស) និងលាភការសម្រាប់ធនាគារ • ការតែងតាំងសវនករឯករាជ្យរបស់ធនាគារ • របាយការណ៍ស្តីអំពីអភិបាលកិច្ច សម្រាប់បោះពុម្ពក្នុងរបាយការណ៍ប្រចាំឆ្នាំ២០១៩ • ការធ្វើបច្ចុប្បន្នភាពអភិបាលកិច្ចក្រុមហ៊ុន/គោលការណ៍ស្តីអំពីក្រុមប្រតិបត្តិរបស់ក្រុមប្រឹក្សាភិបាល របស់ក្រុមហ៊ុន និងបុត្រសម្ព័ន្ធ ដែលចេញដោយគណៈកម្មាធិការមូលបត្ររបស់ប្រទេសម៉ាឡេស៊ី

របាយការណ៍ស្តីពីអភិបាលកិច្ចក្រុមហ៊ុន

សមាសភាព និងភាពចម្រុះរបស់ក្រុមប្រឹក្សាភិបាល

ដោយគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ក្រុមប្រឹក្សាភិបាល មានសមាសភាពចំនួន៥រូប រួមមាន៖

២	អភិបាលមិនឯករាជ្យមិនប្រតិបត្តិ	៤0%
៣	អភិបាលឯករាជ្យមិនប្រតិបត្តិ	៦0%

សមាសភាពក្រុមប្រឹក្សាភិបាល គឺបានប្រតិបត្តិតាមបទប្បញ្ញត្តិ របស់ធនាគារជាតិ នៃកម្ពុជា ដែលតម្រូវឲ្យមានយ៉ាងហោចណាស់អភិបាល២រូបជា អភិបាលឯករាជ្យ។

ក្រុមប្រឹក្សាភិបាល បានប្តេជ្ញាចិត្តក្នុងការធានាឲ្យមានភាពចម្រុះ និងបរិយាប័ន្ននៅក្នុងសមាសភាពក្រុមប្រឹក្សាភិបាល និងដំណើរការក្នុងការធ្វើសេចក្តីសម្រេច។ នៅក្នុងបរិបទនេះ ក្រុមប្រឹក្សាភិបាល បានពិចារណាលើភាពចម្រុះ ដោយផ្តោតលើកត្តាផ្សេងៗដូចជា ភេទ អាយុ វប្បធម៌ និងការអប់រំ សញ្ជាតិបទពិសោធន៍នៃវិជ្ជាជីវៈ ជំនាញ ចំណេះដឹង និងរយៈពេលនៃការបំពេញការងារ។

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវមានជំនាញ និងបទពិសោធន៍ពាក់ព័ន្ធដូចខាងក្រោម៖

- ធនាគារកិច្ច
- ធានារ៉ាប់រង និង Takaful
- ការគ្រប់គ្រងទ្រព្យសកម្ម
- ផែនការយុទ្ធសាស្ត្រ និងផែនការពាណិជ្ជកម្ម
- ការគ្រប់គ្រងហានិភ័យ
- បទពិសោធន៍ថ្នាក់តំបន់
- អភិបាលកិច្ចក្រុមហ៊ុន
- ច្បាប់ និងការប្រតិបត្តិតាម
- គោលនយោបាយសាធារណៈ និងបទប្បញ្ញត្តិ
- គណនេយ្យនិងហិរញ្ញវត្ថុ
- ធនធានមនុស្ស

ការបែងចែកតួនាទីរបស់ក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិ

តួនាទី និងទំនួលខុសត្រូវនៃប្រធានក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិ ត្រូវបានបែងចែកចេញពីគ្នាយ៉ាងច្បាស់លាស់ ហើយត្រូវបានចងក្រង និងអនុម័តដោយក្រុមប្រឹក្សាភិបាល ដើម្បីធានាថា គណៈគ្រប់គ្រងបានដឹកនាំដោយសមស្រប។ ការបែងចែកនេះ បានផ្តល់ភាពងាយស្រួលក្នុងការស្វែងយល់ និងបានកំណត់តួនាទី និងការទទួលខុសត្រូវយ៉ាងច្បាស់លាស់។ រចនាសម្ព័ន្ធ ដែលប្រកបដោយឋានានុក្រមជាក់លាក់ នឹងជួយឲ្យមានការសម្រេចចិត្ត ដែលប្រកបដោយប្រសិទ្ធភាព និងឆាប់រហ័ស។

ឯករាជ្យភាព

ដើម្បីជាជំនួយរបស់គណៈកម្មាធិការតែងតាំង និងលាភការនៃសម្ព័ន្ធធនាគារ ក្នុងការវាយតម្លៃឯករាជ្យភាពនៃអភិបាលឯករាជ្យមិនប្រតិបត្តិ ក្រុមប្រឹក្សាភិបាល បានបង្កើតនូវគោលនយោបាយស្តីពីឯករាជ្យភាពនៃអភិបាល (គោលនយោបាយស្តីពីឯករាជ្យភាព) ដែលបានកំណត់នូវវិធីសាស្ត្ររបស់ធនាគារក្នុងការកំណត់ឯករាជ្យភាពរបស់អភិបាល។ ដូចមានចែងក្នុងគោលនយោបាយស្តីពីឯករាជ្យភាព គណៈកម្មាធិការតែងតាំង និងលាភការនៃសម្ព័ន្ធធនាគារ និងក្រុមប្រឹក្សាភិបាល បានវាយតម្លៃលើឯករាជ្យភាពរបស់អភិបាលឯករាជ្យមិនប្រតិបត្តិ នៅចុងឆ្នាំ២០២០ បន្ថែមពីលើការវាយតម្លៃប្រចាំឆ្នាំស្តីពីភាពសមស្រប និងជាក់លាក់ ហើយជាលទ្ធផលអភិបាលឯករាជ្យមិនប្រតិបត្តិបានបំពេញលក្ខខណ្ឌស្តីពីឯករាជ្យភាព ហើយអាចបំពេញភារៈកិច្ចដោយឯករាជ្យ និងសក្ខានុម័ត។ លើសពីនេះទៅទៀត អភិបាលឯករាជ្យមិនប្រតិបត្តិនីមួយៗ បានប្រកាស និងបញ្ជាក់អំពីឯករាជ្យភាពរបស់ខ្លួនក្នុងពេលវាយតម្លៃប្រចាំឆ្នាំស្តីពីភាពសមស្រប និងជាក់លាក់។ អភិបាលឯករាជ្យមិនប្រតិបត្តិ មានកាតព្វកិច្ចក្នុងការរាយការណ៍ជូនក្រុមប្រឹក្សាភិបាលគ្រប់កាលៈទេសៈ ដែលអាចនាំឲ្យប៉ះពាល់ដល់ឯករាជ្យភាពរបស់ខ្លួន។

គណៈកម្មាធិការតែងតាំង និងលាភការ

ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី ពឹងផ្អែកលើគណៈកម្មាធិការតែងតាំង និងលាភការរបស់សម្ព័ន្ធធនាគារ ដែលមានសមាសភាពភាគច្រើនជាអភិបាលឯករាជ្យមិនប្រតិបត្តិ និងត្រូវបានដឹកនាំដោយអភិបាលឯករាជ្យមិនប្រតិបត្តិជាន់ខ្ពស់។ តួនាទី និងភារៈកិច្ចរបស់គណៈកម្មាធិការតែងតាំង និងលាភការ ត្រូវបានកំណត់ក្នុងក្រមប្រតិបត្តិ ដែលអាចស្វែងរកបាននៅលើគេហទំព័រផ្លូវការរបស់សម្ព័ន្ធធនាគារ មេយប៊ែង www.maybank.com។

ការតែងតាំងក្រុមប្រឹក្សាភិបាល និងផែនការបន្តវេន

គណៈកម្មាធិការតែងតាំង និងលាភការ មានតួនាទីសំខាន់ ក្នុងការតែងតាំងនៅក្នុងដំណើរការជ្រើសរើសបេក្ខជនដែលមានសុក្ខានុពល សម្រាប់តែងតាំងជាក្រុមប្រឹក្សាភិបាលរបស់ធនាគារក៏ដូចជាសម្ព័ន្ធធនាគារ។ ការជ្រើសរើស និងតែងតាំងអភិបាលថ្មី ត្រូវបានណែនាំដោយគោលនយោបាយ និងនីតិវិធី ដែលបានកំណត់ដូចខាងក្រោម៖

១. គោលនយោបាយស្តីអំពីលក្ខខណ្ឌនៃភាពសមស្រប និងជាក់លាក់សម្រាប់ការតែងតាំង និងតែងតាំងសារជាថ្មី នៃនិយោជិ ដែលមានតួនាទីសំខាន់របស់ស្ថាប័នវិជ្ជាជីវៈរបស់សម្ព័ន្ធ ធនាគារ
២. គោលនយោបាយស្តីអំពី នីតិវិធីជ្រើសរើស សម្រាប់ការតែងតាំងប្រធានក្រុមប្រឹក្សាភិបាល អភិបាល និងនាយកប្រតិបត្តិនៃ ស្ថាប័នវិជ្ជាជីវៈរបស់សម្ព័ន្ធធនាគារ
៣. គោលនយោបាយស្តីអំពី អាណត្តិរបស់អភិបាល
៤. គោលនយោបាយស្តីអំពី ឯករាជ្យភាពរបស់អភិបាល និង
៥. គោលនយោបាយស្តីអំពី ភាពចម្រុះលើយេនឌ័រក្នុងសមាសភាពក្រុមប្រឹក្សាភិបាល

សេចក្តីលម្អិតរបស់គោលនយោបាយ ដែលបានរៀបរាប់ខាងលើនេះ គឺមានចែងនៅក្នុងរបាយការណ៍ស្តីពីអភិបាលកិច្ច។

គោលនយោបាយស្តីពី នីតិវិធីជ្រើសរើស មានចែងយ៉ាងច្បាស់នូវនីតិវិធីក្នុងការជ្រើសរើស និងតែងតាំងអភិបាលថ្មីប្រកបដោយតម្លាភាព ដែលមានដូចតទៅ៖

ដំណាក់កាល១ - ការកំណត់អត្តសញ្ញាណបេក្ខជន

ដំណាក់កាល២ - ជំនួបជាមួយបេក្ខជន

ដំណាក់កាល៣ - ការពិភាក្សារបស់គណៈកម្មាធិការតែងតាំង និងលាភការ

ដំណាក់កាល៤ - ការរៀបចំសំណើទៅក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលជឿជាក់ថា ផែនការបន្តវេនដែលប្រកបដោយប្រសិទ្ធភាព អាចកាត់បន្ថយហានិភ័យពាក់ព័ន្ធជាមួយការចាកចេញ និងអវត្តមានរបស់សមាជិក ដែលមានបទពិសោធន៍ និងសមត្ថភាពណាមួយហើយអាចធានាបានថាសមាជិកក្រុមប្រឹក្សាភិបាល និង គណៈគ្រប់គ្រងគឺជាធនធានពោរពេញដោយជំនាញ និងបទពិសោធន៍ផ្ទាល់ខ្លួនដើម្បីជួយឲ្យយុទ្ធសាស្ត្ររបស់ធនាគារ និងសម្ព័ន្ធធនាគារ ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពនិងជោគជ័យ។

ជាផ្នែកមួយនៃផែនការបន្តវេន គណៈកម្មាធិការតែងតាំង និងលាភការ បានបង្កើតនូវបញ្ជីបេក្ខជន ដែលមានទេពកោសល្យជាសក្តានុពល សម្រាប់ការពិចារណាក្នុងការជ្រើសតាំង ជាអភិបាលមិនប្រតិបត្តិនៃក្រុមប្រឹក្សាភិបាល ក៏ដូចជាក្រុមប្រឹក្សាភិបាលនៃបុត្រសម្ព័ន្ធ។ គណៈកម្មាធិការតែងតាំង និងលាភការ តែងតែពិនិត្យលើប្រវត្តិរូបរបស់បេក្ខជន ដែលបានមកពីប្រភពខាងក្នុង និងខាងក្រៅស្ថាប័ន ដើម្បីយកមកពិចារណា។គណៈកម្មាធិការតែងតាំង និងលាភការក៏តែងតែពិនិត្យជាទៀងទាត់ផងដែរ នូវបញ្ជីបេក្ខជន ដែលមានទេពកោសល្យរបស់សម្ព័ន្ធធនាគារ ដើម្បីធានាឲ្យបានថាក្រុមប្រឹក្សាភិបាលមានបេក្ខជន ដែលមានទេពកោសល្យ សម្រាប់ជ្រើសរើសនៅពេលមានតម្រូវការ ក្នុងការតែងតាំងអភិបាលថ្មី។

គោលនយោបាយ របស់សម្ព័ន្ធធនាគារ ស្តីពីអាណិត្តរបស់អភិបាល (គោលនយោបាយអាណិត្ត) បានជួយសម្របសម្រួលផែនការបន្តវេន ដោយផ្តល់ឲ្យក្រុមប្រឹក្សាភិបាលនូវឱកាស ក្នុងការពិចារណា និងវាយតម្លៃសារជាថ្មីលើសមាជិករបស់ខ្លួនជាដំណាក់កាល។ ទាំងនេះអាចធានាបាននូវ ការបន្តសម្រេចគោលដៅនិងវត្ថុបំណងរយៈពេលវែង ហើយថែមទាំងអាចធានាផងដែរ ថាសមាជិកក្រុមប្រឹក្សាភិបាលមាន ចំណេះដឹង បទពិសោធន៍ និងជំនាញ ដែលអាចឆ្លើយតបបានយ៉ាងប្រសើរចំពោះតម្រូវការ នៃការផ្លាស់ប្តូរសណ្ឋានដែលមិនធ្លាប់មាននៅក្នុងវិស័យហិរញ្ញវត្ថុ។ យោងតាមគោលនយោបាយអាណិត្ត អភិបាលឯករាជ្យមិនប្រតិបត្តិត្រូវបានកំណត់អាណិត្តត្រឹមតែ៩ឆ្នាំ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ មិនមានអភិបាលឯករាជ្យមិនប្រតិបត្តិណាមួយ មានអាណិត្តលើសពី ៩ឆ្នាំឡើយ។

របាយការណ៍ស្ដីពីអភិបាលកិច្ចក្រុមហ៊ុន

ការវាយតម្លៃប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាភិបាល

ការវាយតម្លៃប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាភិបាល មានសារៈសំខាន់ចំពោះភាពជោគជ័យរបស់ធនាគារ។ ក្រុមប្រឹក្សាភិបាល ធ្វើការវាយតម្លៃលើសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងគណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាលជារៀងរាល់ឆ្នាំ។ ក្នុងឆ្នាំ២០១៧ ក្រុមប្រឹក្សាភិបាលបានសម្រេចថា ការវាយតម្លៃនេះត្រូវធ្វើដោយទីប្រឹក្សាឯករាជ្យរៀងរាល់៣ឆ្នាំម្តង។ ហេតុនេះគណៈកម្មាធិការតែងតាំង និងលាភការបានចាត់តាំងទីប្រឹក្សាឯករាជ្យ ដើម្បីធ្វើការវាយតម្លៃប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាភិបាលធនាគារ និងបុគ្រសម្ព័ន្ធសម្រាប់ឆ្នាំ២០២០។ វាយតម្លៃនេះ ធ្វើឡើងជាពីរដំណាក់ដូចខាងក្រោម៖

ដំណាក់កាលទី១៖ សម្ភាសន៍ជាមួយក្រុមប្រឹក្សានីមួយៗ និងជ្រើសរើសគណៈគ្រប់គ្រងជាន់ខ្ពស់ ដើម្បីវាយតម្លៃប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល។

ដំណាក់កាលទី២៖ កម្រងសំណួរ វាយតម្លៃលើ ការបំពេញតួនាទី បុគ្គលិកលក្ខណៈ និងគុណភាពរបស់អភិបាលនីមួយៗ រួមជាមួយការវាយតម្លៃរបស់អភិបាលឯករាជ្យមិនប្រតិបត្តិ។

ជារួមលទ្ធផលនៃការវាយតម្លៃក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ២០២០ គឺវិជ្ជមាន ជាមួយនឹងការវាយតម្លៃខ្លាំង ឬពេញចិត្តលើផ្នែកដែលត្រូវវាយតម្លៃ របាយការណ៍នេះបានឆ្លុះបញ្ចាំងអំពីភាពខ្លាំងក្នុងការបំពេញតួនាទីរបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាលទាំងអស់។ ភាពខ្លាំងសំខាន់ៗត្រូវបានរកឃើញដូចខាងក្រោម៖

(i) វប្បធម៌ និងភាពរហ័សរហួនរបស់ក្រុមប្រឹក្សាភិបាល

(ii) ការឆ្លើយតប និងទំនាក់ទំនង

(iii) ភាពជាអ្នកដឹកនាំរបស់ប្រធានក្រុមប្រឹក្សាភិបាល

(iv) ភាពចំម្រុះនិងចំណេះដឹងរបស់អភិបាល

(v) ការគាំទ្រគណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល

(vi) ការពិនិត្យតួនាទីចម្បងៗរបស់ក្រុមប្រឹក្សាភិបាល

(vii) កិច្ចការរដ្ឋបាល និងដំណើរការរបស់ក្រុមប្រឹក្សាភិបាល

ជាងនេះទៅទៀត ក្រុមប្រឹក្សាភិបាលបានកំណត់នូវផ្នែកសម្រាប់ពង្រឹងបន្ថែមនាពេលអនាគតរួមមាន៖

(i) ពង្រឹងទំនាក់ទំនងជាមួយសម្ព័ន្ធធនាគារ

(ii) យុទ្ធសាស្ត្រលំវិស័យឌីជីថល និងស្វែងយល់ឲ្យកាន់តែស៊ីជម្រៅយុទ្ធសាស្ត្រសម្រាប់ទីផ្សារក្នុងស្រុក

(iii) ការពិនិត្យតួនាទីចម្បងៗរបស់ក្រុមប្រឹក្សាភិបាល និង

(iv) ការអភិវឌ្ឍរបស់ក្រុមប្រឹក្សាភិបាល

ជារួមលទ្ធផលនៃការវាយតម្លៃក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ២០២០ គឺវិជ្ជមាន និងពេញចិត្ត ហើយឆ្លុះបញ្ចាំងអំពីភាពខ្លាំងនិងប្រសិទ្ធភាពក្នុងការបំពេញតួនាទីរបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាលទាំងអស់។

ក្នុងអំឡុងពេលនៃការវាយតម្លៃលើប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាភិបាល សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់បានផ្តល់មតិយោបល់ មិនត្រឹមតែចំពោះផ្នែក ដែលត្រូវវាយតម្លៃប៉ុណ្ណោះទេ គឺរួមបញ្ចូលចំពោះផ្នែកដែលក្រុមប្រឹក្សាភិបាលអាចនឹងធ្វើឲ្យប្រសើរឡើងនាពេលខាងមុខផងដែរ។

ការបណ្តុះបណ្តាលអភិបាល

ក្រុមប្រឹក្សាភិបាល បានទទួលស្គាល់ពីសារៈសំខាន់ នៃការបន្តការបណ្តុះបណ្តាលដល់អភិបាលរបស់ខ្លួន ដើម្បីធានាថាអភិបាល ត្រូវបានផ្តល់នូវជំនាញ និងចំណេះដឹងចាំបាច់ក្នុងការបំពេញតួនាទី និងឆ្លើយតបបញ្ហាប្រឈម ដែលក្រុមប្រឹក្សាភិបាលកំពុងជួបប្រទះ។

នៅក្នុងឆ្នាំ២០២០នេះ សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ បានចូលរួមការបណ្តុះបណ្តាលនានា និងសិក្ខាសាលាផ្សេងៗ ដែលពាក់ព័ន្ធនឹងធនាគារ។ សម្រាប់ឆ្នាំ២០២១ ប្រធានបទសំខាន់សម្រាប់ការបណ្តុះបណ្តាល ត្រូវបានកំណត់តាមរយៈការវាយតម្លៃរបស់ក្រុមប្រឹក្សាភិបាល ដែលបានធ្វើឡើង ដោយក្រុមប្រឹក្សាភិបាលរួមមាន៖

(i) ធនាគារកិច្ចបែបឌីជីថល

(ii) សេវាកម្មធនាគារបើកទូលាយ

(iii) ចំណេះផ្នែកឌីជីថល និងបច្ចេកវិទ្យា

កម្មវិធីណែនាំដំបូង

កម្មវិធីណែនាំដំពេញលេញមួយ ត្រូវបានបង្កើតឡើង ដើម្បីសម្រួលដល់អភិបាលថ្មីស្តីពីតួនាទីថ្មីរបស់អភិបាល និងសម្រួលដល់អភិបាល ក្នុងការស្វែងយល់ពីផែនការអាជីវកម្ម និងប្រតិបត្តិការរបស់សម្ព័ន្ធធនាគារក៏ដូចជាធនាគារ។ អភិបាលថ្មីទាំងអស់ ត្រូវចូលរួមកម្មវិធីឲ្យបានឆាប់បំផុតបន្ទាប់ពីត្រូវបានតែងតាំង។ ជាទូទៅកម្មវិធីនេះ មានរយៈពេលពីរថ្ងៃ ដែលរួមបញ្ចូលរបៀបវារៈ ការជួបសម្ភាត់ជាមួយ នាយកប្រតិបត្តិ ក៏ដូចជាសមាជិកគណៈកម្មាធិការប្រតិបត្តិ ហើយតាមរយៈកម្មវិធីនេះ អភិបាលថ្មី នឹងត្រូវបានទទួលព័ត៌មានដោយសង្ខេប និងបច្ចុប្បន្នភាពអំពីឧបសគ្គ និងបញ្ហាដែលធនាគារកំពុងប្រឈម។

ប្រសិទ្ធភាពនៃសវនកម្ម និងការគ្រប់គ្រងហានិភ័យ

ការគ្រប់គ្រងផ្ទៃក្នុង និងការគ្រប់គ្រងហានិភ័យ

ធនាគារ មានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងយ៉ាងពេញលេញ ដែលបានរៀបចំឡើង ដើម្បីធានាថារាល់ហានិភ័យត្រូវបានកាត់បន្ថយ និងវត្ថុបំណងរបស់ធនាគារអាចសម្រេចបាន។ ក្រុមប្រឹក្សាភិបាល ចាត់ទុកថា នេះជាទំនួលខុសត្រូវក្នុងការបង្ហាញឲ្យឃើញនូវ ភាពស្មើគ្នា តុល្យភាព និងការយល់ដឹងពីដំណើរការ នៅលើជំហរ និងការព្យាករណ៍របស់ធនាគារ។ នេះជាតួនាទីរបស់ក្រុមប្រឹក្សាភិបាលក្នុងការពិនិត្យ និងអនុម័តលប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុង ដែលត្រូវបានអនុវត្តដោយធនាគារ រួមជាមួយការត្រួតពិនិត្យហិរញ្ញវត្ថុការត្រួតពិនិត្យប្រតិបត្តិការនិងប្រតិបត្តិតាម និងការគ្រប់គ្រងហានិភ័យ។ ក្រុមប្រឹក្សាភិបាល ចាត់ទុកថានេះ ជាទំនួលខុសត្រូវរបស់ខ្លួន ក្នុងការគោរពតាមដំណើរការនៃការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ និងតាមដានសកម្មភាពរបស់សនវករឯករាជ្យ ក៏ដូចជាមុខងារនៃការគ្រប់គ្រងហានិភ័យរបស់ធនាគារ ដែលត្រូវបានប្រគល់ភារៈកិច្ចជូនគណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម។

របាយការណ៍ស្តីពីការចនាសម្ព័ន្ធក្នុងការគ្រប់គ្រងហានិភ័យ និងវិធីសាស្ត្រក្នុងការគ្រប់គ្រងហានិភ័យ មាននៅទំព័រទី៤៤ដល់ទំព័រ៤៨។ សូមទៅកាន់ទំព័រទី ៤៦ សម្រាប់របាយការណ៍សវនកម្ម តួនាទីរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម។

ចំណុចផ្តោតចម្បង និងអាទិភាពសម្រាប់អនាគត

ក្រៅពីផែនការ ដែលបានគ្រោងទុកក្នុងការពិភាក្សានិងសម្រេច ក្រុមប្រឹក្សាភិបាល បានកំណត់នូវការងារអាទិភាពសំខាន់ៗសម្រាប់ធនាគារនាពេលអនាគតដូចខាងក្រោម៖

ក. ត្រួតពិនិត្យប្រសិទ្ធិភាព ក្នុងការសម្រេចបាននូវយុទ្ធសាស្ត្រ ដែលបានកំណត់នៅក្នុងផែនការ៥ឆ្នាំ (M២៥) ដោយរួមបញ្ចូលនូវគោលការណ៍ បរិស្ថាន សង្គម និងអភិបាលទៅក្នុងអាជីវកម្មរបស់ធនាគារ។

ខ. ពង្រឹងគោលនយោបាយស្តីពីអភិបាលកិច្ច និង

គ. ធានាឲ្យបាននូវប្រសិទ្ធភាពរបស់ផែនការបន្តវេនរបស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់។

របាយការណ៍លើការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង

កាលបរិច្ឆេទនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

ក្រុមប្រឹក្សាភិបាល មានសេចក្តីសោមនស្សរីករាយ ក្នុងការផ្តល់ជូននូវរបាយការណ៍លើការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង ដែលហៅកាត់ថា "របាយការណ៍" ដែលបង្ហាញអំពីលក្ខណៈសំខាន់ៗនៃប្រព័ន្ធគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារក្នុងការិយបរិច្ឆេទ។ របាយការណ៍នេះ បានរៀបចំឡើងស្របទៅតាមប្រកាសស្តីអំពីការត្រួតពិនិត្យផ្ទៃក្នុងនៃស្ថាប័នធនាគារ និងហិរញ្ញវត្ថុ ចេញដោយធនាគារជាតិ នៃកម្ពុជា។

ចំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ទទួលយកនូវចំនួលខុសត្រូវរួមរបស់ខ្លួន ក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុងដ៏សមស្របមួយ ក៏ដូចជាការត្រួតពិនិត្យលើភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពក្នុងការកំណត់ ការវាយតម្លៃ និងការឆ្លើយតបចំពោះហានិភ័យ ដើម្បីសម្រេចបាននូវគោលបំណងរបស់ធនាគារ។ ក្រុមប្រឹក្សាភិបាលដើរ តួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់នូវការត្រួតពិនិត្យហានិភ័យ និងការកំណត់កម្រិតសរុប និងប្រភេទនៃហានិភ័យ ដែលធនាគារ នឹងធ្វើការទទួលយក ដើម្បីសម្រេចបាននូវគោលបំណងអាជីវកម្ម និងយុទ្ធសាស្ត្រ (ហានិភ័យ ដែលអាចទទួលយកបាន) របស់ខ្លួន។ ក្រុមប្រឹក្សាភិបាល ចូលរួមយ៉ាងសកម្មក្នុងការកំណត់គោលបំណង និងយុទ្ធសាស្ត្ររបស់ធនាគារ និងធានាឲ្យបានថាហានិភ័យត្រូវបានបន្ទួរបន្ថយឲ្យសមស្របនឹងហានិភ័យ ដែលអាចទទួលយកបានមកអនុម័ត។ នៅក្នុងទិដ្ឋភាព ដែលមានដែនកំណត់លើប្រព័ន្ធគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង អាចត្រឹមតែផ្តល់នូវការធានាសមហេតុផល ជាជាងការធានាដាច់ខាតចំពោះការសម្រេចគោលបំណងរបស់ធនាគារ និងប្រឆាំងនូវកំហុសឆ្គងនៃការបង្ហាញផ្នែកហិរញ្ញវត្ថុជាសារវន្ត ការខ្លែងបន្លំ និងការខាតបង់។

ក្រុមប្រឹក្សាភិបាលបានបង្កើតឲ្យមានការគ្រប់គ្រងហានិភ័យ និងរចនាសម្ព័ន្ធអភិបាលកិច្ច នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដ៏រឹងមាំមួយ ដែលមានសារៈសំខាន់នៅក្នុងការកំណត់របៀប និងវប្បធម៌ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង។ ដើម្បីអនុវត្តតួនាទី ក្នុងការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព ក្រុមប្រឹក្សាភិបាល មានជំនួយពីគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការក្រុមប្រឹក្សាសវនកម្ម ក្នុងការត្រួតពិនិត្យរាល់បញ្ហាដែលជាប់ពាក់ព័ន្ធនឹងហានិភ័យការប្រតិបត្តិតាម និងការត្រួតពិនិត្យ។ ក្រុមប្រឹក្សាភិបាល ទទួលបានរបាយការណ៍ជាទៀងទាត់ពីគណៈកម្មាការ ដើម្បីផ្តល់ដំណឹងអំពីការងារ ការជជែកវែកញែក ការពិភាក្សា និងការសម្រេចផ្សេងៗលើបញ្ហានានា។

ក្រុមប្រឹក្សាភិបាលមានការពេញចិត្ត ដែលធនាគារបានអនុវត្តការត្រួតពិនិត្យជាប្រចាំ ដោយកំណត់វាយតម្លៃតាមដានគ្រប់គ្រង និងឆ្លើយតបទៅនឹងហានិភ័យសំខាន់ៗ ដែលបានជួបប្រទះដោយធនាគារ ដើម្បីសម្រេចបាននូវគោលដៅ និងគោលបំណងអាជីវកម្ម និងបរិយាកាសអាជីវកម្ម ដែលពោរពេញដោយការប្រកួតប្រជែង និងបង្កើនការត្រួតពិនិត្យបទប្បញ្ញត្តិជាពិសេស ក្នុងអំឡុងពេលនៃជំងឺរាតត្បាតកូវីដ១៩ លើសកលលោក។ ដំណើរការដែលកំពុងបន្តនេះត្រូវបានបង្កើតឡើង ពេញមួយការិយបរិច្ឆេទនៃការត្រួតពិនិត្យនេះ រហូតដល់ការិយបរិច្ឆេទនៃការអនុម័តលើរបាយការណ៍នេះ សម្រាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំ។

ចំនួលខុសត្រូវរបស់គណៈគ្រប់គ្រង

គណៈគ្រប់គ្រង គឺទទួលខុសត្រូវជារួមក្នុងការអនុវត្តនូវគោលនយោបាយ និងនីតិវិធីរបស់ក្រុមប្រឹក្សាភិបាលលើហានិភ័យ និងការគ្រប់គ្រង ហើយតួនាទីរបស់ខ្លួនរួមមាន៖

- កំណត់ និងវាយតម្លៃហានិភ័យ ដែលពាក់ព័ន្ធនឹងអាជីវកម្ម និងការសម្រេចបាននូវគោលបំណង និងយុទ្ធសាស្ត្រអាជីវកម្មរបស់ធនាគារ
- រៀបចំនូវគោលនយោបាយ និងនីតិវិធី ដែលពាក់ព័ន្ធ ដើម្បីគ្រប់គ្រងហានិភ័យទាំងនេះ ដោយប្រតិបត្តិតាមចក្ខុវិស័យជាយុទ្ធសាស្ត្រ និងកម្រិតហានិភ័យមួយដែលអាចទទួលយកបានរបស់ធនាគារ
- បង្កើត អនុវត្ត និងតាមដានលើប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
- អនុវត្តដំណោះស្រាយឆ្លើយតបទៅនឹងកង្វះខាតនៃការប្រតិបត្តិតាម ដូចដែលបានចង្អុលបង្ហាញដោយក្រុមប្រឹក្សាភិបាល និង
- រាយការណ៍ជូនក្រុមប្រឹក្សាភិបាល ឲ្យបានទាន់ពេលវេលានូវការផ្លាស់ប្តូរណាមួយនៃហានិភ័យ ឬហានិភ័យដែលនឹងកើតឡើង និងសកម្មភាពកែតម្រូវ ឬសកម្មភាពកាត់បន្ថយផ្សេងៗ ដែលបានអនុវត្ត។

ការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

ការគ្រប់គ្រងហានិភ័យ

ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ

ការគ្រង់គ្រងហានិភ័យ បានវិវឌ្ឍទៅជាផ្នែកមួយដ៏សំខាន់មួយ សម្រាប់ការសម្រេចចិត្តជាយុទ្ធសាស្ត្រ ដើម្បីគាំទ្រយុទ្ធសាស្ត្រអាជីវកម្ម ព្រមទាំងធ្វើឲ្យមានតុល្យភាពរវាងកម្រិតហានិភ័យ ទៅនឹងកម្រិតរង្វាន់ដែលប្រាថ្នា។ ដើម្បីបំពេញបន្ថែមនេះ យើងបានអនុម័តក្របខ័ណ្ឌការគ្រប់គ្រងហានិភ័យរបស់សម្ព័ន្ធធនាគារ មេយវ៉ៃង ដើម្បីរៀបចំឲ្យមានការប្រុងប្រយ័ត្ន និងយល់ដឹងពីហានិភ័យសំខាន់ៗ ចំពោះសមិទ្ធិផលនៃគោលបំណងសំខាន់បំផុតរបស់ធនាគារ ពោលគឺការផ្តល់សេវាហិរញ្ញវត្ថុ ដែលមានគោលបំណង តាមរយៈការដាក់អតិថិជន និងសហគមន៍ឲ្យកាន់តែ ទូលំទូលាយ នូវអ្វីគ្រប់យ៉ាងដែលធនាគារធ្វើ។ វាត្រូវបានគាំទ្រដោយបណ្តុំនៃអាគារ ដែលដើរតួជាមូលដ្ឋានគ្រឹះ ក្នុងការជំរុញវប្បធម៌នៃការគ្រប់គ្រងហានិភ័យ ការអនុវត្ត និងដំណើរការគ្រប់គ្រងហានិភ័យ៖

១

វប្បធម៌ហានិភ័យ

វប្បធម៌ហានិភ័យ គឺជាសមាសធាតុសំខាន់មួយក្នុងការពង្រឹងអភិបាលកិច្ចនៃហានិភ័យ និងបង្កើតគោលការណ៍គ្រឹះ នៃការគ្រប់គ្រងហានិភ័យរឹងមាំ។

២

ការធានារ៉ាប់រងហានិភ័យ

ធនាគារ ត្រូវកំណត់យុទ្ធសាស្ត្រ អាជីវកម្ម គោលដៅ និងគោលបំណងរបស់ខ្លួន និងវាយតម្លៃលើហានិភ័យរបស់ខ្លួន ដែលមាននៅក្នុងយុទ្ធសាស្ត្រនោះមុនពេល ដែលវាអាចបង្ហាញពីហានិភ័យ ដែលអាចទទួលយកបាន។

៣

ហានិភ័យ ដែលអាចទទួលយកបាន

ហានិភ័យ ដែលអាចទទួលយកបាន កំណត់ពីកម្រិតនៃហានិភ័យ ដែលធនាគារមានបំណងក្នុងការសន្មត់សមត្ថភាពហានិភ័យរបស់ខ្លួន។

៤

ការឆ្លើយតបនៃហានិភ័យ

ការជ្រើសរើសចម្លើយ ដែលសមស្របទៅនឹងហានិភ័យ គឺជាការចាំបាច់ ដើម្បីតម្រឹមហានិភ័យជាមួយនឹងភាពអត់ធ្មត់ទៅនឹងហានិភ័យរបស់សម្ព័ន្ធ និងហានិភ័យដែលអាចទទួលយកបាន។

៥

អភិបាលកិច្ច និងការត្រួតពិនិត្យហានិភ័យ

រចនាសម្ព័ន្ធ អភិបាលកិច្ចច្បាស់លាស់មានប្រសិទ្ធភាព និងរឹងមាំ ជាមួយនឹងភាពទំនួលខុសត្រូវ ដែលបានកំណត់ច្បាស់លាស់ តម្លាភាព និងជាប់លាប់។

៦

ប្រតិបត្តិការណ៍ និងនីតិវិធីនៃការគ្រប់គ្រងហានិភ័យ

នីតិវិធី នៃការគ្រប់គ្រងហានិភ័យដ៏រឹងមាំត្រូវបានបង្កើតឡើង ដើម្បីកំណត់វាស់វែងត្រួតពិនិត្យតាមដាន និងរាយការណ៍នូវហានិភ័យ ដែលមានជាប់ទាក់ទងនឹងផលិតផល និងសកម្មភាពទាំងអស់ ដែលអនុវត្តដោយធនាគារ។

៧

ស្ត្រេសតេស្ត

កម្មវិធីស្ត្រេសតេស្ត (Stress Testing) ត្រូវបានប្រើដើម្បីកំណត់ទៅនឹងព្រឹត្តិការណ៍ ដែលអាចកើតមាន ឬការផ្លាស់ប្តូរនាពេលអនាគត នៅក្នុងស្ថានភាពហិរញ្ញវត្ថុ និងសេដ្ឋកិច្ចដែលអាចមានផលប៉ះពាល់ មិនល្អដល់ទំហំរបស់ធនាគារ។

៨

ធនធាន និងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ

ធានាបាននូវធនធានគ្រប់គ្រាន់ ហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកទេស ត្រូវបានបង្កើតឡើង ដើម្បីឲ្យការគ្រប់គ្រងហានិភ័យ ប្រកបដោយប្រសិទ្ធភាព។

របាយការណ៍លើការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង

ការិយបរិច្ឆេទនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

ហានិភ័យ ដែលអាចទទួលយកបាន

ហានិភ័យ ដែលអាចទទួលយកបានរបស់ធនាគារ គឺជាធាតុសំខាន់ក្នុងក្របខ័ណ្ឌការគ្រប់គ្រង ហានិភ័យ ហើយត្រូវបានជំរុញដោយការដឹកនាំពីថ្នាក់លើ និងការចូលរួមពីថ្នាក់គ្រប់គ្រងទាំងអស់។ ហានិភ័យ ដែលអាចទទួលយកបាន បានធ្វើឲ្យក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំជាន់ខ្ពស់អាចទំនាក់ទំនងស្វែងយល់ និងសិក្សាពីប្រភេទ និងកម្រិតនៃហានិភ័យ ដែលធនាគារអាចនឹងទទួលយកបានក្នុងការសម្រេចគោលបំណងអាជីវកម្មខណៈ ដែលសំពាធស្ថិតនៅក្រោមបរិយាកាសតានតឹងលើកយកមកពិចារណា។

ហានិភ័យដែលអាចទទួលយកបាន ត្រូវបានរួមបញ្ចូលទៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រហើយវានៅតែរក្សាសន្ទុះ និងឆ្លើយតបទៅនឹងកត្តាប្រែប្រួលខាងក្នុង និងខាងក្រៅដែលមានដូចជាលក្ខខណ្ឌទីផ្សារ ការរំពឹងទុករបស់ភាគីពាក់ព័ន្ធ និងសមត្ថភាពផ្ទៃក្នុង។ លើសពីនេះទៅទៀត ការរៀបចំផែនការថវិកា គឺស្របទៅនឹងហានិភ័យដែលអាចទទួលយកបាន ដើម្បីធានាថាការព្យាករចំណូលដែលបានមកពីសកម្មភាពអាជីវកម្មស្របតាមទម្រង់ហានិភ័យដែលបានបង្កើតឡើង។ ហានិភ័យដែលអាចទទួលយកបានរបស់យើងផ្តល់នូវភាពសមស្របជាមួយនឹងរចនាសម្ព័ន្ធក្នុងការទទួលយកហានិភ័យ និងត្រូវបានដាក់បញ្ចូលទៅក្នុងសកម្មភាពអាជីវកម្មប្រចាំថ្ងៃ ហើយធ្វើការសម្រេចតាមរយៈធនាគារ។តាមការណែនាំនៃគោលការណ៍ទាំងនេះ ហានិភ័យ ដែលអាចទទួលយកបានរបស់យើង ត្រូវបានផ្សព្វផ្សាយតាមរយៈរបាយការណ៍ហានិភ័យដែល អាចទទួលយកបាន សម្រាប់គ្រប់ហានិភ័យជាសារវ័ន្តទូទាំងធនាគារ ដើម្បីរក្សាតុល្យភាពគោលបំណងយុទ្ធសាស្ត្ររបស់ធនាគារ។

គោលការណ៍ នៃហានិភ័យដែលអាចទទួលយកបាន



អភិបាលកិច្ច និងការគ្រប់គ្រងហានិភ័យ

គំរូអភិបាលកិច្ចហានិភ័យផ្តល់នូវរចនាសម្ព័ន្ធអភិបាលកិច្ច ដែលមានតម្លាភាព និងប្រសិទ្ធភាព ដែលជំរុញឲ្យមានការចូលរួមយ៉ាងសកម្ម ពីក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំជាន់ខ្ពស់នៅក្នុងដំណើរការគ្រប់គ្រងហានិភ័យ ដើម្បីធានាឲ្យបាននូវទស្សនៈរួមមួយលើហានិភ័យនៅក្នុងធនាគារ។ គំរូអភិបាលកិច្ច មានបំណងបង្កើតឲ្យមានទំនួលខុសត្រូវ និងភាពម្ចាស់ការ ព្រមទាំងរៀបចំ ឲ្យមានឯករាជ្យភាព និងការបែងចែកភារកិច្ចសមស្របរវាងខ្សែការពារទាំងបី។ ការគ្រប់គ្រងហានិភ័យ មាននៅគ្រប់កំរិតឋានានុក្រម និងត្រូវបានបញ្ជាក់តាមរយៈកម្រិតផ្សេងៗ នៃគណៈកម្មាធិការ សង្វាក់ពាណិជ្ជកម្ម មុខងារត្រួតពិនិត្យ និងមុខងាររាយការណ៍។

វប្បធម៌ហានិភ័យ និងការប្រតិបត្តិតាម

វប្បធម៌ហានិភ័យ និងការប្រតិបត្តិតាម ត្រូវបានជំរុញពីថ្នាក់លើ និងបំពេញបន្ថែមដោយថ្នាក់កណ្តាល ដើម្បីឲ្យជ្រួតជ្រាបនូវគុណតម្លៃ និងគោលការណ៍នៃការប្រព្រឹត្ត ដែលបានរំពឹងទុក ក្នុងការដុះខាត់ឥរិយាបទរបស់និយោជិតនៅគ្រប់កម្រិតអាជីវកម្ម និងសកម្មភាពរបស់ធនាគារ។ ក្របខ័ណ្ឌ និងគោលការណ៍ហានិភ័យត្រូវបានគេកំណត់យ៉ាងច្បាស់ ប្រាស័យទាក់ទងជាប្រចាំ ហើយបន្តពង្រឹងនៅក្នុងធនាគារ ដើម្បីបញ្ជ្រៀបនូវវប្បធម៌ដ៏រឹងមាំមួយ ដែលបណ្តុះនូវការកំណត់អត្តសញ្ញាណ ការវាយតម្លៃ និងការកាត់បន្ថយហានិភ័យយ៉ាងសកម្ម ដែលជាផ្នែកមួយនៃទំនួលខុសត្រូវរបស់និយោជិតទាំងអស់នៅក្នុងធនាគារ។

ជាផ្នែកនៃវប្បធម៌ហានិភ័យ និងប្រតិបត្តិតាម ធនាគារបានដាក់បញ្ចូលវប្បធម៌ប្រតិបត្តិតាម ដែលក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងជាន់ខ្ពស់ និងនិយោជិតគ្រប់រូបរបស់ធនាគារ ប្តេជ្ញាប្រកាន់ខ្ជាប់ចំពោះតម្រូវការដែលទាក់ទងទៅនឹងច្បាប់ បទបញ្ញា និយ័តកម្ម និងគោលការណ៍ណែនាំផ្សេងៗ។ ការប្តេជ្ញានេះ ត្រូវបានបង្ហាញយ៉ាងច្បាស់តាមរយៈការបង្កើតគោលការណ៍ច្បាប់ នីតិវិធី និងការគ្រប់គ្រង ដើម្បីធានាឲ្យបានថា ហានិភ័យពីការមិនប្រតិបត្តិតាម ត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។

ប្រតិបត្តិការ និងនីតិវិធីនៃការគ្រប់គ្រងហានិភ័យ

ប្រតិបត្តិការ និងនីតិវិធីនៃការគ្រប់គ្រងហានិភ័យ អនុញ្ញាតឲ្យអាចកំណត់ វាស់វែង ត្រួតពិនិត្យ តាមដាន និង រាយការណ៍ពីទំហំហានិភ័យទូទាំងធនាគារ។

ការកំណត់

- កំណត់អត្តសញ្ញាណ យល់ដឹង និងវាយតម្លៃហានិភ័យដែលពាក់ព័ន្ធនឹងផលិតផល សកម្មភាព និងគំនិតផ្តួចផ្តើមអាជីវកម្ម ។
- កំណត់ហានិភ័យបានភ្លាមៗ និងធានាឲ្យមាននូវដំណើរការនៃការគ្រប់គ្រងហានិភ័យល្អមួយ ដើម្បីចាត់ចែង និងគ្រប់គ្រងហានិភ័យផលិតផល។
- អនុម័តយកវិធីសាស្ត្រសម្លឹងមើលទៅមុខ ក្នុងការកំណត់អត្តសញ្ញាណហានិភ័យ ដែលលេចឡើង ដើម្បីធានា ថាសកម្មភាពសមស្របនានាត្រូវបានអនុវត្តក្នុងការកាត់បន្ថយផលប៉ះពាល់របស់ធនាគារ។

ការវាស់វែង

- បង្កើតបច្ចេកទេសវាស់វែងហានិភ័យនៅវិមាត្រផ្សេង នៃកត្តាហានិភ័យដើម្បីធានាឲ្យមានការបន្តនូវការវាយតម្លៃឡើងវិញ និងការកំណត់អត្តសញ្ញាណហានិភ័យ។
- វាស់វែងផលប៉ះពាល់រួមរបស់ធនាគារ ជាអាជីវកម្មមួយ និងប្រទេសមួយ តាមប្រភេទហានិភ័យ ក៏ដូចជាផលប៉ះពាល់រយៈពេលខ្លី និងរយៈពេលវែង។

ការត្រួតពិនិត្យ

- បង្កើតការគ្រប់គ្រងទាំងគុណភាព និងបរិមាណ ដែលរួមមានកម្រិត និងដែនកំណត់ហានិភ័យ ដើម្បីត្រួតពិនិត្យ និងគ្រប់គ្រង ទំហំហានិភ័យ ដែលបានកំណត់រួច។
- អនុវត្តបច្ចេកទេសបញ្ជៀសហានិភ័យក្នុងគោលបំណងកាត់បន្ថយហានិភ័យ ដែលមានស្រាប់ ឬ បង្ការហានិភ័យថ្មីៗ ឬកំពុងលេចឡើងកុំឲ្យកើតមានឡើង។

ការតាមដាន និងរាយការណ៍

- ត្រួតពិនិត្យសូចនាករហានិភ័យសំខាន់ៗនៅពេលខាងមុខ និងសញ្ញាព្រមាន ដើម្បីធានាឲ្យបានថាសកម្មភាពគ្រប់គ្រាន់ និងទាន់ពេលត្រូវបានរៀបចំឡើង ដើម្បីកាត់បន្ថយ សក្តានុពល នៃហានិភ័យណាមួយ ចំពោះធនាគារ។
- រាយការណ៍អំពីស្ថានភាពនៃការប្រតិបត្តិតាម ទៅកាន់គណៈកម្មាធិការហានិភ័យនៃថ្នាក់គណៈគ្រប់គ្រង និងថ្នាក់ក្រុមប្រឹក្សាភិបាល ក៏ដូចជាទៅក្រុមប្រឹក្សាភិបាលឲ្យបានទៀងទាត់។

របាយការណ៍លើការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង

ការិយបរិច្ឆេទនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

ក្របខ័ណ្ឌគ្រប់គ្រងការប្រតិបត្តិតាម

ក្របខ័ណ្ឌនេះ ផ្តល់នូវគោលការណ៍ និងសេចក្តីណែនាំជាមូលដ្ឋានទៅលើ ការគ្រប់គ្រង ការប្រតិបត្តិតាម និងការត្រួត ពិនិត្យសម្រាប់ធនាគារ។ វាត្រូវបានអនុម័ត និងអនុវត្តនៅគ្រប់ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រផ្សេងៗរបស់ធនាគារ។ ក្របខ័ណ្ឌនេះ បម្រើជាឧបករណ៍សំខាន់មួយសម្រាប់មន្ត្រីប្រតិបត្តិតាម ជាមួយនឹងក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងជាន់ខ្ពស់ និងគ្រប់និយោជិតទាំងអស់ក្នុងការស្វែងយល់ អនុវត្តតាម និងគ្រប់គ្រងហានិភ័យនៃ ការប្រតិបត្តិតាម។

- គោលការណ៍សំខាន់ៗសម្រាប់ការគ្រប់គ្រងហានិភ័យនៃការប្រតិបត្តិតាមរយៈធនាគារ
- យុទ្ធសាស្ត្ររួម ក្នុងការគ្រប់គ្រងហានិភ័យនៃការប្រតិបត្តិតាម ដើម្បីធានាឲ្យមានភាពសមស្របនៅក្នុងការអនុវត្ត ក្នុងការបំពេញតាមកាតព្វកិច្ចបទប្បញ្ញត្តិ និងច្បាប់នៅទូទាំងធនាគារ
- បទដ្ឋានអប្បបរមាស្តីពីការពឹងទុកសំរាប់ការគ្រប់គ្រងការប្រតិបត្តិតាម និង
- តួនាទី និងការទទួលខុសត្រូវ នៃការគ្រប់គ្រងហានិភ័យនៃការប្រតិបត្តិតាម នៅទូទាំងធនាគារ។

ស្ត្រេសតេស្ត

កម្មវិធីស្ត្រេសតេស្ត (Stress Testing) របស់ធនាគារ ត្រូវបានដាក់បញ្ចូល នៅក្នុងប្រតិបត្តិការគ្រប់គ្រងហានិភ័យ និងដើមទុន ហើយក៏ជាមុខងារគន្លឹះនៃការរៀបចំផែនការអាជីវកម្ម។ កម្មវិធីនេះ ដើរតួនាទីជាឧបករណ៍សម្រាប់ព្យាករណ៍ ដើម្បីសម្របសម្រួលការយល់ដឹងអំពីអត្តសញ្ញាណហានិភ័យស្ថិតនៅក្រោមព្រឹត្តិការណ៍ធ្ងន់ធ្ងរ ប៉ុន្តែអាចជឿជាក់បាន ដែលបានចូលរួមចំណែកដោយកត្តាផ្សេងៗដូចជា សេដ្ឋកិច្ចនយោបាយ បរិស្ថាន និងបញ្ហាក់អំពីផលប៉ះពាល់ចំពោះធនាគារ និងធ្វើយ៉ាងណាដើម្បីគ្រប់គ្រងហេតុការណ៍ទាំងអស់នេះឲ្យបានទាន់ពេល។

ការផ្តល់ប្រាក់កម្ចីប្រកបដោយការទទួលខុសត្រូវ

ភាពជោគជ័យលើហិរញ្ញវត្ថុរយៈពេលវែងរបស់យើង ពឹងផ្អែកលើសមត្ថភាពរបស់យើង ដើម្បីកំណត់អត្តសញ្ញាណ និងលើកឡើងនូវបញ្ហាបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ដែលបង្កើតហានិភ័យចំពោះឱកាសអាជីវកម្មរបស់ធនាគារ ប៉ុន្តែសំខាន់ជាងនេះទៀត ដើម្បីកំណត់វិស័យឱកាសសម្រាប់អាជីវកម្ម ក៏ដូចជាអតិថិជនរបស់យើងឲ្យរីកចម្រើនប្រកបដោយចីរភាព។ ជាមួយនឹងបញ្ហានេះដែរ នឹងត្រូវបានរៀបចំឡើងដោយផ្អែកលើគោលការណ៍នៃការផ្តល់ប្រាក់កម្ចីប្រកបដោយការទទួលខុសត្រូវ ដែលត្រូវបានបង្កប់នៅក្នុងគោលនយោបាយ បរិស្ថាន សង្គម និងអភិបាលកិច្ចរបស់ធនាគារមេយវើង យើងពិនិត្យឡើងវិញ និងលើកកំពស់ការអនុវត្ត (ESG) របស់យើង ដោយធ្វើការជាមួយភាគីពាក់ព័ន្ធ ដើម្បីជំរុញកិច្ចខិតខំប្រឹងប្រែងក្នុងការផ្តល់ប្រាក់កម្ចីប្រកបដោយការទទួលខុសត្រូវ។

ក្របខណ្ឌការគ្រប់គ្រងហានិភ័យតាមអ៊ីនធឺណែត និងបច្ចេកវិទ្យា

ក្របខណ្ឌការគ្រប់គ្រងហានិភ័យតាមអ៊ីនធឺណែតបានបង្កើតឡើង សម្រាប់ការកំណត់អត្តសញ្ញាណ ហានិភ័យកសាងភាពធន់ ការគំរាមកំហែងតាមអ៊ីនធឺណែត និងឆ្លើយតបយ៉ាងមានប្រសិទ្ធភាពចំពោះព្រឹត្តិការណ៍ហានិភ័យតាមអ៊ីនធឺណែតនានា។ ក្របខ័ណ្ឌនេះ រួមមានយុទ្ធសាស្ត្រការគ្រប់គ្រងហានិភ័យតាមអ៊ីនធឺណែតរចនាសម្ព័ន្ធអភិបាលកិច្ច និងឧបករណ៍គ្រប់គ្រងហានិភ័យ។ ក្របខ័ណ្ឌនេះបំពេញបន្ថែមលើក្របខ័ណ្ឌការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា ហើយគ្របដណ្តប់ទាំងអាជីវកម្ម និងបច្ចេកវិទ្យាដោយផ្តោតលើស្រទាប់សំខាន់ៗនៃមនុស្ស ប្រតិបត្តិការ និងបច្ចេកវិទ្យា។ ជាមួយនឹងការចេញផ្សាយនៃការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា ដោយធនាគារជាតិនៃកម្ពុជា (NBC) ក្របខណ្ឌការគ្រប់គ្រងហានិភ័យតាមអ៊ីនធឺណែត គឺត្រូវបានត្រួតពិនិត្យ ដើម្បីបន្តអនុលោមជាមួយតម្រូវការបទប្បញ្ញត្តិ។

ក្របខណ្ឌការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា កំណត់ស្តង់ដារសម្រាប់ការកំណត់អត្តសញ្ញាណហានិភ័យ និងទាមទារប្រព័ន្ធត្រួតពិនិត្យផ្សេងៗនៅក្នុងអង្គភាពបច្ចេកវិទ្យា ដែលមានមុខងារជាប់ទាក់ទង និងទទួលយកសកម្មភាពកែតម្រូវហានិភ័យដោយសមស្រប។ ទាំងនេះ គឺត្រូវបានបង្កើតឡើង ដើម្បីធ្វើឲ្យមានបទដ្ឋាននៃបរិស្ថានប្រតិបត្តិការបច្ចេកវិទ្យា ដែលនឹងអាចបង្កើនគុណភាពសេវាកម្មជូនដល់អតិថិជន និងអង្គភាពអាជីវកម្មផងដែរ។

ការត្រួតពិនិត្យផ្ទៃក្នុង

ធាតុសំខាន់ៗនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង បានបង្កើតដោយក្រុមប្រឹក្សាភិបាល ដែលផ្តល់នូវប្រសិទ្ធភាពនៃអភិបាលកិច្ច និងការត្រួតពិនិត្យ សម្រាប់ការត្រួតពិនិត្យផ្ទៃក្នុង ដែលរួមមាន៖

- **រចនាសម្ព័ន្ធអង្គភាព**

  ក្រុមប្រឹក្សាភិបាល បានបង្កើតរចនាសម្ព័ន្ធអង្គភាពមួយ ដែលបានកំណត់យ៉ាងច្បាស់នូវទំនួលខុសត្រូវ សិទ្ធិអំណាច និងទំនួលខុសត្រូវទៅតាមតម្រូវការអាជីវកម្ម និងប្រតិបត្តិការ ដែលគាំទ្រការថែទាំនៃប្រព័ន្ធការត្រួតពិនិត្យដ៏រឹងមាំ។

- **គម្រោងអាជីវកម្ម និងថវិកាប្រចាំឆ្នាំ**

  ក្រុមប្រឹក្សាភិបាលពិចារណា និងអនុម័តគម្រោងអាជីវកម្មថវិកាប្រចាំឆ្នាំសម្រាប់ការិយបរិច្ឆេទ។ សមិទ្ធិផលប្រតិបត្តិការ ត្រូវបានពិនិត្យឡើងវិញជៀបនឹងលទ្ធផល គោលដៅជារៀងរាល់ខែដែលអនុញ្ញាតឲ្យមានពេលវេលា សម្រាប់ការឆ្លើយតបសមស្របនិងសកម្មភាពចាំបាច់ ដើម្បីចាត់វិធានការ។ ក្រុមប្រឹក្សាភិបាលពិនិត្យមើលជាទៀងទាត់ នូវរបាយការណ៍ពីគណៈគ្រប់គ្រង ចំពោះស្ថិតិប្រតិបត្តិការសំខាន់ៗ ក៏ដូចជាបញ្ហាទាក់ទងនឹងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ។ រាល់ការផ្លាស់ប្តូរ ឬវិសោធនកម្មណាមួយ នៃគោលនយោបាយរបស់ធនាគារ ត្រូវបានបញ្ចូលទៅក្នុងក្រុមប្រឹក្សាភិបាល ដើម្បីអនុម័ត។

- **ការត្រួតពិនិត្យដោយគណៈកម្មាធិការគ្រប់គ្រងហានិភ័យនៃក្រុមប្រឹក្សាភិបាល**

  ក្រុមប្រឹក្សាភិបាល ក៏បានផ្ទេរទំនួលខុសត្រូវ នៃការត្រួតពិនិត្យប្រសិទ្ធភាពលើការគ្រប់គ្រងហានិភ័យទៅឲ្យគណៈកម្មាធិការគ្រប់គ្រងហានិភ័យ។ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ មានទំនួលខុសត្រូវក្នុងការបង្កើតគោលនយោបាយ និងក្របខ័ណ្ឌ ដើម្បីកំណត់ តាមដាន គ្រប់គ្រង និងត្រួតពិនិត្យធាតុហានិភ័យជាសារវន្តដែលប៉ះពាល់ដល់ពាណិជ្ជកម្ម។ ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហានិភ័យ ត្រូវបានត្រួតពិនិត្យ និងវាយតម្លៃដោយផ្នែកគ្រប់គ្រងហានិភ័យ និងតណាទានជាប្រចាំ។ គណៈកម្មាធិការគ្រប់គ្រងហានិភ័យក៏ជួយក្រុមប្រឹក្សាភិបាលផងដែរ ក្នុងការវាយតម្លៃលើហានិភ័យប្រតិបត្តិតាម និងធានាថាការត្រួតពិនិត្យ បានផ្តល់ឲ្យមានការយកចិត្តទុកដាក់ចាំបាច់ស្ថិតក្នុងកម្រិតខ្ពស់បំផុត ដើម្បីបញ្ជាក់ថាហានិភ័យប្រតិបត្តិតាមបទបញ្ញត្តិ គឺត្រូវបានគ្រប់គ្រង ប្រកបដោយប្រសិទ្ធភាព ដើម្បីគាំទ្រកំណើនអាជីវកម្ម ឲ្យសមស្របជាមួយនឹងសេចក្តីប្រាថ្នានិងកំរិតហានិភ័យ ដែលអាចទទួលយកបានរបស់ធនាគារ។ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ត្រួតពិនិត្យ និងវាយតម្លៃផងដែរ នូវភាពគ្រប់គ្រាន់នៃហេដ្ឋារចនាសម្ព័ន្ធ ធនធាន និងប្រព័ន្ធ ដើម្បីគ្រប់គ្រង ហានិភ័យប្រតិបត្តិតាមនៅទូទាំងធនាគារ និងផ្តល់អនុសាសន៍ធ្វើឲ្យប្រសើរឡើង ដើម្បីធានាដើម្បីធានាប្រសិទ្ធភាពនៃក្របខ័ណ្ឌប្រតិបត្តិតាម។

- **ការត្រួតពិនិត្យដោយគណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល**

  គណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលដើម្បី ជួយក្នុងការប្រតិបត្តិនៃអភិបាលកិច្ចរបស់ខ្លួន ត្រួតពិនិត្យទំនួលខុសត្រូវ និងដើម្បីធានាឲ្យបានថា ដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុនៃធនាគារ អាចជឿទុកចិត្តបាន និងមានតម្លាភាព។ ទំនួលខុសត្រូវនេះ រួមបញ្ចូលទាំង ការវាយតម្លៃនៃប្រសិទ្ធភាព និងភាពគ្រប់គ្រាន់នៃអភិបាលកិច្ចរបស់ធនាគារ ការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង តាមរយៈមុខងារសវនកម្មផ្ទៃក្នុង។ គណៈកម្មាធិការក្រុមប្រឹក្សាសវនកម្ម ត្រួតពិនិត្យយ៉ាងសកម្មលើឯករាជ្យភាពរបស់សវនកម្មផ្ទៃក្នុងវិសាលភាពការងារ និងធនធាននៃសវនករផ្ទៃក្នុង។ គណៈកម្មាធិការសវនកម្ម នៃក្រុមប្រឹក្សាភិបាល មានការប្រជុំតាមកាលវិភាគជាមូលដ្ឋាន ដើម្បីពិនិត្យ និងស៊ើបអង្កេតរបាយការណ៍សវនកម្ម ដែលរៀបចំឡើងដោយសវនកម្មផ្ទៃក្នុង ហើយទទួលយកមកមកពិចារណា ពិភាក្សា លើរបាយការណ៍ ដែលដូចគ្នា នៅក្នុងគណៈកម្មាធិការក្រុមប្រឹក្សាសវនកម្មផ្ទៃក្នុង។ ប្រសិនបើចាំបាច់ ចំនុចគួរកែលម្អក្នុងការគ្រប់គ្រងដែលសំខាន់ៗ ត្រូវបានលើកឡើងដោយគណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល ទៅកាន់ក្រុមប្រឹក្សាភិបាលសម្រាប់ពិភាក្សាបន្តទៀត។ គណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល ក៏ពិភាក្សាលើការរកឃើញផ្សេងៗរបស់សវនករ ដែលមិនទាន់បានដោះស្រាយ ដើម្បីធានាថាគណៈគ្រប់គ្រងអនុវត្តសកម្មភាពកែតម្រូវសំខាន់ៗ តាមកាលកំណត់ ដែលបានប្តេជ្ញា។

- **គណៈកម្មាធិការគ្រប់គ្រងថ្នាក់ប្រតិបត្តិ**

  គណៈគ្រប់គ្រង បង្កើតគណៈកម្មាធិការគ្រប់គ្រងថ្នាក់ប្រតិបត្តិផ្សេងៗ ដើម្បីជួយ និងគាំទ្រគណៈកម្មាធិការក្រុមប្រឹក្សាភិបាលនានាក្នុងការត្រួតពិនិត្យផ្នែកសំខាន់ៗ នៃប្រតិបត្តិការអាជីវកម្ម។ គណៈកម្មាការគ្រប់គ្រងថ្នាក់ប្រតិបត្តិទាំងអស់ រួមមានគណៈកម្មាធិការប្រតិបត្តិ គណៈកម្មាធិការតណាទាន គណៈកម្មាការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម គណៈកម្មាធិការដឹកនាំបច្ចេកវិទ្យាព័ត៌មាន គណៈកម្មាធិការដឹកនាំគម្រោង គណៈកម្មាធិការសវនកម្មផ្ទៃក្នុងគណៈកម្មាធិការនិយោជិត និងគណៈកម្មាធិការគ្រប់គ្រងប្រតិបត្តិតាម។

- **ការគ្រប់គ្រងទ្រព្យសកម្មផ្នែកព័ត៌មាន**

  ការសម្ងាត់ សុចរិតភាព និងសុពលភាពនៃព័ត៌មាន គឺមានសារៈសំខាន់ដល់ប្រតិបត្តិការប្រចាំថ្ងៃ និងដើម្បីសម្របសម្រួល ដល់គណៈគ្រប់គ្រងក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ គោលការណ៍ណែនាំការគ្រប់គ្រងហានិភ័យព័ត៌មានរបស់ធនាគារ មេយវើង ជាគោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងទ្រព្យសកម្មផ្នែកព័ត៌មានប្រកបដោយប្រសិទ្ធភាព។ ព័ត៌មានទាំងអស់ត្រូវតែ គ្រប់គ្រង និងការពារឲ្យបានត្រឹមត្រូវតាមការណែនាំនៃវិធានការណ៍គ្រប់គ្រងព័ត៌មាន ដែលមាននៅក្នុងគោលនយោបាយ និងគោលការណ៍ណែនាំការគ្រប់គ្រងហានិភ័យរបស់ធនាគារ មេយវើងផងដែរ។ ជាមួយនឹងការកើនឡើងនៃសមត្ថភាពនិងការប្រើប្រាស់បច្ចេកវិទ្យាក៏ដូចជាការកើនឡើងនូវហានិភ័យនៃការគំរាមកំហែងតាមអ៊ីនធឺណែតសុវត្ថិភាពព័ត៌មានត្រូវបានដាក់ចាត់ចូលជាចំនុចផ្តោតសំខាន់របស់ធនាគារ។

  ការគ្រប់គ្រងបច្ចេកវិទ្យាត្រូវបានអនុវត្តនៅគ្រប់ដំណាក់កាលនៃវដ្តព័ត៌មាន។ក្នុងចំណោមការគ្រប់គ្រងផ្សេងៗ គឺ មានការការពារពីការបាត់បង់ទិន្នន័យ ដើម្បីការពារ និងរាំងសក្តានុពលនៃការបាត់បង់ និងការលួចទិន្នន័យ។ ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា និងការគ្រប់គ្រងសុវត្ថិភាព ត្រូវបានពង្រឹងនិងឃ្លាំមើលនៅពេលដែលធនាគារមេយវើង បានរៀបចំការងារចល័តបន្ទាប់ពី មានការរីករាលដាលនៃជំងឺរាតត្បាតកូវីដ១៩។ គោលនយោបាយសម្អាតតុការិយាល័យ ត្រូវបានបំពេញបន្ថែមនៅកន្លែងរៀបចំចាត់ចែងការងារបម៉ាមជំនួសការងារចល័ត ដើម្បីការពារព័ត៌មានសម្ងាត់ និងកម្មសិទ្ធិ។

បាយការណ៍លើការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង

ការិយបរិច្ឆេទនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

- **ការគ្រប់គ្រងប្រកបដោយចីរភាព**

ដោយត្រូវបានបង្កើតឡើងក្នុងបេសកកម្មសេវាកម្មហិរញ្ញវត្ថុមនុស្សធម៌ ធនាគារ បានដាក់ចេញនូវ មហិច្ឆិតាស្នូល ដែលគាំទ្រនូវការទទួលខុសត្រូវរបស់ខ្លួនក្នុងការជំរុញ និងបង្កើតកំណើនប្រកបដោយ ចីរភាពដូចដែលបានចែង នៅក្នុងគោលនយោបាយបរិស្ថាន សង្គម និងអភិបាលកិច្ចរបស់ធនាគារ មេយប៉ែង។ មហិច្ឆិតាទាំងនេះ រួមមានការរក្សានិរន្តរភាព ដែលជាផ្នែកសំខាន់មួយនៃយុទ្ធសាស្ត្រ និងវប្បធម៌របស់ខ្លួន ទន្ទឹមនឹងការចាប់ដៃគូជាមួយអតិថិជនរបស់ខ្លួន ដើម្បីសម្រួលដល់ការផ្លាស់ប្តូរ ឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព និងការទទួលខុសត្រូវ។ នៅក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បី រួមបញ្ចូលមហិច្ឆិតាទាំងនេះទៅក្នុងការអនុវត្តអាជីវកម្មសម្ព័ន្ធក្រុមប្រឹក្សានិរន្តរភា ត្រូវបានបង្កើតឡើង ដោយមានគោលបំណងកំណត់យុទ្ធសាស្ត្រនិរន្តរភាពកំណត់ព្រំដែន និងការអនុម័តសំណើរបស់ ធនាគារក៏ដូចជាការត្រួតពិនិត្យ និងផ្តល់យោបល់លើផែនការសកម្មភាព និងបញ្ហាទាក់ទងនឹងចីរភាព។ ផ្នែកផ្តោតសំខាន់មួយទៀត គឺភាគីពាក់ព័ន្ធរបស់ធនាគារ ដែលធនាគារទទួលស្គាល់ពីតម្រូវការស្វែង យល់ពីបញ្ហាសម្ភារៈរបស់ពួកគេ ដើម្បីជួយឲ្យមានវិធីសាស្ត្ររួមមួយ ឆ្ពោះទៅរកការដោះស្រាយ និរន្តរភាពនៅទូទាំងសម្ព័ន្ធ។ ធនាគារ មេយប៉ែង ខេមបូឌា កំពុងអនុវត្តគោលនយោបាយនិងការអនុវត្ត ដែលពាក់ព័ន្ធទាំងនេះ។

- **បច្ចុប្បន្នភាព និងការផ្សព្វផ្សាយទៀងទាត់នៃគោលការណ៍ គោលនយោបាយ នីតិវិធី និងការអនុវត្តនៃ ការគ្រប់គ្រងហានិភ័យ**

គោលការណ៍គោលនយោបាយនីតិវិធី និងការអនុវត្តនៃការគ្រប់គ្រងហានិភ័យ ត្រូវបានពិនិត្យមើល ឡើងវិញ និងធ្វើបច្ចុប្បន្នភាពដោយទៀងទាត់ ដើម្បីធានាឲ្យមានការពាក់ព័ន្ធទៅនឹងបរិស្ថានអាជីវកម្ម ក៏ដូចជា អនុលោមទៅតាមច្បាប់និងបទប្បញ្ញត្តិនាពេលបច្ចុប្បន្ន។ ក្របខ័ណ្ឌគោលនយោបាយ និងនីតិវិធីហានិភ័យ ត្រូវបានអនុម័តជាគោលការណ៍ ដែលបានកំណត់ដោយធនាគារហើយក៏ត្រូវ អនុលោមតាមតម្រូវការក្នុងតំបន់ផងដែរ។ ដើម្បីពង្រឹងការអនុវត្តតាមបទដ្ឋានរបស់ធនាគារ ហានិភ័យ ត្រូវបានត្រួតពិនិត្យលើការអនុម័ត និងប្តូរតាមតម្រូវការនៅទូទាំងធនាគារ។

- **សៀវភៅណែនាំលទ្ធកម្ម និងអំណាចសម្រេចចិត្តមិនពាក់ព័ន្ធនឹងឥណទាន**

សៀវភៅណែនាំលទ្ធកម្មត្រូវបានរចនាឡើង ដើម្បីជួយជំរុញមុខងារលទ្ធកម្មនៅក្នុងធនាគារ។ សៀវភៅ នេះបម្រើជាការណែនាំបទដ្ឋានមួយ សម្រាប់ការអនុវត្ត ការគ្រប់គ្រងល្អដែលបានរំពឹងទុកក្នុងដំណើរ ការនិងនីតិវិធីលទ្ធកម្ម។ អ្នកមានសិទ្ធក្នុង ការអនុម័តសំណូមពរណាមួយ ទៅតាមគម្រោងថវិការ ការចំណាយ ដែលមិនបានព្រាងទុកជាមុនត្រូវតែគោរពទៅតាម គោលនយោបាយអំណាចអនុម័ត ដែលពាក់ព័ន្ធឧទាហរណ៍៖ គោលនយោបាយស្តីពីការសម្រេចចិត្តមិនពាក់ព័ន្ធនឹងឥណទាន ការប្រគល់ អំណាច ឬ អ្វីដែលមានតម្លៃស្មើ។ គោលនយោបាយនេះ សម្រេចចិត្តមិនពាក់ព័ន្ធនឹងឥណទានកំណត់ យ៉ាងច្បាស់លាស់ ពីសិទ្ធិក្រុមប្រឹក្សាភិបាលសម្រាប់សកម្មភាពលទ្ធកម្មការទិញ និងលក់ទ្រព្យសកម្ម ការលុបចោលប្រតិបត្តិការ ការបរិច្ចាគ ក៏ដូចជាការអនុម័តលើចំណាយទូទៅ និងចំណាយប្រតិបត្តិការ។

- **សេចក្តីណែនាំស្តីពីបទដ្ឋានក្នុងការអនុវត្ត**

គោលនយោបាយ និងនីតិវិធីត្រូវបានបង្កីតឡើង ដើម្បីធានាឲ្យបាននូវការប្រតិបត្តិតាម ការត្រួតពិនិត្យ ផ្ទៃក្នុង ច្បាប់ និងបទប្បញ្ញត្តិនានាដែលមានជាធរមាន។ គោលការណ៍នយោបាយ និងនីតិវិធីទាំងនេះ ត្រូវបានកំណត់ក្នុង សេចក្តីណែនាំស្តីពីបទដ្ឋានក្នុងការអនុវត្តិរបស់ធនាគារ និងត្រូវបានធ្វើបច្ចុប្បន្នភាព បានធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ ស្របតាមការផ្លាស់ប្តូរបរិស្ថានអាជីវកម្ម ឬច្បាប់។ ស្តង់ដារទាំងនេះ ត្រូវបានបោះផ្សាយជូនដល់និយោជិតទាំងអស់ ដែលជាប់ពាក់ព័ន្ធក្នុងការប្រើប្រាស់។

- **គោលនយោបាយនិយោជិតរបស់ធនាគារ មេយប៉ែង**

គោលនយោបាយនិយោជិតរបស់ ធនាគារ មេយប៉ែង ត្រូវបានប្រើជាមូលដ្ឋានគ្រឹះលើទស្សនវិជ្ជា និង គោលការណ៍ សម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍនិយោជិតនៅក្នុងធនាគារមេយប៉ែង។ គោលនយោបាយនេះ រួមបញ្ចូលគោលការណ៍ និងទស្សនវិជ្ជាសំខាន់ៗ ដែលគាំទ្របេសកកម្មសម្ព័ន្ធ ធនាគារ មេយប៉ែង ក្នុងការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយអរិយ្យភាព។ គោលនយោបាយនិយោជិត របស់ធនាគារមេយប៉ែង មានសំណុំនៃគោលនយោបាយ និងគោលការណ៍ណែនា ដែលគ្រប់គ្រងគ្រប់ ទិដ្ឋភាទាំងអស់នៃការគ្រប់គ្រងធនធានមនុស្ស ដែលរួមមានការជ្រើសរើសនិយោជិត និងការអភិវឌ្ឍ និយោជិតការគ្រប់គ្រងលទ្ធផល និងក្រមប្រតិបត្តិនៃការប្រព្រឹត្ត និងការលាឈប់ពីការងារ។ គោលនយោបាយវិន័យ ត្រូវបានបង្កើតឡើងផងដែរ ដើម្បីផ្តល់នូវរចនាសម្ព័ន្ធមួយ ដែលបញ្ហាវិន័យត្រូវ បានដោះស្រាយដោយស្មើភាពដូចគ្នា ហើយស្របតាមច្បាប់ និងបទបញ្ញត្តិការងារជាទូទៅ។

ដោយសារការគ្របដណ្តប់ដោយជំងឺកូវីដ១៩ និងតាមតម្រូវការ របស់ការគ្រប់គ្រងបន្តអាជីវកម្ម ក្នុងការប្រមើលមើលជាមុននៃជំងឺរាតត្បាតនាពេលអនាគត ធនាគារ មេយប៉ែងបានណែនាំនូវ គោលនយោបាយរៀបចំការងារចល័ត។ គោលការណ៍នេះឆ្លុះបញ្ចាំងពី ការរៀបចំការងារចល័ត ទាំងមូល ដែលនឹងជួយឲ្យអង្គភាពមានតុល្យភាពទាក់ទងនឹងគោលបំណង ដើម្បីសម្រេចបាននូវ បរិយាកាសការងារ ដែលមានផលិតភាពខ្ពស់ និងសុខដុមរមនាដែលឆ្លើយតបទៅនឹងការផ្លាស់ប្តូរ ជំនាញវិជ្ជាជីវៈនិងតម្រូវការផ្ទាល់ខ្លួននៃកម្លាំងពលកម្ម នាពេលបច្ចុប្បន្នស្របពេលដែលគិតគូរពីតម្រូវ ការអាជីវកម្ម និងអង្គភាព ដើម្បីធានាការបន្តអាជីវកម្ម និងនិរន្តរភាព។ គោលការណ៍នេះអនុញ្ញាត ឲ្យនិយោជិកធ្វើការពីផ្ទះនៅនឹងកន្លែង និងនៅទីតាំងបំបែកគ្នា។ នេះគឺជាកិច្ចព្រមព្រៀងទ្វេភាគីរវាង ធនាគារមេយប៉ែង និងនិយោជិក ដែលផ្តល់នូវផលប្រយោជន៍ទៅវិញទៅមកសម្រាប់ភាគីទាំងពីរ។ ការត្រួតពិនិត្យ និងការផ្សាភ្ជាប់ផ្សេងៗត្រូវបានបង្កើតឡើង ដើម្បីគ្រប់គ្រងយ៉ាងសកម្ម និងធានាថា និយោជិកស្ថិតក្រោមការរៀបចំការងារចល័តត្រូវបានគាំទ្របន្ត។ ការរៀបចំដែលមានវិន័យ និងត្រូវ បានកំណត់និយោជិកត្រូវបានចាត់តាំងនូវគំរូនៃ ការគ្រប់គ្រងដែលបានឯកភាពរួមទាំងការរំពឹងទុក និងលទ្ធផល ដែលបានព្រមព្រៀង និងអប្បបរមានៃកាលវិភាគប្រចាំសប្តាហ៍ដោយផ្ទាល់/និម្មិត តាមរយៈការឆែកអ៊ីន (check-ins) និងការធ្វើបច្ចុប្បន្នភាពនូវលទ្ធផលការងារ ដែលត្រូវបានបង្ហាញ នៅកំណត់ហេតុ សន្ទនាក្នុង myHR2u។

- **គុណតម្លៃ និងក្រមនៃសីលធម៌**

គុណតម្លៃរបស់ធនាគារ T.I.G.E.R. (ការងារជាក្រុម ភាពសុចរិត ភាពរីកចម្រើន ឧត្តមភាព និងប្រសិទ្ធភាព និងការកសាងទំនាក់ទំនង) គឺជាគោលការណ៍ណែនាំដ៏សំខាន់ ដើម្បីជំរុញនូវ ការប្រព្រឹត្តប្រកបដោយក្រមសីលធម៌។ គុណតម្លៃទាំងនេះត្រូវបានបំពេញបន្ថែមដោយក្រមសីលធម៌ និងការប្រព្រឹត្ត ដែលបានកំណត់គោលការណ៍ និងបទដ្ឋានក្នុងការអនុវត្តល្អសម្រាប់និយោជិត ទាំងអស់។

- **ការគ្រប់គ្រងការលួចបន្លំ**

ធនាគារ បានបណ្តុះបណ្តាលវប្បធម៌នៃការប្រុងប្រយ័ត្នមួយដល់និយោជិតទាំងអស់ ក្នុងការដោះស្រាយ និងការប្រយុទ្ធនឹងការលួចបន្លំ និងដើម្បីការពារមិនឲ្យមានការកើតឡើង នាថ្ងៃអនាគត។ ឧបករណ៍ ហេដ្ឋារចនាសម្ព័ន្ធ និងកម្មវិធីផ្សេងៗដ៏ទូលំទូលាយ ត្រូវបានដាក់ឲ្យប្រើប្រាស់ ដើម្បីធានាថាហានិភ័យ ដែលកើតចេញឡើងអំពីការលួចបន្លំ ត្រូវបានរាយការណ៍ និងគ្រប់គ្រងឲ្យទាន់ពេលវេលា។ ការដាក់ វិន័យធ្ងន់ធ្ងរ នឹងត្រូវអនុវត្តចំពោះនិយោជិតណា ដែលជាប់ពាក់ព័ន្ធជាមួយនឹងការលួចបន្លំ។

- **ការគ្រប់គ្រងហានិភ័យកេរ្តឹ៍ឈ្មោះ**

ធនាគារអនុវត្តនូវវិធីសាស្ត្ររួម និងអភិបាលកិច្ចល្អក្នុង ការគ្រប់គ្រងហានិភ័យកេរ្តឹ៍ឈ្មោះ និងដើម្បីលើក កម្ពស់ ការយល់ដឹងពីស្ថាប័ន និងផលវិបាក។ ការការពារកេរ្តឹ៍ឈ្មោះរបស់ធនាគារមានសារៈសំខាន់ បំផុតក្នុងការធ្វើប្រតិបត្តិការជាស្ថាប័ន ដែលផ្តល់សេវាកម្មហិរញ្ញវត្ថុ។ ការលើកកម្ពស់ទំនុកចិត្ត បទពិសោធន៍ដ៏ល្អប្រសើរ និងសុវត្ថិភាពអតិថិជនបង្កើតបានជាផ្ទៃកមួយដ៏សំខាន់នៃកាតព្វកិច្ចរបស់ យើង ក្នុងនាមជាស្ថាប័នហិរញ្ញវត្ថុ។ ដូចនេះ ធនាគារបានដាក់ចេញនូវគោលនយោបាយអំពីតួនាទី និងការទទួលខុសត្រូវនៃភាគីពាក់ព័ន្ធ និងដំណើរការសំខាន់ៗ ដើម្បីជួយសម្រួលដល់ការគ្រប់គ្រង ហានិភ័យកេរ្តឹ៍ឈ្មោះប្រកបដោយប្រសិទ្ធភាព និងតាមដានហានិភ័យដែលមាននៅក្នុងហានិភ័យ ដែល អាចកើតមានឡើង។

- **គោលនយោបាយ និងនីតិវិធីសម្រាប់រាយការណ៍**

ធនាគារ មេយប៉ែងប្តេជ្ញាចិត្តខ្ពស់បំផុត ចំពោះក្រមសីលធម៌ និងសុចរិតភាព ក្នុងការធ្វើអាជីវកម្ម និង ប្រតិបត្តិការរបស់ខ្លួន។ គោលនយោបាយ និងនីតិវិធីសម្រាប់រាយការណ៍ ត្រូវបានកែសម្រួល ដើម្បីផ្តល់ ឲ្យនូវវិធីសាស្ត្ត ដែលសមស្រប និងមានសុវត្ថិភាព សម្រាប់និយោជិតធនាគារ មេយប៉ែង ឬ សាធារណៈជន ដែលដឹងអំពីការប្រព្រឹត្តមិនត្រឹមត្រូវ ដើម្បីរាយការណ៍ពីការលួចបន្លំពុករលួយ សកម្មភាពឧក្រិដ្ឋ ដែលគួរឲ្យសង្ស័យ ឬការប្រព្រឹត្ត អាកប្បកិរិយាគ្មានសីលធម៌ ណាមួយនៅក្នុងកន្លែង ការងារ ដោយគ្មានការភ័យខ្លាចពីផលវិបាកអវិជ្ជមានណាមួយ។

ការទទួលបានព័ត៌មានតាមរយៈការរាយការណ៍នេះ ត្រូវបានគ្រប់គ្រងដោយការរក្សាការសម្ងាត់បំផុត ក្រោមការត្រួតពិនិត្យរបស់អភិបាលឯករាជ្យមិនប្រតិបត្តិនៃក្រុមប្រឹក្សាភិបាល។

- **គោលនយោបាយ និងនីតិវិធីប្រឆាំងការសូកប៉ាន់ និងអំពើពុករលួយ**

ធនាគារមេយប៉ែង ប្រកាន់យកនូវវិធីសាស្ត្រគ្មានការអត់អោនដាច់ខាត រាល់ការសូកប៉ាន់ និងអំពើ ពុករលួយក្នុងការអនុវត្តប្រតិបត្តិការប្រចាំថ្ងៃរបស់ខ្លួន។ គោលនយោបាយ និងនីតិវិធីប្រឆាំង ការសូកប៉ាន់ និងអំពើពុករលួយរបស់ធនាគារ មេយប៉ែង បានដាក់ចេញនូវគោលការណ៍ណែនាំ សម្រាប់ធនាគារដើម្បីដោះស្រាយ និងគ្រប់គ្រងហានិភ័យនៃការសូកប៉ាន់ និងអំពើពុករលួយ ដែល បានប្រឈមមុខទាំងនៅក្នុង និងក្រៅធនាគារ មេយប៉ែងទាំងអស់។

របាយការណ៍លើការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង

ការិយបរិច្ឆេទនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

- **ការប្រឆាំងបទល្មើសឧក្រិដ្ឋកម្មហិរញ្ញវត្ថុ**

  ធនាគារ មេយវែង បានប្តេជ្ញាប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មហិរញ្ញវត្ថុ និងធ្វើការធានាលើការប្រតិបត្តិតាមច្បាប់ និងបទប្បញ្ញត្តិទាំងអស់ ដែលជាប់ទាក់ទង។ ហានិភ័យលើបទឧក្រិដ្ឋហិរញ្ញវត្ថុ គឺ ត្រូវបានខិតខំគ្រប់គ្រង ដើម្បីការពារសុចរិតភាព និងកិត្តិនាមនៃធនាគារ និងប្រព័ន្ធហិរញ្ញវត្ថុ។ ធនាគារ មានគោលបំណងបង្កើតការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ដើម្បីការពារ និងឆ្លើយតបចំពោះការសម្អាតប្រាក់កខ្វក់ និងហានិភ័យហិរញ្ញប្បទានភេរវកម្ម។ ការផ្តើមគំនិត និងការវិនិយោគផ្សេងៗត្រូវបានបង្កើតឡើង ដើម្បីពង្រឹងការគ្រប់គ្រងលើការប្រតិបត្តិតាមឧក្រិដ្ឋកម្មហិរញ្ញវត្ថុ នៅក្នុងការិយបរិច្ឆេទ ២០២០ និងនៅក្នុងឆ្នាំបន្តបន្ទាប់ទៀត។ ទាំងនេះ គឺបានរួមបញ្ចូលការបង្កើត និងការពង្រឹងអង្គភាព ការប្រតិបត្តិតាមមុខងារ បទឧក្រិដ្ឋហិរញ្ញវត្ថុដែលផ្តោតសំខាន់លើ ការធានាប្រសិទ្ធភាព ការអនុវត្ត ការថ្លឹងថ្លែងនៅក្នុងចំនុចផ្សេងៗ នៃការប្រឆាំងនឹងការសម្អាតប្រាក់កខ្វក់ និងហិរញ្ញប្បទានភេរវកម្ម ការដាក់ទណ្ឌកម្ម និងការប្រឆាំងនឹងសំណូក និងអំពើពុករលួយ។ បន្ថែមពីនេះទៅទៀត ការបន្តធ្វើឲ្យមានគុណភាពលើមនុស្ស វប្បធម៌ ដំណើរការ និងប្រព័ន្ធកំពុងបន្តអនុវត្តធ្វើឲ្យប្រសើរឡើងនៃសមត្ថភាពរបស់ធនាគារ ដើម្បីការពារ រារាំង និងកំណត់រាល់សកម្មភាពឧក្រិដ្ឋកម្មហិរញ្ញវត្ថុ។

- **ក្រុមប្រឹក្សាភិបាល បង្កើតមុខងារសវកម្ម**

  ក្រុមប្រឹក្សាភិបាល បង្កើតមុខងារសវនកម្មផ្ទៃក្នុង ដើម្បីបន្តត្រួតពិនិត្យលើការធានាឯករាជ្យលើភាពគ្រប់គ្រាន់និងប្រសិទ្ធភាពនៃអភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង។ មុខងារសវនកម្មផ្ទៃក្នុង មានឯករាជ្យនៃរាល់សកម្មភាព និងប្រតិបត្តិការ នៃអង្គភាពប្រតិបត្តិការផ្សេងទៀតនៅក្នុងធនាគារ។ មុខងារនេះ គឺត្រូវបានគ្រប់គ្រងដោយ នាយក នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលជាអ្នករាយការណ៍ផ្ទាល់ទៅកាន់ក្រុមប្រឹក្សាភិបាល និងរាយការណ៍លក្ខណៈរដ្ឋបាលជូន នាយកប្រតិបត្តិ។ ដំណើរការនិងសកម្មភាពរបស់សវនកម្មផ្ទៃក្នុង ត្រូវបានណែនាំដោយធម្មនុញ្ញសវនកម្ម និងគ្រប់គ្រងដោយក្របខ័ណ្ឌបទបញ្ជាត្តិ ដែលជាប់ទាក់ទងនឹងក្រមសីលធម៌របស់ធនាគារ និងគោលការណ៍ណែនាំជាចាំបាច់នៃវិទ្យាស្ថានសវនករផ្ទៃក្នុង ដែលបានបង្កើតឡើងស្ថិតនៅក្រោមក្របខ័ណ្ឌអនុវត្តវិជ្ជាជីវៈអន្តរជាតិ។

ការធានាពីគណៈគ្រប់គ្រង

នាយកប្រតិបត្តិ និងនាយកនាយកដ្ឋានហិរញ្ញវត្ថុ បានផ្តល់នូវការធានា របស់ខ្លួនយ៉ាងសមស្របចំពោះក្រុមប្រឹក្សាភិបាលថា ការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង របស់ធនាគារកំពុងប្រតិបត្តិយ៉ាងពេញលេញ និងមានប្រសិទ្ធភាពជាសារវ័ន្ត ក្នុងអំឡុងពេលការិយបរិច្ឆេទ ស្ថិតក្រោមការត្រួតពិនិត្យរហូតដល់ការបរិច្ឆេទនៃការអនុម័តលើរបាយការណ៍នេះ សម្រាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំ។ ដោយពិចារណាលើការធានាពីគណៈគ្រប់គ្រង និងមតិយោបល់ពីអ្នកធានា ដែលពាក់ព័ន្ធផ្សេងៗទៀត ក្រុមប្រឹក្សាភិបាល មានទស្សនៈថា ការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ កំពុងដំណើរការយ៉ាងពេញលេញ និងមានប្រសិទ្ធភាព ដើម្បីការពារការវិនិយោគរបស់ម្ចាស់ភាគហ៊ុន និងទ្រព្យសកម្មរបស់ធនាគារ។

ក្រុមប្រឹក្សាភិបាលមានសេចក្តីពេញចិត្ត ដែលធនាគារបានអនុវត្តដំណើរការកំពុងបន្តមួយ ដើម្បីកំណត់អត្តសញ្ញាណវាយតម្លៃ តាមដាន គ្រប់គ្រង និងឆ្លើយតបទៅកាន់ហានិភ័យសំខាន់ៗ ដែលបានជួបប្រទះដោយធនាគារក្នុងការសម្រេចបានគោលដៅ អាជីវកម្ម និងយុទ្ធសាស្ត្ររបស់ខ្លួនក្នុងខណៈពេលដែលបរិយាកាសអាជីវកម្ម កំពុងមានភាពស្មុគស្មាញ និងប្រកួតប្រជែង និងបង្កើនការត្រួតពិនិត្យបទប្បញ្ញត្តិជាពិសេស ក្នុងអំឡុងពេលនៃជំងឺរាតត្បាតកូវីដ១៩ លើសកលលោក។ ដំណើរការនេះ បានដាក់ឲ្យមានសម្រាប់ពេញមួយការិយបរិច្ឆេទស្ថិតក្រោមការត្រួតពិនិត្យ និងបច្ចុប្បន្នភាពនៃការយល់ព្រមនៃសេចក្តីថ្លែងការណ៍នេះសម្រាប់ដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំ។

របាយការណ៍គណៈកម្មាធិការ
សវនកម្មនៃក្រុមប្រឹក្សាភិបាល

ក. សមាសភាព និងគួនាទី

សមាសភាព

គណៈកម្មាធិការនេះ ត្រូវមានសមាជិកយ៉ាងតិចបី(៣)រូប ក្នុងនោះពីរ(២)រូប ជាអភិបាលមិនប្រតិបត្តិ ដែលតែងតាំងដោយ ក្រុមប្រឹក្សាភិបាល ក្នុងចំណោមអភិបាលមិនប្រតិបត្តិនៃធនាគារ៖

១. ប្រធាន ត្រូវតែជាអភិបាលឯករាជ្យ ហើយយ៉ាងហោចណាស់អភិបាលឯករាជ្យម្នាក់នៃ គណៈកម្មាធិការ ត្រូវតែមានជំនាញហិរញ្ញវត្ថុ និងគណនេយ្យ និងអភិបាលឯករាជ្យម្នាក់ទៀត ត្រូវមានជំនាញផ្នែកច្បាប់ និងធនាគារ។

២. នៅពេលដែលប្រធាន មិនអាចចូលរួមប្រជុំបាន សមាជិកទាំងអស់ ត្រូវជ្រើសរើសសមាជិក ម្នាក់នៅក្នុងក្រុមធ្វើជាប្រធាន។

៣. ការពិនិត្យឡើងវិញនូវសមាសភា របស់គណៈកម្មាធិការ ត្រូវប្រព្រឹត្តឡើងរៀងរាល់បីឆ្នាំម្តង។ ការពិនិត្យឡើងវិញនេះ ទាក់ទងទៅនឹងអាណត្តិ និងលទ្ធផលសម្រេចបានរបស់សមាជិក ទាំងឡាយ។

កិច្ចប្រជុំ

១. កិច្ចប្រជុំ នឹងប្រព្រឹត្តឡើងយ៉ាងតិចមួយត្រីមាសម្តង ដើម្បីឲ្យស្របជាមួយ នឹងកិច្ចប្រជុំ ក្រុមប្រឹក្សាភិបាល ឬអាចញឹកញាប់ជាងនេះ អាស្រ័យទៅលើសេចក្តីសម្រេចរបស់ គណៈកម្មាធិការ។ គណៈកម្មាធិការ អាចកោះអញ្ជើញបុគ្គលណាម្នាក់ក៏បាន ឲ្យចូលរួមក្នុង អង្គប្រជុំ ដើម្បីជួយសម្រួលក្នុងការពិភាក្សា។ ជាធម្មតានាយកប្រតិបត្តិ និងនាយក នាយកដ្ឋានសវនកម្មផ្ទៃក្នុង នឹងត្រូវចូលរួមក្នុងអង្គប្រជុំនេះ។ យ៉ាងហោចណាស់ម្តងក្នុង មួយឆ្នាំគណៈកម្មាធិការ នឹងត្រូវជួបជាមួយសវនករឯករាជ្យ ដោយមិនមានវត្តមានគណៈ គ្រប់គ្រង។

២. គណៈកម្មាធិការ នឹងកំណត់នីតិវិធីរបស់ខ្លួន ជាពិសេសទាក់ទងនឹងការកោះប្រជុំ ការជូន ដំណឹងពីការប្រជុំ ការបោះឆ្នោត និងនីតិវិធីនៃការប្រជុំ ការកត់ត្រា និងការរក្សា ការបង្កើត និងការអង្កេតលើកំណត់ហេតុប្រជុំ។

៣. យោងទៅតាមសំណើរបស់សវនករឯករាជ្យ កិច្ចប្រជុំនឹងត្រូវបើក ដើម្បីពិចារណានូវរាល់ បញ្ហាដែលសវនករយល់ថាអភិបាល និងម្ចាស់ភាគហ៊ុនគួរតែយកចិត្តទុកដាក់។

ក្វ៉ុម

យ៉ាងតិចណាស់៥១% នៃចំនួនសមាជិកទាំងអស់ត្រូវតែមានវត្តមាន ដើម្បីបង្កើតជាក្វ៉ុម។

លេខាធិការ

លេខាធិការរួមរបស់គណៈកម្មាធិការសវនកម្មនៃ ក្រុមប្រឹក្សាភិបាល រួមមាននាយិកា នាយកដ្ឋាន កិច្ចការក្រុមហ៊ុន និងទំនាក់ទំនងសាជីវកម្ម និងនាយក ផ្នែកកិច្ចការច្បាប់ក្រុមហ៊ុន។

សិទ្ធិ

គណៈកម្មាធិការ ត្រូវបានអនុញ្ញាតដោយក្រុមប្រឹក្សាភិបាលក្នុង៖

- ការស៊ើបអង្កេតលើគ្រប់សកម្មភាព ឬបញ្ហានៅក្នុងក្របខណ្ឌរបស់ខ្លួន។
- មានធនធាន ដែលចាំបាច់ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន។
- មានសិទ្ធិប្រើប្រាស់នូវរាល់ព័ត៌មាន និងឯកសារដែលទាក់ទង នឹងសកម្មភាពរបស់ខ្លួន ដោយ មិនមានការដាក់កំហិត។
- មានបណ្តាញទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងសវនករឯករាជ្យបុគ្គល ដែលទទួលបន្ទុកមុខងារ ឬសកម្មភាពសវនកម្ម ផ្ទៃក្នុង និងគណៈគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារ។
- ទទួលយកការប្រឹក្សាច្បាប់ពីខាងក្រៅ ឬពីអ្នកជំនាញឯករាជ្យផ្សេងៗទៀត និងធានាឲ្យមាន ការចូលរួមពីអ្នកខាងក្រៅដែលមានដែលមានបទពិសោធន៍ និងជំនាញក្នុងករណីចាំបាច់។
- កោះប្រជុំជាមួយនឹងសវនករផ្ទៃក្នុង និងសវនករឯករាជ្យ ដោយមិនចាំបាច់មានវត្តមាន របស់ គណៈកម្មាការប្រតិបត្តិនៅពេលដែលចាំបាច់។

ខ. កាតព្វកិច្ច និងការទទួលខុសត្រូវ

កាតព្វកិច្ច និងការទទួលខុសត្រូវចម្បង របស់គណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល ដែល ទាក់ទងនឹងមុខងារសវនកម្មផ្ទៃក្នុង សវនករឯករាជ្យ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង របាយការណ៍ ហិរញ្ញវត្ថុប្រតិបត្តិការជាមួយសម្ព័ន្ធញ្ញាត្តិ របាយការណ៍ប្រចាំឆ្នាំ និងការស៊ើបអង្កេតរបស់ធនាគារ មានដូចខាងក្រោម៖

សវនកម្មផ្ទៃក្នុង

- ត្រួតពិនិត្យ និងអនុម័តនូវភាពគ្រប់គ្រាន់នៃវិសាលភាព និងផែនការ មុខងារ ធនធាននៃ សវនកម្ម ផ្ទៃក្នុង និងលក្ខន្តិកៈសវនកម្មផ្ទៃក្នុង ដែលផ្តល់ជាសិទ្ធិអំណាចចាំបាច់ក្នុង ការអនុវត្តការងាររបស់ខ្លួន។
- ត្រួតពិនិត្យ និងវាយតម្លៃរបាយការណ៍សវនកម្មផ្ទៃក្នុង និងធានាថាដំណោះស្រាយសមរម្យ និងឆាប់រហ័សបានធ្វើឡើងដោយគណៈគ្រប់គ្រងលើកង្វះខាតនៃការគ្រប់គ្រង ឬនីតិវិធី ដែលបានកំណត់កន្លងមកដោយសវនកម្មផ្ទៃក្នុង។
- វាយតម្លៃ និងអនុម័តលើការតែងតាំង ឬការបញ្ឈប់នាយក នាយកដ្ឋានសវនកម្មផ្ទៃក្នុង។
- វាយតម្លៃការបំពេញការងាររបស់សវនការផ្ទៃក្នុង កំណត់ ឬអនុម័តប្រាក់បៀវត្ស និង ការដំឡើងប្រាក់បៀវត្សប្រចាំឆ្នាំរបស់សវនការផ្ទៃក្នុង។
- ទទួលដឹងពីការលាលែងនៃនិយោជិតសវនកម្មផ្ទៃក្នុង និងហេតុផលនៃការលាលែង។

សវនកម្មឯករាជ្យ

- ត្រួតពិនិត្យ ការតែងតាំង និងការបំពេញការងារ របស់សវនករឯករាជ្យ ការលាលែង និង ការបញ្ចប់ នៃសវនករឯករាជ្យ កម្រៃសេវាសវនកម្ម និងធ្វើការណែនាំផ្តល់អនុសាសន៍ជូន ដល់ក្រុមប្រឹក្សាភិបាល។
- វាយតម្លៃកម្រិតវប្បធម៌ វិជ្ជាជីវៈ ជំនាញធនធាន និងប្រសិទ្ធភាពរបស់សវនករឯករាជ្យ។
- ត្រួតពិនិត្យពីប្រសិទ្ធភាពការងារ និងឯករាជ្យភាពព្រមទាំងវត្ថុវិស័យរបស់សវនករ ឯករាជ្យ។
- ត្រួតពិនិត្យវិសាលភាព និងផែនការសវនកម្មរបស់សវនករឯករាជ្យ រួមទាំងការផ្លាស់ប្តូរ វិសាលភាពនៃផែនការសវនកម្ម។
- ត្រួតពិនិត្យរបាយការណ៍សវនកម្មសំខាន់ៗ និងលទ្ធផល ដែលលើកឡើង ដោយសវនករ ឯករាជ្យ និងការឆ្លើយតបរបស់គណៈគ្រប់គ្រង រួមទាំង ការវិវត្តនានានៃការផ្តល់ អនុសាសន៍សវនកម្មកន្លងមក។
- ត្រួតពិនិត្យលើ ការជួយជ្រោមជ្រែងពីនិយោជិតធនាគារ ទៅដល់សវនករឯករាជ្យ និងរាល់ បញ្ហាលំបាក ដែលបានជួបប្រទះក្នុង ដំណើរការសវនកម្ម រួមទាំងការដាក់កំហិតលើ វិសាលភាពការងារ ឬការទទួលព័ត៌មានដែលចាំបាច់។
- អនុម័តលើសេវាកម្មផ្សេងៗ មិនមែនជាសវនកម្ម ដែលផ្តល់ដោយសវនករឯករាជ្យ។

ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

ត្រួតពិនិត្យ វាយតម្លៃ និងរាយការណ៍ជូនក្រុមប្រឹក្សាភិបាលលើ៖

- ភាពគ្រប់គ្រាន់នៃគោលនយោបាយ នីតិវិធី និងគោលការណ៍ណែនាំលើប្រព័ន្ធត្រួតពិនិត្យ ផ្ទៃក្នុង ដែលបានបង្កើតឡើង។
- ប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការវាយតម្លៃរបស់សវនការផ្ទៃក្នុង និងឯករាជ្យ លើប្រព័ន្ធត្រួតពិនិត្យ ជាពិសេសអនុសាសន៍របស់សវនករឯករាជ្យចំពោះគណៈគ្រប់គ្រង និងការឆ្លើយតបរបស់គណៈគ្រប់គ្រង។

របាយការណ៍ហិរញ្ញវត្ថុ

ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងចុងឆ្នាំដោយផ្តោតលើ៖

- ការផ្លាស់ប្តូរលើគោលនយោបាយគណនេយ្យ និងការអនុវត្ត។
- ព្រឹត្តិការណ៍សំខាន់ៗ និងគួរឲ្យកត់សំគាល់។
- ការអនុវត្តតាមបទដ្ឋានរបាយការណ៍ហិរញ្ញវត្ថុ និងតម្រូវការផ្ទៃកច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ទៀត។

របាយការណ៍គណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល

ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ

ត្រូតពិនិត្យរាល់ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ និងស្ថានភាពទំនាស់នៃផលប្រយោជន៍ ដែលអាចកើតមានឡើងនៅក្នុងធនាគារ ឬសម្ព័ន្ធធនាគារ មេយវ៉ៃង រួមទាំងប្រតិបត្តិការ នីតិវិធី ឬក្រមសីលធម៌ ដែលនឹងអាចលើកជាចំណោទសម្រាប់សុចរិតភាពរបស់គណៈគ្រប់គ្រង។

របាយការណ៍ប្រចាំឆ្នាំ

រៀបចំរបាយការណ៍គណៈកម្មាធិការសវនកម្ម នៅរាល់ចុងការិយបរិច្ឆេទនីមួយៗ ហើយរបាយការណ៍នេះ នឹងដាក់ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំ។

ការស៊ើបអង្កេត

ណែនាំឲ្យធ្វើការស៊ើបអង្កេតលើសកម្មភាព ឬបញ្ហាណាមួយដែលស្ថិតក្នុងក្របខ័ណ្ឌការងាររបស់ខ្លួន។

បញ្ហាផ្សេងៗ

ចាត់ការលើបញ្ហាផ្សេងៗ ដែលគណៈកម្មាធិការយល់ឃើញថាសមស្រប ឬដូចដែលបានផ្តល់សិទ្ធិអំណាច ដោយក្រុមប្រឹក្សាភិបាល។ ទទួល និងពិចារណារបាយការណ៍ដែលជាប់ទាក់ទង ដែលជាប់ទាក់ទង នឹងការចំពាន និងការការពារនៃការលួចបន្លំ។

ក. សកម្មភាពរបស់គណៈកម្មាធិការសវនកម្ម នៃក្រុមប្រឹក្សាភិបាល សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

វត្តមានក្នុងកិច្ចប្រជុំ

កិច្ចប្រជុំនៃគណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល ចំនួនប្រាំមួយ(៦)ដង បានធ្វើឡើងក្នុងអំឡុងការិយបរិច្ឆេទ២០២០ ហើយសេចក្តីលំអិតនៃវត្តមានសមាជិកនីមួយៗនៃអង្គប្រជុំមានដូចជា៖

ឈ្មោះសមាជិកគណៈកម្មាធិការ	ចំនួននៃអង្គប្រជុំ ដែលបានប្រារព្ធឡើង និងចូលរួមក្នុងអំឡុងការិយបរិច្ឆេទ២០២០
លោក ហ្សាវីហ្សាឌីន ខាឡីត (ប្រធាន) - តែងតាំងនៅថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០១៩ - អភិបាលមិនប្រតិបត្តិឯករាជ្យ	៦/៦
លោក ស្តេនសឺ លី ទៀនឈី (សមាជិក) - តែងតាំងនៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១២ - អភិបាលមិនប្រតិបត្តិឯករាជ្យ	៦/៦
ជាតុ ហាមី រុលឡា ប៊ូហាន់ (សមាជិក) - តែងតាំងនៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១២ - អភិបាលមិនប្រតិបត្តិមិនឯករាជ្យ	៦/៦
លោក ស៊ូន ស៊ូ ឡុង (សមាជិក) - តែងតាំងនៅថ្ងៃ ៣១ ខែមីនា ២០១៥ - អភិបាលមិនប្រតិបត្តិមិនឯករាជ្យ	៦/៦

ដើម្បីសម្របសម្រួល កិច្ចពិភាក្សានៃលទ្ធផលសវនកម្ម នាយក នាយកដ្ឋាន សវនកម្មផ្ទៃក្នុង និងប្រធានសវនកម្មផ្ទៃក្នុង បានចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការសវនកម្ម នៃក្រុមប្រឹក្សាភិបាលដើម្បីធ្វើបទបង្ហាញ អំពីរបាយការណ៍សវនកម្ម និងស៊ើបអង្កេតរបស់ខ្លួន។ នាយក នាយកដ្ឋានហិរញ្ញវត្ថុ គឺជាប្រធាននៃគណៈកម្មាការសវនកម្មផ្ទៃក្នុង និងជាតំណាងនៃគណៈកម្មាធិការគ្រប់គ្រងដើម្បីផ្តល់នូវការធានា និងការប្តេជ្ញា ចំពោះគណៈកម្មាធិការក្រុមប្រឹក្សាសវនកម្ម លើដំណោះស្រាយឲ្យទាន់ពេលវេលា នៃលទ្ធផលសវនកម្ម និងរាល់បញ្ហាផ្សេងៗ ដែលបានលើកឡើងដោយសវនករផ្ទៃក្នុង។ ប្រសិនបើចាំបាច់គណៈកម្មាធិការគ្រប់គ្រង ដែលពាក់ព័ន្ធទៅនឹងប្រធានបទនៃការពិភាក្សាក៏ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសវនកម្ម នៃក្រុមប្រឹក្សាភិបាលនេះផងដែរ ដើម្បីផ្តល់នូវការបកស្រាយលើចំណុចខ្វះខាតនៃការត្រួតពិនិត្យផ្ទៃក្នុង និងបញ្ហាដែលបានលើកឡើងនៅក្នុងរបាយការណ៍សវនកម្មជូនដល់គណៈកម្មាធិការ។

ចំពោះសវនករឯករាជ្យ ត្រូវបានអញ្ជើញចូលរួមអង្គប្រជុំ គណៈកម្មាធិការក្រុមប្រឹក្សាសវនកម្ម ដើម្បីបង្ហាញនូវ អនុស្សរណៈ ផែនការសវនកម្មអនុសាសន៍ ចំពោះគណៈកម្មាធិការគ្រប់គ្រង និងបញ្ហាដែលជាប់ពាក់ព័ន្ធផ្សេងៗទៀត។ សវនករឯករាជ្យ រួមជាមួយ នឹងគណៈកម្មាធិការប្រតិបត្តិ និងនាយក នាយកដ្ឋានហិរញ្ញវត្ថុ បានចូលរួមប្រជុំជាមួយ គណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល ដើម្បីពិភាក្សា និងពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារដែលបានធ្វើសវនកម្ម។

ក្នុងអំឡុងកាលរិយបរិច្ឆេទ២០២០ គណៈកម្មាធិការក្រុមប្រឹក្សាសវនកម្មមានកិច្ចប្រជុំដោយឡែក ២លើកជាមួយសវនករ ដោយមិនមានវត្តមាននៃគណៈគ្រប់គ្រង។ មួយវគ្គជាមួយសវនករផ្ទៃក្នុង និងមួយវគ្គផ្សេងទៀត ជាមួយនឹងសវនករឯករាជ្យ។

ក្នុងអំឡុងឆ្នាំនៃការត្រួតពិនិត្យ គណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាលបានអនុវត្តនូវភារកិច្ច និងមុខងារ ដែលមានសកម្មភាពដូចខាងក្រោម៖

សវនកម្មផ្ទៃក្នុង

១. បានពិនិត្យ និងអនុម័តលើការកែប្រែ ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំសម្រាប់ការិយបរិច្ឆេទ២០២០ នៅក្នុងទិដ្ឋភាពនៃការរំខាន ដែលបណ្តាលមកពីជំងឺរាតត្បាត និងបានផ្តល់នូវហានិភ័យ / ការព្រួយបារម្ភដែលអាចកើតឡើងមកពី ការផ្លាស់ប្តូរនៃដំណើរការការងារ បរិយាកាសនៃប្រតិបត្តិការថ្មី និងភាពប្រក្រតីថ្មីក្នុងការគ្រប់គ្រងអាជីវកម្ម។ នេះគឺដើម្បីធានាថាការធានាសវនកម្មអាចត្រូវបានផ្តល់ជូនជាបន្តបន្ទាប់ ដោយផ្តោតលើតំបន់ហានិភ័យដែលពាក់ព័ន្ធ ក៏ដូចជាពិចារណាលើវិធីសាស្ត្រផ្សេងទៀត ដែលអាចអនុវត្តបាន។

២. ពិនិត្យ និងអនុម័ត ចំពោះផែនការសវនកម្មផ្ទៃក្នុង ប្រចាំឆ្នាំសម្រាប់ការិយបរិច្ឆេទ២០២១ ដើម្បីធានាឲ្យបាននូវវិសាលភាព ការគ្របដណ្តប់ ជាមួយនឹងធនធានគ្រប់គ្រាន់ និងសមត្ថភាពសម្រាប់សវនកម្មផ្ទៃក្នុង ក្នុងការអនុវត្តមុខងាររបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព។ គណៈកម្មាធិការក្រុមប្រឹក្សាសវនកម្ម យល់ស្របលើតម្រូវការកញ្ចប់ថវិកាប្រតិបត្តិការប្រចាំឆ្នាំ របស់សវនកររផ្ទៃក្នុងសម្រាប់ការិយបរិច្ឆេទ២០២១ ដែលនឹងត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលធ្វើការសម្រេច ជាមួយគ្នានឹងកញ្ចប់ថវិកាប្រតិបត្តិការសម្រាប់ធនាគារទាំងមូល។

៣. វាយតម្លៃ និងអនុម័តលើ លទ្ធផលការងារ និងរង្វាន់សម្រាប់ការិយបរិច្ឆេទ២០១៩ របស់នាយក នាយកដ្ឋានសវនកម្មផ្ទៃក្នុង រួមទាំងនិយោជិកសវនកម្មផ្ទៃក្នុង ដោយផ្អែកទៅលើសមិតិផលសម្រេចបានប្រចាំឆ្នាំរបស់នាយកដ្ឋាន និងស្របគ្នាទៅ នឹងម៉ាទ្រីស ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល ។

៤. ពិភាក្សា និងអនុម័តលើការកំណត់គោលដៅរបស់ នាយក នាយកដ្ឋានសវនកម្មផ្ទៃក្នុង សម្រាប់ឆ្នាំ២០២០ ដែលបានពិចារណាទៅលើគន្លឹះសូចនាករលទ្ធផលការងារសំខាន់ៗ។

៥. ត្រួតពិនិត្យ របាយការណ៍លទ្ធផលសវនកម្មប្រចាំខែ ដែលនិយាយលម្អិតពីការបញ្ចប់នៃផែនការសវនកម្មនៅក្នុងផែនការអនុម័តក្នុងឆ្នាំ២០២០ ព្រមជាមួយការផ្លាស់ប្តូរនិយោជិតសវនកម្មផ្ទៃក្នុងផងដែរ។

៦. ពិភាក្សាទៅលើរបាយការណ៍សវនកម្ម និងរបាយការណ៍ស៊ើបអង្កេត និងផ្តល់អនុសាសន៍ដល់គណៈគ្រប់គ្រងឲ្យរៀបចំ និងប្រតិបត្តិកិច្ចការចាំបាច់ ដើម្បីពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។ ក្នុងករណីចាំបាច់ នាយក នាយកដ្ឋានហិរញ្ញវត្ថុ ត្រូវបានណែនាំឲ្យលើកយកភាពចន្លោះខ្វះខាតនៃការត្រួតពិនិត្យ និងអនុសាសន៍ ទាំងនោះទៅពិភាក្សានៅក្នុងគណៈកម្មាធិការប្រតិបត្តិ។

៧. ពិនិត្យរបាយការណ៍ស្ថានភាពនៃការរកឃើញរបស់សវនកម្មប្រចាំខែ និងពិភាក្សាសកម្មភាព និងពេលវេលាកែតម្រូវ ដែលកំណត់ដោយគណៈគ្រប់គ្រង ដើម្បីធានាថា ចន្លោះប្រហោងត្រូវបានត្រួតពិនិត្យ បានកែតម្រូវ និងដោះស្រាយទាន់ពេលវេលា។

៨. ពិនិត្យ និងកត់ចំណាំកំណត់ហេតុប្រជុំ របស់គណៈកម្មាធិការសវនកម្មផ្ទៃក្នុង សម្រាប់ទិដ្ឋភាពទូទៅនៃការពិភាក្សា និងសកម្មភាពកែលម្អប្រតិបត្តិដោយគណៈគ្រប់គ្រង ចំពោះចន្លោះប្រហោងនៃការត្រួតពិនិត្យ ដែលលើកឡើងដោយសវនករផ្ទៃក្នុង។

៩. ពិភាក្សារបាយការណ៍គុណភាពនៃសវនកម្មផ្ទៃក្នុង ដែលបានរៀបចំឡើងដោយសម្ព័ន្ធសវនកម្មលើការងារ ដែលបានអនុវត្តដោយសវនករផ្ទៃក្នុង ដើម្បីធានាក្នុងការបន្តប្រតិបត្តិជាមួយនឹងបទដ្ឋានអន្តរជាតិ ដែលបានផ្សព្វផ្សាយដោយវិទ្យាស្ថានសវនករផ្ទៃក្នុង។

របាយការណ៍គណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល

របាយការណ៍ប្រចាំឆ្នាំ

១០. ត្រូតពិនិត្យ និងអនុម័តរបាយការណ៍លើការគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុង ដើម្បីស្នើសុំការអនុម័តពីក្រុមប្រឹក្សាភិបាល និងដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំ និងប្រគល់ជូនទៅធនាគារជាតិ នៃកម្ពុជា សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៩។

១១. ត្រូតពិនិត្យ និងអនុម័តរបាយការណ៍គណៈកម្មាធិការសវនកម្ម សម្រាប់ដាក់បញ្ចូលនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ២០១៨ និងដាក់ស្នើជូនធនាគារជាតិ នៃកម្ពុជា។

របាយការណ៍ហិរញ្ញវត្ថុ

១២. ត្រូតពិនិត្យរបាយការណ៍សវនកម្មហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ធនាគារដើម្បីធានាថារបាយការណ៍ហិរញ្ញវត្ថុ និងការកំណត់នានា ត្រូវបានអនុលោមតាមបទដ្ឋានគណនេយ្យ ដោយផ្តោតលើការផ្លាស់ប្តូរគោលការណ៍គណនេយ្យ ក៏ដូចជាព្រឹត្តិការណ៍ ប្រតិបត្តិការមិនធម្មតា និងគួរឲ្យកត់សម្គាល់។

សវនកម្មឯករាជ្យ

១៣. ត្រូតពិនិត្យ និងឯកភាពលើការតែងតាំងឡើងវិញនៃសវនករឯករាជ្យ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២១ និងថ្លៃឈ្នួលសវនកម្ម សម្រាប់ការិយបរិច្ឆេទ២០២០។ វាយតម្លៃឯករាជ្យភាព គោលដៅ កម្រិតវប្បធម៌ ជំនាញ ធនធាន និងប្រសិទ្ធភាពការងារនៃសវនករឯករាជ្យ។

១៤. ត្រូតពិនិត្យនូវលទ្ធផលសវនកម្ម របាយការណ៍សវនកម្ម និងលិខិតរបស់សវនករឯករាជ្យ ចំពោះគណៈគ្រប់គ្រង ព្រមទាំងការឆ្លើយតបរបស់គណៈគ្រប់គ្រង។

១៥. ត្រូតពិនិត្យការធានាជាលាយលក្ខណ៍អក្សរ ដែលបានផ្តល់ដោយសវនករឯករាជ្យ ដោយគោរពឯករាជ្យភាពរបស់ពួកគេ។ ពិនិត្យលើការជួយជ្រោមជ្រែងពីនិយោជិតធនាគារទៅកាន់សវនករឯករាជ្យ និងរាល់បញ្ហាលំបាក ដែលបានជួបប្រទះក្នុងអំឡុងពេលធ្វើសវនកម្ម រួមមានការដាក់កំហិតលើវិសាលភាពការងារ ឬការទទួលបានព័ត៌មានដែលចាំបាច់។

១៦. ត្រូតពិនិត្យប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ ដែលបានប្រកាសនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងភាពសមស្របនៃនីតិវិធីរបស់ធនាគារនៅក្នុងការកំណត់ ការត្រួតពិនិត្យ ការរាយការណ៍ និងការត្រួតពិនិត្យប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ។

ឃ. តួនាទីរបស់សវនកម្មផ្ទៃក្នុង

អង្គភាពឯករាជ្យ

តួនាទីសវនកម្មផ្ទៃក្នុង គឺត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាល ដើម្បីអនុវត្តការត្រួតពិនិត្យ និងវាយតំលៃឯករាជ្យ ដើម្បីផ្តល់នូវការធានាឯករាជ្យភាព និងគោលបំណងលើភាពពេញលេញ និងប្រសិទ្ធភាពនៃការអនុវត្តអភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យ និងដំណើរការអភិបាលកិច្ចរបស់គណៈគ្រប់គ្រង។ មុខងារសវនកម្មផ្ទៃក្នុងរបស់ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី ត្រូវបានបង្កើតឡើង និងមានមុខងាររាយការណ៍ជូនគណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល និងរាយការណ៍បែបការងាររដ្ឋបាលជូន នាយកប្រតិបត្តិ និងរាយការណ៍តាមខ្សែបណ្តាញជូន នាយកនាយកដ្ឋានសវនកម្ម នៃសម្ព័ន្ធធនាគារ។ មុខងាររបស់សវនកម្មផ្ទៃក្នុង គឺមានភាពឯករាជ្យ ពីសកម្មភាព ឬប្រតិបត្តិការរបស់អង្គភាពប្រតិបត្តិការរបស់ធនាគារ។

អង្គភាពសវនកម្មផ្ទៃក្នុង បច្ចុប្បន្ននេះមាន លោក សុខ ច័ន្ទតារា ជានាយក នាយកដ្ឋានសវនកម្មផ្ទៃក្នុង។ លោក មានបទពិសោធន៍ជាង១០ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា។ លោកទទួលបានបរិញ្ញាប័ត្រ២ ដែលក្នុងនោះរួមមានសញ្ញាប័ត្រ ផ្នែកព័ត៌មានវិទ្យា និងមួយទៀត គឺសញ្ញាប័ត្រអភិវឌ្ឍសេដ្ឋកិច្ច។ ក្នុងពេលបច្ចុប្បន្ន លោកសុខ ច័ន្ទតារា កំពុងតែបន្តយក វិជ្ជាជីវៈផ្នែក សវនកម្មផ្ទៃក្នុងដែលរៀបចំដោយវិទ្យាស្ថានសវនកម្មផ្ទៃក្នុង។

ទំនួលខុសត្រូវ វិសាលភាព និងវិធីសាស្ត្រ

ទំនួលខុសត្រូវចម្បងនៃសវនកម្មផ្ទៃក្នុង គឺវាយតម្លៃលើប្រសិទ្ធភាពនៃអភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ និងក្របខ័ណ្ឌគ្រប់គ្រងផ្ទៃក្នុង និងវាយតម្លៃថាតើហានិភ័យផ្សេងៗ ដែលអាចរារាំងធនាគារពីការសម្រេចបានវត្ថុបំណងរបស់ខ្លួន ត្រូវបានវាយតម្លៃ គ្រប់គ្រង និងចាត់ចែងគ្រប់គ្រាន់។ សវនកម្មផ្ទៃក្នុងផ្តល់ជូននូវការធានា អាស្រ័យលើហានិភ័យ និងគោលបំណង ផ្តល់យោបល់ និងការយល់ដឹង ដើម្បីលើកកម្ពស់ និងការពារគុណតម្លៃរបស់អង្គភាព និងជួយដល់ការគ្រប់គ្រង ដើម្បីគាំទ្រធនាគារឲ្យសម្រេចបានវត្ថុបំណងរបស់ខ្លួន។

វិសាលភាពនៃការងាររបស់សវនករផ្ទៃក្នុងឆ្នាំនេះ គ្របដណ្តប់មុខងារអាជីវកម្ម និងប្រតិបត្តិការនៃធនាគារ ដែល ត្រូវកំណត់រួចនៅក្នុងផែនការណ៍សវនកម្ម ប្រចាំឆ្នាំ២០២០ ដែលបានអនុម័តដោយគណៈកម្មាធិការ សវនកម្មនៃក្រុមប្រឹក្សាភិបាល ក្នុងខែធ្នូ ឆ្នាំ២០១៩។ ក្នុងការបង្កើតផែនការអង្គភាព ដែលអាចធ្វើសវនកម្មបានទាំងអស់ ត្រូវបានរៀបតាមលំដាប់នៃហានិភ័យ អាស្រ័យតាមវិធីសាស្ត្រកំណត់ហានិភ័យរបស់ធនាគារ មេយប៊ែង ខណៈគោលការណ៍ COSO ត្រូវបានយកមកប្រើប្រាស់ សម្រាប់ការវាយតម្លៃភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុង។ ផែនការសវនកម្មប្រចាំឆ្នាំ គឺស្របទៅនឹងយុទ្ធសាស្ត្រ គោលបំណង និងហានិភ័យផ្សេងៗរបស់ធនាគារ និងត្រូវបានអភិវឌ្ឍដោយបានពិភាក្សាជាមួយនាយកដ្ឋានសវនកម្មនៃសម្ព័ន្ធធនាគារ និងគណៈគ្រប់គ្រង។ សវនកម្មផ្ទៃក្នុង ក៏ផ្តល់ជូននូវការពិនិត្យពិគ្រោះយោបល់ឯករាជ្យ និងគោលបំណងលើការអនុវត្តគំនិតផ្តួចផ្តើម និងគម្រោង ថ្មីៗនៅក្នុងធនាគារ។

ដំណើរការ និងសកម្មភាពរបស់សវនកម្មផ្ទៃក្នុង ត្រូវបានគ្រប់គ្រងដោយគោលការណ៍ណែនាំបទប្បញ្ញត្តិក៏ដូចជាក្រមសីលធម៌ និងគោលការណ៍ណែនាំចាំបាច់ របស់វិទ្យាស្ថានសវនកម្មអន្តរជាតិ (IIA) នៃក្របខ័ណ្ឌអនុវត្តវិជ្ជាជីវៈអន្តរជាតិ (IPPF)។ របាយការណ៍សវនកម្ម គឺត្រូវបានដាក់ជូនទៅគណៈកម្មាធិការក្រុមប្រឹក្សាសវនកម្ម សម្រាប់ត្រួតពិនិត្យ និងពិភាក្សា ពាក់ព័ន្ធទៅនឹងបញ្ហាដើមហេតុ អនុសាសន៍សវនកម្ម ការឆ្លើយតបរបស់ថ្នាក់ដឹកនាំ និងផែនការសកម្មភាពសម្រាប់កែលម្អជាមួយការកែតម្រូវ។ ការកែតម្រូវនៃការរកឃើញ របស់សវនកម្ម ត្រូវបានតាមដាន និងរាយការណ៍ ជូនទៅគណៈកម្មាធិការសវនកម្ម ជាដំណាក់កាលទៀងទាត់ ដើម្បីធានាបាននូវការដោះស្រាយទាន់ពេលវេលា និងរាល់ការស្នើសុំសំរាបពេលវេលាបន្ថែម ត្រូវបានដាក់ចូលក្នុងកិច្ចប្រជុំសម្រាប់គណៈកម្មាធិការសវនកម្មធ្វើការអនុម័ត។

ការធានាគុណភាព និងកម្មវិធីកែលំអ នឹងត្រូវបានដាក់បន្តឲ្យប្រើប្រាស់ ដើម្បីវាយតំលៃ ទៅលើគុណភាពនៃដំណើរការរបស់សវនកម្មប្រៀបធៀបទៅ នឹងបទដ្ឋានអន្តរជាតិ ដែលបានប្រកាសឲ្យប្រើ ដោយវិទ្យាស្ថានសវនកម្មអន្តរជាតិ។ អនុសាសន៍ និងឱកាសសម្រាប់កែលំអ ត្រូវបានកំណត់តាមរយៈការវាយតម្លៃផ្ទៃក្នុង និងការវាយតម្លៃឯករាជ្យ។ ការវាយតម្លៃផ្ទៃក្នុង គឺត្រូវបានអនុវត្តប្រចាំឆ្នាំ ដោយក្រុមអ្នកវាយតម្លៃការធានាគុណភាពឯករាជ្យផ្ទៃក្នុងពីនាយកដ្ឋានសវនកម្ម នៃសម្ព័ន្ធធនាគារ ដែលក្រោមការគ្រប់គ្រងផ្ទាល់ដោយ ក្រុមប្រឹក្សាភិបាលនៃសវនកម្ម នៃសម្ព័ន្ធធនាគារ។ ការវាយតម្លៃឯករាជ្យ គឺត្រូវបានរៀបចំរៀងរាល់៥ឆ្នាំម្តង ដោយអ្នកវាយតម្លៃឯករាជ្យ និងវិជ្ជាជីវៈ។ ការធានាគុណភាព និងកម្មវិធីកែលំអ ធ្វើឡើងដោយសម្ព័ន្ធសវនកម្ម មកលើសវនកម្មនៃធនាគារ មេយប៊ែង ត្រូវបានធ្វើបទបង្ហាញក្នុងគណៈកម្មាធិការក្រុមប្រឹក្សាសវនកម្ម ឆ្នាំ២០២០។ ការវាយតម្លៃឯករាជ្យលើកចុងក្រោយគឺបានធ្វើឡើងដោយក្រុមហ៊ុនសវនកម្ម KPMG នៅក្នុងឆ្នាំ២០១៧ ដែលកាលនោះ សវនករផ្ទៃក្នុងរបស់ធនាគារ ត្រូវបានវាយតម្លៃថា បានអនុលោមជាមួយនឹងស្តង់ដារសវនកម្មផ្ទៃក្នុងអន្តរជាតិ និងអនុវត្តនាំមុខ។

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ សវនកម្មផ្ទៃក្នុងនៃធនាគារ មេយប៊ែង មាននិយោជិតសរុបចំនួន៦នាក់ ដែលមានប្រវត្តិរូប និងវិជ្ជាជីវៈផ្សេងៗគ្នា។ តាមទស្សនៈនៃការគ្រប់គ្រងចលនា និងតម្រូវការនៃគម្លាតសង្គម ការអភិវឌ្ឍនិងការកសាងជំនាញ និងសមត្ថភាពរបស់សវនករបានបន្តនៅលើវេទិកានិម្មិត។ បច្ចុប្បន្ននេះ សវនករទាំងអស់ បានកំពុងបន្តការសិក្សាលើជំនាញវិជ្ជាជីវៈផ្សេងៗ មានដូចជាគណនេយ្យការអាជីព សញ្ញាប័ត្រវាយតម្លៃតំណទាន វិជ្ជាជីវៈធនាគារអាជីព សវនកម្មផ្ទៃក្នុងអាជីព និងជំនាញផ្សេងៗទៀត។ វគ្គបណ្តុះបណ្តាល និងការណែនាំដែលជាប់ពាក់ព័ន្ធត្រូវបានផ្តល់ដោយសម្ព័ន្ធសវនកម្ម ដល់សវនកម្មផ្ទៃក្នុងរបស់ធនាគារ មេយប៊ែង ដើម្បីធានាភាពស្របគ្នាក្នុងកម្មវិធីនៃបទដ្ឋានសវនកម្ម ដំណើរការ ការអនុវត្ត ក៏ដូចជានីតិវិធីសាកល្បង។

សេចក្តីសង្ខេបនៃសកម្មភាពរបស់សវនកម្មផ្ទៃក្នុងសម្រាប់ការិយបរិច្ឆេទ ២០២០

១. ចូលរួមក្នុងកិច្ចប្រជុំ របស់គណៈកម្មាធិការគ្រប់គ្រងនានាដោយផ្ទាល់ និងនិម្មិតដូចជា គណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មាន គណៈកម្មាធិការប្រតិបត្តិ និងគណៈកម្មាធិការគ្រប់គ្រងប្រតិបត្តិតាម លើសមត្ថភាពប្រឹក្សា និងផ្តល់យោបល់ ដើម្បីផ្តល់នូវទស្សនៈឯករាជ្យទៅលើទិដ្ឋភាពនៃអភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យ។

២. បានបង្កើតផែនការសវនកម្មប្រចាំឆ្នាំ សម្រាប់ការិយបរិច្ឆេទ២០២០ និងកែតម្រូវផែនការដោយមើលឃើញពីតំបន់ហានិភ័យសំខាន់ៗ ដែលកើតឡើងដោយជំងឺរាតត្បាត ក៏ដូចជាភារកិច្ចបន្ថែមដែលធ្វើឡើង ដោយគណៈគ្រប់គ្រង និងគណៈកម្មាធិការក្រុមប្រឹក្សាសវនកម្ម ដើម្បីធានាថា ការធានារបស់សវនកម្ម អាចត្រូវបានផ្តល់ជូនជាបន្តបន្ទាប់ ដោយផ្តោតលើតំបន់ហានិភ័យដែលពាក់ព័ន្ធ និងពិចារណាវិធីសាស្ត្រផ្សេងទៀតដើម្បី ធ្វើសវនកម្ម។ ផែនការយុទ្ធសាស្ត្ររបស់ធនាគារ ទិដ្ឋភាពអាជីវកម្ម តម្រូវការបទប្បញ្ញត្តិក៏ដូចជាការផ្តល់យោបល់ពី គណៈកម្មាធិការគ្រប់គ្រង និងគណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល។

៣. បានចូលរួមសម័យប្រជុំការពារផែនការសវនកម្ម ក្នុងតំបន់រយៈពេលបីថ្ងៃ ដើម្បីពិភាក្សាវិធីសាស្ត្រសវនកម្ម និងការគ្រប់ដណ្តប់សម្រាប់ឆ្នាំ២០២១ មុនពេលការសម្រេចចុងក្រោយផែនការសវនកម្មប្រចាំឆ្នាំ សម្រាប់ការិយបរិច្ឆេទ២០២១។ ផែនការសវនកម្មប្រចាំឆ្នាំសម្រាប់ការិយបរិច្ឆេទ២០២១បានដាក់ជូន និងអនុម័ត ដោយគណៈកម្មាធិការក្រុមប្រឹក្សាសវនកម្ម និងក្រោយមកទៀត បានធ្វើបទបង្ហាញជូនក្រុមប្រឹក្សាភិបាល សម្រាប់ជាព័ត៌មាននៅក្នុងខែធ្នូ ឆ្នាំ២០២០។

របាយការណ៍គណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល

៤. បានធ្វើតេស្តត្រួតពិនិត្យផ្ទៃក្នុងជាប្រចាំទៅលើអង្គភាពអាជីវកម្ម ប្រតិបត្តិការ និងដំណើរការនៅក្នុងធនាគារ ដូចដែលបានកំណត់នៅក្នុងផែនការសវនកម្មប្រចាំឆ្នាំ២០២០ ហើយបានផ្តល់នូវ ការវាយតម្លៃដោយឯករាជ្យ និងអំណះអំណាងលើភាពពេញលេញ និងប្រសិទ្ធភាពអភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង របស់អង្គភាពដែលបានធ្វើសវនកម្មរួច។ ក្នុងចំណោមផ្នែកនានា ដែលបានវាយតម្លៃក្នុងឆ្នាំ២០២០ រួមមាន បណ្តាញសាខាហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា និងសុវត្ថិភាពឥណទានគ្រប់ផ្នែក មុខងារហានិភ័យអង្គភាពប្រឆាំង នឹងការសម្អាតប្រាក់កខ្វក់ ការគ្រប់គ្រងគុណភាពទ្រព្យសកម្ម សេវាកម្មធនាគារនិម្មិត និងការទូទាត់ រដ្ឋបាលឥណទាន ដំណើរការវាយតំលៃភាពគ្រប់គ្រាន់នៃដើមទុនផ្ទៃក្នុង ស្ត្រេសតេស្ត (Stress Testing) ។ល។

៥. រៀបចំ និងចេញរបាយការណ៍សវនកម្ម ទៅសវនករគណៈគ្រប់គ្រង និងគណៈកម្មាធិការក្រុមប្រឹក្សាសវនកម្ម ជាមួយសមិទ្ធិផលនៃការវាតតម្លៃត្រួតពិនិត្យផ្ទៃក្នុង ដោយរួមទាំងការវិភាគលម្អិត ការឆ្លើយតបរបស់គណៈគ្រប់គ្រង និងអនុសាសន៍របស់សវនកម្មព័ត៌មានដើម្បីពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការគ្រប់គ្រងហានិភ័យ។

៦. ផ្តល់នូវការត្រួតពិនិត្យឯករាជ្យ និងជាក់លាក់លើភាពពេញលេញនៃការត្រួតពិនិត្យផ្ទៃក្នុងដើម្បីកាត់បន្ថយការប្រឈម និងកំណត់អត្តសញ្ញាណហានិភ័យនៃការដាក់ឲ្យប្រើប្រាស់នូវផលិតផលក៏ដូចជាសេវាកម្មថ្មីៗ និងពង្រីកផលិតផល និងការអនុវត្ត ដែលមានស្រាប់។

៧. អនុវត្តភារកិច្ចបន្ថែម ការត្រួតពិនិត្យពិសេស និងការស៊ើបអង្កេត ទៅតាមការណែនាំពីគណៈកម្មាធិការក្រុមប្រឹក្សាសវនកម្ម ឬស្នើដោយគណៈគ្រប់គ្រង។ លទ្ធិផលដែលបានមកពីការត្រួតពិនិត្យ ដែលត្រូវបានដាក់ជូនគណៈកម្មាធិការសវនកម្មផ្ទៃក្នុង និងគណៈកម្មការក្រុមប្រឹក្សាសវនកម្មសម្រាប់ពិភាក្សា។

៨. រៀបចំរបាយការណ៍គណៈកម្មាធិការសវនកម្ម និងរបាយការណ៍លើការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង សម្រាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំការិយបរិច្ឆេទឆ្នាំ២០១៩ នៅពេលមានការយល់ព្រមពីគណៈកម្មាធិការក្រុមប្រឹក្សាសវនកម្ម និងក្រុមប្រឹក្សាភិបាល។

៩. ចូលរួមក្នុងការគ្រប់គ្រងបន្តអាជីវកម្ម រួមជាមួយលំហាត់សមក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺរាតត្បាត ដើម្បីធានាបាននូវសកម្មភាពអាជីវកម្មឡើងវិញមិនត្រូវបានរារាំង។

១០. ចូលរួមជាមួយ និងអង្គភាពដែលពាក់ព័ន្ធផ្សេងៗ ដើម្បីពិភាក្សា និងលើកឡើងពីហានិភ័យ និងការគ្រប់គ្រងបរិវេណ នៅក្នុងតំបន់ផ្សេងៗរបស់ពួកគេ។

១១. តាមដាន និងរាយការណ៍អំពីការអនុវត្តផែនការសកម្មភាព ដើម្បីដោះស្រាយលទ្ធផលសវនកម្មដែលគួសបញ្ជាក់ដោយសវនកម្មផ្ទៃក្នុង។ ការស្នើសុំពន្យាពេលត្រូវបានដាក់ទៅគណៈកម្មាធិការក្រុមប្រឹក្សាសវនកម្ម ដើម្បីពិភាក្សានិងអនុម័ត។

របាយការណ៍
ស្តីអំពីចីរភាព

ការប្តេជ្ញាចិត្តរបស់យើង ចំពោះចីរភាព គឺផ្អែកលើទស្សនៈដែលយល់ថា ការប្រតិបត្តិការអាជីវកម្មប្រកបដោយទំនួលខុសត្រូវលើសេដ្ឋកិច្ច បរិស្ថាន និងសង្គម គឺជាការចាំបាច់ចំពោះសុខុមាលភាព និងភាពរឹងមាំរយៈពេលវែងរបស់ភាគីពាក់ព័ន្ធ និងអាជីវកម្មរបស់ពួកយើង។ ស្របតាមបេសកកម្ម សេវាកម្មហិរញ្ញវត្ថុប្រកបដោយអារិយ្យភាព របស់ពួកយើង ការខិតខំប្រឹងប្រែង របស់សម្ព័ន្ធធនាគារ មេយប៊ែង ក្នុងការបញ្ចូលចីរភាពទៅក្នុងការប្រតិបត្តិការអាជីវកម្មរបស់ពួកយើង ត្រូវបានកំណត់តាមរយៈតម្រូវការរបស់ក្រុមមនុស្សនានា ដែលពួកយើងបម្រើដែលរួមមានអតិថិជន បរិស្ថាន និយោជិត និងសហគមន៍របស់ពួកយើង។ នៅក្នុងការពិនិត្យឡើងវិញនៃរបាយការណ៍ចីរភាពនេះ ពួកយើងបានរាយការណ៍អំពីគុណតម្លៃ ដែលធនាគារ បានបង្កើតសម្រាប់ភាគីពាក់ព័ន្ធទាំងអស់ និងសហគមន៍ផ្សេងៗទៀតនាឆ្នាំ២០២០នេះ។

ចាប់តាំងពីឆ្នាំ២០១៥ កិច្ចខិតខំប្រឹងប្រែងប្រកបដោយចីរភាពរបស់ធនាគារ មេយប៊ែង ត្រូវបានអនុវត្តតាមផែនការចីរភាព២០/២០ របស់ធនាគារ ដែលផ្តោតលើការបង្កើតគុណតម្លៃរយៈពេលវែងនៅលើសសរស្តម្ភទាំង៣ គឺ៖ សហគមន៍ និងភាពជាពលរដ្ឋគំរូ និយោជិតរបស់យើង និងការទទួលបានសេវាកម្មនិងផលិតផល។ ផ្អែកលើការប្តេជ្ញាចិត្តទាំង១០ ដែលមានចែងនៅក្នុងផែនការចីរភាព២០/២០ ធនាគារ មេយប៊ែង បានបង្កើតនូវកម្មវិធី និងការផ្តួចផ្តើមនានាប្រកបដោយប្រសិទ្ធភាព នៅតាមបណ្តាប្រទេស ដែលពួកយើងបានធ្វើប្រតិបត្តិការក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ។ ផែនការ ២០/២០ ក៏បានជួយពង្រឹងដល់ការធ្វើសមាហរណកម្មចីរភាពក្នុងការអនុវត្តអាជីវកម្មរបស់ពួកយើង ដោយបង្កើតជាមូលដ្ឋានគ្រឹះមួយ ដើម្បីកាត់បន្ថយផលប៉ះពាល់នាពេលអនាគត។

រូបថតជាក្រុមនៃ លោកជំទាវ ជា សិរី ឧបការីទេសាភិបាល និងអគ្គនាយកបច្ចេកទេស នៃធនាគារជាតិ នៃកម្ពុជា ឯកឧត្តមបណ្ឌិត អ៊ឹម កុច រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ដាតុ ម៉ូហាមាដ ហានីវស៊ូអាឌី នាយកប្រតិបត្តិនៃធនាគារ មេយប៊ែង លោក សារៀល អាស៊ូ ជីមីន នាយកប្រតិបត្តិ នៃមូលនិធិធនាគារ មេយប៊ែង ម៉ៃឃើល រីស ស្ថាបនិក MoneyTreeអាស៊ីប៉ាស៊ីហ្វិក គណៈគ្រប់គ្រងនៃធនាគារ មេយប៊ែង គណៈគ្រប់គ្រងនៃមូលនិធិធនាគារ មេយប៊ែង ម្ចាស់ពានរង្វាន់សាលាល្អបំផុត ពានរង្វាន់អ្នកអប់រំល្អបំផុត និងពានរង្វាន់សិស្សឆ្នើម បេក្ខជនជម្រើសចុងក្រោយ និងអាណាព្យាបាលសិស្ស។

ផែនការចីរភាព ២០/២០ របស់សម្ព័ន្ធ ធនាគារ មេយប៊ែង

សសរស្តម្ភទាំង៣ នៃផែនការចីរភាព ២០/២០

ការប្តេជ្ញាចិត្តទាំង១០

ការរួមចំណែកដល់គោលដៅអភិវឌ្ឍប្រកបដោយចីរភាព

សហគមន៍ និងប្រជាជាតិ

វិនិយោគដើម្បីផ្តល់ផលប្រយោជន៍

- ការអប់រំ
- ការលើកកម្ពស់សហគមន៍
- សិល្បៈ និងវប្បធម៌
- ភាពចម្រុះនៃបរិស្ថាន
- ការរស់នៅប្រកបដោយសុខុមាលភាព
- ជំនួយមនុស្សធម៌

និយោជិតរបស់យើង

- ការចូលរួមរបស់និយោជិត
- ភាពជាអ្នកដឹកនាំ និងធនធានមនុស្ស
- ការបណ្តុះបណ្តាល និងកសាងសមត្ថភាព
- កន្លែងការងារដែលមានភាពចម្រុះ និងការដាក់បញ្ចូល
- សុវត្ថិភាព សុខភាព និងសុខុមាលភាព

ការទទួលបានសេវាកម្ម និងផលិតផល

- ការប្តេជ្ញាចិត្តចំពោះបរិស្ថាន
- ការផ្តោតទៅលើអតិថិជន
- ប្រព័ន្ធឌីជីថល
- សេវាកម្មគ្រប់គ្រងហិរញ្ញវត្ថុ

របាយការណ៍ស្តីអំពីចីរភាព

អភិបាលកិច្ចប្រកបដោយចីរភាព

ការទទួលខុសត្រូវចំពោះយុទ្ធសាស្ត្រចីរភាពរបស់ធនាគារ មេយប៊ែង ត្រូវបានដាក់បញ្ចូលនៅក្នុងក្របខណ្ឌនៃអភិបាលកិច្ចសាជីវកម្មកម្រិតខ្ពស់។ ភាពស៊ីជម្រៅនៃវិធីសាស្ត្រ និងការអនុវត្តនានាប្រកបដោយចីរភាពរបស់ធនាគារ ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាល។ អភិបាលកិច្ចប្រកបដោយចីរភាព ត្រូវបានដាក់បញ្ចូលទៅក្នុងការអនុវត្តការងារនានារបស់ធនាគារ ដោយមានការទទួលខុសត្រូវត្រឹមត្រូវ នៅគ្រប់កម្រិតនៃការគ្រប់គ្រង។

ធនាគារ មេយប៊ែង នៅប្រទេសកម្ពុជា	
គណៈអភិបាល	**តួនាទី**
ក្រុមប្រឹក្សាភិបាល	ពិនិត្យមើលការអនុវត្តប្រកបដោយចីរភាព និងយុទ្ធសាស្ត្រសាជីវកម្មរបស់ធនាគារ ដើម្បីពង្រឹងការអនុវត្តការងារប្រកបដោយចីរភាព ដោយផ្អែកលើគោលការណ៍ បរិស្ថាន សង្គម និងអភិបាលកិច្ច។.
នាយកប្រតិបត្តិ	សម្របសម្រួល និងអនុម័តរាល់បញ្ហាដែលទាក់ទងនឹងចីរភាពរបស់ធនាគារ។
ក្រុមប្រឹក្សាចីរភាពនៃសម្ព័ន្ធធនាគារ	កំណត់របៀបវារៈផ្នែកចីរភាពរបស់សម្ព័ន្ធធនាគារ រួមទាំងយុទ្ធសាស្ត្រ ការកំណត់គោលការណ៍បង្ហាញផ្លូវ និងការត្រួតពិនិត្យផែនការសកម្មភាព។ ក្រុមប្រឹក្សា ធ្វើការរាយការណ៍ទៅ ប្រធាន និងនាយកប្រតិបត្តិនៃសម្ព័ន្ធធនាគារ និងត្រូវបានតំណាងដោយនាយកប្រតិបត្តិប្រចាំប្រទេសនីមួយៗ នាយកផ្នែកអាជីវកម្ម និងនាយកផ្នែកប្រតិបត្តិការនានា ដោយមានាយក នៃនាយកដ្ឋាននានា ដែលបានកំណត់ ត្រូវបានអញ្ជើញឲ្យចូលរួម។.
នាយកដ្ឋានផ្សេងៗ	ផែនការប្រតិបត្តិការប្រកបដោយចីរភាព ២០/២០ ត្រូវបានអនុវត្តនៅក្នុងវិស័យអាជីវកម្ម និងប្រតិបត្តិការនីមួយៗ។ នាយកដ្ឋាន និងក្រុមនីមួយៗ ផ្តល់ព័ត៌មាន ដែលឆ្លើយតបទៅនឹងសូចនាការនានា ដែលអាចវាស់វែងបាន។

មូលនិធិធនាគារ មេយប៊ែង	
គណៈអភិបាល	**តួនាទី**
ក្រុមប្រឹក្សាភិបាល	អនុម័ត និងពិនិត្យមើលកម្មវិធី និងការអនុវត្ត។
នាយកប្រតិបត្តិ	ពិនិត្យមើលជារួមនូវយុទ្ធសាស្ត្រ និងវឌ្ឍនភាពទាំងមូល។
សមាជិកក្រុមការងារមូលនិធិ ធនាគារ មេយប៊ែង	អនុវត្ត និងត្រួតពិនិត្យកម្មវិធីសហគមន៍របស់ធនាគារ មេយប៊ែង ដោយផ្អែកលើការផ្តោតសំខាន់ៗក្រោមសរសេរស្តម្ភសហគមន៍ និងភាពជាពលរដ្ឋគំរូ នៅក្នុងផែនការចីរភាព ២០/២០ របស់ពួកយើង។ គាំទ្រភាពជាដៃគូ និងការផ្តួចផ្តើមកម្មវិធីសហគមន៍នៅទូទាំងសម្ព័ន្ធធនាគារ។

ការគ្រប់គ្រងហានិភ័យលើបរិស្ថាន សង្គម និងអភិបាលកិច្ច

ធនាគារ មេយប៊ែង កំពុងបន្តលើកកម្ពស់ការគិតគូរពីបរិស្ថាន សង្គម និងអភិបាលកិច្ច ទៅក្នុងសកម្មភាពគ្រប់គ្រងហានិភ័យរបស់ពួកយើង ដើម្បីធានាថា ពួកយើងកំពុងធ្វើការដោះស្រាយនូវហានិភ័យនានា ដែលកំពុងរីករាលដាល ប្រកបដោយប្រសិទ្ធភាព។ ការគ្រប់គ្រងហានិភ័យលើ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច របស់ធនាគារ មេយប៊ែង ត្រូវបានគ្រប់គ្រងតាមរយៈក្របខណ្ឌគ្រប់គ្រងហានិភ័យរបស់យើង ដែលកំណត់ចីរភាពជាកត្តាជំរុញ។ នៅឆ្នាំ ២០២០ យើងបានចាប់ផ្តើមបង្កើតក្របខណ្ឌគ្រប់គ្រងហានិភ័យ គោលការណ៍ បរិស្ថាន សង្គម និងអភិបាលកិច្ច ដែលជាឯកសារហានិភ័យដ៏ទូលំទូលាយមួយនៃសម្ព័ន្ធធនាគារ ដែលគូសបញ្ជាក់ពីគោលការណ៍ និងប្លុកគ្រឹះសម្រាប់ការគ្រប់គ្រងហានិភ័យគោលការណ៍ បរិស្ថាន សង្គម និងអភិបាលកិច្ច។ គោលការនេះ បានបំពេញក្របខណ្ឌគ្រប់គ្រងហានិភ័យសហគ្រាស របស់សម្ព័ន្ធធនាគារ មេយប៊ែង ហើយត្រូវបានគាំទ្រដោយគោលការណ៍ហានិភ័យទាំងអស់ ដែលមានធាតុបញ្ចូលហានិភ័យស្តីអំពីគោលការណ៍ បរិស្ថាន សង្គម និងអភិបាលកិច្ច។ វានឹងត្រូវបានដាក់ចេញជាព័ត៌មាន និងអនុម័តដោយប្រទេសនានារួមទាំងប្រទេសកម្ពុជាផងដែរ។

សកម្មភាពផ្តល់ហិរញ្ញប្បទានរបស់ពួកយើង បានបង្ហាញនូវចំនុចសំខាន់មួយ ដែលមានសក្តានុពលក្នុងការបង្កើតការគ្រប់គ្រងហានិភ័យស្តីអំពីគោលការណ៍ បរិស្ថាន សង្គម និងអភិបាលកិច្ច សម្រាប់ធនាគារ។ គោលនយោបាយ គោលការណ៍ បរិស្ថាន សង្គម និងអភិបាលកិច្ច របស់យើងរួមបញ្ចូលទាំងការពិចារណាលើហានិភ័យស្តីអំពីគោលការណ៍ បរិស្ថាន សង្គម និងអភិបាលកិច្ច ចូលទៅក្នុងការផ្តល់ហិរញ្ញប្បទានរបស់ពួកយើង ដូច្នេះពួកយើង អាចផ្តោតលើការកាត់បន្ថយហានិភ័យស្តីអំពីគោលការណ៍ បរិស្ថាន សង្គម និងអភិបាលកិច្ច ខណៈពេលបង្កើតតម្លៃរយៈពេលវែងសម្រាប់ម្ចាស់ភាគហ៊ុននិងអតិថិជន។ យោងតាមគោលនយោបាយ គោលការណ៍ បរិស្ថាន សង្គម និងអភិបាលកិច្ចរបស់ពួកយើង តម្រូវការសម្រាប់ការបញ្ជាក់ឧស្សាហកម្ម ដែលទាក់ទងនឹងគោលការណ៍ បរិស្ថាន សង្គម និងអភិបាលកិច្ច និងលក្ខន្តិកៈនៃការទទួលយកហានិភ័យជាក់លាក់ ត្រូវបានបង្កើតឡើងសម្រាប់ឧស្សាហកម្ម ដែលមានហានិភ័យខ្ពស់ រួមមានឧស្សាហកម្មព្រៃឈើ ការរុករកឥន្ធនៈ និងប្រេងដូង រ៉ែ និងឧស្សាហកម្មថ្មី។ លើសពីដំណើរការវាយតម្លៃដែលមានចែងនៅក្នុងគោលនយោបាយស្តីអំពីគោលការណ៍ បរិស្ថាន សង្គម និងអភិបាលកិច្ច របស់ពួកយើង ធនាគារ មេយប៊ែង មានវិធីសាស្ត្រសកម្មក្នុងការអភិវឌ្ឍសមត្ថភាពស្ថាប័នសម្រាប់ការគ្រប់គ្រងហានិភ័យស្តីអំពីគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច។ ការអន្តរាគមន៍ទៅលើ គោលការណ៍ស្តីអំពីបរិស្ថាន សង្គម និងអភិបាលកិច្ច របស់យើង ត្រូវបានគ្រប់គ្រងដោយក្រុមវាយតម្លៃការអនុវត្តគោលការណ៍ស្តីអំពីបរិស្ថាន សង្គម និងអភិបាលកិច្ច ដែលធ្វើការជាមួយភាគីពាក់ព័ន្ធ និងអតិថិជន ដើម្បីកំណត់ឱកាសក្នុងការដាក់បញ្ចូលចីរភាព ទៅក្នុងការអនុវត្តអាជីវកម្មរបស់អតិថិជន។ ក្រុមការងារនេះ ក៏ជាអ្នកផ្តល់ការយល់ដឹងអំពីសក្តានុពល និងហានិភ័យអាជីវកម្ម ដែលកំពុងកើតមាន និងធ្វើការ ដើម្បីកាត់បន្ថយហានិភ័យបែបនេះផងដែរ។

របាយការណ៍ហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ

វិធីសាស្ត្រ ដែលបានរៀបចំឡើងរបស់ពួកយើង ក្នុងការកំណត់ និងគ្រប់គ្រងបម្រែបម្រួលហានិភ័យ អនុញ្ញាតឲ្យពួកយើងផ្តោតលើការយល់ដឹងអំពីហានិភ័យពិតប្រាកដ ដោយប្រើប្រាស់គោលនយោបាយ ដែលបានកំណត់និងការផ្តួចផ្តើមនានាដើម្បីកាត់បន្ថយការបំពុលដោយកាបូនឲ្យនៅទាបបំផុត តាមដែលអាចធ្វើទៅបាន។ ក្នុងនាមជាសម្ព័ន្ធធនាគារ ឆ្នាំនេះ គឺជាឆ្នាំទីបីរបស់ពួកយើងក្នុងការផ្តល់ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុស្របទៅតាមការផ្តល់អនុសាសន៍។

អភិបាលកិច្ច

- គោលការណ៍ណែនាំស្តីពីការផ្តល់ហិរញ្ញប្បទានប្រកបដោយការទទួលខុសត្រូវ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៥ និងត្រូវបានពង្រីកជាបន្តបន្ទាប់នៅឆ្នាំ ២០១៨ ដើម្បីបង្កើតគោលនយោបាយស្តីអំពីគោលការណ៍ បរិស្ថាន សង្គម និងអភិបាលកិច្ច។
- ការពិចារណាទាក់ទងនឹងអាកាសធាតុកំពុងត្រូវបានបញ្ចូលទៅក្នុងគោលនយោបាយស្តីអំពីគោលការណ៍ បរិស្ថាន សង្គម និងអភិបាលកិច្ចរបស់ពួកយើង និងកំណត់ជាប្រភេទហានិភ័យទាក់ទងនឹងចីរភាព។ គណៈកម្មាធិការប្រតិបត្តិរបស់សម្ព័ន្ធធនាគារ និងក្រុមប្រឹក្សាភិបាល បានត្រួតពិនិត្យកិច្ចការទាំងនេះតាមរយៈក្រុមប្រឹក្សាភិបាលផ្នែកចីរភាពរបស់សម្ព័ន្ធធនាគារ មេយប៊ែង គណៈកម្មាធិការហានិភ័យ និងផែនការចីរភាព២០/២០ ។

ការគ្រប់គ្រងហានិភ័យ

- ធនាគារ មេយប៊ែង មានគោលនយោបាយស្តីអំពីការមិនពាក់ព័ន្ធនឹងការកាប់បំផ្លាញព្រៃឈើ ការអភិវឌ្ឍលើឥន្ធនៈ និងការកេញប្រវ័ញ្ញកម្លាំងពលកម្ម (NDPE) ជាផ្លូវការ ដែលត្រូវបានទទួលដោយក្រុមប្រឹក្សាភិបាល។
- ហានិភ័យស្តីអំពីគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ត្រូវបានដាក់បញ្ចូលទៅក្នុងការវាយតម្លៃការផ្តល់ហិរញ្ញប្បទាន ហើយលក្ខន្តិកៈនៃការទទួលយកហានិភ័យ គឺមាននៅក្នុងឧស្សាហកម្មព្រៃឈើ ការរុករកឥន្ធនៈ និងប្រេងដូង រ៉ែ និងឧស្សាហកម្មថ្មី។
- បង្កើតក្របខណ្ឌ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ចរបស់សម្ព័ន្ធធនាគារ ដើម្បីផ្តល់ទិសដៅសម្រាប់ការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ដែលគាំទ្រដោយក្របខណ្ឌហានិភ័យសំខាន់ៗ និងគោលនយោបាយ និងនីតិវិធីពាក់ព័ន្ធនានា។

ម៉ាទ្រីស និងគោលដៅ

- ស្របតាមយុទ្ធសាស្ត្រចីរភាពរបស់ធនាគារ មេយប៊ែង ផែនការចីរភាព២០/២០ ពួកយើងបានធ្វើការតាមដានអំពីឥទ្ធិពលលើបរិស្ថាន ដែលកើតចេញពីការធ្វើប្រតិបត្តិការរបស់ពួកយើងនៅបណ្តាប្រទេសនានាដូចជាប្រទេសម៉ាឡេស៊ី និងសិង្ហបុរី។
- ធនាគារ មេយប៊ែង បានធ្វើការវាស់វែងអំពីធនធាន ដែលយើងបានប្រើប្រាស់ផ្ទៃក្នុង ដូចជាការប្រើប្រាស់អគ្គីសនី និងក្រដាសជាដើម។

បោយការណ៍ស្តីអំពីចីរភាព

ការយកចិត្តទុកដាក់ចំពោះអតិថិជន និងសហគមន៍

ផែនការចីរភាព ២០/២០

ការប្តេជ្ញាចិត្ត៖

- ការផ្តោតលើអតិថិជន
- ការប្រើប្រាស់ប្រព័ន្ធឌីជីថល
- ភាពលេចធ្លោនៃទំនួលខុសត្រូវលើផលិតផល

វឌ្ឍនភាព៖

ធនាគារ មេយប៉ែង បានបន្តលើកកម្ពស់គុណភាពសេវាកម្មក្រោមផែនការចីរភាព ២០/២០ ។ ឌីជីថលនីយកម្ម បានដើរតួជាជាកម្លាំងចលការដ៏សំខាន់ ក្នុងការកែលម្អដល់ការទទួលបានផលិតផល និងសេវាកម្មហិរញ្ញវត្ថុរបស់ធនាគារ ហើយធនាគារ បានដាក់ដំណើរការឧស្សាហកម្មជាលើកដំបូង នៅក្នុងផលិតផលហិរញ្ញវត្ថុឌីជីថលបានដោយជោគជ័យ។ ធនាគារ មេយប៉ែង បន្តផ្តល់ជូននូវផលិតផល និងសេវាកម្ម ដែលឆ្លើយតបទៅនឹងតម្រូវការអតិថិជនខាងសេដ្ឋកិច្ច និងសង្គម។

SDGs

ធនាគារ នៅក្នុងបេះដូងរបស់សហគមន៍៖ ការផ្តោតសំខាន់របស់ពួកយើង គឺធានាថា អតិថិជន និងសហគមន៍ អាចទទួលបានសេវាហិរញ្ញវត្ថុ ដែលពួកគេត្រូវការ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ពួកយើង បានប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ដើម្បីផ្តល់សេវាកម្មហិរញ្ញវត្ថុ ដែលកាន់តែមានលក្ខណៈឌីជីថល ចល័ត និងអាចប្រើប្រាស់បានតាមតម្រូវការ។ នៅពេលដែល ពួកយើងពង្រីក និងបង្កើនការផ្តល់ជូនផលិតផល និងសេវាកម្មរបស់ពួកយើងជូនដល់អតិថិជន និងសហគមន៍ ពួកយើងនៅតែផ្តោតលើការធ្វើសកម្មភាពដោយយកចិត្តទុកដាក់ និងផ្តល់នូវបទពិសោធន៍ដ៏ល្អបំផុត សម្រាប់អតិថិជន ដែលពួកយើងបម្រើ។

នៅឆ្នាំ ២០២០ ការផ្តល់សេវាកម្មហិរញ្ញវត្ថុរបស់ពួកយើង ត្រូវបានរងផលប៉ះពាល់ដោយសារជំងឺរាតត្បាតកូវីដ១៩។ ឆ្លើយតបទៅនឹងបញ្ហាហិរញ្ញវត្ថុ ដែលបានកើតឡើងដោយព្រឹត្តិការណ៍នេះ ធនាគារ មេយប៉ែង បានអនុវត្តវិធានការណ៍មួយចំនួន ដើម្បីគាំទ្រដល់អតិថិជនរបស់ពួកយើង រួមទាំងសេវាកម្មប្រឹក្សាយោបល់ផ្នែកហិរញ្ញវត្ថុដោយឥតគិតថ្លៃដល់អតិថិជនអាជីវកម្មរបស់យើង និងផ្តល់ការគាំទ្របន្ទាប់ពីការរងផលប៉ះពាល់ពីជំងឺរាតត្បាតកូវីដ១៩ តាមរយៈការរៀបចំឥណទានឡើងវិញ និងការកំណត់ពេលវេលាសងឥណទានឡើងវិញ ក៏ដូចជាការផ្អាកការសងប្រាក់កម្ចី។ ជំនួយហិរញ្ញវត្ថុនេះ គឺត្រូវបានផ្តល់ជូនដល់អតិថិជនអាជីវកម្ម និងអតិថិជនបុគ្គលទាំងអស់ ដែលរងផលប៉ះពាល់ដោយស្ថានភាពដ៏លំបាកមួយនេះ ហើយនឹងត្រូវធ្វើការសិក្សានិងវាយតម្លៃតាមករណីជាក់ស្តែងរបស់អតិថិជនម្នាក់ៗ។

ដោយសារតម្រូវការរបស់អតិថិជន មានការវិវឌ្ឍនៅក្នុងវិស័យឌីជីថល ធនាគារ មេយប៉ែង បានបន្តផ្តល់ជូននូវបទពិសោធន៍ និងភាពងាយស្រួលខ្ពស់បំផុត ស្របតាមការប្តេជ្ញាចិត្តរបស់ពួកយើង ដើម្បីក្លាយជាធនាគារជម្រើសឌីជីថល។ នៅឆ្នាំនេះ ពួកយើង បានបន្តធ្វើឲ្យប្រសើរឡើងនូវការផ្តល់ជូនរបស់ពួកយើង សម្រាប់អតិថិជនរួមទាំងការពង្រឹងប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់តាមតំបន់ (Maybank2e) ដោយមានការណែនាំអំពីដំណោះស្រាយ host-to-host ដល់អតិថិជនរបស់ធនាគារ និងការដាក់ឲ្យប្រើប្រាស់នូវកម្មវិធីធនាគារចល័ត Maybank2u ដ៏ថ្មីស្រឡាងសម្រាប់អតិថិជននៅក្នុងប្រទេសកម្ពុជា។ កម្មវិធីធនាគារចល័ត Maybank2u ដែលបានរចនាថ្មីនេះ ផ្តល់ជូននូវរូបរាង និងមុខងារកាន់តែប្រសើរ និងផ្ទុកនូវមុខងារថ្មីៗដូចជាការចូលទៅកាន់គណនី ដោយស្វ័យប្រវត្តិ ការផ្ទើរសាររំលឹក ការទូទាត់វិក្កយបត្រ ការបញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទ។ ល។

ពួកយើង ក៏បានធ្វើការលើកកម្ពស់នូវសេវាកម្មធនាគារតាមអ៊ីនធឺណែត តាមរយៈយុទ្ធនាការទីផ្សារមួយចំនួន ដូចជា ការផ្តល់ជូនពិសេសនូវការផ្ទេរប្រាក់តាមប្រព័ន្ធអ៊ីនធឺណេតទៅកាន់បណ្តាធនាគារនានានៅក្នុងប្រទេសកម្ពុជា ដោយមានកម្រៃសេវាកម្មត្រឹមតែ១ដុល្លារ តាមរយៈសេវាកម្មធនាគារ Maybank2u និង Maybank2e យុទ្ធនាការធ្វើការទាញយកកម្មវិធីធ្វើប្រតិបត្តិការ និងឈ្នះរង្វាន់។ល។



ការគាំទ្រដល់អាជីវកម្មរបស់យើង

ផែនការចីរភាព ២០/២០

ការប្តេជ្ញាចិត្ត៖

- ការផ្តោតលើអតិថិជន

វឌ្ឍនភាព៖

ក្នុងរយៈពេលមួយឆ្នាំកន្លងមក ធនាគារ មេយប៉ែង បានបន្តការគាំទ្រដល់អតិថិជនអាជីវកម្ម ជាពិសេសសហគ្រាសធុនតូច និងមធ្យម និងសហគ្រាសធុនតូច ដែលមានលទ្ធភាពទទួលបានហិរញ្ញវត្ថុ ឬសេវាកម្មហិរញ្ញវត្ថុនៅមានកម្រិត។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ ត្រូវបានជំរុញតាមរយៈភាពជាដៃគូជាមួយធនាគារធុនតូច និងមធ្យមនៅកម្ពុជា ដើម្បីដោះស្រាយសេចក្តីត្រូវការនៅក្នុងវិស័យនេះ។

SDGs

នៅធនាគារ មេយប៉ែង ពួកយើងតែងតែខិតខំប្រឹងប្រែង ដើម្បីជួយអាជីវកម្មឲ្យរីកចម្រើន។ ក្នុងការធ្វើដូច្នេះយើងមានការយល់ដឹងជាពិសេស អំពីតម្រូវការរបស់សហគ្រាសធុនតូច និងមធ្យម ដែលដើរតួនាទីយ៉ាងសំខាន់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងការបង្កើតការងារដល់និយោជិត។ ធនាគារ មេយប៉ែង បានសហការជាមួយធនាគារធុនតូច និងមធ្យមនៅកម្ពុជា តាមរយៈគម្រោងសហហិរញ្ញប្បទានខ្នាតតូច និងមធ្យមប្រកបដោយប្រសិទ្ធភាព និងចីរភាព ដើម្បីគាំទ្រសហគ្រាសធុនតូច និងមធ្យមក្នុងស្រុក និងដើម្បីបង្កើនការកាត់បន្ថយហានិភ័យផ្នែកសេដ្ឋកិច្ច និងជំរុញសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ក្នុងពេលមានបញ្ហាប្រឈមនេះ។

ដើម្បីទ្រទ្រង់ដល់អតិថិជនអាជីវកម្មរបស់ពួកយើង អំឡុងពេលរាត្បាតនៃជំងឺកូវីដ១៩នេះ ធនាគារ មេយប៉ែង បានដាក់ចេញនូវវិធានការណ៍មួយចំនួន ដើម្បីធ្វើការយ៉ាងជិតស្និទ្ធជាមួយអតិថិជនរបស់ពួកយើង ក្នុងការផ្តល់ការប្រឹក្សាយោបល់ផ្នែកហិរញ្ញវត្ថុ រួមទាំងជំនួយហិរញ្ញវត្ថុក្នុងការរៀបចំឥណទានឡើងវិញ និងការកំណត់ពេលវេលាសងឥណទានឡើងវិញ ដល់អតិថិជន ដែលរងផលប៉ះពាល់ដោយការរាតត្បាតនេះ។

របាយការណ៍ស្តីអំពីចីរភាព

ការផ្តល់ភាពអង់អាចដល់និយោជិត

ផែនការចីរភាព ២០/២០

ការប្តេជ្ញាចិត្ត៖
- វេទិកាចូលរួមរបស់និយោជិត
- ទេពកោសល្យ និងភាពជាអ្នកដឹកនាំ
- ការរៀនសូត្រ និងការអភិវឌ្ឍ
- កន្លែងធ្វើការ ដែលមានភាពចម្រុះ
- សុវត្ថិភាព សុខភាព និងសុខុមាលភាព

វឌ្ឍនភាព៖

ក្រោមផែនការចីរភាព ២០/២០ ធនាគារ មេយប៊ែង បានបន្តបង្ហាញនូវការអនុវត្តល្អៗ ឈានមុខគេ ក្នុងវិស័យឧស្សាហកម្ម លើការកសាងកន្លែងធ្វើការប្រកបដោយសុវត្ថិភាព ភាពចម្រុះ និងការលើកទឹកចិត្ត។ កិច្ចខិតខំប្រឹងប្រែងរបស់ពួកយើង ត្រូវបានជំរុញជាពិសេសតាមរយៈប្រព័ន្ធឌីជីថល - ការប្រកាន់យកនូវវិធីសាស្ត្រប្រកបដោយភាពច្នៃប្រឌិត ដើម្បីបង្កើនបទពិសោធន៍របស់និយោជិត និងប្រើប្រាស់វេទិកាឌីជីថល ដើម្បីអភិវឌ្ឍ និងបង្កើនសមត្ថភាពរបស់និយោជិតឲ្យរីកចម្រើននៅក្នុងយុគសម័យឌីជីថល។

SDGs

សុខុមាលភាពនៃនិយោជិតរបស់ពួកយើង គឺជាស្នូលនៃយុទ្ធសាស្ត្រចីរភាពរបស់យើង ហើយវាមិនត្រឹមតែជាកត្តាជំរុញនៃវឌ្ឍនភាពប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាសមាសធាតុសំខាន់នៃអាជីវកម្មប្រកបដោយចីរភាពក៏ដូចជាសង្គមផងដែរ។ យ៉ាងណាមិញនិយោជិតជាង៤២,០០០នាក់របស់ពួកយើងទូទាំងសម្ព័ន្ធធនាគារ មានសមត្ថភាព និងភាពប៉ិនប្រសប់នានា ដែលអាចបង្កើតនូវតម្លៃពលយ៉ាងទូលំទូលាយនៅក្នុងសង្គមដែលពួកយើងកំពុងធ្វើប្រតិបត្តិការ។ ក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺរាតត្បាត១៩ ពួកយើង ក៏បានបន្តយកចិត្តទុកដាក់លើការអនុវត្តល្អ និងពង្រឹងប្រព័ន្ធអេកូឡូស៊ី នៅកន្លែងធ្វើការ និងក្នុងសហគមន៍ឲ្យមានការរីកចម្រើន។ នៅឆ្នាំ២០២០ ពួកយើង បានរៀបចំឲ្យនិយោជិតរបស់ពួកយើងនូវកន្លែងធ្វើការបែបគន្លងថ្មី ដើម្បីឲ្យពួកគាត់អាចឆ្លងកាត់ឧបសគ្គ និងសម្រេចបានគោលដៅការងារ និងគោលដៅផ្ទាល់ខ្លួន។ ចាប់ពីការអនុវត្តនីតិវិធី និងសេចក្តីណែនាំស្តង់ដារប្រតិបត្តិការរបស់ធនាគារ រហូតដល់ការថែរក្សា ការសិក្សា ការអភិវឌ្ឍ ការចូលរួម និងគំនិតល្អៗ ដែលពួកយើងធ្វើគឺ ដើម្បីបង្កើតឱកាសដ៏មានតម្លៃសម្រាប់និយោជិតរបស់ពួកយើងទន្ទឹមនឹងនោះធានានូវការបន្តអាជីវកម្មដើម្បីទ្រទ្រង់ដំណើរការរឹងមាំរបស់ធនាគារ។

សម្រាប់ព័ត៌មានបន្ថែមអំពី ការបន្តគាំទ្រនិយោជិតរបស់ពួកយើងក្នុងឆ្នាំ ២០២០ សូមអានទំព័រទី៣២។

ការផ្តល់ភាពអង់អាចដល់និយោជិត

ផែនការចីរភាព ២០/២០

ការប្តេជ្ញាចិត្ត៖
- ការប្តេជ្ញាចិត្តចំពោះបរិស្ថាន
- ភាពលេចធ្លោលើទំនួលខុសត្រូវលើផលិតផល

វឌ្ឍនភាព៖

ក្នុងនាមជាសម្ព័ន្ធធនាគារ មេយប៊ែង ពួកយើង បានបន្តត្រួតពិនិត្យប្រតិបត្តិការ ដែលពាក់ព័ន្ធនឹងបរិស្ថានរបស់ខ្លួន ដើម្បីពង្រឹងភាពជាក់លាក់នៃទិន្នន័យ ស្តីអំពីបរិស្ថានរបស់ខ្លួនសម្រាប់ការបង្កើតគោលដៅ និងគោលបំណង។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ពួកយើង បានជួយសម្រួលដល់ការបង្កើតប្រព័ន្ធហិរញ្ញវត្ថុបៃតង តាមរយៈការជួយគាំទ្រទៅដល់ការចេញមូលប័ត្របៃតង និងការរួមចំណែកហិរញ្ញវត្ថុបៃតងដំបូងបង្អស់របស់យពួកយើង។ ធនាគារ មេយប៊ែង ក៏បានបន្តផ្តល់ហិរញ្ញប្បទានដល់គម្រោងស្តីអំពីថាមពលកកើតឡើងវិញ និងគម្រោងហេដ្ឋារចនាសម្ព័ន្ធបៃតងផ្សេងទៀត។.

SDGs

ជាមួយនឹងប្រតិបត្តិការ ដែលលាតសន្ធឹងលើប្រទេសអាស៊ានទាំង ១០ និងមជ្ឈមណ្ឌលហិរញ្ញវត្ថុធំ ៗ នៅជុំវិញពិភពលោកយើងដឹងអំពីផលប៉ះពាល់ ដែលការអនុវត្តអាជីវកម្មរបស់យើងជះឥទ្ធិពលដល់បរិស្ថានពិភពលោក។ ចាប់តាំងពីឆ្នាំ ២០១៤ យើងបានតាមដានធនធានដែលបានប្រើប្រាស់ និងឧស្ម័នផ្ទះកញ្ចក់ ដែលបញ្ចេញដោយប្រតិបត្តិការរបស់ពួកយើង ដើម្បីយល់ដឹងឲ្យកាន់តែច្បាស់ និងព្យាយាមកាត់បន្ថយផលប៉ះពាល់ពីសកម្មភាពប្រតិបត្តិការរបស់ពួកយើង។ ពួកយើងបន្តផ្តោតលើការពង្រឹងសមត្ថភាពរបស់យើងក្នុងការតាមដាន និងគ្រប់គ្រងស្នាមប៉ះពាល់បរិស្ថានដោយប្រើសូចនាករ និងវិធីសាស្ត្រផ្សេងៗគ្នា។

ធនាគារ ក៏បានប្តេជ្ញាចិត្តគាំទ្រការអនុវត្តអាជីវកម្មប្រកបដោយចីរភាពបរិស្ថាន និងជំរុញសេដ្ឋកិច្ចបៃតង តាមរយៈសេវាកម្មហិរញ្ញវត្ថុ។ បន្ថែមពីវិធានការដែលពួកយើង ដោះស្រាយហានិភ័យស្តីអំពីគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច តាមរយៈការផ្តល់ហិរញ្ញប្បទានរបស់ពួកយើងទៅនោះ ធនាគារ មេយប៊ែង ក៏បានបន្តផ្តល់ហិរញ្ញប្បទានដល់គម្រោងថាមពលឡើងវិញ និងគាំទ្រដល់ការចេញមូលប័ត្រវិនិយោគបៃតង។ នៅឆ្នាំ ២០២០ ធនាគារ មេយប៊ែង ប្រទេសម៉ាឡេស៊ី បានបើកដំណើរការមូលនិធិសមធម៌ប្រកបដោយចីរភាពដំបូងរបស់ខ្លួន គឺមូលនិធិសកលចីរភាព ដែលនឹងបញ្ចូលកត្តាបរិស្ថាន សង្គម និងអភិបាលកិច្ចទៅក្នុងដំណើរការសម្រេចចិត្តវិនិយោគរបស់ពួកយើង។

ការលើកកម្ពស់សហគមន៍របស់ពួកយើង

ផែនការចីរភាព ២០/២០

ការប្តេជ្ញាចិត្ត៖

ការវិនិយោគដែលមានឥទ្ធិពលដល់សង្គម

វឌ្ឍនភាព៖

ក្រោមផែនការចីរភាព ២០/២០ ធនាគារ មេយប៊ែង បានពង្រឹងឥទ្ធិពលលើសហគមន៍របស់ខ្លួន ដើម្បីក្លាយជាអ្នកដឹកនាំថ្នាក់តំបន់ នៅក្នុងកម្មវិធីលើកកម្ពស់សហគមន៍ ដែលត្រូវបានរៀបចំយ៉ាងល្អ និងមានអត្ថន័យ។ តាមរយៈកម្មវិធីគំរូរបស់ធនាគារ ក៏ដូចជាការចូលរួមរបស់និយោជិត ធនាគារ មេយប៊ែង ក្នុងការផ្តួចផ្តើមស្ម័គ្រចិត្ត បានជះឥទ្ធិពលវិជ្ជមានដល់សហគមន៍ជាច្រើននៅទូទាំងអាស៊ាន។

SDGs

1 NO POVERTY, 4 QUALITY EDUCATION, 8 DECENT WORK AND ECONOMIC GROWTH, 10 REDUCED INEQUALITIES, 15 LIFE ON LAND, 17 PARTNERSHIPS FOR THE GOALS

អស់រយៈពេល៦០ឆ្នាំមកហើយ ដែលធនាគារ មេយប៊ែង បានក្លាយខ្លួនជាដៃគូ ដែលអាចទុកចិត្តបាននៅក្នុងសហគមន៍នានានៅទូទាំងអាស៊ាន។ នៅប្រទេសកម្ពុជា ធនាគារ មេយប៊ែង ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៣ ហើយបានរីកចម្រើនពីសាខាតែមួយទៅជាធនាគារកំពូលទាំង១០ នៅប្រទេសកម្ពុជា ដោយផ្អែកលើទ្រព្យសកម្ម។ ជាមួយគ្នានឹងភាពស្មោះត្រង់ និងការគាំទ្ររបស់សហគមន៍ទាំងនេះ ដែលបានជំរុញឲ្យអាជីវកម្មរបស់ពួកយើង ទទួលជោគជ័យ ហើយពួកយើងព្យាយាមជំរុញការរីកចម្រើន និងអភិវឌ្ឍន៍របស់ពួកគេ តាមរយៈការផ្តួចផ្តើម និងការវិនិយោគ ដែលបានកំណត់ដោយមូលនិធិធនាគារ មេយប៊ែង ដែលបានសហការជាមួយបណ្តាប្រទេសនានា។ នៅឆ្នាំ ២០២០ ការយកចិត្តទុកដាក់ចំពោះសហគមន៍របស់ពួកយើង មានសារៈសំខាន់ខ្លាំងជាងពេលណាទាំងអស់ ហើយធនាគារ បានព្យាយាមធ្វើវា តាមរយៈកម្មវិធី ដែលមានស្រាប់របស់ពួកយើង ក៏ដូចជាការផ្តួចផ្តើម ដើម្បីសម្រេចគោលដៅដើម្បីដោះស្រាយផលប៉ះពាល់នៃការរាតត្បាតពីជំងឺកូវីដ១៩ ។

នៅឆ្នាំ២០២០ ក្នុងនាមជាសម្ព័ន្ធធនាគារ ពួកយើង បានវិនិយោគប្រហែលជា ១% នៃប្រាក់ចំណេញសុទ្ធទៅលើការងារ សហគមន៍របស់ពួកយើង ដែលជាកម្រិតមួយ ដែលយើងបានរក្សាតាំងពីឆ្នាំ២០១៣មកម្ល៉េះ។ មូលនិធិទាំងនេះ បានជួយគាំទ្រដល់គំនិតផ្តួចផ្តើម ដែលកំពុងបន្តរបស់ពួកយើងនៅទូទាំងអាស៊ានក្នុងវិស័យអប់រំ ការសង្គ្រោះគ្រោះមហន្តរាយ បរិស្ថាន សុខុមាលភាព សិល្បៈ និងវប្បធម៌។ បន្ថែមលើការកែសំរួលកម្មវិធីគោលជាច្រើនរបស់ពួកយើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការសហគមន៍ ដែលកើតឡើងពីការរីករាលដាលនៃជំងឺរាតត្បាតកូវីដ១៩ឆ្នាំនេះ ធនាគារ ក៏បានដាក់ចេញនូវគំនិតផ្តួចផ្តើមសហគមន៍មួយចំនួន ដើម្បីឆ្លើយតបដោយផ្ទាល់ទៅនឹងផលប៉ះពាល់នៃជំងឺកូវីដ១៩។

ការគាំទ្រដល់សហគមន៍ក្នុងអំឡុងពេលកូវីដ១៩

នៅប្រទេសកម្ពុជា ពួកយើងបានប្តេជ្ញាចិត្តយ៉ាងមុតមាំជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការដោះស្រាយវិបត្តិកូវីដ១៩ តាមរយៈការផ្តួចផ្តើមមួយចំនួនដូចជា ការចូលរួមវិភាគទានមូលនិធិតាមរយៈសមាគមធនាគារ នៅកម្ពុជា (អេប៊ីស៊ី) និងចូលរួមក្នុងគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៃអង្គាសប្រាក់សម្រាប់ការទិញវ៉ាក់សាំងការពារការឆ្លងជំងឺកូវីដ១៩។ ពួកយើង ក៏បានចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការជួយដល់ជនរងគ្រោះដោយសារទឹកជំនន់នៅរដូវវស្សា ដែលបង្កការលំបាកជាយូរមកហើយ ស្របពេលដែលសហគមន៍ កំពុងប្រឈមនឹងបញ្ហា ដែលបណ្តាលមកពីជំងឺរាតត្បាតកូវីដ១៩។

នៅកម្រិតសហគមន៍ ពួកយើង ក៏បានគាំទ្រគំនិតផ្តួចផ្តើមរបស់ស្ត្រីតម្បាញប្រមាណជា២៥០នាក់ នៃកម្មវិធីស្ត្រី និងតម្បាញ ដែលជាការសហការជាមួយអង្គការសូត្រព័ណ៌កម្ពុជា ដើម្បីត្បាញម៉ាសដែលត្បាញដោយដៃប្រមាណជា ១១១,០០០ ដែលធ្វើអំពីក្រណាត់កាតុង និងសូត្រ ដើម្បីរួមចំណែកក្នុងការកាត់បន្ថយសម្ពាធផ្នែកតម្រូវការនៃម៉ាស់សម្រាប់វិស័យសុខាភិបាល។ តាមរយៈគំនិតផ្តួចផ្តើមនេះ ស្ត្រីតម្បាញរបស់ពួកយើង អាចរកប្រាក់ចំណូលបានចន្លោះពី ២០០ដុល្លារ ទៅ ៣៥០ដុល្លារ ក្នុងមួយខែ ដើម្បីផ្គត់ផ្គង់គ្រួសាររបស់ពួកគេក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺនេះ។

រូបភាពជាក្រុម ដែលរួមមានឯកឧត្តម Dato' Lim Jock Hoi អគ្គលេខាធិការអាស៊ាន តំណាងបណ្តាប្រទេសសមាជិកអចិន្ត្រៃយ៍នៃអាស៊ាន ឯកអគ្គរដ្ឋទូតតំណាងដៃគូសន្ទនាអាស៊ាន លេខាធិការអាស៊ាន ក្នុងឱកាសពិធីប្រគល់ម៉ាស់ និងកម្រងស៊ុមម៉ាស នៅទីស្នាក់ការអាស៊ាន នៅទីក្រុងចាកាតា។

"អំណោយនៃក្តីស្រឡាញ់" ដែលជាម៉ាស់ដែលត្បាញដោយដៃរបស់ស្ត្រីតម្បាញ ត្រូវបានប្រគល់ជូនអគ្គលេខាធិការដ្ឋានអាស៊ាន ដោយបង្ហាញនូវសុច្ឆន្ទៈនិងសាមគ្គីភាពនៅតាមបណ្តាប្រទេសនានា។

ម៉ាស់សរុបចំនួន ១៥០ម៉ាស់ ត្រូវបានប្រគល់ជូន ឯកឧត្តម Dato' Lim Jock Hoi អគ្គលេខាធិការអាស៊ានសម្រាប់ចែកជូន តំណាងមន្ត្រីអចិន្ត្រៃយ៍ចំនួន១០នាក់ ឯកអគ្គរដ្ឋទូតតំណាងដៃគូសន្ទនាអាស៊ាន លេខាធិការអាស៊ាន និងបេសកជនម៉ាឡេស៊ី២នាក់ នៅទីក្រុងចាកាតា។ លើសពីនេះទៅទៀត កម្រងស៊ុមម៉ាស់សូត្រសរុបចំនួន១០ ដែលជានិមិត្តរូបនៃក្តីសង្ឃឹម និងការបន់ស្រន់របស់ស្ត្រីតម្បាញតំណាងប្រទេសសមាជិកអាស៊ានទាំង១០ ក៏ត្រូវបានប្រគល់ទៅឲ្យ Dato' Lim នៅក្នុងឱកាសពិសេសនេះផងដែរ។

រូបភាពជាក្រុមនៃការប្រគល់ជូនម៉ាស់ត្បាញដោយដៃ ជូនឯកឧត្តមបណ្ឌិតហង់ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ពួកយើង បានពង្រីកគំនិតផ្តួចផ្តើម "អំណោយនៃក្តីស្រឡាញ់" តាមរយៈការចូលរួមចំណែកផ្តល់ជាម៉ាស់ ជូនដល់ក្រសួងអប់រំ យុវជន និងកីឡា នៅក្នុងឱកាសនៃការបើកឡើងវិញនូវសាលារៀនជាសាធារណៈ និងគម្រប់ខួបលើកទី ៦០ របស់ធនាគារ មេយប៊ែង។

ម៉ាស់ការពារទាំងនេះ ត្រូវបានប្រគល់ជូន ឯកឧត្តមបណ្ឌិតហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។ គំនិតផ្តួចផ្តើមនេះ បានកត់សម្គាល់ពីការបន្តការប្តេជ្ញាចិត្តរបស់ធនាគារ មេយប៊ែង ក្នុងការគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡាក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីផ្តល់ការអប់រំដល់ក្មេងៗជំនាន់ក្រោយ ជាពិសេសខណៈពេល ដែលពួកគេត្រូវការការប្រុងប្រយ័ត្នជាចាំបាច់ ដើម្បីការពារសិស្សានុសិស្ស គ្រូបង្រៀន និយោជិតអប់រំ និងគ្រួសាររបស់ពួកគេ។ ការផ្តួចផ្តើមទាំងនេះ ក៏បានផ្តល់នូវឱកាសផ្នែកសេដ្ឋកិច្ចបន្ថែមដ៏ចម្បងសម្រាប់ស្ត្រីតម្បាញ ដែលស្របទៅនឹងបេសកកម្មជារួមរបស់រាជរដ្ឋាភិបាល តម្រង់ឆ្ពោះទៅរកការជំរុញកំណើនសេដ្ឋកិច្ច និងជួយសហគមន៍ឲ្យងើបឡើងវិញពីការរំខាន ដែលបណ្តាលមកពីការរាតត្បាតពីជំងឺកូវីដ១៩។

របាយការណ៍ស្តីអំពីចីរភាព

ការឆ្លុះបញ្ចាំងពីកម្មវិធីលើកកម្ពស់សហគមន៍ឆ្នាំ២០២០

នៅឆ្នាំ២០២០នេះ ការផ្តោតសំខាន់របស់ពួកយើង ដើម្បីធានាបាននូវការបន្តកម្មវិធីលើកកម្ពស់សហគមន៍ ត្រូវបានផ្លាស់ប្តូរ តាមដែលពួកយើងអាចធ្វើទៅបាន និងនៅពេលដែលអាចធ្វើទៅបាន ស្របពេលដែលពួកយើងប្រកាន់ភ្ជាប់នូវការការពារ និងបទបញ្ជាត្តិដែលពាក់ព័ន្ធនឹងជំងឺកូវីដ១៩ ដោយនៅតែរក្សាបានការសម្រេចនូវគោលដៅ ដែលបានកំណត់។ ឧទាហរណ៍ ការអនុវត្តកម្មវិធីបណ្តុះបណ្តាលចំណេះដឹងផ្នែកហិរញ្ញវត្ថុ Maybank Cashville Kidz ត្រូវបានពន្យាពេលដោយសារតែការបិទសាលារៀន ដោយសារការរាតត្បាតពីជំងឺកូវីដ១៩ ប៉ុន្តែពួកយើង បានបន្តអនុវត្តកម្មវិធីនេះ តាមរយៈការផ្តួចផ្តើមលើកកម្ពស់កម្រិតចំណេះដឹងផ្នែកហិរញ្ញវត្ថុក្នុងចំណោមប្រជាជនកម្ពុជាតាមរយៈវេទិការសិក្សានិម្មិត តាមអ៊ីនធឺណែត។ ការសិក្សាតាមប្រព័ន្ធអ៊ីនធឺណែត បានអនុញ្ញាតឲ្យយើងបន្តការអនុវត្តកម្មវិធីបណ្តុះបណ្តាលចំណេះដឹងផ្នែកហិរញ្ញវត្ថុ Maybank Cashvill Kidz តាមរយៈការចាក់ផ្សាយកម្រងវីដេអូគំនូជីវចលអប់រំនេះ នៅលើគេហទំព័រឌីជីថលរបស់ក្រសួង អប់រំ យុវជន និងកីឡា ដែលបានក្លាយជាបណ្តាញចែកចាយការសិក្សាដ៏សំខាន់មួយនៅទូទាំងប្រទេស។

ឆ្វេងទៅស្តាំ៖ លោកស្រីហ្គាសរីន ចាន់អាប់ឌុលឡា នាយិកា នាយកដ្ឋានកិច្ចការក្រុមហ៊ុន និងទំនាក់ទំនងសាជីវកម្ម និងនាយិកានាយកដ្ឋានធនធានមនុស្ស តណ្ឌចិន ដាតុ ម៉ូហាមាដ ហានីវស៊ូអាឌី នាយកប្រតិបត្តិ នៃធនាគារ មេយបែង ឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុង រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា លោកជំទាវ គីម សិទ្ធីនី រដ្ឋលេខាធិការ និងឯកឧត្តមបណ្ឌិត សាន វឌ្ឍនា អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា

កម្មវិធីបណ្តុះបណ្តាលចំណេះដឹងផ្នែកហិរញ្ញវត្ថុ

កម្មវិធីបណ្តុះបណ្តាលចំណេះដឹងផ្នែកហិរញ្ញវត្ថុ ផ្តោតសំខាន់លើសិស្សានុសិស្ស ដែលមានអាយុពី ៩ ដល់១២ឆ្នាំ ដែលផ្តោតលើការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន ដែលផ្តល់ឲ្យសិស្សានុសិស្សគិតគូរពីសេដ្ឋកិច្ចប្រាក់ចំណូល និងប្រាក់សន្សំ។

ទទួលបានការចូលមើលជាង **៥៥.000** (views)

ទទួលបានការគាំទ្រជាង **៣.៦00** (likes)

ចំនួនសរុបនៃការចូលទស្សនា និងចំនួនគាំទ្រទាំង១២វីដេអូ នៅលើទំព័រហ្វេសប៊ុករបស់ក្រសួងអប់រំ យុវជន និងកីឡា

កម្មវិធីលើកកម្ពស់យុវជនអាស៊ាន

ការផ្តល់មូលនិធិសម្រាប់គាំទ្រដល់ការផ្តួចផ្តើមនានារបស់ក្រុមយុវជន ដើម្បីអាចដំណើរការគម្រោងនៅក្នុងសហគមន៍ ដែលជះឥទ្ធិពលជាវិជ្ជមានដល់ភាពក្រីក្រ ក៏ដូចជាការចិញ្ចឹមជីវិតល្អប្រសើរនៅក្នុងសហគមន៍អាស៊ាន។

កម្មវិធីនេះ ត្រូវបានពន្យាទៅឆ្នាំ២០២១ ដោយសារតែជំងឺកូវីដ១៩

កម្មវិធីស្ត្រី និងតម្បាញ

ការផ្តល់ភាពអង់អាចដល់ស្ត្រីតម្បាញក្នុងសហគមន៍ និងជនក្រីក្រឲ្យទទួលបានការបណ្តុះបណ្តាល ការកសាងសមត្ថភាព និងឱកាសមីក្រូហិរញ្ញវត្ថុ ដើម្បីអាចបន្តការអនុវត្តសិល្បៈតម្បាញតាមបែបប្រពៃណី និងទទួលបានឯករាជ្យភាពផ្នែកហិរញ្ញវត្ថុ។ កម្មវិធីដាំដំណាំមន ផ្តល់ឲ្យកសិករនូវការដាំដំណាំមន ដើម្បីរក្សាការផ្គត់ផ្គង់ផលិតភាពនៃសូត្រ ដែលជាប្រភពចំណូលបន្ថែមសម្រាប់សហគមន៍។

ចំនួនស្ត្រីតម្បាញ **៨៨** នាក់ថ្មី ដែលត្រូវបានបណ្តុះបណ្តាល និង

ចំនួនកសិករ **១៧២** នាក់ថ្មីដែលទទួលបានការគាំទ្រ

ចំនួនសរុបនៃស្ត្រីតម្បាញ និងកសិកដែលទទួលបានការគាំទ្រនៅក្នុងឆ្នាំ២០២០

កម្មវិធីឧបត្ថម្ភដល់កុមារ របស់ធនាគារ មេយបែង

ការឧបត្ថម្ភ និងការចូលរួមគាំទ្រដល់សិស្សានុសិស្សក្រីក្រ ដែលធ្លាប់រស់នៅក្នុងតំបន់ចោលសំរាមនៅក្នុងទីក្រុង និងតំបន់អនាធិបតេយ្យ ដោយមានការសហការជាមួយអង្គការលើកស្ទួយប្រជាជន (ភីអាយអូ) ។

ឧបត្ថម្ភទៅដល់ **៥0** សិស្សានុសិស្សកម្រិតវិទ្យាល័យ

ការកសាងឡើងវិញនូវអគារស្នាក់នៅ និងថ្នាក់រៀន អង្គការ ភីអាយអូ

ការកសាងឡើងវិញនូវអគារស្នាក់នៅ នៃអង្គការលើកស្ទួយប្រជាជន (ភីអាយអូ) ដើម្បីអង្គការនេះ មានលទ្ធភាព ក្នុងការផ្តល់ឱកាសឲ្យកុមារកាន់តែច្រើន អាចគេចផុតពីភាពក្រីក្រ តាមរយៈការអប់រំត្រឹមត្រូវ និងពេញលេញ។

បញ្ចប់ការចាក់បេតុងអគារជាន់ទី **៣**

ការផ្តួចផ្តើមផ្សេងទៀត ដើម្បីដោះស្រាយវិបត្តិកូវីដ១៩

ការបរិច្ចាគថវិកាជូនដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីគាំទ្រដល់គំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលក្នុងការដោះស្រាយវិបត្តិកូវីដ១៩ និងការចូលរួមក្នុងគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការរៃអង្គាសប្រាក់សម្រាប់ការទិញវ៉ាក់សាំងការពារជំងឺកូវីដ១៩ ។

បាយការណ៍ស្តីអំពីចីរភាព

ទិសដៅចីរភាព

រាល់ការបញ្ចប់ និងការចាប់ផ្តើម សុទ្ធតែមានដំណើរការរនៃការរៀនសូត្រយ៉ាងស៊ីជម្រៅ។ ឆ្នាំ២០២០ គឺជាឆ្នាំបញ្ចប់នៃផែនការចីរភាព២០/២០ ដែលជាត្រីវិស័យយុទ្ធសាស្ត្រចីរភាពរបស់ធនាគារសម្រាប់រយៈពេល ៥ឆ្នាំកន្លងមក។ ក្រោមផែនការចីរភាព២០/២០ ធនាគារ មេយបើង ទទួលបានសមិទ្ធិផលសំខាន់ៗ ក្នុងការកាត់បន្ថយផលប៉ះពាល់សហគមន៍ បង្កើនការផ្តល់សេវាឌីជីថល គាំទ្រដល់ការអភិវឌ្ឍនិយោជិតរបស់យើង និងការសម្រេចបានជាច្រើនផ្សេងទៀត។ នៅពេលដែលពួកយើង បន្តកសាងអនាគតប្រកបដោយចីរភាពសម្រាប់មនុស្សជំនាន់ក្រោយ វាជាការសំខាន់ ដែលពួកយើងផ្លាស់ប្តូរដោយមានគោលបំណងលើកកម្ពស់ទំនុកចិត្តរបស់ភាគីពាក់ព័ន្ធនៅក្នុងសម្ព័ន្ធធនាគារ មេយបើង ដែលជាអ្នកផ្តល់សេវាកម្មហិរញ្ញវត្ថុ ដែលអាចជឿទុកចិត្តបាន។ នេះ គឺជាកត្តាសំខាន់មួយ ស្របពេលដែលពិភពលោក បន្តឆ្លើយតប និងងើបឡើងវិញបន្ទាប់ពីផលប៉ះពាល់នៃជំងឺកូវីដ១៩ ដោយធនាគារ មេយបើង កំពុងព្យាយាមពង្រឹងភាពធន់ ក្រោយពីជំងឺរាតត្បាត នៅទូទាំងពិភពលោកនេះ។

ការកំណត់អាទិភាព

ពួកយើង កំពុងធ្វើការបង្កើតយុទ្ធសាស្ត្រមួយ ដែលនឹងតំរង់ទិសដៅបន្ទាប់នៃការធ្វើដំណើរ ប្រកបដោយចីរភាពរបស់ពួកយើងជាមួយនឹងផែនទីបង្ហាញផ្លូវគោលដៅ និងសូចនាការការងារសំខាន់ៗ។ ក្នុងការទទួលស្គាល់ការពិត ដែលថាភាពជោគជ័យផ្នែកហិរញ្ញវត្ថុរបស់ធនាគារ និងសម្ព័ន្ធធនាគារពឹងផ្អែកលើយុទ្ធសាស្ត្រដែលបង្កើតលទ្ធផលវិជ្ជមាន មិនត្រឹមតែសម្រាប់អាជីវកម្មរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់សង្គម និងបរិស្ថាន។ គ្រឹះសំខាន់នៃដំណើរការអភិវឌ្ឍយុទ្ធសាស្ត្ររបស់ពួកយើង គឺការចូលរួមរបស់ភាគីពាក់ព័ន្ធ។ នៅឆ្នាំនេះ ពួកយើង បានចូលរួមជាមួយភាគីពាក់ព័ន្ធសំខាន់ៗទាំងក្នុង និងក្រៅសម្ព័ន្ធធនាគារ ក្នុងការសន្ទនាលម្អិត និងស៊ីជម្រៅ ដែលផ្តោតលើបញ្ហាសំខាន់ៗជាច្រើន ដែលផ្តោតលើទាំងយុទ្ធសាស្ត្រ និងដំណើរការបច្ចុប្បន្នក៏ដូចជាហានិភ័យ និងឱកាស។ លទ្ធផលនៃការវាយតម្លៃ បានបង្ហាញឲ្យមានការសង្កត់ធ្ងន់ជាថ្មី លើវិធីដែលពួកយើងអាចជំរុញការផ្លាស់ប្តូរដ៏ត្រឹមត្រូវមួយសម្រាប់ភាគីពាក់ព័ន្ធរបស់ពួកយើង ដោយបន្តផ្តល់ជូននូវផលិតផល និងសេវាកម្មប្រកបដោយចីរភាព ដោយតែងតែយកសហគមន៍របស់ពួកយើង ជាចំនុចសំខាន់មុននឹងធ្វើការសម្រេចចិត្តនានា។

ឆ្ពោះទៅមុខជាមួយ M25

នៅពេលដែលធនាគារ មេយបើង ធ្វើដំណើរឆ្ពោះទៅមុខ ដោយមានការចង្អុលបង្ហាញពីផែនការ M25 ដែលជាយុទ្ធសាស្ត្ររបស់ធនាគារ មេយបើង ឆ្នាំ២០២៥។ ការគិតគូអំពីចីរភាព នឹងដើរតួនាទីយ៉ាងសំខាន់នៅក្នុងផែនការរបស់យើងនាពេលអនាគត។ ដោយកំណត់ចីរភាពជាអាទិភាពមួយក្នុងចំណោមអាទិភាពទាំងបីរបស់សម្ព័ន្ធធនាគារ ក្របខណ្ឌ M25 របស់សម្ព័ន្ធធនាគារ នឹងបម្រើដល់ការគិតពិចារណាអំពីហានិភ័យបរិស្ថាន សង្គម និងអភិបាលកិច្ច ដែលជាមូលដ្ឋានគ្រឹះសម្រាប់អនាគតរបស់ធនាគារ មេយបើង។

វិធីសាស្ត្ររបស់ពួកយើង ចំពោះការសម្រេចបាននូវគោលដៅចីរភាពនៃការអនុវត្តផែនការ M25 នឹងត្រូវបានចង្អុលបង្ហាញដោយសសរស្តម្ភទាំងបី ដែលនឹងធ្វើឲ្យកិច្ចខិតខំប្រឹងប្រែងរបស់ពួកយើងកាន់តែស៊ីជម្រៅ ចំពោះសេវាកម្មហិរញ្ញវត្ថុប្រកបដោយអារិយ្យភាព។ ផ្នែកដំបូងនៃចំនុចសំខាន់ គឺ "ការផ្លាស់ប្តូរប្រកបដោយការទទួលខុសត្រូវ" ចំពោះសេដ្ឋកិច្ចប្រកបដោយចីរភាព តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុផ្តោតលើចីរភាព និងការគ្រប់គ្រងនូវហានិភ័យបរិស្ថាន សង្គម និងអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព។ ផ្នែកទី ២ គឺ "ការលើកកម្ពស់សហគមន៍របស់យើងឲ្យមានចក្ខុវិស័យសម្រាប់អនាគត" ផ្តោតលើការបើកឱកាសថ្មីសម្រាប់សង្គម ឲ្យទទួលបានភាពស្មើភាព ការដាក់បញ្ចូល និងការគិតគូអំពីបម្រែបម្រួលអាកាសធាតុ តាមរយៈបរិយាបន្នហិរញ្ញវត្ថុ ការផ្តល់ភាពអង់អាចដល់សហគមន៍ និងប្រតិបត្តិការដែលមានការដាក់បញ្ចូល។ ជាចុងក្រោយ ពួកយើងនឹងផ្តោតលើការលើកស្ទួយការអនុវត្តល្អ នៅក្នុងអាជីវកម្មរបស់ពួកយើងក្រោមសសរស្តម្ភ "ការពង្រឹងផ្ទៃក្នុង និងការអនុវត្តនូវការប្តេជ្ញាចិត្ត" ដែលបង្ហាញឲ្យឃើញថា ធនាគារ មេយបើង ផ្តោតលើការពង្រឹងអភិបាលកិច្ច យុទ្ធសាស្ត្រ និយោជិត និងការគ្រប់គ្រងផលប៉ះពាល់ដល់បរិស្ថាន និងសង្គម ខ្សែសង្វាក់នៃគុណតម្លៃរបស់ពួកយើង។ តាមរយៈសសរស្តម្ភទាំងបី យុទ្ធសាស្ត្ររបស់យើង នឹងត្រូវបានបង្ហាញឲ្យឃើញនៅក្នុងគោលដៅរយៈពេលវែងប្រកបដោយមហិច្ឆតា ដែលនឹងពង្រឹងការប្តេជ្ញាចិត្តរបស់ធនាគារ មេយបើង ក្នុងការផ្តល់ដំណោះស្រាយប្រកបដោយចីរភាពសម្រាប់សហគមន៍ ដែលយើងធ្វើប្រតិបត្តិការ។

រយៈពេញមួយឆ្នាំ ២០២១ ពួកយើង នឹងបន្តវាស់ស្ទង់ឥទ្ធិពល ដែលនឹងក្លាយជាការផ្តោតអារម្មណ៍របស់ពួកយើង ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ដោយកំណត់គោលដៅសមស្របបង្កើតប្រព័ន្ធត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព និងបង្កើតយុទ្ធសាស្ត្រ សម្រាប់ការរាយការណ៍ប្រកបដោយតម្លាភាពលើវឌ្ឍនភាពរបស់ពួកយើង។ នៅដំណាក់កាលចុងក្រោយនៃដំណើរប្រកបដោយចីរភាពរបស់យើង គឺនឹងបន្តដឹកនាំដោយបេសកម្មរបស់ពួកយើង សេវាកម្មហិរញ្ញវត្ថុប្រកបដោយអារិយ្យភាព នៅពេលពួកយើងបង្កើននូវភាពស៊ីជម្រៅនូវការចូលរួម និងការវិនិយោគរបស់យើង ដើម្បីកសាងអនាគតប្រកបដោយចីរភាព។

ការធ្វើឲ្យស៊ីជម្រៅផ្នែកសេវាកម្មហិរញ្ញវត្ថុប្រកបដោយអារិយ្យភាពក្នុងសហគមន៍ដែលយើងធ្វើប្រតិបត្តិការ

តាមរយៈការផ្តោតទៅលើការអនុវត្ត និងដោយការអនុវត្តឲ្យស្របតាមគុណតម្លៃរបស់យើងនោះ ពួកយើង នឹងបន្តកសាងអនាគតប្រកបដោយចីរភាពសម្រាប់មនុស្សជំនាន់ក្រោយ។

ការផ្លាស់ប្តូរ ប្រកបដោយទំនួលខុសត្រូវ

- គាំទ្រការផ្លាស់ប្តូរនៃសេដ្ឋកិច្ចដោយរក្សាកម្រិតកាបូនទាប
- អភិវឌ្ឍផលិតផល និងសេវាកម្មផ្តោតលើចីរភាព
- ការគ្រប់គ្រងហានិភ័យជាប្រព័ន្ធ
- ការដាក់បញ្ចូល គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ទៅក្នុងការវិភាគហិរញ្ញវត្ថុ
- ការចូលរួមជាមួយប្រជាជនរបស់យើងក្នុងការគិតគូអំពីចីរភាព
- ក្រមសីលធម៌អាជីវកម្ម

ធ្វើឲ្យសហគមន៍របស់ពួកយើងមានចក្ខុវិស័យសម្រាប់អនាគត

- ផ្តល់ភាពអង់អាចដល់សហគមន៍
- បរិយាបន្នហិរញ្ញវត្ថុ
- ភាពគិតគូអំពីបម្រែបម្រួលអាកាសធាតុ
- តម្លាភាព និងទំនុកចិត្ត
- ភាពចម្រុះ សមធម៌ និងការដាក់បញ្ចូល

ការពង្រឹងផ្ទៃក្នុង និងការអនុវត្តនូវការប្តេជ្ញាចិត្ត

- អភិបាលកិច្ច និងការប្រតិបត្តិតាម
- ឯកជនភាព
- ខ្សែសង្វាក់ផ្គត់ផ្គង់របស់យើង
- ផលប៉ះពាល់ដល់បរិស្ថានរបស់យើង

របាយការណ៍របស់
ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ ធនាគារមេយបែង (ខេមបូឌា) ភីអិលស៊ី ("ធនាគារ") បង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់។

ព័ត៌មានអំពីធនាគារ

ធនាគារមេយបែង ត្រូវបានបង្កើតចាប់តាំងពីឆ្នាំ1993 និងធ្វើប្រតិបត្តិការជាដំបូងនៅសាខាភ្នំពេញ ("សាខា") នៃធនាគារ Malayan Banking Berhad ("MBB") ដែលបានចុះបញ្ជីអាជីវកម្មនៅប្រទេសម៉ាឡេស៊ី។

នៅថ្ងៃទី2 ខែមេសា ឆ្នាំ2012 សាខាត្រូវបានចុះបញ្ជីអាជីវកម្មជាក្រុមហ៊ុនមហាជន ទទួលខុសត្រូវមានកម្រិត ដោយមានឈ្មោះថា ធនាគារមេយបែង (ខេមបូឌា) ភីអិលស៊ី និងជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ MBB។ ធនាគារត្រូវបានចុះបញ្ជីអាជីវកម្ម ដោយអនុលោមតាមច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានផ្តល់អាជ្ញាប័ណ្ណក្រោមបទប្បញ្ញត្តិរបស់ ធនាគារជាតិនៃកម្ពុជា។

ធនាគារ ផ្តល់សេវាកម្មធនាគារទូលំទូលាយនិងសេវាហិរញ្ញវត្ថុ ដែលពាក់ព័ន្ធជាច្រើនទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមទៅតាមអាជ្ញាប័ណ្ណលេខ 02 ចេញដោយធនាគារជាតិនៃកម្ពុជា ដោយមិនមានកាលកំណត់។

ទីស្នាក់ការចុះបញ្ជីរបស់ធនាគារមានទីតាំងនៅអគារលេខ 43 មហាវិថី ព្រះនរោត្តម សង្កាត់ផ្សារថ្មី3 ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារនាការិយបរិច្ឆេទបញ្ចប់នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 ត្រូវបានលាតត្រដាងដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

ភាគលាភ

ក្រុមប្រឹក្សាភិបាលបានប្រកាស និងទូទាត់ភាគលាភមានចំនួន 16 លាន់ ដុល្លារអាមេរិក ពីប្រាក់ចំណេញសុទ្ធក្រោយពេលបង់ពន្ធសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 ដោយយោងតាមការអនុញ្ញាតរបស់ធនាគារជាតិនៃកម្ពុជា នាថ្ងៃទី20 ខែមករា ឆ្នាំ2019។

ដើមទុន

នៅក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានការប្រែប្រួលទៅលើដើមទុនរបស់ធនាគារទេ។

ទុនបម្រុង និងសវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ លើកលែងតែបម្រែបម្រួលដែលត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ការខាត់បង់ដែលពឹងទុកលើឥណទាន និងបុរេប្រទាន

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលធនាគារបានចាត់វិធានការសមស្របនានា ដើម្បីឈានដល់ការអះអាងថានីតិវិធីក្នុងការលុបចោលឥណទាន និងបុរេប្រទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានអាក្រក់ ត្រូវបានយកមកអនុវត្តហើយ និងជឿជាក់ថា រាល់ឥណទាន និងបុរេប្រទានអាក្រក់ ត្រូវបានលុបចោល ហើយសំវិធានធនគ្រប់គ្រាន់ត្រូវបានកំណត់ឡើង សម្រាប់ឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យ។

នាការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលធនាគារពុំបានដឹងពីកាលៈទេសៈណាមួយ ដែលអាចនឹងបណ្តាលឲ្យ ចំនួននៃការលុបចេញ ឥណទានអាក្រក់ពីបញ្ជី ឬ ចំនួននៃការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យ ក្នុងរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រាមានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះឡើយ។

ទ្រព្យសកម្ម

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលធនាគារ បានចាត់វិធានការសមស្របនានា ដើម្បីឈានដល់ការអះអាងថាទ្រព្យសកម្មដែលទំនងជាមិនអាចលក់បានក្នុងតម្លៃដូចដែលកត់ត្រាក្នុងបញ្ជីគណនេយ្យរបស់ធនាគារនោះ ត្រូវបានកត់ត្រាឲ្យស្មើនឹងតម្លៃដែលនឹងអាចប្រមូលមកវិញបានជាក់ស្តែង។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលធនាគារពុំបានដឹងពីព្រឹត្តិការណ៍ណាមួយ ដែលអាចបណ្តាលឲ្យតម្លៃនៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានការយល់ច្រឡំ ឬ មិនសមស្របជាសារវន្តនោះទេ។

វិធីសាស្ត្រកំណត់តម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលធនាគារពុំបានដឹងពីកាលៈទេសៈណាមួយ ដែលបានកើតឡើង ហើយធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តន៍វិធីសាស្ត្រកំណត់តម្លៃទ្រព្យសកម្ម និងទ្រព្យអកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានការយល់ច្រលំ ឬ មិនសមស្របជាសារវន្តនោះទេ។

បំណុលយថាហេតុ និងបំណុលផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

- ពុំមានបន្ទុកលើទ្រព្យសកម្ម របស់ធនាគារដែលកើតមានសម្រាប់ការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយចាប់ពីកាលបរិច្ឆេទនៃការិយបរិច្ឆេទបញ្ចប់ និង
- ពុំមានបំណុល យថាហេតុទាក់ទងនឹងធនាគារដែលបានកើតឡើងចាប់ពីកាលបរិច្ឆេទនៃការិយបរិច្ឆេទ បញ្ចប់ ក្រៅពីបំណុលដែលមានទាក់ទងនឹងសកម្មភាពអាជីវកម្មប្រក្រតីរបស់ធនាគារ។

ផ្អែកតាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាលធនាគារ ពុំមានបំណុលយថាហេតុ ឬ បំណុលផ្សេងទៀត របស់ធនាគារ ដែលអាច ឬ ទំនងក្លាយជាកាតព្វកិច្ចក្នុងអំឡុងរយៈពេលដប់ពីរខែខាងមុខ បន្ទាប់ពី ការិយបរិច្ឆេទបញ្ចប់នេះ ដែលនឹងមាន ឬ អាចមានឥទ្ធិពលជាសារវន្តទៅលើលទ្ធភាពរបស់ធនាគារក្នុងការ បំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលបំណុលទាំងនោះដល់ការកំណត់សងនោះទេ។

បាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទ

មិនមានព្រឹត្តិការណ៍គួរឲ្យកត់សម្គាល់ណាមួយកើតឡើងបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ ដែលតម្រូវឲ្យមានការកែតម្រូវ ឬ បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទេ។

ក្រុមប្រឹក្សាភិបាល

សមាសភាពនៃក្រុមប្រឹក្សាភិបាល នៅក្នុងអំឡុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

លោក Anthony Brent Elam	ប្រធាន / អភិបាលឯករាជ្យ និងមិនប្រតិបត្តិ
លោក Spencer Lee Tien Chye	អភិបាលឯករាជ្យ និងមិនប្រតិបត្តិ
លោក Datuk Hamirullah Boorhan	អភិបាលមិនឯករាជ្យ និងមិនប្រតិបត្តិ
លោក Soon Su Long	អភិបាលមិនឯករាជ្យ និងមិនប្រតិបត្តិ
លោក Sharifffuddin Khalid	អភិបាលឯករាជ្យ និងមិនប្រតិបត្តិ

សវនករ

ក្រុមហ៊ុនសវនកម្មឯករាជ្យ Ernst & Young (Cambodia) Ltd. ជាសវនកររបស់ធនាគារ។

ភាគហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

ពុំមានសមាជិកនៃក្រុមប្រឹក្សាភិបាលណាម្នាក់ បានកាន់កាប់ភាគហ៊ុនរបស់ធនាគារទេ។

អត្ថប្រយោជន៍របស់អភិបាល

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 និងនាការិយបរិច្ឆេទបញ្ចប់នេះ ពុំមានកិច្ចព្រមព្រៀងណាមួយ ដែលក្នុងនោះធនាគារជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះ អាចបង្កលទ្ធភាពដល់សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ ដើម្បីទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេង។ ដូចជាការទិញភាគហ៊ុន ឬ ប័ណ្ណបំណុលរបស់ធនាគារ ឬ របស់សាជីវកម្មដទៃ។

ពុំមានអភិបាលណាម្នាក់របស់ធនាគារបានទទួល ឬ មានសិទ្ធិនឹងទទួលបាននូវអត្ថប្រយោជន៍ណាមួយតាមរយៈហេតុផលនៃកិច្ចសន្យា ដែលបានធ្វើឡើងដោយធនាគារ ឬជាមួយនឹងសហគ្រាសដែលអភិបាលនោះ ជាសមាជិកក្រុមប្រឹក្សាភិបាល ឬក៏ជាមួយក្រុមហ៊ុនណាមួយដែលអភិបាលនោះ មានភាគកម្មហិរញ្ញវត្ថុ ជាសារវន្ត លើកលែងតែអត្ថប្រយោជន៍ទាំងឡាយណា ដែលត្រូវបានលាតត្រដាងព័ត៌មានក្នុងរបាយការណ៍ ហិរញ្ញវត្ថុ។

បាយការណ៍ស្តីពីការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល ជាអ្នកទទួលខុសត្រូវដើម្បីធានាអះអាងថា របាយការណ៍ហិរញ្ញវត្ថុផ្តល់នូវទិដ្ឋភាពពិត និង ត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 និងលទ្ធផលហិរញ្ញវត្ថុ ហើយនិងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់។ ក្រុមប្រឹក្សាភិបាល ត្រូតពិនិត្យនូវការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ដែលត្រូវបានរៀបចំដោយគណៈគ្រប់គ្រងដែលតម្រូវឲ្យគណៈគ្រប់គ្រងចាំបាច់ត្រូវ៖

- អនុម័តនូវគោលនយោបាយគណនេយ្យ ដែលសមស្របដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មាន ដោយសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ហើយនិងត្រូវអនុវត្តគោលនយោបាយទាំងនោះដោយមានសង្គតភាព។
- អនុលោមទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហើយប្រសិនបើមានការប្រាសចាកពីការបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ត្រូវធានាឲ្យបានថាការប្រាសចាកនេះត្រូវបានដាក់បង្ហាញ និងពន្យល់ និងកំណត់ជាបរិមាណសាច់ប្រាក់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឲ្យបានសមស្រប។
- រក្សាទុកបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធនៃការត្រូតពិនិត្យផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយឈរលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែ ក្នុងករណីដែលធនាគារមិនអាចបន្តសកម្មភាពអាជីវកម្មនាពេលអនាគតដែលគិតទុកជាមុនបាន និង
- ការគ្រប់គ្រង និងដឹកនាំប្រកបដោយប្រសិទ្ធភាព រាល់ការសម្រេចជាសារវន្តដែលមានឥទ្ធិពលលើប្រតិបត្តិការអាជីវកម្ម និងលទ្ធផលនៃប្រតិបត្តិការ ហើយត្រូវប្រាកដថាកិច្ចការទាំងនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងសមស្របក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវ ដើម្បីធានាថាបញ្ជីគណនេយ្យសមស្របត្រូវបានរក្សាទុក ឲ្យបានត្រឹមត្រូវសមហេតុផលគ្រប់ពេល ដែលលាតត្រដាងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ ហើយនិងធានាថាបញ្ជីគណនេយ្យអនុលោមតាមប្រព័ន្ធគណនេយ្យដែលបានចុះបញ្ជី។ គណៈគ្រប់គ្រងក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសកម្មរបស់ធនាគារ ដែលហេតុដូចនេះហើយ ត្រូវចាត់វិធានការសមស្រប សម្រាប់ការទប់ស្កាត់និងស្វែងរកកំហុសចេតនា ហើយនិងភាពមិនប្រក្រតីផ្សេង។

ក្រុមប្រឹក្សាភិបាលបញ្ជាក់ថា ធនាគារបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នានា ដូចដែលបានបញ្ជាក់ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើង ក្រុមប្រឹក្សាភិបាលធនាគារ សូមអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមានភ្ជាប់ជាមួយនេះ ថាបានផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទង នឹងហិរញ្ញវត្ថុអន្តរជាតិកម្ពុជា។

តំណាងឲ្យក្រុមប្រឹក្សាភិបាល ៖

លោក Anthony Brent Elam

ប្រធាន / អភិបាលឯករាជ្យ និងមិនប្រតិបត្តិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី26 ខែមីនា ឆ្នាំ2021

របាយការណ៍របស់
សវនករឯករាជ្យ

ជូនចំពោះ៖ ភាគទុនិកនៃ ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី

មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមេយប៊ែង (ខេមបូឌា) ភីអិលស៊ី ("ធនាគារ") ដែលមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 និងរបាយការណ៍លទ្ធផលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និង របាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទបញ្ចប់ ហើយនិងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានសេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ ហើយនិងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs")។

មូលដ្ឋានក្នុងការផ្តល់មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្ម នៃកម្ពុជា ("CISAs")។ ការទទួលខុសត្រូវរបស់យើងខ្ញុំ យោងតាមស្តង់ដារទាំងនោះ ត្រូវបានបរិយាយបន្ថែមនៅក្នុងផ្នែកនៃ ការទទួលខុសត្រូវ របស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានភាពឯករាជ្យពីធនាគារ ដោយអនុលោមទៅតាមប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់គណនេយ្យករ និងសវនករជំនាញ ដែលចេញដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំក៏បានបំពេញនូវទំនួលខុសត្រូវខាងសីលធម៌ផ្សេងទៀតរបស់យើងខ្ញុំ ដោយស្របទៅតាមតម្រូវការនៃប្រកាសនេះ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្ម ដែលយើងខ្ញុំបានទទួល គឺគ្រប់គ្រាន់ និងសមស្រប ដើម្បីជាមូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។

ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ

ព័ត៌មានផ្សេងទៀតដែលទទួលបាន នាកាលបរិច្ឆេទរបាយការណ៍សវនករ គឺជារបាយការណ៍របស់ក្រុមប្រឹក្សាភិបាល។ គណៈគ្រប់គ្រងមានទំនួលខុសត្រូវ ចំពោះព័ត៌មានផ្សេងៗនេះ។

មតិយោបល់របស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុពុំគ្របដណ្តប់លើព័ត៌មានផ្សេងៗនេះទេ ហើយយើងខ្ញុំក៏មិនបង្ហាញក្នុងទម្រង់ណាមួយនៃសេចក្តីសន្និដ្ឋានបែបធានាអះអាងទៅលើព័ត៌មានផ្សេងៗនេះដែរ។ ទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ទំនួលខុសត្រូវរបស់យើងខ្ញុំ គឺការអានព័ត៌មានផ្សេងៗនេះ ហើយពិចារណាថា តើព័ត៌មានផ្សេងៗនេះ មានភាពខុសគ្នាជាសារវន្តឬទេ ជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬចំណេះដឹងរបស់យើងខ្ញុំដែលទទួលបាននៅក្នុងការធ្វើសវនកម្ម ឬថាតើព័ត៌មានផ្សេងៗនេះមាន កំហុសឆ្គងជាសារវន្តឬទេ ដោយផ្អែកលើការងារដែលបានអនុវត្តប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តលើ ព័ត៌មានផ្សេងៗនេះ យើងខ្ញុំតម្រូវឲ្យរាយការណ៍តាមភាពជាក់ស្តែង។ យើងខ្ញុំពុំមានហេតុការណ៍អ្វីដែលត្រូវរាយការណ៍ចំពោះព័ត៌មានផ្សេងៗនេះទេ។

ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ចចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រង ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និងការបង្ហាញទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវនៃ របាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាម CIFRSs ហើយនិងមានការទទួលខុសត្រូវចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងគិតថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលពុំមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវក្នុងការវាយតម្លៃលទ្ធភាពនិរន្តរភាពអាជីវកម្មរបស់ធនាគារ និងធ្វើការលាតត្រដាងនូវបញ្ហាទាំងឡាយណា ដែលទាក់ទង នឹងនិរន្តរភាពអាជីវកម្ម និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មនៅក្នុងប្រព័ន្ធគណនេយ្យរបស់ ធនាគារ លើកលែងតែក្នុងករណីគណៈគ្រប់គ្រងមានបំណងរំលាយ ឬបញ្ឈប់ដំណើរការប្រតិបត្តិការធនាគារ ឬ ក៏គ្មានមធ្យោបាយជាក់លាក់ណាមួយទៀតក្រៅពីនេះ។

អ្នកទទួលបន្ទុកលើអភិបាលកិច្ចមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យមើលលើដំណើរនៃ ការរាយការណ៍អំពីហិរញ្ញវត្ថុរបស់ធនាគារ។

ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ ហើយធ្វើការចេញផ្សាយ របាយការណ៍របស់សវនករដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ ការធានាអះអាង ដែលសមហេតុផល គឺជាការធានាអះអាងកម្រិតខ្ពស់មួយ ប៉ុន្តែមិនមែនជាការធានាថាការងារសវនកម្ម ដែលប្រព្រឹត្តទៅដោយអនុលោមតាម CISAs តែងតែរកឃើញកំហុសឆ្គងជាសារវន្ត ដែលមាននោះទេ ។ កំហុសឆ្គងអាចកើតចេញពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ និងត្រូវបានចាត់ទុកថាជាសារវន្ត ប្រសិនបើកំហុសឆ្គងទាំងអស់នោះ (តែមួយ ឬ បញ្ចូលគ្នាជារួម) អាចមានឥទ្ធិពលលើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយផ្អែកលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ជាផ្នែកមួយនៃការងារសវនកម្មដែលអនុលោមតាម CISAs យើងខ្ញុំបានធ្វើការវិនិច្ឆ័យ និងរក្សារនូវចម្ងល់ប្រកបដោយវិជ្ជាជីវៈក្នុងដំណើរការសវនកម្ម។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃហានិភ័យនៃកំហុសឆ្គងជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ បង្កើត និងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ ហើយប្រមូលភស្តុតាងសវនកម្មឲ្យបានគ្រប់គ្រាន់ និងសមស្របសម្រាប់ផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំមានកម្រិតខ្ពស់ជាងហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គង ដែលបណ្តាលមកពីការភាន់ច្រឡំ ព្រោះថាការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការបន្លំ ការលុបចេញដោយចេតនាការរាយការណ៍មិនត្រឹមត្រូវ ឬ មិនគោរពតាមប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលពាក់ព័ន្ធ នឹងការងារសវនកម្ម ដើម្បីបង្កើតជានីតិវិធីសវនកម្ម ដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារទេ។
- វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញ ដែលជាប់ទាក់ទងផ្សេងទៀត ដែលធ្វើឡើងដោយគណៈគ្រប់គ្រង។
- ធ្វើសេចក្តីសន្និដ្ឋានទៅលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្ម នៅក្នុងប្រព័ន្ធ គណនេយ្យដោយគណៈគ្រប់គ្រង និងតាមរយៈភស្តុតាងសវនកម្មដែលទទួលបាន យើងខ្ញុំធ្វើការសន្និដ្ឋាន ថាតើមានវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្តទាក់ទង នឹងព្រឹត្តិការណ៍ ឬកាលៈទេសៈទាំងឡាយណា ដែលនាំឲ្យមានការសង្ស័យជាសារវន្តទៅលើនិរន្តរភាពនៃដំណើរការអាជីវកម្មរបស់ធនាគារ។ ប្រសិនបើយើងសន្និដ្ឋានថាមានវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំតម្រូវឲ្យទាញចំណាប់អារម្មណ៍ ក្នុងរបាយការណ៍សវនករលើកំណត់សម្គាល់ពាក់ព័ន្ធដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើកំណត់សម្គាល់នេះពុំមានលក្ខណៈគ្រប់គ្រាន់ទេនោះ យើងខ្ញុំ នឹងធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺពឹងផ្អែកលើភស្តុតាងសវនកម្ម ដែលទទួលបានរហូតដល់ថ្ងៃចេញរបាយការណ៍សវនករ។ តែទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬកាលៈទេសៈនាពេលអនាគត ក៏អាចបង្ក៲ឲ្យធនាគារ មិនអាចបន្តនិរន្តរភាពរបស់អាជីវកម្មបានផងដែរ។
- វាយតម្លៃការដាក់បង្ហាញ ទម្រង់ និងមាតិកាទាំងស្រុងនៃរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងកំណត់សម្គាល់ផ្សេងៗ និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុ តំណាងឲ្យប្រតិបត្តិការណ៍ និងព្រឹត្តិការណ៍ដែលជាមូលដ្ឋានដើម្បីសម្រេចបាននូវការបង្ហាញដ៏ត្រឹមត្រូវ។

របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះ៖ ភាគទុនិកនៃ ធនាគារ មេយវ៉ៃង (ខេមបូឌា) ភីអិលស៊ី

ក្នុងចំណោមបញ្ហាដទៃទៀត យើងខ្ញុំបានធ្វើការទំនាក់ទំនងជាមួយអ្នកទទួលបន្ទុកលើអភិបាលកិច្ចអំពីវិសាលភាព និងពេលវេលា ដែលបានគ្រោងទុកនៃការងារសវនកម្ម និងរបកគំហើញសំខាន់ៗ រួមបញ្ចូលផងដែរនូវកង្វះខាតសំខាន់ៗ ទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំរកឃើញក្នុងពេលធ្វើសវនកម្ម។

Emmanuel A. Guelas

Partner

Ernst & Young (Cambodia) Ltd.

គណនេយ្យករសាធារណៈប្រតិស្រុត

សវនករប្រតិស្រុត

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី26 ខែមីនា ឆ្នាំ2021

បាយការណ៍
ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020

		2020		2019	
	កំណត់សម្គាល់	ដុល្លារអាមេរិក	សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2.1.4)	ដុល្លារអាមេរិក	សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2.1.4)
ទ្រព្យសកម្ម					
សាច់ប្រាក់ក្នុងដៃ		66,820,402	270,288,526	43,865,242	178,750,861
សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា	4	236,584,358	956,983,728	395,510,749	1,611,706,302
សមតុល្យជាមួយធនាគារផ្សេងៗ	5	224,268,689	907,166,847	231,242,408	942,312,813
សមតុល្យជាមួយក្រុមហ៊ុនមេ	6	125,694	508,432	10,378	42,290
សមតុល្យជាមួយក្រុមហ៊ុនសម្ព័ន្ធញាតិ	7	1,514,534	6,126,290	1,017,554	4,146,533
ឥណទាន និងបុរេប្រទាន	8	764,152,987	3,090,998,832	674,515,974	2,748,652,594
អចលកម្ម និងហត្ថូបករណ៍	9	4,480,736	18,124,577	3,671,526	14,961,468
កម្មវិធីកុំព្យូទ័រ	10	1,533,763	6,204,071	1,093,390	4,455,564
សិទ្ធិនៃការប្រើប្រាស់ទ្រព្យសកម្ម	11	18,903,708	76,465,499	19,219,240	78,318,403
ពន្ធពន្យាជាទ្រព្យសកម្មសុទ្ធ	14	1,844,479	7,460,918	2,135,731	8,703,104
ទ្រព្យសកម្មផ្សេងៗ	12	3,007,701	12,166,151	3,250,120	13,244,240
ទ្រព្យសកម្មសរុប		**1,323,237,051**	**5,352,493,871**	**1,375,532,312**	**5,605,294,172**
ទ្រព្យអកម្ម និងមូលនិធិភាគទុនិក					
ទ្រព្យអកម្ម					
ប្រាក់បញ្ញើរបស់អតិថិជន	13	1,009,986,960	4,085,397,253	1,079,464,510	4,398,817,878
ប្រាក់បញ្ញើរបស់ស្ថាប័នហិរញ្ញវត្ថុផ្សេងៗ	13	53,652,734	217,025,309	53,958,368	219,880,350
ប្រាក់កម្ចី		2,472,188	10,000,000	-	-
សមតុល្យជាមួយក្រុមហ៊ុនមេ	6	2,273,412	9,195,952	3,102,957	12,644,550
បំណុលបន្ទាប់បន្សំ	6	45,000,000	182,025,000	30,000,000	122,250,000
បំណុលពន្ធលើប្រាក់ចំណូល	14	4,576,501	18,511,947	6,179,875	25,182,991
បំណុលភតិសន្យា	15	21,090,297	85,310,251	20,373,978	83,023,960
ទ្រព្យអកម្មផ្សេងៗ	16	15,588,132	63,053,993	16,434,877	66,972,124
ទ្រព្យអកម្មសរុប		**1,154,640,224**	**4,670,519,705**	**1,209,514,565**	**4,928,771,853**
មូលនិធិភាគទុនិក					
ដើមទុន	18	75,000,000	300,000,000	75,000,000	300,000,000
ទុនបម្រុងទូទៅ		10,000,000	40,000,000	10,000,000	40,000,000
ទុនបម្រុងបទប្បញ្ញត្តិ	18	8,988,816	36,428,342	7,612,089	30,815,426
ប្រាក់ចំណេញរក្សាទុក		74,608,011	302,441,609	73,405,658	297,539,616
លម្ដៀងបង្គរពីការប្រែសម្រួលរូបិយប័ណ្ណ		-	3,104,215	-	8,167,277
មូលនិធិភាគទុនិកសរុប		**168,596,827**	**681,974,166**	**166,017,747**	**676,522,319**
ទ្រព្យអកម្ម និងមូលនិធិភាគទុនិកសរុប		**1,323,237,051**	**5,352,493,871**	**1,375,532,312**	**5,605,294,172**

ទិដ្ឋភាពទូទៅ ទំព័រទី ៤-១៩
យុទ្ធសាស្ត្រដើម្បីបង្កើតតុណតម្លៃ ទំព័រទី ២០-២៣
ធនធានហិរញ្ញវត្ថុ ទំព័រទី ២៤-២៩
ធនធានបញ្ញ ទំព័រទី ៣០-៣១
ធនធានមនុស្ស ទំព័រទី ៣២-៣៩
អភិបាលកិច្ចប្រកបដោយទំនួលខុសត្រូវ ទំព័រទី ៤០-៤២
ធនធានសង្គម និងទំនាក់ទំនង ទំព័រទី ៤៣-៤៩
រាយការណ៍ហិរញ្ញវត្ថុ ទំព័រទី ៦-១១៣
ព័ត៌មានផ្សេងៗ ទំព័រទី ១៦៤

របាយការណ៍
លទ្ធផលពេញលេញ

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020

	កំណត់សម្គាល់	2020		2019	
		ដុល្លារអាមេរិក	សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2.1.4)	ដុល្លារអាមេរិក	សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2.1.4)
ចំណូលពីការប្រាក់	19	60,004,697	244,639,150	58,104,845	235,440,832
ចំណាយលើការប្រាក់	20	(24,490,335)	(99,847,096)	(18,650,211)	(75,570,656)
ចំណូលពីការប្រាក់សុទ្ធ		35,514,362	144,792,054	39,454,634	159,870,176
ចំណូលលើថ្លៃសេវា និងកម្រៃជើងសារ	21	7,638,584	31,142,507	8,982,967	36,398,982
ចំណាយលើថ្លៃសេវា និងកម្រៃជើងសារ		(1,168,425)	(4,763,669)	(1,408,639)	(5,707,805)
ចំណូលថ្លៃសេវា និងកម្រៃជើងសារសុទ្ធ		6,470,159	26,378,838	7,574,328	30,691,177
ចំណូលផ្សេងៗ	22	3,408,231	13,895,358	4,414,519	17,887,631
ចំណូលប្រតិបត្តិការសុទ្ធសរុប		**45,392,752**	**185,066,250**	**51,443,481**	**208,448,984**
ចំណាយបរិញ្ញាវត្ថុ	23	(886,914)	(3,615,948)	(791,386)	(3,206,695)
ចំណាយទូទៅ និងរដ្ឋបាល	24	(18,562,928)	(75,681,058)	(20,896,754)	(84,673,647)
ការកត់ត្រាបញ្ច្រាស់នៃសំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុក	5, 8, 12, 27	(1,797,135)	(7,326,919)	4,145,575	16,797,870
ចំណេញមុនបង់ពន្ធ		**24,145,775**	**98,442,325**	**33,900,916**	**137,366,512**
ចំណាយពន្ធលើប្រាក់ចំណូល	14	(5,566,695)	(22,695,416)	(7,007,445)	(28,394,167)
ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ		**18,579,080**	**75,746,909**	**26,893,471**	**108,972,345**
លម្អៀងពីការប្រែសម្រួលរូបិយប័ណ្ណ		-	(5,063,062)	-	8,548,633
ចំណូលពេញលេញសរុបសម្រាប់ការិយបរិច្ឆេទ		**18,579,080**	**70,683,847**	**26,893,471**	**117,520,978**

កំណត់សម្គាល់ភ្ជាប់ពីលេខ 1 ដល់ 30 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុ។

របាយការណ៍
បម្រែបម្រួលមូលធន

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020

	ដើមទុន		ទុនបម្រុងទូទៅ		ទុនបម្រុងតាមបទប្បញ្ញត្តិ		ប្រាក់ចំណេញរក្សាទុក		លម្អៀងបង្គរពីការប្រែ សម្រួលរូបិយប័ណ្ណ	សរុប	
	ដុល្លារអាមេរិក	សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.1.4)	ដុល្លារអាមេរិក	សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.1.4)	ដុល្លារអាមេរិក	សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.1.4)	ដុល្លារអាមេរិក	សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.1.4)	សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.1.4)	ដុល្លារអាមេរិក	សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.1.4)
សមតុល្យនាថ្ងៃទី 1 ខែមករា ឆ្នាំ2020	**75,000,000**	**300,000,000**	**10,000,000**	**40,000,000**	**7,612,089**	**30,815,426**	**73,405,658**	**297,539,616**	**8,167,277**	**166,017,747**	**676,522,319**
ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ	-	-	-	-	-	-	18,579,080	75,746,909	-	18,579,080	75,746,909
ភាគលាភជាសាច់ប្រាក់ (កំណត់សម្គាល់លេខ 18)	-	-	-	-	-	-	(16,000,000)	(65,232,000)	-	(16,000,000)	(65,232,000)
ការផ្ទេរទៅទុនបម្រុងតាមបទបញ្ញត្តិ	-	-	-	-	1,376,727	5,612,916	(1,376,727)	(5,612,916)	-	-	-
លម្អៀងពីការប្រែសម្រួលរូបិយប័ណ្ណក្នុងការិយបរិច្ឆេទ	-	-	-	-	-	-	-	-	(5,063,062)	-	(5,063,062)
សមតុល្យនាថ្ងៃទី31 ខែមករាឆ្នាំ2020	**75,000,000**	**300,000,000**	**10,000,000**	**40,000,000**	**8,988,816**	**36,428,342**	**74,608,011**	**302,441,609**	**3,104,215**	**168,596,827**	**681,974,166**
សមតុល្យនាថ្ងៃទី 1 ខែមករាឆ្នាំ2019	**75,000,000**	**300,000,000**	**10,000,000**	**40,000,000**	**4,108,337**	**16,618,223**	**50,015,939**	**202,764,474**	**(381,356)**	**139,124,276**	**559,001,341**
ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ	-	-	-	-	-	-	26,893,471	108,972,345	-	26,893,471	108,972,345
ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ	-	-	-	-	3,503,752	14,197,203	(3,503,752)	(14,197,203)	-	-	-
លម្អៀងពីការប្រែសម្រួលរូបិយប័ណ្ណក្នុងការិយបរិច្ឆេទ	-	-	-	-	-	-	-	-	8,548,633	-	8,548,633
សមតុល្យនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2019	**75,000,000**	**300,000,000**	**10,000,000**	**40,000,000**	**7,612,089**	**30,815,426**	**73,405,658**	**297,539,616**	**8,167,277**	**166,017,747**	**676,522,319**

កំណត់សម្គាល់ភ្ជាប់ពីលេខ 1 ដល់ 30 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុ។

របាយការណ៍
លំហូរសាច់ប្រាក់

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020

	កំណត់សម្គាល់	2020		2019	
		ដុល្លារអាមេរិក	សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2.1.4)	ដុល្លារអាមេរិក	សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2.1.4)
សាច់ប្រាក់សុទ្ធ (ប្រើក្នុង) បានពីសកម្មភាពប្រតិបត្តិការ	25	**(84,742,760)**	**(345,496,232)**	**80,605,059**	**326,611,698**
សកម្មភាពវិនិយោគ					
ការទិញ ៖					
អចលកម្ម និងហត្ថូបករណ៍	9	(2,228,629)	(9,086,120)	(735,136)	(2,978,771)
កម្មវិធីកុំព្យូទ័រ	10	(896,885)	(3,656,600)	(700,380)	(2,837,940)
សាច់ប្រាក់បានពីការលក់អចលកម្មនិងហត្ថូបករណ៍	9	2,218	9,043	-	-
សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ		**(3,123,296)**	**(12,733,677)**	**(1,435,516)**	**(5,816,711)**
សកម្មភាពហិរញ្ញប្បទាន					
សាច់ប្រាក់បានពីបំណុលបន្ទាប់បន្សំ	6	45,000,000	183,465,000	-	-
សាច់ប្រាក់បានពីប្រាក់កម្ចី		2,472,188	10,079,110	-	-
ការទូទាត់បំណុលបន្ទាប់បន្សំ	6	(30,000,000)	(122,310,000)	-	-
ភាគលាភបានបង់	18	(16,000,000)	(65,232,000)	-	-
ការទូទាត់ចំណែកប្រាក់ដើមនៃបំណុលភតិសន្យា	15	(2,005,114)	(8,174,850)	(1,602,067)	(6,491,575)
សាច់ប្រាក់សុទ្ធបានប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន		**(532,926)**	**(2,172,740)**	**(1,602,067)**	**(6,491,575)**
(ការថយចុះ) កើនឡើងសុទ្ធ នៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល		**(88,398,982)**	**(360,402,649)**	**77,567,476**	**314,303,412**
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ		512,998,128	2,090,467,372	435,430,652	1,749,560,360
លម្អៀងពីការប្រែសម្រួលរូបិយប័ណ្ណ		-	(12,561,178)	-	26,603,600
សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ	4	**424,599,146**	**1,717,503,545**	**512,998,128**	**2,090,467,372**

ព័ត៌មានបន្ថែមអំពីលំហូរសាច់ប្រាក់ប្រតិបត្តិការពីការប្រាក់

ការប្រាក់ទទួលបាន		59,424,805	242,274,930	57,923,394	234,705,592
ការប្រាក់បានទូទាត់		21,903,585	89,300,916	18,096,379	73,326,528

កំណត់សម្គាល់ភ្ជាប់ពីលេខ 1 ដល់ 30 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុ។

កំណត់សម្គាល់លើ
របាយការណ៍ហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

១. ព័ត៌មានអំពីធនាគារ

ការបង្កើត និងប្រតិបត្តិការ

ធនាគារមេយប៉ែង ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតចាប់តាំងពីឆ្នាំ1993 និងធ្វើប្រតិបត្តិការក្នុងនាមជាសាខាភ្នំពេញ ("សាខា") នៃធនាគារ Malayan Banking Berhad (ក្រុមហ៊ុនមេ ឬ "MBB") ដែលជាធនាគារមួយចុះបញ្ជីអាជីវកម្មនៅប្រទេសម៉ាឡេស៊ី។

នៅថ្ងៃទី2 ខែមេសា ឆ្នាំ2012 សាខា ត្រូវបានចុះបញ្ជីអាជីកម្មជាក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិតដោយមានឈ្មោះថា ធនាគារមេយប៉ែង (ខេមបូឌា) ភីអិលស៊ី ("ធនាគារ") និងជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ MBB។ ធនាគារ ត្រូវបានចុះបញ្ជីអាជីវកម្ម ដោយអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានផ្តល់អាជ្ញាប័ណ្ណក្រោមបទប្បញ្ញត្តិទាំងឡាយនៃធនាគារជាតិនៃកម្ពុជា ("NBC")។

ធនាគារផ្តល់សេវាកម្មធនាគារទូលំទូលាយ និងសេវាហិរញ្ញវត្ថុដែលពាក់ព័ន្ធជាច្រើនទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមទៅតាមអាជ្ញាប័ណ្ណធនាគារលេខ 02 ចេញដោយធនាគារជាតិនៃកម្ពុជា ដោយមិនមានកាលកំណត់។

ដើមទុន

ដើមទុនសរុបរបស់ធនាគារ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 មានចំនួន 75 លានដុល្លារអាមេរិក (ឬ 300 ពាន់លានរៀល) (ឆ្នាំ2019៖ 75 លានដុល្លារអាមេរិក ឬ 300 ពាន់លានរៀល)។

ក្រុមប្រឹក្សាភិបាល

សមាសភាពនៃក្រុមប្រឹក្សាភិបាល នៅក្នុងអំឡុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

លោក Anthony Brent Elam	ប្រធានក្រុមប្រឹក្សាភិបាល / អភិបាលឯករាជ្យ និងមិនប្រតិបត្តិ
លោក Spencer Lee Tien Chye	អភិបាលឯករាជ្យ និងមិនប្រតិបត្តិ
លោក Datuk Hamirullah Boorhan	អភិបាលមិនឯករាជ្យ និងមិនប្រតិបត្តិ
លោក Soon Su Long	អភិបាលមិនឯករាជ្យ និងមិនប្រតិបត្តិ
លោក Sharifffuddin Khalid	អភិបាលឯករាជ្យ និងមិនប្រតិបត្តិ

ទីតាំង

ទីស្នាក់ការចុះបញ្ជីរបស់ធនាគារមានទីតាំងនៅអគារលេខ43 មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី3 ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020។ ធនាគារមានសាខាសរុបចំនួនម្ភៃមួយ (21) ដែលមានទីតាំងនៅក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តបាត់ដំបង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តបន្ទាយមានជ័យ និងខេត្តតាកែវ។

បុគ្គលិក

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 ធនាគារមានបុគ្គលិកសរុបចំនួន 406 នាក់ (ឆ្នាំ2019 មានចំនួន 405 នាក់)។

កាលបរិច្ឆេទនៃការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី26 ខែមីនា ឆ្នាំ2021។

២. គោលនយោបាយគណនេយ្យ។

២.១ សេចក្តីថ្លែងការណ៍នៃការអនុលោម

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារបានរៀបចំ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs") ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ ដែលក្រុមប្រឹក្សាស្តង់ដារគណនេយ្យនៃកម្ពុជាបានអនុវត្តយ៉ាងពេញលេញ។

គោលនយោបាយគណនេយ្យបានបង្ហាញខាងក្រោម ត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនដោយធនាគារ។

២.១.១ មូលដ្ឋាននៃរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើងផ្អែកតាមមូលដ្ឋានថ្លៃដើមប្រវត្តិ លើកលែងតែទ្រព្យសកម្មហិរញ្ញវត្ថុក្នុងតម្លៃជាក់ស្តែងតាមរយៈចំណូលពេញលេញផ្សេងទៀត ("FVOCI") ដែលត្រូវបានវាស់វែងតាមតម្លៃជាក់ស្តែង។

២.១.២ ការិយបរិច្ឆេទសារពើពន្ធ

ការិយបរិច្ឆេទសារពើពន្ធរបស់ធនាគារចាប់ផ្តើមពីថ្ងៃទី1 ខែមករា និងបញ្ចប់នៅថ្ងៃទី31 ខែធ្នូ។

២.១.៣ រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់កំណត់បង្ហាញ

របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក (US$) ហើយរាល់តម្លៃទាំងអស់ត្រូវបានបង្គត់ទៅជាប្រាក់ដុល្លារ ដែលនៅជិតបំផុតលើកលែងតែមានការចង្អុលបង្ហាញ។ ការប្រែសម្រួលប្រាក់ដុល្លារជាប្រាក់រៀល (KHR) ត្រូវបានធ្វើក្នុងការបំពេញតាមតម្រូវការនៃបទបង្ហាញដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្មតែប៉ុណ្ណោះ។ រូបិយប័ណ្ណមុខងាររបស់ធនាគារគឺដុល្លារអាមេរិក។

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណបរទេស ("FC") ត្រូវបានប្រែសម្រួលទៅជាប្រាក់ដុល្លារ អាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ទ្រព្យសកម្ម និងទ្រព្យអកម្ម ដែលជារូបិយប័ណ្ណផ្សេងទៀតក្រៅពីដុល្លារអាមេរិកមាននាកាលបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើប្រាស់អត្រានាកាលបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ភាពលម្អៀងពីការប្រែសម្រួលរូបិយប័ណ្ណត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

២.១.៤ ការប្រែសម្រួលទឹកប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល

ការប្រែសម្រួលប្រាក់ដុល្លារអាមេរិកទៅជាពាន់រៀល ("KHR'000") ត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីគោរពតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ដោយប្រើអត្រាប្តូរប្រាក់ចុងគ្រា និងអត្រាប្តូរប្រាក់ជាមធ្យម សម្រាប់ចុងការិយបរិច្ឆេទ ដូចដែលបានប្រកាសដោយធនាគារជាតិនៃ កម្ពុជា ("NBC")។

ទ្រព្យសកម្ម និងទ្រព្យអកម្មដែលមាននៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវប្រែសម្រួលតាម អត្រាប្តូរប្រាក់នៅចុងគ្រា នាចុងកាលបរិច្ឆេទសម្រាប់របាយការណ៍ ចំណែកឯចំណូល និងចំណាយដែលបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលពេញលេញ ត្រូវបានប្រែសម្រួលទៅតាមអត្រាប្តូរប្រាក់ជាមធ្យមសម្រាប់ចុងការិយបរិច្ឆេទ។ ភាពលម្អៀងពីការប្រែសម្រួលលទ្ធផលទាំងអស់ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។ ការប្រែសម្រួលមិនគួរបកស្រាយបរិមាណដុល្លារអាមេរិកជាតំណាង ឬ ធ្លាប់បាន ឬ អាចត្រូវបានកែសម្រួលទៅជាប្រាក់រៀលក្នុងអត្រាណាមួយ។ តម្លៃទាំងអស់ដែលគិតជាប្រាក់រៀល ត្រូវបានបង្គត់ទៅជាខ្ទង់ពាន់ ដែលនៅជិតបំផុត ("KHR'000") លើកលែងតែមានការចង្អុលបង្ហាញ។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់រៀលដោយផ្អែកលើអត្រាប្តូរប្រាក់ ដែលត្រូវអនុវត្តក្នុង 1 ដុល្លារអាមេរិកដូចខាងក្រោម៖

	2020	2019
អត្រាចុងគ្រា	4,045	4,075
អត្រាមធ្យម	4,077	4,052

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

២. គោលនយោបាយគណនេយ្យ (តពីទំព័រមុន)

២.២ ស្តង់ដារគណនេយ្យថ្មី និងបានកែសម្រួល និងការបកប្រែ

គោលនយោបាយគណនេយ្យ ដែលបានអនុម័ត គឺដូចគ្នានឹងឆ្នាំមុនលើកលែងតែស្តង់ដារគណនេយ្យថ្មី និងបានកែសម្រួល និងការបកប្រែ ដែលមានសុពលភាពចាប់ពីថ្ងៃទី01 ខែមករា ឆ្នាំ2020ប៉ុណ្ណោះ។ ការផ្លាស់ប្តូរនូវគោលនយោបាយគណនេយ្យនេះ មិនមានផលប៉ះពាល់សំខាន់ទៅលើលទ្ធផល និងស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនោះទេ លើកលែងតែមានការចង្អុលបង្ហាញ។

ការកែសម្រួលក្របខណ្ឌទស្សនៈរបស់ការរាយការណ៍ហិរញ្ញវត្ថុ

IASB បានចេញនូវការកែសម្រួលលើក្របខណ្ឌទស្សនៈរបស់ការរាយការណ៍ហិរញ្ញវត្ថុដែលនឹងត្រូវបានប្រើប្រាស់ក្នុងការសម្រេចចិត្តកំណត់ស្តង់ដារដោយមានសុពលភាពភ្លាមៗ។ ការផ្លាស់ប្តូរសំខាន់ៗរួមមាន ៖

- បង្កើនភាពលេចធ្លោនៃទំនួលខុសត្រូវទៅលើគោលដៅនៃការរាយការណ៍ហិរញ្ញវត្ថុ
- បំពេញឡើងវិញនូវភាពប្រុងប្រយ័ត្ន ដែលជាផ្នែកមួយនៃអព្យាក្រឹតភាព
- ការកំណត់អង្គភាពរាយការណ៍ ដែលអាចជានីតិបុគ្គល ឬជាចំណែកនៃអង្គភាព
- ពិនិត្យឡើងវិញនូវនិយមន័យនៃទ្រព្យសកម្ម និងទ្រព្យអកម្ម
- លុបចេញនូវប្រូបាប៊ីលីតេកម្រិតចាប់ប្រែប្រួល សម្រាប់ទទួលស្គាល់ និងបន្ថែមការណែនាំលើការមិនទទួលស្គាល់
- បន្ថែមការណែនាំលើមូលដ្ឋានវាស់វែងផ្សេងៗគ្នា និង
- កំណត់ប្រាក់ចំណេញ និងខាតជាសូចនាករនៃការអនុវត្តដំបូង ហើយក្នុងគោលការណ៍ប្រាក់ចំណូល និងចំណាយក្នុងចំណូលសរុបផ្សេងទៀតគួរតែត្រូវបានកែច្នៃឡើងវិញដែលនេះជួយបង្កើនភាពពាក់ព័ន្ធ ឬ ការបង្ហាញឡើងវិញដោយស្មោះត្រង់នៃរបាយការណ៍ហិរញ្ញវត្ថុ។ មិនមានការផ្លាស់ប្តូរកើតឡើងទៅស្តង់ដារគណនេយ្យបច្ចុប្បន្ននោះទេ។ ទោះយ៉ាងណាក៏ដោយអង្គភាព ដែលពឹងផ្អែកលើក្របខ័ណ្ឌក្នុងការកំណត់គោលនយោបាយគណនេយ្យសម្រាប់ប្រតិបត្តិការព្រឹត្តិការណ៍ ឬ លក្ខខណ្ឌ ដែលមិនត្រូវបានដោះស្រាយតាមស្តង់ដារគណនេយ្យ នឹងត្រូវអនុវត្តតាមក្របខ័ណ្ឌ ដែលបានកែសម្រួលចាប់ពីថ្ងៃទី01 ខែមករា ឆ្នាំ2020។ អង្គភាពនឹងត្រូវពិចារណាថាតើគោលនយោបាយគណនេយ្យរបស់ពួកគេនៅតែសមស្រប ក្រោមក្របខ័ណ្ឌ ដែលបានកែសម្រួលឬ ទេ។

ធនាគារបានវាយតម្លៃថាការធ្វើវិសោធនកម្មនេះមិនមានផលប៉ះពាល់ដល់ហិរញ្ញវត្ថុក្នុងអំឡុងឆ្នាំចាប់តាំងពីធនាគារបានបង្កើតគោលនយោបាយគណនេយ្យស្របតាម CIFRSs។

ចំណាត់ថ្នាក់នៃទ្រព្យអកម្មជាចរន្ត ឬ អចរន្ត (វិសោធនកម្មលើCIAS 1)

នាថ្ងៃទី23 ខែមករា ឆ្នាំ2020 IASB បានបានចេញវិសោធនកម្មលើវិសាលភាពបង្រួមតូចចំពោះ CIAS 1 ដើម្បីបញ្ជាក់ថាបំណុលត្រូវបានចាត់ថ្នាក់ជាបំណុលចរន្ត ឬ អចរន្តអាស្រ័យលើសិទ្ធិដែលមាននាការិយបរិច្ឆេទរបាយការណ៍ចុងគ្រា។ ការធ្វើវិសោធនកម្មតម្រូវឲ្យមានដូចខាងក្រោម៖

- បំណុលត្រូវបានចំណាត់ថ្នាក់ជាអចរន្ត ប្រសិនបើអង្គភាពមានសិទ្ធិគ្រប់គ្រាន់ក្នុងការពន្យាពេលទូទាត់យ៉ាងហោចណាស់រយៈពេល ១២ ខែនៅការិយបរិច្ឆេទរបាយការណ៍ចុងគ្រា។ ការធ្វើវិសោធនកម្មនេះមិនសំដៅទៅលើសិទ្ធិ ដែលគ្មានលក្ខខណ្ឌនោះទេពីព្រោះកម្ចីកម្រមិនមានលក្ខខណ្ឌ (ឧទាហរណ៍ ពីព្រោះកម្ចីអាចមានកិច្ចព្រមព្រៀង)។
- ការវាយតម្លៃកំណត់ថាតើមានសិទ្ធិកើតមានឡើងដៃរឬទេ ប៉ុន្តែគេមិនពិចារណាថាតើអង្គភាព នឹងអនុវត្តសិទ្ធិដៃរឬទេ។ ដូច្នេះការរឹតបិតទុករបស់អ្នកគ្រប់គ្រងមិនមានឥទ្ធិពលលើការចាត់ថ្នាក់ទេ។
- សិទ្ធិពន្យាពេលមានលុះត្រាតែអង្គភាពគោរពតាមលក្ខខ័ណ្ឌពាក់ព័ន្ធណាមួយនាការិយបរិច្ឆេទរាយការណ៍។ បំណុលត្រូវបានចាត់ថ្នាក់ជាចរន្ត ប្រសិនបើលក្ខខណ្ឌមួយត្រូវបានបំពាននា ឬ មុនការិយបរិច្ឆេទរាយការណ៍ ហើយការលះបង់ត្រូវបានទទួលបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍។ កម្ចីត្រូវបានចាត់ថ្នាក់ជាអចរន្តប្រសិនបើមានការបំពានទៅលើកិច្ចព្រមព្រៀងបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍។

ការទូទាត់ ត្រូវបានកំណត់ថាជាការបញ្ចប់បំណុល ជាមួយសាច់ប្រាក់ ធនធានសេដ្ឋកិច្ចផ្សេងទៀត ឬ ឧបករណ៍មូលធនផ្ទាល់របស់អង្គភាព។ មានករណីលើកលែងទៅលើឧបករណ៍ដែលអាចបម្លែងបាន ដែលអាចបំលែងទៅជាមូលធន ប៉ុន្តែសម្រាប់តែឧបករណ៍ណាដែលការបម្លែងនៃសមភាគ បានចាត់ថ្នាក់ជាឧបករណ៍មូលធន ដែលជាសមាសធាតុដាច់ដោយឡែកនៃឧបករណ៍ហិរញ្ញវត្ថុផ្តួប។

ធនាគារដែលជាស្ថាប័នហិរញ្ញវត្ថុមិនចាត់ថ្នាក់បំណុល ជាបំណុលចរន្ត ឬ អចរន្តទេ។

និយមន័យនៃអាជីវកម្មវិសោធនកម្មលើ CIFRS 3

IASB បានធ្វើវិសោធនកម្មលើនិយមន័យនៃអាជីវកម្មនៅក្នុង CIFRS 3 ការបញ្ចូលអាជីវកម្មរួមគ្នា។ ការធ្វើវិសោធនកម្មមានគោលបំណងជួយអង្គភាពក្នុងការកំណត់ថាតើប្រតិបត្តិការមួយគួរតែគិតជាការបញ្ចូលអាជីវកម្មរួមគ្នា ឬ ជាការទិញទ្រព្យសកម្ម។

ជាពិសេសការធ្វើវិសោធនកម្មបានបញ្ជាក់អំពីតម្រូវការអប្បបរមាដើម្បីធ្វើអាជីវកម្ម លុបចេញការវាយតម្លៃពីសមត្ថភាពរបស់អ្នកចូលរួមក្នុងទីផ្សារដំនួសធាតុដែលបាត់ និងបង្រួមនិយមន័យនៃលទ្ធផល។ធនាគារបានវាយតម្លៃថាការធ្វើវិសោធនកម្មនេះមិនមានផលប៉ះពាល់ដល់ហិរញ្ញវត្ថុក្នុងអំឡុងឆ្នាំចាប់តាំងពីក្នុងអំឡុងឆ្នាំ ធនាគារមិនបានចូលក្នុងការបញ្ចូលអាជីវកម្មរួមគ្នានោះទេ។

CIFRS IC សម្រេចចិត្តទៅលើ CIFRS 16 រយៈពេលភតិសន្យា

CIFRS 16ភតិសន្យាតម្រូវឲ្យអ្នកជួលទទួលស្គាល់បំណុលភតិសន្យាសម្រាប់ស្នើរតែគ្រប់ភតិសន្យា។ បំណុលភតិសន្យាគឺជាតម្លៃបច្ចុប្បន្ននៃការបង់ប្រាក់ជួលរយៈពេលជួល។រយៈពេលភតិសន្យាកាន់តែយូរ នោះជាធម្មតានឹងបង្កើតឲ្យមានបំណុលភតិសន្យាកាន់តែធំ។

រយៈពេលភតិសន្យាមិនអាចលើសពីរយៈពេលដែលភតិសន្យាអនុវត្តបានឡើយ។ កថាខ័ណ្ឌទី 33 នៃCIFRS 16 បានចែងថា" ភតិសន្យានឹងមិនអាចអនុវត្តបានទៀតទេនៅពេលដែលអ្នកជួលនិងម្ចាស់ជួល មានសិទ្ធិបញ្ចប់ភតិសន្យា ដោយគ្មានការអនុញ្ញាតពីភាគីម្ខាងទៀតដោយគ្មានការពិន័យដែលមិនសំខាន់។

CIFRS 16 មិនបានកំណត់ពាក្យ" ពិន័យ" ឬ" អាចអនុវត្តបាន" ទេ។ គណៈកម្មាធិការបកស្រាយបានសង្កេតឃើញថា ក្នុងការអនុវត្តកថាខណ្ឌ B34 អង្គភាពពិចារណាលើសេដ្ឋកិច្ចទូលំទូលាយនៃកិច្ចសន្យា ហើយមិនត្រឹមតែការទូទាត់បញ្ចប់កិច្ចសន្យាប៉ុណ្ណោះទេ។ ប្រសិនបើភាគីណាមួយនឹងទទួលពិន័យលើសពីការបញ្ចប់ (រួមទាំងការដាក់ទណ្ឌកម្មសេដ្ឋកិច្ច) ភតិសន្យាអាចអនុវត្តបានលើសពីកាលបរិច្ឆេទនោះ។

នៅពេលដែលរយៈពេលអនុវត្តត្រូវបានកំណត់ អ្នកជួលអនុវត្តគោលការណ៍ណែនាំអំពីជម្រើសរវាងការពន្យាពេល / ការបញ្ចប់អ្នកជួល ដើម្បីកំណត់រយៈពេលភតិសន្យា ពោលគឺប្រសិនបើអ្នកជួលមានហេតុផលជាក់លាក់ក្នុងការបន្តប្រើប្រាស់ទ្រព្យសកម្មនោះការិយបរិច្ឆេទត្រូវបានរាប់បញ្ចូលក្នុងរយៈពេលភតិសន្យា។

ធនាគារបានវាយតម្លៃថាការធ្វើវិសោធនកម្មនេះមិនមានផលប៉ះពាល់ដល់ហិរញ្ញវត្ថុក្នុងអំឡុងឆ្នាំចាប់តាំងពីភតិសន្យាទាំងអស់របស់ធនាគារ មិនរួមមានជម្រើសរវាងការពន្យាពេល/ការបញ្ចប់ដើម្បីកំណត់រយៈពេលភតិសន្យាទេ។

សម្បទានជួលដែលទាក់ទងនឹង កូវីត-19 វិសោធនកម្មលើCIAS 16

IASB បានចេញផ្សាយការធ្វើវិសោធនកម្មលើ CIAS 16 ដែលភតិសន្យាដែលផ្តល់នូវជម្រើសចាំបាច់ជាក់ស្តែងសម្រាប់អ្នកជួលពីការវាយតម្លៃថាតើសម្បទានជួលមានទាក់ទងនឹង កូវីត 19 ឬ ទេ គឺភតិសន្យាកែតម្រូវ។ អ្នកជួលអាចជ្រើសរើសគណនេយ្យសម្រាប់សម្បទានជួលទាំងនេះតាមរបៀបដែលពួកគេចង់បានប្រសិនបើពួកគេមិនមែនជាភតិសន្យាកែតម្រូវ។ ក្នុងករណីជាច្រើនវានឹងធ្វើឲ្យមានគណនេយ្យភាពសម្រាប់សម្បទានដែលជាការទូទាត់ភតិសន្យាអថេរក្នុងការិយបរិច្ឆេទ ដែលព្រឹត្តិការណ៍ ឬ លក្ខខណ្ឌបង្កឲ្យមានកាត់បន្ថយក្នុងការទូទាត់។

ធនាគារបានវាយតម្លៃថាការធ្វើវិសោធនកម្មនេះមិនមានផលប៉ះពាល់ដល់ហិរញ្ញវត្ថុក្នុងអំឡុងការិយបរិច្ឆេទនេះទេ។

២. គោលនយោបាយគណនេយ្យ (តពីទំព័រមុន)

២.៣ សេចក្តីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យដែលបានបង្ហាញខាងក្រោមត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនគ្រប់ការិយបច្ចេទ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះលើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

២.៣.១ ទ្រព្យសកម្មហិរញ្ញវត្ថុ

ក. កាលបរិច្ចេទនៃការទទួលស្គាល់

រាល់ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ត្រូវបានទទួលស្គាល់ជាដំបូងនៅថ្ងៃដែលជួញដូរ ពោលគឺថ្ងៃដែលធនាគារក្លាយជាភាគីមួយនៃកិច្ចសន្យារបស់ឧបករណ៍ហិរញ្ញវត្ថុ។នេះរួមបញ្ចូលទាំងការជួញដូរជាប្រចាំ ទិញ ឬ លក់នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលតម្រូវឲ្យប្រគល់ទ្រព្យសកម្មក្នុងរយៈពេលកំណត់ដែលបានបង្កើតឡើងដោយបទបញ្ជា ឬ អនុសញ្ញានៅក្នុងទីផ្សា។

ខ. ការទទួលស្គាល់លើកដំបូង និងការវាស់វែងជាបន្តបន្ទាប់

រាល់ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ត្រូវបានវាស់វែងលើកដំបូងតាមតម្លៃជាក់ស្តែង បូកនឹងចំណាយថ្លៃដើមប្រតិបត្តិការ លើកលែងតែក្នុងករណីដែលទ្រព្យសកម្មហិរញ្ញវត្ថុបានកត់ត្រាតម្លៃជាក់ស្តែង តាមរយៈចំណេញ ឬ ខាត។ ចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2019 ធនាគារធ្វើចំណាត់ថ្នាក់រាល់ទ្រព្យសកម្មហិរញ្ញវត្ថុផ្អែកលើម៉ូឌែលអាជីវកម្មសម្រាប់គ្រប់គ្រងទ្រព្យសកម្មនិងចរិតលក្ខណៈកិច្ចសន្យាលំហូរ សាច់ប្រាក់នៃទ្រព្យសកម្មបានវាស់វែង៖

- ទ្រព្យសកម្មហិរញ្ញវត្ថុតាមថ្លៃដើមរំលស់
- តម្លៃជាក់ស្តែងតាមរយៈលទ្ធផលពេញលេញផ្សេងៗ ("FVOCI")
- តម្លៃជាក់ស្តែងតាមរយៈចំណូលចំណាយ ("FVTPL")

ទ្រព្យសកម្មហិរញ្ញវត្ថុតាមថ្លៃដើមរំលស់

ធនាគារវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុតាមថ្លៃដើមរំលស់ ប្រសិនបើលក្ខខណ្ឌទាំងពីរត្រូវបានបំពេញដូចខាងក្រោម៖

- លក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុលើកឡើងនៅកាលបរិច្ចេទជាក់លាក់ នៃលំហូរសាច់ប្រាក់ដែលផ្អែកលើការទូទាត់ប្រាក់ដើម និងការប្រាក់តែឯង("SPPI") លើចំនួនប្រាក់ដើមដែលនៅសល់និង
- ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានអនុវត្តតាម ម៉ូឌែលអាជីវកម្មមួយ ដែលមានគោលដៅកាន់កាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ដើម្បីប្រមូលនូវលំហូរសាច់ប្រាក់តាមកិច្ចសន្យា។

ព័ត៌មានលម្អិតនៃលក្ខខណ្ឌទាំងនេះដូចខាងក្រោម៖

(i) ការធ្វើតេស្ត SPPI

តាមជំហានដំបូងនៃដំណើរការធ្វើចំណាត់ថ្នាក់របស់ខ្លួន ធនាគារវាយតម្លៃលើលក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុដើម្បីកំណត់ថាតើពួកគេឆ្លើយតបនឹងតេស្ត SPPI ដែរឬទេ។

"ប្រាក់ដើម" សម្រាប់គោលដៅនៃការធ្វើតេស្តនេះត្រូវបានកំណត់តាមតម្លៃជាក់ស្តែងនៃទ្រព្យសកម្មហិរញ្ញវត្ថុនៅពេលមានការទទួលស្គាល់លើកដំបូង និងអាចផ្លាស់ប្តូរអាយុកាលនៃទ្រព្យសកម្មហិរញ្ញវត្ថុ (ឧទាហរណ៍ ប្រសិនបើមានការទូទាត់សងលើប្រាក់ដើម ឬរំលស់តាមបុព្វលាភ / អប្បហារ)។

ធាតុសំខាន់ៗនៃការប្រាក់ក្នុងការរៀបចំប្រាក់កម្ចីត្រូវបានពិចារណាជាធម្មតាលើតម្លៃតាមវេលានៃសាច់ប្រាក់ និងហានិភ័យឥណទាន។

ដើម្បីធ្វើការវាយតម្លៃលើការទូទាត់ប្រាក់ដើម និងការប្រាក់ (SPPI) ធនាគារអនុវត្តការ វិនិច្ឆ័យ និងពិចារណាលើកត្តាពាក់ព័ន្ធដូចជារូបិយប័ណ្ណ ដែលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកំណត់ និងរយៈពេលដែលអត្រាការប្រាក់ត្រូវបានកំណត់។

លក្ខខណ្ឌកិច្ចសន្យា ដែលបង្ហាញពីការប៉ះពាល់ទៅ នឹងហានិភ័យ ឬ ភាពមិនចុះសម្រុងក្នុងលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលមិនទាក់ទង នឹងការរៀបចំប្រាក់កម្ចីជាមូលដ្ឋាន មិនបង្កឲ្យមានលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលបានទូទាត់តែឯងនូវប្រាក់ដើម និងការប្រាក់ទៅលើចំនួនទឹកប្រាក់ដែលនៅសល់ទេ។ ក្នុងករណីបែបនេះ ទ្រព្យសកម្មហិរញ្ញវត្ថុបានតម្រូវឲ្យមានការវាស់វែងតាម FVTPL។

(ii) ការវាយតម្លៃម៉ូឌែលអាជីវកម្ម

ធនាគារ បានកំណត់ម៉ូឌែលអាជីវកម្មរបស់ខ្លួននៅកម្រិតមួយ ដែលឆ្លុះបញ្ចាំងពីរបៀប ដែលចាត់ក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានគ្រប់គ្រងដើម្បីសម្រេចគោលបំណងអាជីវកម្មរបស់ខ្លួន។

ម៉ូដលអាជីវកម្មរបស់ធនាគារ មិនត្រូវបានវាយតម្លៃដោយផ្អែកលើមូលដ្ឋានឧបករណ៍ នីមួយៗនោះទេ ប៉ុន្តែវាយតម្លៃក្នុងកម្រិតខ្ពស់ ដោយផ្អែកលើឧបករណ៍នៅក្នុងសសម្គាធសរុប និងផ្អែកលើកត្តា ដែលអាចសង្កេតបានដូចជា៖

- របៀបនៃការអនុវត្តម៉ូឌែលអាជីវកម្ម និងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមាននៅក្នុងម៉ូឌែលអាជីវកម្មនោះ ត្រូវបានវាយតម្លៃ និងរាយការណ៍ទៅបុគ្គលិកគ្រប់គ្រងសំខាន់ៗ
- ហានិភ័យ ដែលជះឥទ្ធិពលដល់ការអនុវត្តលើគំរូអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលរក្សាទុកនៅក្នុងម៉ូឌែលអាជីវកម្ម) និងជាពិសេសវិធីសាស្ត្រ ដែលប្រើក្នុងការគ្រប់គ្រងហានិភ័យ។
- របៀប ដែលអ្នកគ្រប់គ្រងអាជីវកម្មទទួលបានសំណង (ឧទាហរណ៍ថាតើសំណង គឺផ្អែកលើតម្លៃជាក់ស្តែងនៃទ្រព្យសម្បត្តិ ដែលបានគ្រប់គ្រង ឬលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលបានប្រមូល)។
- ភាពញឹកញាប់ តម្លៃ និងការកំណត់ពេលនៃការលក់ដែលបានរំពឹងទុក ជាទិដ្ឋភាពសំខាន់ៗនៃការវាយតម្លៃរបស់ធនាគារ។

ការវាយតម្លៃម៉ូឌែលអាជីវកម្ម គឺផ្អែកលើសេណារីយ៉ូដែលរំពឹងទុកដោយសមហេតុផលនិងមិនរួមបញ្ចូលករណីអាក្រក់បំផុត ឬ ករណីមានភាពតានតឹង។ ប្រសិនបើលំហូរសាច់ប្រាក់បន្ទាប់ពីការទទួលស្គាល់ដំបូងត្រូវបានទទួលស្គាល់ក្នុងវិធីសាស្ត្រខុសពីការរំពឹងទុករបស់ធនាគារ ធនាគារមិនផ្លាស់ប្តូរចំណាត់ថ្នាក់ហិរញ្ញវត្ថុ ដែលនៅសល់ទេ។ ប៉ុន្តែធនាគារបញ្ចូលទិន្នន័យនាពេលវាយតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលទើបនឹងទទួលបាន។

ទ្រព្យសកម្ម ដែលត្រូវបូកបញ្ចូលជាទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមរំលស់មានដូចជាសាច់ប្រាក់ និងមូលនិធិរយៈពេលខ្លី ប្រាក់បញ្ញើនិង ប្រាក់កម្ចីជាមួយស្ថាប័នហិរញ្ញវត្ថុ ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានទិញក្រោមកិច្ចព្រមព្រៀងលក់បន្ត ការវិនិយោគហិរញ្ញវត្ថុ និងឥណទាន បុរេប្រទាន និង ហិរញ្ញប្បទាន ដូចបានបង្ហាញនៅក្នុង កំណត់ត្រារៀងៗខ្លួនលើរបាយការណ៍ហិរញ្ញវត្ថុ។

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

២. គោលនយោបាយគណនេយ្យ (តពីទំព័រមុន)

២.៣ សេចក្តីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

២.៣.១ ទ្រព្យសកម្មហិរញ្ញវត្ថុ (តពីទំព័រមុន)

ខ. **ការទទួលស្គាល់លើកដំបូង និងការវាស់វែងជាបន្តបន្ទាប់ (តពីទំព័រមុន)**

(ii) ការវាយតម្លៃម៉ូឌែលអាជីវកម្ម (តពីទំព័រមុន)

ទ្រព្យសកម្មក្នុង (“FVOCI”)

ធនាគារអនុវត្តនូវប្រភេទថ្មីក្រោម CIFRS9នៃលិខិតុបករណ៍ដែលបានអនុវត្តតាម FVOCI នៅពេលលក្ខខណ្ឌទាំងពីរខាងក្រោមត្រូវបានបំពេញ៖

- លិខិតុបករណ៍នេះត្រូវបានធ្វើឡើងតាមគំរូអាជីវកម្មគោលដៅលបំណងនៃ លិខិតុបករណ៍នេះ ត្រូវបានសម្រេចដោយការប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យានិងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុនិង
- លក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវគ្នា នឹងការសាកល្បងលើ SPPI។

ទ្រព្យសកម្មហិរញ្ញវត្ថុនៅ FVOCI ត្រូវបានគណនាជាបន្តបន្ទាប់តាមតម្លៃជាក់ស្តែងជាមួយ នឹងការចំណេញ និងខាតដែលកើតឡើងដោយសារការបំលាស់ប្តូរតម្លៃជាក់ស្តែង ដែលបានទទួលស្គាល់ក្នុងលទ្ធផលពេញលេញ (“OCI”)។ ចំណូលការប្រាក់ និង ការចំណេញឬខាតលើអត្រាប្តូរប្រាក់បរទេសត្រូវបានទទួលស្គាល់នៅក្នុងការចំណេញ ឬ ខាត ដែលមានតរិយាបទនៃវិធានដូចគ្នានឹងទ្រព្យសកម្មហិរញ្ញវត្ថុដែលបានគណនាលើចំណាយរំលស់។ បាត់បង់តាមរបៀបដូចគ្នានឹងសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់ដោយថ្លៃរំលស់។ នៅពេលធនាគារធ្វើការវិនិយោគច្រើនជាងមួយលើមូលប័ត្រដូចគ្នា ធនាគារត្រូវបោះបង់ចោលការគណនាតាមរបៀប first-in first-out។ តាមការមិនទទួលស្គាល់ការចំណេញឬការខាតបង់ ដែលត្រូវបានទទួលស្គាល់ពីមុននៅក្នុងលទ្ធផលពេញលេញត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញពីលទ្ធផលពេញលេញទៅការចំណេញ ឬខាតវិញ។

ឧបករណ៍មូលធនជាធម្មតាត្រូវបានគណនាតាម FVTPL។ ទោះយ៉ាងណាក៏ដោយចំពោះឧបករណ៍មូលធនដែលមិនបានធ្វើពាណិជ្ជកម្មជាមួយជម្រើស ដែលមិនអាចកែប្រែបាននៅពេលចាប់ផ្តើមធនាគារបានធ្វើការវាស់វែងលើចំលាស់ប្តូរតាមរយៈ FVOCI (ដោយមិនមានការកែឡើងវិញនូវចំណេញ ឬខាតរហូតដល់មានការលែងទទួលស្គាល់)។

- ការរៀបចំនេះលុបបំបាត់ ឬកាត់បន្ថយការ ដែលមិនស៊ីចង្វាក់គ្នាដែលអាចនឹងកើតឡើងពីការគណនាទ្រព្យសកម្ម ឬ បំណុលឬការទទួលស្គាល់លើការចំណេញឬខាតរបស់ពួកគេដោយផ្អែកលើមូលដ្ឋានផ្សេងគ្នា ឬ
- ទ្រព្យសកម្ម និង បំណុល គឺជាផ្នែកមួយនៃក្រុមទ្រព្យសកម្មហិរញ្ញវត្ថុឥណទាន ហិរញ្ញវត្ថុ ឬ ទាំងពីរដែលត្រូវបានគ្រប់គ្រងនិងការវាយតម្លៃការអនុវត្តរបស់ទ្រព្យសកម្មដោយផ្អែកលើមូលដ្ឋានតម្លៃជាក់ស្តែង អនុលោមតាមឯកសារគ្រប់គ្រង ហានិភ័យឬយុទ្ធសាស្ត្រវិនិយោគ។

រាប់បញ្ចូលទ្រព្យសកម្មហិរញ្ញវត្ថុតាម FVTPL រួមមានការវិនិយោគហិរញ្ញវត្ថុ ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានកំណត់លើការទទួលស្គាល់ដំបូងឥណទាន និងបុរេប្រទាន និងហិរញ្ញប្បទានដល់អតិថិជន និងនិស្សន្ទបង្កក់។

បន្ទាប់ពីការទទួលស្គាល់ដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានទុកសម្រាប់ប្រតិបត្តិការពាណិជ្ជកម្ម និងទ្រព្យសកម្មហិរញ្ញវត្ថុបានកំណត់តាម FVTPL ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដោយតម្លៃជាក់ស្តែង។ បំលាស់ប្តូរតម្លៃជាក់ស្តែងត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលក្រោមចំណងជើងនៃ “ប្រាក់ចំណូលប្រតិបត្តិការផ្សេងទៀត” ។

ឥណទាន និងបុរេប្រទាន

ឥណទាន និងបុរេប្រទានក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួមមានឥណទាន និងបុរេប្រទាន ដែលត្រូវបានវាស់វែងដោយថ្លៃដើមរំលស់ វាត្រូវបានគេវាស់វែងលើកដំបូងតាមតម្លៃជាក់ស្តែងបូក នឹងចំណាយប្រតិបត្តិការបន្ថែម និងវាស់វែងជាបន្តបន្ទាប់ ដោយប្រើថ្លៃដើមរំលស់ដែលមានអត្រាការប្រាក់ប្រសិទ្ធភាព។

គ. **ការលែងទទួលស្គាល់ដោយសារមានការកែសម្រួលសំខាន់ៗនៃលក្ខខណ្ឌ**

ធនាគារលែងទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុដូចជាឥណទាន និងបុរេប្រទាននាពេលដែលលក្ខន្តិកៈត្រូវបានពិភាក្សាឡើងវិញក្នុងកំរិតមួយ។ ភាគច្រើនវាក្លាយជាប្រាក់កម្ចីថ្មីជាមួយនឹងការទទួលស្គាល់ផ្សេងដែលជាការមិនទទួលស្គាល់លើការចំណេញ ឬ ខាត ដល់កំរិតមួយដែលអ៊ីមែរភែមិនមិនត្រូវបានកត់ត្រា។

ប្រាក់កម្ចីដែលទើបតែបានទទួលស្គាល់ថ្មីត្រូវបានចាត់ក្នុងដំណាក់កាលទី 1 សម្រាប់គោលបំណងគណនា ECL លើកលែងតែប្រាក់កម្ចីថ្មីដែលបានចាត់ទុកថាត្រូវបានទិញ ឬ មានអ៊ីមែរភែមិននៃឥណទាន(“POCI”) ។

ប្រសិនបើការកែសម្រួលនេះមិនបណ្តាលឲ្យមានលំហូរសាច់ប្រាក់ខុសប្លែកខ្លាំងនោះការកែសម្រួលមិនបណ្តាលឲ្យមានការមិនទទួលស្គាល់ទេ។ ផ្អែកលើបម្រែបម្រួលលំហូរសាច់ប្រាក់ដែលបានបញ្ចុះតាមអត្រាការប្រាក់មានសពុលភាព (EIR) ធនាគារត្រូវកត់ត្រាបម្រែបម្រួលលើការចំណេញ ឬ ខាត ដើម្បីឈានដល់កំរិតមួយដែលអ៊ីមែរភែមិនមិនត្រូវបានកត់ត្រា។

ឃ. **អ៊ីមែរភែមិននៃទ្រព្យសកម្មហិរញ្ញវត្ថុ**

តម្រូវការនៃអ៊ីមែរភែមិនរបស់ CIFRS 9 គឺផ្អែកលើវិធាន ECL ដែលជំនួសវិធាននៃការខាតបង់ដែលបានកើតឡើងក្រោម CAS 9។ វិធាន ECLត្រូវបានអនុវត្តចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានគណនាដោយចំណាយរំលស់ ឬតាម FVOCI កិច្ចសន្យាប្រាក់កម្ចីដែលមិនអាចដកហូតបាននិងកិច្ចសន្យាធានាហិរញ្ញវត្ថុ ដែលរួមមានឥណទាន បុរេប្រទានហិរញ្ញប្បទាន និងលិខិតុបករណ៍នៃឥណទានដែលធនាគារកាន់កាប់។វិធាន ECL ក៏ត្រូវបានអនុវត្តចំពោះកិច្ចសន្យាទ្រព្យសកម្មក្រោម CIFRS 15 ប្រាក់ចំណូលពីកិច្ចសន្យាជាមួយអតិថិជន និងគណនីត្រូវទទួលបានពីការជួលបានចែងក្នុង CIFRS 16។

ការគណនានៃការខាតបង់ឥណទាន រំពឹងទុក ពាក់ព័ន្ធនឹងការកើនឡើងនៃភាពស្មុគស្មាញ និងការវិនិច្ឆ័យរួមមាន៖

(i) កំណត់ពីការកើនឡើងនូវហានិភ័យឥណទានចាប់តាំងពីមានការទទួលស្គាល់ដំបូង

ការវាយតម្លៃលើអ៊ីមែរភែមិន ដែលគួរឲ្យកត់សំគាល់ចាប់តាំងពីការទទួលស្គាល់ដំបូងជាគន្លឹះក្នុងការបង្កើតការផ្លាស់ប្តូរវាងតម្រូវការគណនាប្រាក់ឧបត្ថម្ភដោយផ្អែកលើ ECL 12ខែ និងផ្អែកលើ ECL ពេញមួយជីវិត។ ការវាយតម្លៃលើបរិមាណ និងគុណភាពតម្រូវឲ្យប៉ាន់ស្មានលើការកើនឡើងគួរឲ្យកត់សម្គាល់នៃ ហានិភ័យឥណទាន ដោយប្រៀបធៀបហានិភ័យនៃការកើតឡើងជាប្រចាំលើទ្រព្យសកម្មហិរញ្ញវត្ថុកាលបរិច្ឆេទរបាយការណ៍ជាមួយ នឹងហានិភ័យនៃការកើតឡើងជប្រចាំលើទ្រព្យសកម្មហិរញ្ញវត្ថុនៅកាលបរិច្ឆេទនៃការទទួលស្គាល់ដំបូង។ការវាយតម្លៃលើអ៊ីមែរភែមិន ដែលគួរឲ្យកត់សំគាល់ចាប់តាំងពីការទទួលស្គាល់ដំបូង ជាគន្លឹះក្នុងការបង្កើតការផ្លាស់ប្តូរវាងតម្រូវការគណនាប្រាក់ឧបត្ថម្ភដោយផ្អែកលើ ECL 12ខែ និងផ្អែកលើ ECL ពេញមួយជីវិត។ ការវាយតម្លៃលើបរិមាណ និងគុណភាពតម្រូវឲ្យប៉ាន់ស្មានលើការកើនឡើងគួរឲ្យកត់សម្គាល់នៃហានិភ័យឥណទាន ដោយប្រៀបធៀបហានិភ័យ នៃការកើតឡើងជាប្រចាំលើ ទ្រព្យសកម្មហិរញ្ញវត្ថុកាលបរិច្ឆេទរបាយការណ៍ជាមួយ នឹងហានិភ័យនៃការកើតឡើងជាប្រចាំលើទ្រព្យសកម្មហិរញ្ញវត្ថុនៅកាលបរិច្ឆេទនៃការទទួលស្គាល់ដំបូង។

២. គោលនយោបាយគណនេយ្យ (តពីទំព័រមុន)

២.៣ សេចក្តីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

២.៣.១ ទ្រព្យសកម្មហិរញ្ញវត្ថុ (តពីទំព័រមុន)

ឃ. អ៊ីមភែមិននៃទ្រព្យសកម្មហិរញ្ញវត្ថុ (តពីទំព័រមុន)

ធនាគារអនុវត្តវិធីសាស្រ្តបីដំណាក់កាល ដោយផ្អែកលើការផ្លាស់ប្តូរគុណភាពឥណទានចាប់តាំងពីមានការទទួលស្គាល់ដំបូង៖

វិធាន3ដំណាក់កាល	ដំណាក់កាលទី 1	ដំណាក់កាលទី 2	ដំណាក់កាលទី 3
	ដំណើរការ	កំពុងដំណើរការ	មិនដំណើរការ
វិធានECL	ECL 12 ខែ	ECLពេញមួយជីវិត	ECLពេញមួយជីវិត
លក្ខណវិនិច្ឆ័យ	មិនមានការកើនឡើងគួរឲ កត់សម្គាល់លើហានិភ័យ ឥណទានទេ	ហានិភ័យឥណទាន កើនឡើងគួរឲកត់សម្គាល់	ទ្រព្យសកម្មដែលបានធ្វើ ក្រេឌីតអ៊ីមភែមិន
ការទទួលស្គាល់ចំណូលការប្រាក់	តម្លៃដុលយោង	តម្លៃដុលយោង	តម្លៃសុទ្ធយោង

(ii) ការគណនា ECL

មានសមាសធាតុសំខាន់បី ដើម្បីគណនា ECL ដូចជា ប្រូបាប៊ីលីតេនៃការគ្មានលទ្ធភាពសង ("PD") ការខាតបង់ នៃការគ្មានលទ្ធភាពសង ("LGD") និងហានិភ័យនៃការគ្មានលទ្ធភាពសង("EAD")។ ម៉ូឌែលនេះគឺ ដើម្បីផ្តល់លទ្ធភាពឲ្យបានច្រើនតាមតែអាចធ្វើទៅបាន នូវម៉ូឌែលបាសែល ទី2 របស់ធនាគារ និងអនុវត្តការកែសម្រួលដើម្បីឲ្យសមស្របទៅតាមការអនុលោមរបស់ CIFRS 9។

CIFRS 9 មិនបែងចែករវាងការវាយតម្លៃបុគ្គល និងការវាយតម្លៃសមូហភាពឡើយ។ ដូច្នេះ ធនាគារបានសម្រេចចិត្តបន្តគណនាអ៊ីមភែមិន ជាចម្បងលើមូលដ្ឋានប្រតិបត្តិការបុគ្គលសម្រាប់ទ្រព្យកម្មហិរញ្ញវត្ថុដែលត្រូវបានចាត់ទុកថាមានលក្ខណៈបុគ្គល និងវាយតម្លៃជារួម សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀតក្នុងគោលនយោបាយរបស់ធនាគារ។

(iii) ការរំពឹងទុកនៃអាយុកាលទ្រព្យសកម្ម

ECL ពេញមួយជីវិតត្រូវតែគណនាតាមអាយុកាលរំពឹងទុក។ ECL ពេញមួយជីវិតត្រូវបានកម្រិតអាយុកាលអតិបរមាលើកិច្ចសន្យា ហើយត្រូវវាយតម្លៃទុកដាក់ពីការទូទាត់មុន ដែលបានរំពឹងទុកការពន្យា និង call និង options លើកលែងតែឧបករណ៍ហិរញ្ញវត្ថុជាក់លាក់ ដែលអាចបង្វិលបានដូចជាកាតឥណទាន និងឥណទានកំណត់។ អាយុកាលរំពឹងទុកសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ បង្វិលជាទូទៅសំដៅទៅលើស្ថានភាពអាយុកាលរបស់ឧបករណ៍ហិរញ្ញវត្ថុទាំងនោះ។

(iv) ការវិនិយោគហិរញ្ញវត្ថុតាម FVOCI

ECLs សម្រាប់ការវិនិយោគហិរញ្ញវត្ថុ ដែលបានគណនាតាម FVOCI មិនកាត់បន្ថយតម្លៃយោង នៃទ្រព្យសកម្មហិរញ្ញវត្ថុទាំងនេះនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុទេ ហើយនៅរក្សាតម្លៃជាក់ស្តែងដដែល។ ផ្ទុយទៅវិញតម្លៃស្មើ នឹងសំវិធានធន នឹងកើតឡើងប្រសិនបើទ្រព្យសកម្ម ត្រូវបានវាស់វែងតាមថ្លៃដើមរំលស់ត្រូវបានទទួលស្គាល់នៅក្នុងលទ្ធផលពេញលេញជាអ៊ីមភែមិនបង្ករ និងត្រូវចាត់ទុកជាចំណាយក្នុងរបាយការណ៍ចំណូលចំណាយ។ ការខាតបង់បង្ករ ដែលត្រូវបានទទួលស្គាល់នៅក្នុងលទ្ធផលពេញលេញ ត្រូវបានរៀបចំកែច្នៃឡើងវិញក្នុងរបាយការណ៍ចំណូលចំណាយ បន្ទាប់ពីមានការមិនទទួលស្គាល់ទ្រព្យសកម្ម។

(v) ព័ត៌មាននាពេលខាងមុខ

ECLគឺមិនលម្អៀងប្រូបាប៊ីលីតេនៃឱនភាពឥណទាន ដែលត្រូវបានកំណត់ដោយការវាយតម្លៃលទ្ធផល ដែលអាចកើតមាន និងពិចារណាលើលក្ខខណ្ឌសេដ្ឋកិច្ចនាពេលអនាគត។ ព័ត៌មាននាពេលខាងមុខដែលសមហេតុផល និងអាចទ្រទ្រង់ គឺផ្អែកទៅលើក្រុមស្រាវជ្រាវ និងក្រុមរបស់ ធនាគារ មេយប៊ែងគីមអេង MKE។ លើសពីនេះទៀត ការសន្ទត់និងការវិភាគស្រាវជ្រាវរបស់ MKE ផ្អែកលើការប្រមូលផ្តុំទិន្នន័យម៉ាក្រូសេដ្ឋកិច្ចផងដែរ ដែលទទួលបានពីប្រភពផ្សេងៗ ប៉ុន្តែមិនមានកំណត់ចំពោះនិយតកររដ្ឋាភិបាល និងក្រសួងកិច្ចការបរទេស ដូចជាអង្គការស្រាវជ្រាវឯករាជ្យ។

នាពេលអាចអនុវត្តបាន ធនាគាររួមបញ្ចូលនិយ័តកម្មលើព័ត៌មាននាពេលខាងមុខទៅក្នុងកត្តាហានិភ័យឥណទានរបស់ PD និង LGD ដែលត្រូវបានប្រើក្នុងការគណនា ECL ដោយគិតគូរពីផលប៉ះពាល់នៃការព្យាករណ៍អំពីស្ថានភាពសេដ្ឋកិច្ចនាពេលអនាគត។

បញ្ចូលក្នុង ECL គឺមានប្រភេទផ្សេងគ្នាទូលំទូលាយ នៃព័ត៌មាននាពេលខាងមុខ ដែលជាទិន្នន័យហិរញ្ញវត្ថុ ដូចជា៖

- កំណើនផលិតផលក្នុងស្រុកដុល (GDP)
- អត្រានិកម្មភាព
- សន្ទស្សន៍ថ្លៃផ្ទះ
- នយោបាយការប្រាក់របស់ធនាគារគោល

ធនាគារ អនុវត្តសេណារីយ៉ូម៉ាក្រូសេដ្ឋកិច្ច ដែលជាជម្រើសទាំងបីដើម្បីឆ្លុះបញ្ចាំងនូវ probability-weighted range ដែលមិនលម្អៀង នៃលទ្ធផលដែលនឹងអាចកើតឡើង នាពេលអនាគតក្នុងការរំពឹងទុក ECL៖

សេណារីយ៉ូមូលដ្ឋានៈ សេណារីយ៉ូនេះឆ្លុះបញ្ចាំងនូវស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន ដែលបន្តរីកចម្រើន

សេណារីយ៉ូឡើង និងចុះៈ សេណារីយ៉ូនេះត្រូវបានបង្កើតទំនាក់ទំនងជាមួយសេណារីយ៉ូមូលដ្ឋាន ឆ្លុះបញ្ចាំងនូវស្ថានភាពម៉ាក្រូសេដ្ឋកិច្ចដែលល្អបំផុត និងអាក្រក់បំផុតដោយផ្អែកការវិនិច្ឆ័យដ៏ឥតខ្ចោះរបស់អ្នកជំនាញ លើស្ថានភាពសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន។

(v) ការវាយតម្លៃលើប្រាតិភោគជាការធានាលើទ្រព្យសកម្មហិរញ្ញវត្ថុ

គោលការណ៍គណនេយ្យរបស់ ធនាគារសម្រាប់ប្រាតិភោគបានរៀបចំតាមការរៀបចំការ អោយជួលអនុលោមតាម CIFRS 9 ដូចគ្នាការអនុលោមតាម GAAP ពីមុន។

(vi). ការលុបចេញ

ពេលដែលឥណទានមិនអាចទទួលមកវិញបាន ឥណទានត្រូវបានលុបចោលលើវិភាជន៍ ដែលទាក់ទងសម្រាប់អ៊ីមភែមែននៃឥណទាន។ ឥណទានទាំងឡាយ ដែលបានលុបចោលបន្ទាប់ពីនីតិវិធីចាំបាច់បានបញ្ចប់ និងចំនួននៃការបាត់បង់បានកំណត់។ ការក្សាចំនួនដើមបន្តបន្ទាប់លើចំនួនដែលបានលុប នឹងត្រូវបានទទួលស្គាល់ក្នុង ការចំណេញ ឬខាត។

ង. ការរៀបចំឡើងវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានចរចាឡើងវិញ ឬកែប្រែ ឬទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានស្រាប់ត្រូវបានជំនួសដោយទ្រព្យសកម្មថ្មី ដោយសារតែមានការលំបាកផ្នែកហិរញ្ញវត្ថុរបស់អ្នកខ្ចី បន្ទាប់មកការវាយតម្លៃ ត្រូវបានធ្វើឡើងថាតើទ្រព្យសកម្មហិរញ្ញវត្ថុគួរមិនទទួលស្គាល់ឬទេ ហើយ ECLត្រូវបានវាស់វែងដូចខាងក្រោម៖

- ប្រសិនបើការរុះរើរចនាសម្ព័ន្ធ ដែលរំពឹងទុកមិនបណ្តាលឲ្យមានការទទួលស្គាល់ទ្រព្យសកម្ម ដែលមានស្រាប់នោះលំហូរសាច់ប្រាក់រំពឹងទុក ដែលបានមកពីការកែប្រែទ្រព្យសកម្ម ត្រូវបានរាប់បញ្ចូលក្នុងការគណនាសាច់ប្រាក់ ដែលខ្វះពីទ្រព្យសកម្ម ដែលមានស្រាប់។

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

២. គោលនយោបាយគណនេយ្យ (តពីទំព័រមុន)

២.៣ សេចក្តីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

២.៣.២ ទ្រព្យសកម្មហិរញ្ញវត្ថុ (តពីទំព័រមុន)

ង. ការរៀបចំឡើងវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុ (តពីទំព័រមុន)

- ប្រសិនបើការរុះរើរចនាសម្ព័ន្ធ ដែលរំពឹងទុកបណ្តាលឲ្យមានការទទួលស្គាល់ទ្រព្យសកម្ម ដែលមានស្រាប់នោះសមស្រប ដែលរំពឹងទុករបស់ទ្រព្យសកម្មថ្មីត្រូវបានចាត់ទុកជាលំហូរសាច់ប្រាក់ចុងក្រោយបានពីទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានស្រាប់នៅក្នុងពេល ដែលមិនទទួលស្គាល់។ ចំនួនទឹកប្រាក់នេះត្រូវបានរាប់បញ្ចូលក្នុងការគណនាសាច់ប្រាក់ ដែលខ្វះពីទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានបញ្ចុះថ្លៃពីកាលបរិច្ឆេទ នៃការមិនទទួលស្គាល់រំពឹងទុករហូតដល់ថ្ងៃវាយការណ៍ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធិភាពដើមរបស់ ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានស្រាប់។

ការរៀបចំឡើងវិញនូវឥណទានដោយសារវិបត្តិ Covid-19

ឆ្លើយតបទៅ នឹងស្ថានភាពសេដ្ឋកិច្ច ដែលបណ្តាលមកពីជំងឺរាតត្បាតកាំរ៉ែ (COVID-19) និង ដើម្បីរក្សាស្ថេរភាពហិរញ្ញវត្ថុព្រមទាំងបន្ធូរបន្ថយករបស់អ្នកទទួលកម្ចី ដែលមានប្រភពចំណូលសំខាន់ត្រូវបានរងផលប៉ះពាល់ពីការរាតត្បាត ធនាគារជាតិនៃកម្ពុជា បានចេញសារាចរលេខ ត7.020.001 ចំពោះធនាគារ និងស្ថាប័នហិរញ្ញវត្ថុនៅកម្ពុជា អោយមានភាពបត់បែនទាក់ទងនឹងការទូទាត់សង ដោយផ្តល់ការរៀបចំឡើងវិញនូវឥណទានដល់អតិថិជន។

ការរៀបចំឡើងវិញនូវឥណទាន អនុវត្តចំពោះឥណទាន ដែលកំពុងដំណើរការ (ឥណទាន ដែលមិនហួសពីរយៈពេលលើសពី 30 ថ្ងៃ) និងឥណទានមិនដំណើរការសម្រាប់អតិថិជន ដែលមានការលំបាកផ្នែកហិរញ្ញវត្ថុ ត្រូវបានគេរំពឹងថាគ្រាន់តែជាការរៀបចំបណ្តោះអាសន្នប៉ុណ្ណោះ ហើយមានសុពលភាពរហូតដល់ថ្ងៃទី 30 ខែមិថុនា ឆ្នាំ2021។ ក្នុងករណីទាំងអស់ចំណាត់ថ្នាក់ សម្រាប់ឥណទានមិនដំណើរការ ត្រូវរក្សានៅដដែល។

ច. ការធ្វើចំណាត់ថ្នាក់ឡើងវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុ

ការធ្វើចំណាត់ថ្នាក់ឡើងវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុ គឺអនុញ្ញាតនៅពេលមានការផ្លាស់ប្តូរម៉ូដែលអាជីវកម្មសម្រាប់ការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលធ្លាប់ជាឧបករណ៍បង្ការហានិភ័យត្រូវបានរៀបចំ និងមានប្រសិទ្ធភាពពីមុននៅក្នុង លំហូរសាច់ប្រាក់ទប់ស្កាត់ហានិភ័យ ឬវិនិយោគសុទ្ធទប់ស្កាត់ហានិភ័យមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៀតហើយ។
- ទ្រព្យសកម្មហិរញ្ញវត្ថុបានក្លាយជាការរៀបចំឧបករណ៍ទប់ស្កាត់ហានិភ័យ និងមានប្រសិទ្ធភាពក្នុងលំហូរសាច់ប្រាក់បង្ការហានិភ័យ និងវិនិយោគសុទ្ធទប់ស្កាត់ហានិភ័យ
- ការប្រែប្រួលក្នុងការវាស់វែង នៅពេល ដែលធនាគារប្រើប្រាស់ជម្រើសនៃតម្លៃជាក់ស្តែង។

២.៣.២ ទ្រព្យអកម្មហិរញ្ញវត្ថុ

ក. កាលបរិច្ឆេទនៃការទទួលស្គាល់

ទ្រព្យអកម្មហិរញ្ញវត្ថុទាំងអស់ ត្រូវបានទទួលស្គាល់ជាលើកដំបូងនាកាលបរិច្ឆេទប្រតិបត្តិការពាណិជ្ជកម្ម។ ឧទាហរណ៍ កាលបរិច្ឆេទដែលធនាគារបានក្លាយជាភាគីនៃការផ្តល់កិច្ចសន្យាសំវិធានធនទៅលើឧបករណ៍។ ទ្រព្យអកម្មហិរញ្ញវត្ថុនេះរួមបញ្ចូលទាំង ប្រតិបត្តិការជាប្រចាំដូចជា ការទិញ ឬលក់នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលតម្រូវឲ្យមានការប្រគល់ទ្រព្យសកម្មក្នុងពេលកំណត់ដែលបានបង្កើតឡើងតាមបទប្បញ្ញត្តិ ឬអនុសញ្ញានៅក្នុងទីផ្សារ។

ខ. ការទទួលស្គាល់លើកដំបូង និងការវាស់វែងជាបន្តបន្ទាប់

ទ្រព្យអកម្មហិរញ្ញវត្ថុ ត្រូវបានធ្វើចំណាត់ថ្នាក់តាមការអនុលោមក្នុងកិច្ចសន្យាដែលបានដាក់បញ្ចូល និងផ្តល់និយមន័យដល់ទ្រព្យអកម្មហិរញ្ញវត្ថុនោះ។

រាល់ទ្រព្យអកម្មហិរញ្ញវត្ថុ គឺគណនាជាលើកដំបូងតាមតម្លៃជាក់ស្តែង ហើយបូកនឹងថ្លៃដើមនៃប្រតិបត្តិការ ដែលបានបែងចែកដោយផ្ទាល់ លើកលែងតែករណីនៃទ្រព្យអកម្មហិរញ្ញវត្ថុតាមរយៈ FVTPL។

ទ្រព្យអកម្មហិរញ្ញវត្ថុ ត្រូវបានចាត់ថ្នាក់ជាទ្រព្យអកម្មហិរញ្ញវត្ថុតាមរយៈ FVTPL ឬ ទ្រព្យអកម្មហិរញ្ញវត្ថុផ្សេងទៀត។

(i) ទ្រព្យអកម្មហិរញ្ញវត្ថុតាម FVTPL

ទ្រព្យអកម្មហិរញ្ញវត្ថុតាម FVTPL រួមបញ្ចូលទាំងទ្រព្យអកម្មហិរញ្ញវត្ថុ HFT និងទ្រព្យអកម្មហិរញ្ញវត្ថុ ដែលត្រូវបានកំណត់នៅពេលមានការទទួលស្គាល់លើកដំបូងតាមFVTPL។

ទ្រព្យអកម្មហិរញ្ញវត្ថុរក្សាទុកសម្រាប់ធ្វើការជួញដូរ (HFT)

ទ្រព្យអកម្មហិរញ្ញវត្ថុ ត្រូវបានធ្វើចំណាត់ថ្នាក់ជាទ្រព្យអកម្មសម្រាប់ប្រតិបត្តិការពាណិជ្ជកម្ម ប្រសិនបើពួកគេត្រូវបានកើតឡើងសម្រាប់គោលបំណង ដើម្បីទិញឡើងវិញក្នុងរយៈពេលដ៏ខ្លី។ ប្រភេទទាំងនេះរួមបញ្ចូលនិស្សន្ទ ដែលបានដាក់បញ្ចូលដោយធនាគារ ដែលមិនបំពេញតាមលក្ខណៈគណនេយ្យទប់ស្កាត់ហានិភ័យ។

ការចំណេញ ឬខាតលើទ្រព្យអកម្មហិរញ្ញវត្ថុ HFT ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលពេញលេញ។

ទ្រព្យអកម្មហិរញ្ញវត្ថុត្រូវបានកំណត់តាមតម្លៃជាក់ស្តែង

ទ្រព្យអកម្មហិរញ្ញវត្ថុ ដែលត្រូវបានកំណត់តាម FVTPLនៅពេលទទួលស្គាល់លើកដំបូង ត្រូវបានកំណត់នៅកាលបរិច្ឆេទដំបូង។

CIFRS 9 មិនបានដកចេញពីវិធានទទួលស្គាល់លើកដំបូង និងការគណនាជាបន្តបន្ទាប់នៃ ទ្រព្យអកម្មហិរញ្ញវត្ថុ។

ទោះយ៉ាងណា ការផ្លាស់ប្តូរតម្លៃជាក់ស្តែងត្រូវបានបង្ហាញខុសៗគ្នាដូចខាងក្រោម៖

- ការផ្លាស់ប្តូរតម្លៃជាក់ស្តែងដោយសារហានិភ័យឥណទានផ្ទាល់ខ្លួន ដែលត្រូវបានបង្ហាញនៅក្នុង ចំណូលពេញលេញផ្សេងៗទៀត។
- ការផ្លាស់ប្តូរតម្លៃជាក់ស្តែងដោយសារហានិភ័យទីផ្សារឬកត្តាផ្សេងៗ ដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលចំណូល។

(ii). ទ្រព្យអកម្មហិរញ្ញវត្ថុផ្សេងៗ

ទ្រព្យអកម្មហិរញ្ញវត្ថុផ្សេងទៀតរបស់ធនាគាររួមមាន៖ ប្រាក់បញ្ញើរបស់អតិថិជនប្រាក់បញ្ញើពីស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត បំណុលភតិសន្យា សមតុល្យឬជាមួយក្រុមហ៊ុនមេ បំណុលបន្ទាប់បន្សំ និងបំណុលផ្សេងទៀត។

ទ្រព្យអកម្មហិរញ្ញវត្ថុផ្សេងទៀត ត្រូវបានវាស់វែងតម្លៃយោងតាមថ្លៃដើមរំលស់ ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព EIR ។

គ. ការលែងទទួលស្គាល់

ទ្រព្យអកម្មហិរញ្ញវត្ថុ ត្រូវបានគេលែងទទួលស្គាល់នៅពេល ដែលកាតព្វកិច្ចបំណុលត្រូវបានលុបចោលរំសាយ ឬផុតកំណត់។ នៅពេលដែលបំណុលហិរញ្ញវត្ថុ ដែលមានស្រាប់ត្រូវបានជំនួសដោយអ្នកផ្តល់ប្រាក់កម្ចីដូចគ្នាដោយមានលក្ខខណ្ឌខុសគ្នា ឬលក្ខខណ្ឌនៃបំណុលដែលមានស្រាប់ត្រូវបានកែប្រែដូចជាការដោះដូរ ឬការកែប្រែត្រូវបានចាត់ទុកជាការមិនទទួលស្គាល់នូវបំណុលដើម និងការទទួលស្គាល់លើបំណុលថ្មី។ ភាពខុសគ្នារវាងចំនួនក្នុងបញ្ជីនៃបំណុលហិរញ្ញវត្ថុដើម និងការពិចារណាដែលបានទូទាត់ត្រូវបានទទួលស្គាល់នក្នុង របាយការណ៍លទ្ធផលពេញលេញ។

២. គោលនយោបាយគណនេយ្យ (តពីទំព័រមុន)

២.៣ សេចក្តីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

២.៣.២ ទ្រព្យសកម្មហិរញ្ញវត្ថុ (តពីទំព័រមុន)

ឃ. ការកាត់កងនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យអកម្មហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានទូទាត់ និងចំនួនទឹកប្រាក់សុទ្ធត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ ប្រសិនបើមានសិទ្ធិអាចប្រតិបត្តិបានដោយស្របច្បាប់នាពេលបច្ចុប្បន្ន ដើម្បីទូទាត់ចំនួនទឹកប្រាក់ ដែលបានទទួលស្គាល់ និងទូទាត់លើមូលដ្ឋានសុទ្ធ ឬដើម្បី ទ្រព្យសកម្មពិតប្រាកដ និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។ មិនមែនជាទូទៅទេ ដែលកិច្ចព្រមព្រៀងអាចកាត់កងបាន ហើយទ្រព្យសកម្ម និង បំណុល ដែលពាក់ព័ន្ធត្រូវបានបង្ហាញជាចំនួនដុល នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ង. និស្សន្ទឧបករណ៍ហិរញ្ញវត្ថុ

ធនាគារជួញដូរនិស្សន្ទដូចជាការផ្លាស់ប្តូរអត្រាការប្រាក់ និងអនាគតការផ្លាស់ប្តូរឥណទានដែលខកខានទូទាត់សង ការផ្លាស់ប្តូរកុំម៉ូឌីធី ការផ្លាស់ប្តូររូបិយប័ណ្ណ និងជម្រើសលើអត្រាការប្រាក់រូបិយប័ណ្ណបរទេស មូលធន និងទំនិញ។

និស្សន្ទឧបករណ៍ហិរញ្ញវត្ថុត្រូវបានទទួលស្គាល់លើកដំបូងនៅតម្លៃជាក់ស្តែង។ចំពោះនិស្សន្ទដែលមិនមានជាជម្រើស ជាធម្មតាតម្លៃជាក់ស្តែងគឺសូន្យ ឬ នៅពេលចាប់ផ្តើម។ ចំពោះជម្រើសដែលបានទិញ ឬ សរសេរ តម្លៃជាក់ស្តែង គឺស្មើនឹងតម្លៃទីផ្សារដែលបានបង់ ឬទទួល។ និស្សន្ទត្រូវបានវាស់វែងឡើងវិញជាបន្តបន្ទាប់ ទៅតាមតម្លៃជាក់ស្តែងរបស់ពួកគេ។ តម្លៃជាក់ស្តែងទទួលបានពីសម្រង់តម្លៃទីផ្សារនៅក្នុងទីផ្សារសកម្មរួមទាំងប្រតិបត្តិការទីផ្សារថ្មីៗ និងបច្ចេកទេសវាយតម្លៃដែលសមស្របរួមបញ្ចូលទាំងម៉ូឌែលលំហូរសាច់ប្រាក់អប្បហារ និងម៉ូឌែល Option Pricing។ រាល់និស្សន្ទត្រូវបានចាត់ទុកជាទ្រព្យសកម្មនៅពេលដែលតម្លៃជាក់ស្តែងវិជ្ជមាន និងជាបំណុលនៅពេលដែលតម្លៃជាក់ស្តែងអវិជ្ជមាន។

២.៣.៣ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

កិច្ចសន្យាធានាហិរញ្ញវត្ថុ គឺជាកិច្ចសន្យាដែលតម្រូវឲ្យធនាគារធ្វើការទូទាត់សងក្នុងទំហំជាក់លាក់ទៅឲ្យអ្នកកាន់កាប់សម្រាប់ការខាតបង់ដែលកើតឡើងដោយសារតែភាគីជាក់លាក់មិនបានគោរពតាមកាតព្វកិច្ចរបស់ខ្លួននៅពេលដែលកាតព្វកិច្ចនេះបានអនុលោមជាមួយលក្ខន្តិកៈនៃកិច្ចសន្យា។ ចំពោះអាជីវកម្មធម្មតា ធនាគារបានផ្តល់ការធានាហិរញ្ញវត្ថុ រួមមានលិខិតឥណទានការធានា និងការទទួលស្គាល់លើការទូទាត់។

បុព្វលាភធានាហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់លើកដំបូងនៅតម្លៃជាក់ស្តែងនាកាលបរិច្ឆេទធានា ដែលបានចេញផ្សាយ។ បន្ទាប់ពីការទទួលស្គាល់ លើកដំបូងបុព្វលាភទទួលបាន គឺត្រូវរំលស់ទៅអាយុកាលនៃការធានាហិរញ្ញវត្ថុ។ ការធានាបំណុល (notional amount) គឺការទទួលស្គាល់ជាបន្ត បន្ទាប់នៅតម្លៃខ្ពស់រវាងបរិមាណរំលស់ និងតម្លៃបច្ចុប្បន្ននៃការទូទាត់រំពឹងទុក (នៅពេលដែលការទូទាត់ក្រោមការធានាអាចនឹងកើតឡើង)។បុព្វលាភដែលមិនរំលស់ទទួលបានលើការធានាហិរញ្ញវត្ថុ រួមបញ្ចូល "បំណុលផ្សេងៗ"ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

២.៣.៤ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សម្រាប់គោលបំណងនៃការរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ សមតុល្យសាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន សាច់ប្រាក់ និងសមតុល្យធនាគារប្រាក់បញ្ញើគ្មានកាលកំណត់ និងការវិនិយោគរយៈពេលខ្លី ដែលងាយស្រួលប្តូរជាសាច់ប្រាក់បានជាមួយ នឹងកាលអវសាន្តដើម បីខែ ឬ តិចជាងនេះពីពេលទិញ ហើយនិង ដែលអាចប្តូរជាសាច់ប្រាក់ដែលកំណត់បាន និងមានហានិភ័យតិចតួចលើការផ្លាស់ប្តូរតម្លៃ។

២.៣.៥ ប្រាក់បញ្ញើ និងសមតុល្យជាមួយធនាគារផ្សេងៗ

ប្រាក់បញ្ញើ និងសមតុល្យជាមួយធនាគារផ្សេងៗ ត្រូវលាតត្រដាងដោយថ្លៃដើមដក ECL។

២.៣.៦ ឥណទាន និងបុរេប្រទាន

ឥណទាន និងបុរេប្រទាន ត្រូវបានវាស់វែងដំបូងដោយតម្លៃសមស្របបូកនឹងថ្លៃដើមប្រតិបត្តិការបន្ថែម ហើយត្រូវបានវាស់វែងជាបន្តបន្ទាប់ដោយគណនាថ្លៃដើមរំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

២.៣.៧ អចលកម្ម និងហត្ថូបករណ៍

(i) អចលកម្ម និងហត្ថូបករណ៍ ត្រូវបានកត់ត្រាតាមតម្លៃដើមដោយដករំលស់បង្គរ និងការខាតបង់ពីឱនភាពតម្លៃបង្គរប្រសិនបើមាន។ នៅពេលដែលធាតុនៃអចលកម្មរួមបញ្ចូលនូវ សមាសធាតុសំខាន់ៗ ដែលមានអាយុកាលកំណត់ប្រើប្រាស់ខុសៗគ្នា អចលទ្រព្យទាំងនោះត្រូវបានចាត់ទុកជាធាតុផ្សេងគ្នានៃអចលទ្រព្យ និងហត្ថូបករណ៍។

(ii) ការរំលស់នៃអចលកម្ម និងហត្ថូបករណ៍ ត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផលពេញលេញ ដោយផ្អែកលើវិធីសាស្ត្ររំលស់ថេរទៅលើអាយុកាលប៉ាន់ស្មាននៃទ្រព្យនីមួយៗ ទៅតាមអត្រាដូចខាងក្រោម៖

	ឆ្នាំ
ការកែលម្អអគារ	៥ទៅ១៥
ហត្ថូបករណ៍ការិយាល័យ	៤ទៅ៥
សង្ហារឹម និងគ្រឿងបំពាក់	៥
យានយន្ត	៤

(iii) ការចំណាយបន្តបន្ទាប់ដែលពាក់ព័ន្ធទៅនឹងធាតុណាមួយនៃអចលកម្ម និងហត្ថូបករណ៍ ដែលបានទទួលស្គាល់រួចមកហើយ នឹងត្រូវបូកបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យសកម្មនោះ ប្រសិនបើអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតអាច នឹងកើតឡើង ដែលលើសពីប្រតិបត្តិការដើមស្តង់ដារការអនុវត្តនៃទ្រព្យសកម្ម ដែលកំពុងមានអាច នឹងហូរចូលទៅក្នុងធនាគារ។ រាល់ការចំណាយបន្ទាប់បន្សំផ្សេងទៀត ត្រូវបានទទួលស្គាល់ជាបន្ទុកចំណាយនៅក្នុងការិយបរិច្ឆេទ ដែលបានកើតឡើង។

(iv) ការចំណេញ ឬ ខាតកើតចេញពីការឈប់ប្រើ ឬ ការលក់ចេញនៃអចលកម្ម និងហត្ថូបករណ៍ណាមួយត្រូវបានកំណត់ ដោយភាពលម្អៀងរវាងប្រាក់ចំណូលសុទ្ធប៉ាន់ស្មានពីការលក់ និងតម្លៃយោងនៃទ្រព្យសកម្មនោះ ហើយត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញនៅថ្ងៃឈប់ប្រើ ឬ លក់ចេញ។

(v) អចលកម្ម និងហត្ថូបករណ៍ ដែលបានរំលស់អស់ហើយ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ថ្ងៃ ដែលអចលកម្ម និងហត្ថូបករណ៍ទាំងនោះត្រូវបានលក់ ឬ លុបបំបាត់ចោល។

(vi) សំណង់កំពុងដំណើរការត្រូវបានផ្ទេរទៅកាន់ថ្នាក់នីមួយៗ នៃទ្រព្យសកម្មនៅពេលដែលវារួចរាល់សព្វគ្រប់សម្រាប់ប្រើប្រាស់។ សំណង់កំពុងដំណើរការ មិនត្រូវបានធ្វើរំលស់ទេរហូតទាល់តែដល់ពេល ដែលទ្រព្យសកម្មពាក់ព័ន្ធទាំងឡាយរួចរាល់ សម្រាប់ប្រើប្រាស់។

២.៣.៨ កម្មវិធីកុំព្យូទ័រ

កម្មវិធីកុំព្យូទ័រដែលធនាគារបានទិញ ត្រូវបានបង្ហាញតាមថ្លៃដើម ដករំលស់បង្គរ និងអ៊ីមភែមិនខាតបង់ប្រសិនបើមាន។ កម្មវិធីកុំព្យូទ័រត្រូវបានរំលស់ ដោយផ្អែកលើវិធីសាស្ត្ររំលស់ថេរ ដែលមានសម្រាប់រយៈពេលពី5 ទៅ 7 ឆ្នាំ។

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

២. គោលនយោបាយគណនេយ្យ (តពីទំព័រមុន)

២.៣ សេចក្តីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

២.៣.៩ អ៊ីមែរកែរមិននៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មដែលមានអាយុកាលប្រើប្រាស់គ្មានកំណត់ មិនត្រូវបានកាត់រំលស់នោះទេ ហើយត្រូវបានធ្វើតេស្តជារៀងរាល់ឆ្នាំចំពោះអ៊ីមែរកែរមិន។ ទ្រព្យសកម្មដែលត្រូវបានកាត់រំលស់ត្រូវបានត្រួតពិនិត្រលើ អ៊ីមែរកែរមិន នៅពេលព្រឹត្តិការណ៍ ឬ ការផ្លាស់ប្តូរក្នុងកាល:ទេស: ដែលបង្ហាញថាតម្លៃយោងមិនអាចយកមកវិញបាន។ ការខាតបង់លើ អ៊ីមែរកែរមិន ត្រូវបានទទួលស្គាល់ដោយតម្លៃយោងរបស់ទ្រព្យសកម្មលើសពីចំនួនដែលអាចប្រមូលបានរបស់វា។ ចំនួនទឹកប្រាក់ ដែលអាចប្រមូលមកវិញគឺ តម្លៃសមស្របរបស់ទ្រព្យសកម្ម ដែលខ្ពស់ជាងគេដកថ្លៃលក់ និងតម្លៃក្នុងការប្រើប្រាស់របស់វា

ការខាតបង់លើអ៊ីមែរកែរមិន ត្រូវបានបន្ទុកក្នុងរបាយការណ៍លទ្ធផលពេញលេញនាការិយបរិច្ឆេទ ដែលបានកើតមានឡើង។ ការបញ្រ្ចាសនៃការខាតបង់លើអ៊ីមែរកែរមិន ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញរហូតដល់តម្លៃយោងរបស់ទ្រព្យសកម្មមិនលើសពីតម្លៃយោង ដែលត្រូវបានកំណត់ការកាត់រំលស់សុទ្ធ ឬ ការកាត់រំលស់មិនមានការខាតបង់លើ អ៊ីមែរកែរ ត្រូវបានទទួលស្គាល់ទេ

២.៣.១០ ភតិសន្យា

នៅពេលចាប់ផ្តើមកិច្ចសន្យា ធនាគារវាយតម្លៃថាតើកិច្ចសន្យាមាន ឬមិនមានភតិសន្យា។

កិច្ចសន្យាជួល ឬ មានកិច្ចសន្យាជួល ប្រសិនបើកិច្ចសន្យាមានសិទ្ធិគ្រប់គ្រងលើការប្រើប្រាស់ទ្រព្យសកម្មដែលបានកំណត់ក្នុងរយៈពេលកំណត់ជាថ្នូរនឹងការពិចារណា។

ដើម្បីវាយតម្លៃថាតើកិច្ចសន្យាមានសិទ្ធិគ្រប់គ្រងការប្រើប្រាស់ទ្រព្យសកម្ម ដែលបានឬកំណត់ ធនាគារវាយតម្លៃថាតើ៖

- កិច្ចសន្យាពាក់ព័ន្ធ នឹងការប្រើប្រាស់ទ្រព្យ ដែលបានកំណត់ - នេះអាចត្រូវបានបញ្ជាក់ច្បាស់ ឬ ច្បាស់លាស់ ហើយគួរតែមានភាពខុសគ្នាជារូបវន្ត ឬ តំណាងឲ្យសមត្ថភាពទាំងអស់នៃទ្រព្យសកម្ម ដែលមានលក្ខណៈរូបវន្ត។ ប្រសិនបើអ្នកផ្គត់ផ្គង់មានសិទ្ធិជំនួសក្នុងរយៈពេលនៃការប្រើប្រាស់ បន្ទាប់មកទ្រព្យសកម្មមិនត្រូវបានកំណត់ទេ។
- ធនាគារមានសិទ្ធិទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចយ៉ាងច្រើនពីការប្រើប្រាស់ទ្រព្យសកម្មក្នុងកំឡុងពេលប្រើប្រាស់ និង
- ធនាគារមានសិទ្ធិក្នុងការប្រើទ្រព្យសកម្មដោយផ្ទាល់។ធនាគារមានសិទ្ធិនៅពេលដែលខ្លួនធ្វើការសម្រេចចិត្ត ដែលពាក់ព័ន្ធបំផុតក្នុងការផ្លាស់ប្តូររបៀប និងគោលបំណងសម្រាប់ទ្រព្យសកម្មដែលត្រូវបានប្រើប្រាស់។ ក្នុងករណីដែលការសម្រេចចិត្តទាំងអស់អំពីរបៀបនិងសម្រាប់គោលបំណងនៃទ្រព្យត្រូវបានប្រើប្រាស់ ត្រូវបានកំណត់ទុកជាមុន ធនាគារមានសិទ្ធិដឹកនាំការប្រើប្រាស់ទ្រព្យសកម្មដោយផ្ទាល់ប្រសិនបើ៖
  - ធនាគារមានសិទ្ធិធ្វើប្រតិបត្តិការទ្រព្យសកម្ម ឬ
  - ធនាគារបានរចនាប្លង់ទ្រព្យសកម្មតាមរបៀបដែលកំណត់ទុកជាមុននូវរបៀប និងសម្រាប់គោលបំណងអ្វី ដែលនឹងត្រូវប្រើប្រាស់។

នៅពេលចាប់ផ្តើម ឬ វាយតម្លៃឡើងវិញនូវកិច្ចសន្យា ដែលមានសមាសធាតុជាភតិសន្យា និងមិនមែនភតិសន្យា ធនាគារបែងចែកការពិចារណានៅក្នុងកិច្ចសន្យាចំពោះសមាសធាតុជាភតិសន្យានីមួយៗ និងសមាសធាតុផ្សំ ដែលមិនមែនជាភតិសន្យា នៅលើមូលដ្ឋាននៃតម្លៃដាច់ដោយឡែករបស់ពួកគេ។ ទោះយ៉ាងណាសម្រាប់ភតិសន្យាលើអគារ ដែលខ្លួនជាអ្នកជួល ធនាគារបានជ្រើសរើសមិនបំបែកសមាសធាតុ ដែលមិនមែនភតិសន្យា និងសមាសធាតុជាភតិសន្យា និងមិនសម្រាប់ជាសមាសធាតុនៃភតិសន្យាតែមួយ។

ភតិសន្យាដែលធនាគារជាអ្នកជួល

ការរៀបចំមួយបានបង្ហាញពីសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម ប្រសិនបើមួយក្នុងចំណោមនេះត្រូវបានបំពេញតាម៖

- អ្នកទិញមានសមត្ថភាព ឬ សិទ្ធិក្នុងការប្រតិបត្តិទ្រព្យសកម្មខណៈពេលទទួលបាន ឬ គ្រប់គ្រងលើសពីបរិមាណមិនសំខាន់នៃលទ្ធផល។
- អ្នកទិញមានសមត្ថភាព ឬ សិទ្ធិក្នុងការគ្រប់គ្រងលទ្ធភាពរបស់ទ្រព្យសកម្មក្នុងពេលទទួលបាន ឬ គ្រប់គ្រងលើសពីបរិមាណ ដែលមិនសំខាន់នៃលទ្ធផល។ ឬ
- អង្គហេតុនិងកាល:ទេស:បានបង្ហាញថាវាជាការដាច់ឆ្ងាយដែលភាគីផ្សេងទៀតនឹងទទួលបានច្រើនជាងនូវបរិមាណ ដែលមិនសំខាន់នៃលទ្ធផល ហើយតម្លៃក្នុងមួយឯកតាមិនមែនជាតម្លៃឯកតានៃទិន្នផលថេរទេ ហើយមិនស្មើ នឹងតម្លៃទីផ្សារបច្ចុប្បន្នក្នុងមួយឯកតានៃលទ្ធផលដែរ។

ធនាគារទទួលស្គាល់នូវសិទ្ធិប្រើប្រាស់ និងបំណុលភតិសន្យានៅកាលបរិច្ឆេទចាប់ផ្តើមជួល រួមមានការជួលលើទឹកន្លែងសម្រាប់ទូរ ATM ដែលមានរយៈពេលជួល 12ខែ ឬ តិចជាងនេះ និងការជួលទ្រព្យសកម្ម ដែលមានតម្លៃតិច។ សិទ្ធិប្រើប្រាស់លើទ្រព្យសកម្មត្រូវបានគណនាលើកដំបូងដោយថ្លៃដើម ដែលរួមបញ្ចូលចំនួនទឹកប្រាក់ដំបូងនៃបំណុលភតិសន្យា ដែលត្រូវបានកែតម្រូវសម្រាប់ការទូទាត់ភតិសន្យា ដែលបានធ្វើឡើងនៅ ឬមុនកាលបរិច្ឆេទចាប់ផ្តើមបូករួម នឹងថ្លៃដើមដំបូង ដែលបានកើតឡើង និងការប៉ាន់ប្រមាណនៃចំណាយដើម្បីរុះរើ និងដកចេញ ទ្រព្យសកម្ម ឬ ដើម្បីស្តារឡើងវិញនូវទ្រព្យសកម្ម ឬ ទីតាំង ដែលមានទីតាំងស្ថិតនៅតិចជាងការលើកទឹកចិត្ត ដែលទទួលបាន។

សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ដែលត្រូវប្រើ ត្រូវបានរំលស់ជាបន្តបន្ទាប់ ដោយប្រើវិធីសាស្ត្ររំលស់ថេរចាប់ពីកាលបរិច្ឆេទចាប់ផ្តើមរហូតដល់ចុងបញ្ចប់ នៃអាយុកាលសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ឬចុងបញ្ចប់នៃរយៈពេលជួល។ លើសពីនេះទៀតទ្រព្យសម្បត្តិនៃការប្រើប្រាស់ត្រូវបានកាត់បន្ថយជាទៀងទាត់ ដោយការខាតបង់លើអ៊ីមែរកែរមិនបើមានហើយត្រូវបានកែតម្រូវ សម្រាប់ការវាស់វែងជាក់លាក់នៃបំណុលភតិសន្យា។

បំណុលភតិសន្យាត្រូវបានគណនាលើកដំបូងនៅតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាដែលមិនត្រូវបានបង់នៅកាលបរិច្ឆេទចាប់ផ្តើម ការបញ្ចុះតម្លៃដោយប្រើអត្រាការប្រាក់ជាក់ស្តែងនៅក្នុងភតិសន្យា ឬប្រសិនបើអត្រានេះមិនអាចត្រូវបានកំណត់រួចរាល់ទៅនឹងការកើនឡើងនៃអត្រាកម្ចី របស់អ្នកជួល។ ជាទូទៅធនាគារប្រើអត្រាប្រាក់កម្ចីបន្ថែមរបស់ខ្លួនជាអត្រាបញ្ចុះតម្លៃ។

ការទូទាត់ភតិសន្យាដែលមាននៅក្នុងការគណនានៃបំណុលភតិសន្យារួមមាន៖

- ការទូទាត់ថេររួមទាំងការទូទាត់ដែលអាចថេរ
- ការទូទាត់ភតិសន្យា ក្នុងជម្រើសរយៈពេលបន្ត ប្រសិនបើធនាគារមានភាពប្រាកដប្រជាក្នុងការប្រើជម្រើសបន្ថែម

បំណុលភតិសន្យាត្រូវបានវាស់វែងដោយថ្លៃដើមរំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ វាត្រូវបានគណនាឡើងវិញនៅពេលមានការផ្លាស់ប្តូរយៈពេលជួលការផ្លាស់ប្តូរ ការវាយតម្លៃនៃជម្រើសក្នុងការទិញទ្រព្យសម្បត្តិមូលដ្ឋានការផ្លាស់ប្តូរការទូទាត់ប្រាក់ជួលនៅពេលអនាគត។

នៅពេល ដែលបំណុលភតិសន្យា ត្រូវបានគណនាតាមវិធីនេះការកែតម្រូវ ដែលត្រូវគ្នាត្រូវបានធ្វើឡើងចំពោះចំនួនទឹកប្រាក់ ដែលបានដាក់នៃសិទ្ធិប្រើប្រាស់ ឬត្រូវបានកត់ក្នុងប្រាក់ចំណេញ និងខាតប្រសិនបើចំនួនទឹកប្រាក់ ដែលបានកាន់កាប់នៃទ្រព្យសម្បត្តិប្រើប្រាស់ត្រឹមត្រូវត្រូវបានកាត់បន្ថយឲ្យស្មើសូន្យ។

២.៣.១១ ទ្រព្យសកម្មផ្សេងៗ

គណនីត្រូវទទួលបានផ្សេងៗ រួមបញ្ចូលទ្រព្យសកម្មផ្សេងទៀត ត្រូវបានយោងតាមតម្លៃទទួលស្គាល់ប៉ាន់ស្មាន ។ការប៉ាន់ប្រមាណត្រូវបានធ្វើឡើងសម្រាប់បំណុលសង្ស័យដោយផ្អែកលើការពិនិត្យឡើងវិញនៃចំនួនទឹកប្រាក់ ដែលនៅសល់នាកាលបរិច្ឆេទរបស់របាយការណ៍លទ្ធផលហិរញ្ញវត្ថុ ។

២. គោលនយោបាយគណនេយ្យ (តពីទំព័រមុន)

២.៣ សេចក្តីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

២.៣.១២ ប្រាក់បញ្ញើរបស់អតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ

ប្រាក់បញ្ញើរបស់អតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ត្រូវកត់ត្រាក្នុងតម្លៃដាក់បញ្ញើ។

២.៣.១៣ បំណុលបន្ទាប់បន្សំ

បំណុលបន្ទាប់បន្សំតំណាងឲ្យបំណុលរយៈពេលវែង ដែលនៅក្រោមបំណុលផ្សេងៗ របស់ធនាគារ។ វាត្រូវបានចាត់ទុកជាផ្នែកមួយនៃទ្រព្យអកម្មរបស់ធនាគារ និងបញ្ចូលក្នុងការគណនា ចំណូលសុទ្ធរបស់ធនាគារ តាមការអនុលោមរបស់ធនាគារជាតិនៃកម្ពុជា។

២.៣.១៤ ទ្រព្យអកម្មផ្សេងៗ

ទ្រព្យអកម្មផ្សេងៗត្រូវបានកត់ត្រាជាថ្លៃដើម។

២.៣.១៥ សំវិធានធនលើទ្រព្យអកម្ម

សំវិធានធនលើទ្រព្យអកម្ម ត្រូវបានទទួលស្គាល់នាពេល ដែលធនាគារមានកាតព្វកិច្ចក្នុងបច្ចុប្បន្ន ភាពជាលទ្ធផលនៃព្រឹត្តិការណ៍កើតឡើងក្នុងអតីតកាលតាមផ្លូវច្បាប់ ឬ តាមរយៈការបង្កើតឡើង ដែលអាចនាំឲ្យមានលំហូរចេញនូវធនធាន ដែលជាផ្នែកនៃអត្ថប្រយោជន៍សេដ្ឋកិច្ច ដើម្បីទូទាត់នូវកាតព្វកិច្ចនោះ ហើយការប៉ាន់ស្មានជាក់លាក់នៃតម្លៃរបស់បំណុលនោះអាចធ្វើឡើងទៅបាន។

សំវិធានធនត្រូវបានត្រួតពិនិត្យឡើងវិញក្នុងកាលបរិច្ចេទនៃតារាងតុល្យការនីមួយៗ ហើយមានការកែតម្រូវឲ្យស្របទៅ នឹងការប៉ាន់ស្មានល្អបំផុតនាពេលបច្ចុប្បន្ន។ នៅពេលតម្លៃនៃសាច់ប្រាក់មានឥទ្ធិពលជាសារវន្តបរិមាណសំវិធានធនគឺជាតម្លៃបច្ចុប្បន្ននៃការចំណាយដែលរំពឹងទុក ដើម្បីទូទាត់នូវកាតព្វកិច្ច។

២.៣.១៦ អត្ថប្រយោជន៍និយោជិក

ប្រាក់បៀវត្ស ប្រាក់ឈ្នួល ប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍ផ្សេងៗ ត្រូវបានបង្ករនៅក្នុងកំឡុងពេល បុគ្គលិកចាប់ផ្តើមបម្រើការងារជាមួយនឹងក្រុមហ៊ុន។

ក្នុងឆ្នាំ2018 ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT) បានចេញផ្សាយប្រកាសលេខ 443 ចុះថ្ងៃទី21 ខែកញ្ញា ឆ្នាំ2018 ស្តីពីការទូទាត់សំណងអតីតភាពការងារ សម្រាប់បុគ្គលិកក្នុងកិច្ចសន្យាគ្មានថេរវេលាកំណត់ច្បាស់លាស់ព្រមជាមួយ នឹងសេចក្តីណែនាំ លេខ 042 ចុះថ្ងៃទី22 ខែមីនាឆ្នាំ2019។ ប្រកាសតម្រូវឲ្យស្ថាប័នធ្វើការបង្ករប្រតិសកម្មទូទាត់អតីតភាពការងារ ស្មើនឹង 15ថ្ងៃជារៀលរាល់ ឆ្នាំនៃរយៈពេល ដែលបុគ្គលិកបានបំពេញការងារ ប៉ុន្តែមិនឲ្យលើសពី 6ខែនៃប្រាក់បៀវត្សសុទ្ធ ប្រចាំឆ្នាំ។ ការទូទាត់សំណងអតីតភាពការងារ ត្រូវចាប់ផ្តើមពីខែធ្នូឆ្នាំ 2021 ដូចខាងក្រោម៖

- ស្មើនឹងបំណុល 3ថ្ងៃរៀងរាល់ខែមិថុនា និង
- ស្មើនឹងបំណុល 3ថ្ងៃរៀងរាល់ខែធ្នូ។

២.៣.១៧ ពន្ធលើប្រាក់ចំណូល

ការចំណាយពន្ធលើប្រាក់ចំណូលរួមមានពន្ធបច្ចុប្បន្ន និងពន្ធពន្យា។ វាត្រូវបានទទួលស្គាល់នៅក្នុងចំណេញ និងខាតលើកលែងតែវត្ថុ ដែលត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធនឬនៅក្នុងចំណូលផ្សេងទៀត។

ធនាគារបានកំណត់ថា ការប្រាក់ និងការដាក់ពិន័យទាក់ទងនឹងពន្ធលើប្រាក់ចំណូលរួមទាំងការព្យាបាលពន្ធមិនបានត្រូវ នឹងនិយមន័យនៃពន្ធលើប្រាក់ចំណូលដូច្នេះហើយបានរាប់បញ្ចូលពួកគេនៅក្រោម CIAS 37 Provisions Contingent Liabilities and Contingent Assets និងបានទទួលស្គាល់ការចំណាយ ដែលពាក់ព័ន្ធនៅក្នុងការចំណាយផ្សេងទៀត។

(i) **ពន្ធលើប្រាក់ចំណូលក្នុងគ្រា**

ពន្ធលើប្រាក់ចំណូលក្នុងគ្រាជាទ្រព្យសកម្ម និងទ្រព្យអកម្ម សម្រាប់ការិយបរិច្ចេទបច្ចុប្បន្ននិងមុនៗ ត្រូវបានវាស់វែងជាទឹកប្រាក់ ដែលត្រូវបានរំពឹងទុកថាត្រូវបានប្រមូលមកវិញ ឬត្រូវបង់ ទៅអាជ្ញាធរពន្ធដារ។ អត្រាពន្ធ និងច្បាប់ពន្ធ ដែលត្រូវបានប្រើ ដើម្បីគណនាទឹកប្រាក់ទាំងនេះគឺជាអត្រា និងច្បាប់ពន្ធ ដែលមានសុពលភាពរហូតដល់កាលបរិច្ចេទនៃតារាងតុល្យការនេះ។

(ii) **ពន្ធពន្យាលើប្រាក់ចំណូល**

ពន្ធពន្យាលើប្រាក់ចំណូលត្រូវបានគណនាដោយប្រើវិធីសាស្ត្រទ្រព្យអកម្មតារាងតុល្យការលើចំនួនខុសគ្នាបណ្តោះអាសន្ន នាកាលបរិច្ចេទនៃតារាងតុល្យការរវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងទ្រព្យអកម្ម ហើយនិងតម្លៃពិតគណនេយ្យរបស់ទ្រព្យទាំងនោះក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ពន្ធពន្យាលើប្រាក់ចំណូល ជាទ្រព្យអកម្មត្រូវបានទទួលស្គាល់លើចំនួនខុសគ្នាបណ្តោះអាសន្ន ជាប់ពន្ធទាំងអស់លើកលែងតែនៅពេលពន្ធពន្យាជាទ្រព្យអកម្មកើតឡើងពីការទទួលស្គាល់នៅគ្រាដំបូងនៃទ្រព្យសកម្ម ឬ ទ្រព្យអកម្មនៅក្នុងប្រតិបត្តិការមួយ ដែលនៅពេលនោះ ប្រតិបត្តិការមិនជះឥទ្ធិពលដល់ប្រាក់ចំណេញគណនេយ្យ និងប្រាក់ចំណេញ ឬ ខាតជាប់ពន្ធ។

ពន្ធពន្យាលើប្រាក់ចំណូលជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់សម្រាប់ភាពខុសគ្នាបណ្តោះ អាសន្នទាំងអស់ ដែលអាចកាត់បន្ថយបានរហូតដល់ទំហំមួយ ដែលទំនងថាប្រាក់ចំណេញជាប់ពន្ធ នឹងអាចមានដើម្បីកាត់កងជាមួយភាពខុសគ្នាបណ្តោះអាសន្ន ដែលអាចប្រើប្រាស់បាន លើកលែងតែនៅពេលពន្ធពន្យាលើប្រាក់ចំណូលជាទ្រព្យសកម្មកើតឡើងពីការទទួលស្គាល់នាគ្រាដំបូងនៃទ្រព្យសកម្ម ឬ ទ្រព្យអកម្មក្នុងប្រតិបត្តិការមួយ ដែលនៅពេលនោះប្រតិបត្តិការមិនជះឥទ្ធិពលដល់ប្រាក់ចំណេញគណនេយ្យ និងប្រាក់ចំណេញ ឬ ខាតជាប់ពន្ធ។

តម្លៃយោងនៃពន្ធពន្យាលើប្រាក់ចំណេញជាទ្រព្យសកម្ម ត្រូវបានពិនិត្យឡើងវិញនៅរៀងរាល់ចុងការិយបរិច្ចេទរបាយកាណ៍នីមួយៗ និងត្រូវបានកាត់បន្ថយមកដល់កម្រិតមួយ ដែលគេជឿថានឹង ពុំមានប្រាក់ចំណេញជាប់ពន្ធគ្រាប់គ្រាន់ ដែលអាចពន្ធពន្យាជាទ្រព្យសកម្មទាំងអស់ ឬផ្នែកណាមួយត្រូវបានប្រើប្រាស់។ ពន្ធពន្យាលើប្រាក់ចំណញជាទ្រព្យសកម្ម ដែលមិនត្រូវបានទទួលស្គាល់ត្រូវបានវាយតំលៃឡើងវិញនៅចុងការិយបរិច្ចេទរបាយកាណ៍នីមួយៗ ហើយត្រូវបានទទួលស្គាល់ដល់កម្រិតមួយ ដែលគេជឿថានឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ដែលធ្វើឲ្យពន្ធពន្យាជាទ្រព្យសកម្មនោះអាចត្រូវបានទទួលត្រឡប់មកវិញ។

២.៣.១៨ មូលធន

(i) **មូលនិធិបានបង់**

ភាគហ៊ុនធម្មតាត្រូវបានចាត់ថ្នាក់ជាមូលនិធិ។ ថ្លៃដើមបន្ថែមដែលផ្តល់អោយផ្ទាល់ទៅកាន់ការបោះផ្សាយភាគហ៊ុនធម្មតា ត្រូវបានគេទទួលស្គាល់ថាជាការកាត់ចេញពីមូលនិធិ ឥទ្ធិពលពន្ធសុទ្ធណាមួយ។ ភាគហ៊ុនផ្សេងទៀតត្រូវបានចាត់ថ្នាក់ជាមូលនិធិ និង/ឬ ទ្រព្យអកម្មយោងទៅតាមខ្លឹមសារសេដ្ឋកិច្ចនៃឧបករណ៍ពិសេស។ វិភាគទានដល់អ្នកកាន់កាប់នៃឧបករណ៍ហិរញ្ញវត្ថុ ដែលបានចាត់ថ្នាក់ជាឧបករណ៍មូលនិធិត្រូវបានគិតទៅលើមូលនិធិដោយផ្ទាល់។

(ii) **ប្រាក់ចំណេញរក្សាទុក**

ប្រាក់ចំណេញរក្សាទុកតំណាងដោយប្រាក់ចំណេញបង្កររបស់ ធនាគារដក នឹងភាគលាភ ដែលបានប្រកាស។

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

២. គោលនយោបាយគណនេយ្យ (តពីទំព័រមុន)

២.៣ សេចក្តីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

២.៣.១៨ មូលធន (តពីទំព័រមុន)

(iii) ទុនបម្រុងទូទៅ និងតាមបទប្បញ្ញត្តិ

ទុនបម្រុងទូទៅត្រូវបានបង្កើតឡើងសម្រាប់ហានិភ័យហិរញ្ញវត្ថុទូទៅ។ ក្រុមប្រឹក្សាភិបាលអនុវត្តការសំរេចចិត្តរបស់ខ្លួន សម្រាប់ការប្រើប្រាស់ និងថែទាំទុនបំរុងទូទៅ។ ការផ្ទេរពីប្រាក់ចំណេញ ដែលបានរក្សាទុកទៅជាប្រាក់បម្រុងទូទៅ គឺអាស្រ័យលើការយល់ព្រមពីក្រុមប្រឹក្សាភិបាលរបស់ធនាគារ។

ទុនបម្រុងតាមបទប្បញ្ញត្តិត្រូវបានបង្កើតឡើង ដោយគិតលើភាពខុសគ្នាទៅលើសំវិធានធនរវាង ECL ដែលបានកំណត់ស្របតាម CIFRS 9 និងសំវិធានធនតាមបទប្បញ្ញត្តិ ដែលបានគណនាស្របតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ខ.017-344 ចុះថ្ងៃទី01 ខែធ្នូ ឆ្នាំ2017 និងសារាចរលេខ 77-018-001 ចុះថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2019 ស្តីពីការចាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានលើអ៊ីមែរកែរមិនរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុ។ សំវិធានធនតាមបទប្បញ្ញត្តិតម្រូវអោយធនាគារ និងស្ថាប័នហិរញ្ញវត្ថុចាត់ចំណាត់ថ្នាក់ផលប័ត្រកម្ចីរបស់ពួកគេជាប្រាំថ្នាក់ និងផ្តល់ប្រាក់ឧបត្ថម្ភទូទៅ និងជាក់លាក់ដោយផ្អែកលើចំណាត់ថ្នាក់ឥណទានដែលបានបង្ហាញនៅក្នុងកំណត់សំគាល់ 2.3.1 (យ)។

ធនាគារត្រូវប្រៀបធៀបសំវិធានធន ដែលបានគណនាស្របតាម CIFRS 9 និងសំវិធានធនតាមបទប្បញ្ញត្តិ និង៖

(ii) ក្នុងករណីសំវិធានធនតាមបទប្បញ្ញត្តិទាបជាងសំវិធានធន ដែលបានគណនាស្របតាមCIFRS 9 ធនាគារ នឹងកត់ត្រាសំវិធានធន ដែលបានគណនាស្របតាមCIFRS 9។

(ii) ក្នុងករណីសំវិធានធនតាមបទប្បញ្ញត្តិខ្ពស់ជាងសំវិធានធន ដែលបានគណនាស្របតាមCIFRS 9 ធនាគារ នឹងកត់ត្រាសំវិធានធន ដែលបានគណនាស្របតាម CIFRS 9 និងផ្ទេរភាពខុសគ្នាពីប្រាក់ចំណេញ ឬគណនីខាតបង្គរទៅទុនបម្រុងតាមបទប្បញ្ញត្តិ។

២.៣.១៩ ការទទួលស្គាល់ចំណូល និងចំណាយការប្រាក់

អត្រាការប្រាក់មានប្រសិទ្ធិភាព

ចំណូលពីការប្រាក់ និង ចំណាយ ត្រូវបានទទួលស្គាល់ជាប្រាក់ចំណេញ និងខាតដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ "អត្រាការប្រាក់មានប្រសិទ្ធិភាព" គឺជាអត្រា ដែលមានការបញ្ចុះតម្លៃពិតប្រាកដ ដែលបានប៉ាន់ស្មានអំពីការទូទាត់សាច់ប្រាក់នាពេលអនាគត ឬចំណូលតាមរយៈអាយុកាលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុ ៖

- តម្លៃយោងដុលរបស់របាយការណ៍ហិរញ្ញវត្ថុ
- ការចំណាយរំលស់លើបំណុលហិរញ្ញវត្ថុ

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធិភាពសម្រាប់ឧបករណ៍ហិរញ្ញវត្ថុក្រៅពីទិញទ្រព្យសកម្មអន់ថយឥណទាននោះ ធនាគារប៉ាន់ប្រមាណលំហូរសាច់ប្រាក់នាពេលអនាគតដោយពិចារណាលើលក្ខខណ្ឌកិច្ចសន្យាទាំងអស់នៃឧបករណ៍ហិរញ្ញវត្ថុ។ ចំពោះការទិញ ឬ ការអន់ថយឥណទានទ្រព្យសកម្មហិរញ្ញវត្ថុ អត្រាការប្រាក់មានប្រសិទ្ធភាពឥណទានកែតម្រូវ ត្រូវបានគណនាដោយប្រើលំហូរទឹកប្រាក់នាពេលអនាគត ដែលបានប៉ាន់ស្មាន រួមមាន ECL។

ការគណនាអត្រាការប្រាក់ប្រសិទ្ធិភាពរួមមាន ថ្លៃប្រតិបត្តិការ និង ថ្លៃឈ្នួល និងកំរិតត្រូវបានបង់ ឬ ត្រូវបានទទួល ដែលជាផ្នែកសំខាន់នៃអត្រាការប្រាក់ប្រសិទ្ធភាព។ ថ្លៃដើមប្រតិបត្តិការ រួមបញ្ចូល ការចំណាយបន្ថែម ដែលត្រូវបានបង្កឡើងដោយផ្ទាល់អាចកំណត់បានទៅ នឹងការទទួលបាន ឬ បោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យអកម្មហិរញ្ញវត្ថុ។

រំលស់ថ្លៃដើម និងតម្លៃយោងដុល

"ថ្លៃដើមរំលស់" នៃទ្រព្យសកម្ម ឬ បំណុលហិរញ្ញវត្ថុគឺជាចំនួនទឹកប្រាក់ ដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យអកម្មហិរញ្ញវត្ថុត្រូវបានគណនាទៅលើការទទួលស្គាល់ដំបូងដកការសងប្រាក់ដើម បូក ឬ ដក តម្លៃបូកយោង ដោយប្រើប្រាស់អត្រាការប្រាក់ប្រសិទ្ធភាពខុសគ្នារវាងចំនួនទឹកប្រាក់ដំបូង និងចំនួនកាលកំណត់ ចំណែកឯទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានកែតម្រូវសម្រាប់ការអនុញ្ញាតចុះថ្លៃរាល់សំវិធានធននៃការបាត់បង់ឥណទានរំពឹងទុក។

ចំនួនតម្លៃយោងដុលនៃទ្រព្យសម្បត្តិសកម្មហិរញ្ញវត្ថុ គឺជាតម្លៃរំលស់នៃរបាយការណ៍ហិរញ្ញវត្ថុមុន នឹងធ្វើការកែតម្រូវលើការអនុញ្ញាតចុះថ្លៃរាល់ការបាត់បង់ឥណទានដែលបានរំពឹងទុក

ការគណនាចំណូលការប្រាក់ និងចំណាយ

អត្រាការប្រាក់ប្រសិទ្ធិភាពនៃទ្រព្យសកម្ម ឬ ទ្រព្យអកម្មហិរញ្ញវត្ថុត្រូវបានគណនាផ្អែកលើការទទួលស្គាល់ដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬ ទ្រព្យអកម្មហិរញ្ញវត្ថុ។

ក្នុងការគណនាចំណូលពីការប្រាក់ និងចំណាយការប្រាក់ អត្រាការប្រាក់ប្រសិទ្ធិភាពត្រូវបានអនុវត្តទៅលើចំនួនតម្លៃយោងដុលនៃទ្រព្យសកម្ម (នាពេលដែលទ្រព្យនោះមិនមានការថយចុះឥណទាន) ឬ ចំពោះការចំណាយរំលោះនៃទ្រព្យអកម្ម។ អត្រាការប្រាក់ប្រសិទ្ធិភាពក៏ត្រូវបានកែសម្រួលសម្រាប់តម្លៃសមស្រប ដែលបានកែតម្រូវរួចនាកាលបរិច្ឆេទ ដែលបានរំលោះនៃការការពារហានិភ័យចាប់ផ្តើម។

ទោះជាយ៉ាងណាក៏ដោយ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានអ៊ីមែរកែរមិនឥណទានជាបន្តបន្ទាប់ទៅ នឹងការទទួលស្គាល់ដំបូង ប្រាក់ចំណូលពីការប្រាក់ ត្រូវបានគណនាតាមអត្រាការប្រាក់ប្រសិទ្ធិភាពទៅ នឹងការចំណាយរំលោះនៃទ្រព្យសកម្មហិរញ្ញវត្ថុ។ ក្នុងករណីទ្រព្យសកម្មនោះលែងមានអ៊ីមែរកែរមិនឥណទានការគណនាចំណូលការប្រាក់នឹងត្រូវគណនាត្រលប់ទៅមូលដ្ឋានដុលវិញ។ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលធ្លាប់បានទទួលស្គាល់ដំបូងនូវអ៊ីមែរកែរមិនឥណទាននោះចំណូលពីការប្រាក់ត្រូវគណនាដោយអនុវត្តតាមអត្រាការប្រាក់ឥណទានកែតម្រូវ ដែលមានប្រសិទ្ធិភាពទៅ នឹងថ្លៃដើមរំលស់នៃទ្រព្យសម្បត្តិ។ ការគណនាចំណូលការប្រាក់ នឹងមិនមានការផ្លាស់ប្តូរបើទោះបីជាហានិភ័យឥណទានរបស់ទ្រព្យសម្បត្តិមានភាពប្រសើរឡើងក៏ដោយ។

ការបង្ហាញ

ចំណូលការប្រាក់ត្រូវបានគណនាដោយ ប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ដែលបានបង្ហាញនៅក្នុងរបាយការណ៍ប្រាក់ចំណេញ ឬ ខាត និងប្រាក់ចំណូលពេញលេញផ្សេងទៀតរួមបញ្ចូលទាំងការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យអកម្មហិរញ្ញវត្ថុ ដែលគណនាដោយថ្លៃដើមរំលស់។

ចំណាយការប្រាក់ ដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍អំពីប្រាក់ចំណេញ ឬ ខាត និង ប្រាក់ចំណូលពេញលេញផ្សេងទៀតរួមបញ្ចូលទាំងទ្រព្យអកម្មហិរញ្ញវត្ថុ ដែលបានគណនាដោយថ្លៃដើមរំលស់។

២.៣.២០ ចំណូលពីថ្លៃឈ្នួល និងកម្រៃជើងសារ

ចំណូល និងចំណាយពីថ្លៃឈ្នួល និងកម្រៃជើងសារ ដែលជាស្នូលសំខាន់ចំពោះអត្រាការប្រាក់ប្រសិទ្ធភាពលើទ្រព្យសកម្មហិរញ្ញវត្ថុ ឬ ចំណុលហិរញ្ញវត្ថុ ត្រូវបានរាប់បញ្ចូលនៅក្នុងអត្រាការប្រាក់ប្រសិទ្ធភាព។

កម្រៃផ្សេងៗ និងចំណូលពីកម្រៃជើងសារ រួមមានកម្រៃជើងសារលើសេវាកម្មត្រូវបានទទួលស្គាល់នៅពេលប្រតិបត្តិការកើតឡើង។

កិច្ចសន្យាជាមួយអតិថិជន ដែលបានទទួលស្គាល់ជាឧបករណ៍ហិរញ្ញវត្ថុ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អាចជាផ្នែកខ្លះនៃវិសាលភាព CIFRSs 9 និងផ្នែកខ្លះនៃវិសាលភាពនៃ CIFRSs 15. ប្រសិនបើមានករណីនេះ ដំបូងធនាគារត្រូវអនុវត្តតាមCIFRSs 9 ដើម្បីបំបែក និង គណនាផ្នែកខ្លះនៃកិច្ចសន្យាដែលមាននៅក្នុងវិសាលភាពនៃ CIFRSs 9 ហើយបន្ទាប់មកអនុវត្ត CIFRSs 15 ទៅនឹងតម្លៃនៅសល់។

២.៣.២១ ចំណាយលើការប្រាក់

ចំណាយការប្រាក់លើប្រាក់បញ្ញើរបស់អតិថិជន គណនីទុទាត់របស់ធនាគារផ្សេងៗ និងប្រាក់កម្ចី ត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្គរ។

២.៣.២២ ចំណាយលើថ្លៃឈ្នួល និងជើងសារ

ចំណាយលើថ្លៃឈ្នួល និងកម្រៃជើងសារត្រូវបានទទួលស្គាល់ នៅពេលចំណាយនោះកើតឡើង។

២. គោលនយោបាយគណនេយ្យ (តពីទំព័រមុន)

២.៣ សេចក្តីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

២.៣.២៣ សម្ព័ន្ធញាតិ

ភាគីទាំងឡាយត្រូវបានចាត់ទុកថាជាសម្ព័ន្ធញាតិ ប្រសិនបើធនាគារមានលទ្ធភាពគ្រប់គ្រងផ្ទាល់ ឬ ប្រយោលលើភាគីផ្សេងទៀត ឬមានឥទ្ធិពលសារវន្តក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការ ឬផ្ទុយមកវិញ ប្រសិនបើធនាគារ និងភាគីនោះស្ថិតនៅក្រោមការគ្រប់គ្រងរួមមួយ ឬក៏ក្រោមឥទ្ធិពលជាសារវន្តរួម។ សម្ព័ន្ធញាតិអាចជារូបវ័ន្តបុគ្គល ឬ នីតិបុគ្គល ហើយក៏បានរួមបញ្ចូលទាំងបុគ្គលជិតស្និតនៅក្នុងសមាជិកសម្ព័ន្ធញាតិផងដែរ។

២.៣.២៤ ទ្រព្យសកម្មដែលស្ថិតក្រោមកិច្ចសន្យាធានា

ទ្រព្យសកម្មដែលផ្ញើរក្សាទុក ឬក្នុងសមាសភាពជាទ្រព្យដាក់ធានា គឺមិនត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុទេ ពីព្រោះទ្រព្យទាំងនេះមិនមែនជាទ្រព្យសកម្មរបស់ធនាគារឡើយ។

២.៣.២៥ ទ្រព្យសកម្មជាយថាហេតុ

